ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ញត្តិ និង នីតិវិធី

## សម្រាប់

## ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

## នីតិកាលទី ២

( ថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ )

# មាតិកា

**ទំព័រ**


**ជំពូកទី ១._ បទប្បញ្ញត្តិទូទៅ** ........ ០១

**ជំពូកទី ២._ ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត ចំនួនអាសនៈ អ្នកបោះឆ្នោត អង្គបោះឆ្នោត ការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោត** ........ ០៥

- ប្រព័ន្ធបោះឆ្នោត ........ ០៥
- មណ្ឌលបោះឆ្នោត ........ ០៦
- ការកំណត់ចំនួនអាសនៈក្នុងព្រឹទ្ធសភា និងតាមមណ្ឌលភូមិភាគ ........ ០៧
- អ្នកបោះឆ្នោត និងអង្គបោះឆ្នោត ........ ០៧
- លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ........ ០៨
- ការិយាល័យចុះឈ្មោះបោះឆ្នោត ........ ០៩
- ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ០៩
- វិធានការសន្តិសុខសំរាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ១១
- ការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ១៤
- សង្ខេបដំណាក់ការនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ........ ១៥
- រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត តាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ........ ១៦
- ការទទួលខុសត្រូវរបស់អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ........ ១៧
- សម្ភារៈឯកសារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត ........ ២០
- ការចុះឈ្មោះបោះឆ្នោត និងការរៀបចំនិងបញ្ជូនបញ្ជីឈ្មោះតាមអង្គបោះឆ្នោតមក គជប ........ ២០

- ការប្រគល់ទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូង ដោយកុំព្យូទ័រនៅ គជប ..... ២៨
- ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ..... ៣១
- ការដាក់ពាក្យបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់នៅ គខ/កប និងការបើកសវនាការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង ..... ៣២
- ការដាក់ពាក្យបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់នៅ គជប និងការបើកសវនាការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង ..... ៣៨
- ការដាក់ពាក្យបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់នៅក្រុមប្រឹក្សាធម្មនុញ្ញ និងការបើកសវនាការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង ..... ៤២
- ការកែតម្រូវបញ្ជីបោះឆ្នោតដំបូង ការរៀបចំ និងការបោះពុម្ព ដើម្បីដាក់ជូន គជប សំរេចផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ ..... ៤៤
- សិទ្ធិបោះឆ្នោត និងលក្ខខណ្ឌសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ..... ៤៩

**ជំពូកទី ៣._ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥១**

- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥១
- លក្ខខណ្ឌ និងបែបបទក្នុងការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥១
- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥២
- ការពិនិត្យសំរេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥៣
- ការប្ដឹងតវ៉ាពាក់ព័ន្ធនឹងសេចក្ដីសំរេចបដិសេធរបស់ គជប ..... ៥៤
- ករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើបណ្ដឹងតវ៉ា ..... ៥៤
- ករណីក្រុមប្រឹក្សាធម្មនុញ្ញបដិសេធលើបណ្ដឹងតវ៉ា ..... ៥៥
- ការបញ្ឈប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ..... ៥៥
- សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន ..... ៥៥
- ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ..... ៥៥

**ជំពូកទី ៤._ បេក្ខជនសមាជិកព្រឹទ្ធសភា** ............ ៥៩
- លក្ខខណ្ឌឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា ............ ៥៩
- គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា ............ ៥៩
- ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ............ ៦០
- ការប្រកាសបេក្ខភាពបេក្ខជនគណបក្សនយោបាយ ............ ៦១

**ជំពូកទី ៥._ ការឃោសនាបោះឆ្នោត** ............ ៦២
- បញ្ញត្តិទូទៅ ............ ៦២
- សម្ភារៈអប់រំអ្នកបោះឆ្នោត ............ ៦៤
- ការឃោសនាផ្សព្វផ្សាយ ............ ៧២
- ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ............ ៧៩

**ជំពូកទី ៦._ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកពត៌មាន** ............ ៨១
- តំណាងគណបក្សនយោបាយ ............ ៨១
- អ្នកសង្កេតការណ៍បោះឆ្នោត ............ ៨៤
- អ្នកសង្កេតការណ៍ជាតិ ............ ៨៥
- អ្នកសង្កេតការណ៍អន្តរជាតិ ............ ៨៨
- អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ ............ ៨៩

**ជំពូកទី ៧._ ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូលសរុបលទ្ធផលនៃការបោះឆ្នោត** ............ ៩៣
- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត ............ ៩៣
- សមាសភាពនៃ គជប ............ ៩៣
- ករណីបាត់បង់មុខតំណែងក្នុងសមាសភាពនៃ គជប ............ ៩៣
- លក្ខណៈវិនិច្ឆ័យ និងការតែងតាំងសមាជិក គជប ............ ៩៤
- រចនាសម្ព័ន្ធនៃ គជប ............ ៩៥
- សិទ្ធិអំណាចរបស់ គជប ............ ៩៥

- ការប្រគល់សិទ្ធិអំណាចរបស់ គជប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត ........ ៩៨
- រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គជប ក្នុងដំណាក់ការចុះឈ្មោះបោះឆ្នោត ដែល គឃ/កប ពុំទាន់ត្រូវបានតែងតាំង ........ ៩៩
- រចនាសម្ព័ន្ធនៃ គឃ/កប ........ ១០០
- លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គឃ/កប ........ ១០១
- ភារកិច្ច និងការទទួលខុសត្រូវនៃ គឃ/កប ........ ១០២
- រចនាសម្ព័ន្ធនៃគណៈកម្មការការិយាល័យបោះឆ្នោត គកប ........ ១០៥
- លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប ........ ១០៦
- ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប ........ ១០៧
- ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គជប សមាជិកនិងបុគ្គលិកនៃ គឃ/កប និងសមាសភាព គកប ........ ១១២
- ការតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ........ ១១៥
- កាលើកសំណើសុំតែងតាំងសមាសភាព គកប ........ ១១៦
- ប្រាក់កំរៃរបស់សមាជិក និងបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ........ ១១៩
- អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ........ ១១៩
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ........ ១១៩
- ការដាក់វិន័យ ការព្យួរការងារ ការបណ្តេញចេញពីការងារចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ ........ ១២០
- គោលការណ៍នៃការប្រើប្រាស់សម្ភារៈ និងបរិក្ខារនៃ គជប ........ ១២០
- ប្រតិទិនការងារបោះឆ្នោត ........ ១២១
- ការងារសន្តិសុខ ........ ១២១
- ការរៀបចំ និងការគ្រប់គ្រងដំណើរការនៃការបោះឆ្នោត ........ ១២៤
- សម្ភារៈឯកសារបោះឆ្នោតដែល គជប ត្រូវផ្គត់ផ្គង់ និងការត្រួតពិនិត្យរបស់ គកប លើសម្ភារៈឯកសារបោះឆ្នោតដែលបានទទួល និងទីតាំងការិយាល័យបោះឆ្នោត ........ ១២៥

- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១៣៥
- ការប្រព្រឹត្តទៅនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ១៣៦
- ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត ១៥២
- ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ១៥៦
- ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និង ត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬ កាលៈទេសៈមានអាសន្ន ឬ/និង ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន បដិសេធដោយ គជប ១៥៩
- ការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១៦៣
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ១៧២
- ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត ១៧៤
- ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំង សម្ភារៈឯកសារបោះឆ្នោតនៅសល់ទៅ គខ/កប ១៧៨
- ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គខ/កប ឬទីកន្លែងមានសុវត្ថិភាព ដែលកំណត់ដោយ គជប ១៧៩
- ការដាក់ពាក្យប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ ការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ និងការដោះស្រាយរបស់ គខ/កប លើបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ១៨២
- កិច្ចប្រតិបត្តិការរបស់ គខ/កប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការ បោះឆ្នោតក្នុងខេត្ត ក្រុង និងការរៀបចំតារាងបូកសរុបលទ្ធផល កំណត់ហេតុ បូកសរុបលទ្ធផល និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ១៨៩
- ការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ឃពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងកញ្ចប់ "ឃ " ដាក់សម្ភារៈឯកសារបោះឆ្នោត ពាក់ព័ន្ធត្រៀមបញ្ជូនទៅ គជប ១៩៧
- ការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសំរេចរបស់ គខ/កប ដែលបានបដិសេធ លើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នៅទីស្តីការ គជប ២០៣

- ការបង្កើតក្រុមទទួលសម្ភារៈឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ និងការត្រៀមលក្ខណសម្បត្តិបំរើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ........ ២០៥
- ការប្រគល់ និងការទទួលកញ្ចប់សុវត្ថិភាព "ឃពិសេស " ដាក់កំណត់ហេតុ បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងកញ្ចប់ "ឃ " ដាក់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គជប ........ ២១១
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ........ ២១៤
- ការត្រួតពិនិត្យឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើននៃខេត្ត ក្រុងចំណុះភូមិភាគដែលត្រូវបាន គខ/កប សម្រេចព្យួរជាបណ្តោះអាសន្ន ........ ២១៧
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគដែលគ្មាន ឬមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបានដាក់នៅ គខ/កប ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ........ ២២៤
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគដែលមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបានដាក់នៅ គខ/កប ឬ/និង គជប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើកផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ប៉ុន្តែ គខ/កប បានសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ........ ២២៧
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះមណ្ឌលភូមិភាគដែលមានការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបាន គជប សំរេចអោយបោះឆ្នោតសាជាថ្មី ........ ២៣៤
- ការបញ្ចូល និងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគក្នុងកុំព្យូទ័រ និងការកំណត់បែងចែកអាសនៈតាមមណ្ឌលភូមិភាគដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវបានទទួល ........ ២៣៨

**ជំពូកទី ៨._ សមត្ថកិច្ច នីតិវិធីសវនាការដោះស្រាយវិវាទ និងនីតិវិធីដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា** ........ ២៤៥

- **នីតិវិធីសវនាការដោះស្រាយវិវាទ** ........ ២៤៦
- សមាសភាពក្រុមប្រឹក្សាជំនុំជំរះ ........ ២៤៦
- ប្រភេទសវនាការ ........ ២៤៨
- ពេលវេលាដោះស្រាយបណ្តឹង និងការចាត់ចែងបើកសវនាការ ........ ២៤៨
- សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ តំណាង ឬមេធាវី ........ ២៤៩
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ........ ២៥១
- **នីតិវិធីដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា** ........ ២៥១
- នីតិវិធីដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅ គ.ខ/កប ........ ២៥៣
- នីតិវិធីដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅ គជប ........ ២៥៦

**ជំពូកទី ៩._ ការជ្រើសតាំងជំនួសសមាជិកព្រឹទ្ធសភា** ........ ២៦០

**ជំពូកទី ១០._ ចរិកា និងហិរញ្ញវត្ថុ** ........ ២៦១

**ជំពូកទី ១១._ ទោសប្បញ្ញត្តិ** ........ ២៦៥

## ឧបសម្ព័ន្ធ

១. ស្តីពីការបែងចែកអាសនៈ ........ ២៧១
២. ស្តីពីក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ........ ២៩៣
៣. ស្តីពីក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ........ ៣០១
៤. ស្តីពីគោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ........ ៣០៦
៥. ស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ........ ៣០៩
៦. ស្តីពីក្រមសីលធម៌សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ........ ៣១៨
៧. ស្តីពីបទបញ្ជាផ្ទៃក្នុងសវនាការដោះស្រាយបណ្តឹង ........ ៣៣២
៨. ស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ ........ ៣៣៣

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.១** អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងតាមរយៈក្របខ័ណ្ឌអំណាចដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) មានសិទ្ធិ និងមានភារកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (បទបញ្ជា និងនីតិវិធី) ដែលកំណត់អំពីការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងបញ្ជីបោះឆ្នោត ។

**ប្រការ ១.២** ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ក្រៅពីសមាជិកព្រឹទ្ធសភាពីរ(២)រូប ដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភាពីរ(២)រូប ដែលត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប សមាជិកព្រឹទ្ធសភាផ្សេងទៀតត្រូវបានជ្រើសតាំង តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**ប្រការ ១.៣** មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានរៀបចំតាមភូមិភាគ ។ ភូមិភាគនីមួយៗរួមបញ្ចូលគ្នានូវខេត្ត ក្រុងមួយ ឬច្រើន ។ មណ្ឌលបោះឆ្នោតនីមួយៗត្រូវមានសមាជិកព្រឹទ្ធសភាស្មើនឹងចំនួនអាសនៈក្នុងមណ្ឌលនោះ ដែលកំណត់ដោយព្រឹទ្ធសភា ។ សមាជិកព្រឹទ្ធសភា ត្រូវបានបោះឆ្នោតដោយអ្នកបោះឆ្នោតដែលកំណត់ដោយច្បាប់ គឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងក្នុងក្របខ័ណ្ឌនៃភូមិភាគនោះ តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ និងប្រកបដោយលក្ខណៈសេរី ស្មើភាព ត្រឹមត្រូវ និងយុត្តិធម៌ស្របតាមបញ្ញត្តិដូចចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីនេះ ។

**ប្រការ ១.៤** ចំនួនអាសនៈក្នុងព្រឹទ្ធសភានឹងត្រូវអនុម័តដោយព្រឹទ្ធសភា នៅប្រាំមួយ( ៦ )ខែមុនចប់នីតិកាលព្រឹទ្ធសភា ។

**ប្រការ ១.៥** នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ប្រាំមួយ( ៦ )ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

**ប្រការ ១.៦** ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើងប្រាំមួយ(៦)ឆ្នាំម្តង លើកលែងតែក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ។ ក្នុងករណីនេះ ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួន មួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ហើយការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភានឹងត្រូវសំរេចដោយមតិយល់ព្រមយ៉ាងតិចពីរភាគបី( ២/៣ )នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**ប្រការ ១.៧** ករណីសង្គ្រាម ឬកាលៈទេសៈពិសេសក្នុងប្រការ ១.៦ ខាងលើនេះ ត្រូវបានកំណត់ថាជាសង្គ្រាម សង្គ្រាមស៊ីវិល អំពើបះបោរ ឬបាតុភូតធម្មជាតិ ៖

១.៧.១ សង្គ្រាម គឺជាការប្រយុទ្ធរវាងកងទ័ពនៃភាគីដែលមានជំលោះនឹងគ្នាក្នុងប្រទេស ឬក៏ការវាយប្រយុទ្ធគ្នាប្រឆាំងកងទ័ពបរទេស ដែលរារាំងមិនឱ្យការចុះឈ្មោះបោះឆ្នោតអាចដំណើរការបាន រារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោតបានដោយសេរី និងមិនអាចឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៧.២ សង្គ្រាមស៊ីវិល គឺជាជំលោះនៅក្នុងប្រទេសដែលប្រជាជនប្រើអាវុធ ដើម្បីប្រយុទ្ធតតាំងនឹងរដ្ឋាភិបាល ឬដើម្បីដណ្តើមយកអំណាច ដែលរារាំងមិនឱ្យការចុះឈ្មោះបោះឆ្នោតអាចដំណើរការបាន រារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោតបានដោយសេរី និងមិនអាចឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៧.៣ ការបះបោរដោយចលនាឧទ្ទាមប្រឆាំងទល់នឹងរដ្ឋាភិបាលលើបញ្ហាមួយ ឬបញ្ហាច្រើន ដែលអាចមានអំពើហិង្សា ឬការបះបោរដោយសន្តិវិធីនៅតាមខេត្ត ក្រុង ភូមិភាគ ឬនៅទូទាំងប្រទេស ឬការរាំងស្ទះផ្នែករដ្ឋបាល ដែលរារាំងមិនឱ្យការចុះឈ្មោះបោះឆ្នោតអាចដំណើរការបាន រារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោតបានដោយសេរី និងមិនអាចឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៧.៤ បាតុភូតធម្មជាតិដែលរួមមាន ការរញ្ជួយផែនដីកំរិត ៤ រិចទ័រឡើងទៅ ទឹកជំនន់ ភាពរាំងស្ងួត អគ្គីភ័យ មហាអគ្គីភ័យ ខ្យល់ព្យុះ ឬគ្រោះធម្មជាតិផ្សេងទៀត ជំងឺរាតត្បាតនៅផ្នែកមួយ ឬនៅទូទាំងប្រទេស ដែលរារាំងមិនឱ្យការចុះឈ្មោះបោះឆ្នោតអាចដំណើរការបាន រារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោតបានដោយសេរី និងមិនអាចឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

**ប្រការ ១.៨** ក្នុងពេលមានសង្គ្រាម ឬកាលៈទេសៈពិសេស ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេស កាលបើសភាពការណ៍អនុញ្ញាត ។

**ប្រការ ១.៩** ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាអាចនឹងធ្វើឡើង នៅក្រោយរយៈពេលប្រាំមួយ (៦)ឆ្នាំបាន ប្រសិនបើព្រឹទ្ធសភាត្រូវបានបន្តនីតិកាលរបស់ខ្លួន ដោយមូលហេតុមានសង្គ្រាម ឬកាលៈទេសៈពិសេស ស្របតាមមាត្រា ១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។ នៅពេលដែលសង្គ្រាម ឬកាលៈទេសៈពិសេសត្រូវបានបញ្ចប់ គជប ត្រូវរៀបចំប្រតិទិនសម្រាប់ការបោះឆ្នោតស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្នុងនោះត្រូវ ៖

១.៩.១ គោរពរយៈពេលបញ្ចប់ នៃការបន្តនីតិកាលរបស់ព្រឹទ្ធសភា ដែលបានចែងក្នុងមាត្រា១០២ថ្មី និងរយៈពេលកំណត់ដែលបានចែងក្នុងមាត្រា១០៦ថ្មីនៃរដ្ឋធម្មនុញ្ញ ដើម្បីធានាឱ្យព្រឹទ្ធសភានីតិកាលថ្មីកោះប្រជុំក្នុងរយៈពេលហុកសិប( ៦០ )ថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោត ។

១.៩.២ លើកយោបល់ជូនរាជរដ្ឋាភិបាល អំពីកាលបរិច្ឆេទនៃការបោះឆ្នោត ព្រមទាំងកត្តាសន្តិសុខ និងបរិយាកាសសំរាប់ការបោះឆ្នោត ។

**ប្រការ ១.១០** ភូមិភាគ ឬខេត្ត ក្រុងណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានដោយសារករណីកាលៈទេសៈពិសេស គជប ត្រូវធ្វើសេចក្តីរាយការណ៍ទូលថ្វាយព្រះមហាក្សត្រ និងជូនព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល ក្រុមប្រឹក្សាធម្មនុញ្ញ ។

១.១០.១ គជប មានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតមួយ ឬច្រើននៅទីប្រជុំជនខេត្ត ក្រុងនៃមណ្ឌលភូមិភាគណាមួយ ក្នុងកាលៈទេសៈពិសេសដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងបរិវេណខាងក្នុង ។

១.១០.២ គជប ត្រូវរាយការណ៍ជាបន្ទាន់ទូលថ្វាយព្រះមហាក្សត្រ និងជូនព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល ក្រុមប្រឹក្សាធម្មនុញ្ញ អំពីការិយាល័យបោះឆ្នោតនៅទីប្រជុំជនខេត្ត ក្រុង នៃមណ្ឌលភូមិភាគណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបាន ដោយករណីកាលៈទេសៈពិសេស ។

**ប្រការ ១.១១** ករណីការិយាល័យបោះឆ្នោតនៅទីប្រជុំជនខេត្ត ក្រុងនៃភូមិភាគណា ដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតបាន ដូចចែងក្រោមប្រការ ១.១០ ខាងលើ ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍នៅទីប្រជុំជនខេត្ត ក្រុងនៃភូមិភាគនោះមានភាពប្រក្រតីឡើងវិញ ។

**ប្រការ ១.១២** ការបោះឆ្នោតសាជាថ្មី ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំបី( ៨ )ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែល គជប ប្រកាសមិនបើកការិយាល័យបោះឆ្នោតណាមួយ ឬបិទការិយាល័យបោះឆ្នោតណាមួយនៅថ្ងៃបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយនៅទីប្រជុំជនខេត្ត ក្រុងនៃភូមិភាគណាមួយ ។

# ជំពូកទី ២

# ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត ចំនួនអាសនៈ អ្នកបោះឆ្នោត អង្គបោះឆ្នោត ការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោត

## ប្រព័ន្ធបោះឆ្នោត

**ប្រការ ២.១** ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើងប្រាំមួយ(៦)ឆ្នាំម្តង នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី៤ មុនដំណាច់ឆ្នាំទី៦នៃនីតិកាលរបស់ព្រឹទ្ធសភា លើកលែងតែក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ នៃព្រឹទ្ធសភា ត្រូវប្រព្រឹត្តទៅនាថ្ងៃអាទិត្យទី ២២ ខែ មករា ឆ្នាំ ២០០៦ ។

**ប្រការ ២.២** ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ហើយការបែងចែកអាសនៈត្រូវគិតតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយកំណត់យកភូមិភាគធ្វើជាមណ្ឌលបោះឆ្នោត ។

២.២.១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវលើកស្នើបញ្ជីបេក្ខជន ដោយផ្អែកលើមូលដ្ឋានមណ្ឌលភូមិភាគ ។

២.២.២ សមាជិកព្រឹទ្ធសភា ដែលមិនត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ឬជ្រើសតាំងដោយរដ្ឋសភា ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

២.២.៣ សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសតាំងតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោត ដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ក្នុងក្របខ័ណ្ឌនៃភូមិភាគ ។

២.២.៣.១ តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងក្នុងក្របខ័ណ្ឌនៃភូមិភាគអាចចុះឈ្មោះនិងមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតតែមួយនៅទីប្រជុំជនខេត្ត ក្រុងតែមួយគត់ចំណុះភូមិភាគ ។

២.២.៣.២ តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្របខ័ណ្ឌភូមិភាគ ដែលជាអ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការជ្រើសរើសឆ្នោតជាសម្ងាត់ ។

២.២.៤ ការបែងចែកអាសនៈត្រូវផ្អែកលើលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាមមណ្ឌលភូមិភាគ និងគិតតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចបានចែងលំអិតក្នុងឧបសម្ព័ន្ធនៃបទបញ្ជានិងនីតិវិធីនេះ ស្តីពីការបែងចែកអាសនៈ ។

**មណ្ឌលបោះឆ្នោត**

**ប្រការ ២.៣** មណ្ឌលបោះឆ្នោតត្រូវបានរៀបចំតាមភូមិភាគ ដែលរួមមានខេត្ត ក្រុងចំនួនមួយ ឬច្រើន ។

២.៣.១ ភូមិភាគទី១ មាន ក្រុងភ្នំពេញ ។

២.៣.២ ភូមិភាគទី២ មាន ខេត្តកំពង់ចាម ។

២.៣.៣ ភូមិភាគទី៣ មាន ខេត្តកណ្តាល ។

២.៣.៤ ភូមិភាគទី៤ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន ។

២.៣.៥ ភូមិភាគទី៥ រួមមាន ខេត្តតាកែវ កំពត និងក្រុងកែប ។

២.៣.៦ ភូមិភាគទី៦ រួមមាន ខេត្តព្រៃវែង និងស្វាយរៀង ។

២.៣.៧ ភូមិភាគទី៧ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ ។

២.៣.៨ ភូមិភាគទី៨ រួមមាន ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ។

## ការកំណត់ចំនួនអាសនៈក្នុងព្រឹទ្ធសភា និងតាមមណ្ឌលភូមិភាគ

**ប្រការ ២.៤** នៅប្រាំមួយ( ៦ )ខែមុនចប់នីតិកាលព្រឹទ្ធសភា ចំនួនអាសនៈក្នុងព្រឹទ្ធសភា និងការបែងចែកអាសនៈតាមមណ្ឌលភូមិភាគនីមួយៗ សំរាប់នីតិកាលបន្ទាប់ នឹងត្រូវអនុម័តដោយព្រឹទ្ធសភា និងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ក្នុងករណី ព្រឹទ្ធសភាមិនបានអនុម័តជាថ្មី នូវចំនួនអាសនៈក្នុងព្រឹទ្ធសភា និងការបែងចែកអាសនៈតាមភូមិភាគ ត្រូវយកតាមចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

២.៤.១ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ដែលត្រូវធ្វើនៅថ្ងៃអាទិត្យ ទី ២២ ខែ មករា ឆ្នាំ ២០០៦ ចំនួនអាសនៈសមាជិកព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំងរួមមាន ៥៧ អាសនៈ ។ អាសនៈទាំងនេះត្រូវបានបែងចែកតាមមណ្ឌលភូមិភាគនានា ដូចខាងក្រោម ៖

២.៤.១.១ ភូមិភាគទី១ មាន ៦ អាសនៈ ។

២.៤.១.២ ភូមិភាគទី២ មាន ៨ អាសនៈ ។

២.៤.១.៣ ភូមិភាគទី៣ មាន ៥ អាសនៈ ។

២.៤.១.៤ ភូមិភាគទី៤ មាន ១០ អាសនៈ ។

២.៤.១.៥ ភូមិភាគទី៥ មាន ៧ អាសនៈ ។

២.៤.១.៦ ភូមិភាគទី៦ មាន ៧ អាសនៈ ។

២.៤.១.៧ ភូមិភាគទី៧ មាន ៨ អាសនៈ ។

២.៤.១.៨ ភូមិភាគទី៨ មាន ៦ អាសនៈ ។

២.៤.២ ចំនួនអាសនៈតាមមណ្ឌលភូមិភាគ ដូចចែងក្រោមចំណុច ២.៤.១ ខាងលើ ត្រូវតែបានផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ ។

## អ្នកបោះឆ្នោត និងអង្គបោះឆ្នោត

**ប្រការ ២.៥** អ្នកបោះឆ្នោតដែលកំណត់ដោយច្បាប់ គឺតំណាងរាស្ត្រក្នុងតំណែងនិងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ទាំងស្រី ទាំងប្រុស ក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។ គជប ត្រូវណែនាំដល់អ្នកបោះឆ្នោត អង្គបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ អំពីបែបបទ បទបញ្ញត្តិនិងនីតិវិធីទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

២.៥.១ ការចុះឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងចំណុះមណ្ឌលភូមិភាគនីមួយៗ ទៅក្នុងបញ្ជីបោះឆ្នោត សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាការងារតម្រូវដោយច្បាប់ ។

២.៥.២ តំណាងរាស្ត្រក្នុងតំណែងម្នាក់ៗ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងម្នាក់ៗ មានសិទ្ធិចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយនៅទីប្រជុំជនខេត្ត ក្រុងតែមួយគត់ចំណុះមណ្ឌលភូមិភាគពាក់ព័ន្ធ ។

២.៥.៣ ការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមរបៀបស្រង់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតបញ្ចូលទៅក្នុងបញ្ជីឈ្មោះដោយឡែកពីគ្នា ទៅតាមអង្គបោះឆ្នោតនីមួយៗ និងបញ្ជូនតាមលំដាប់ឋានានុក្រមមក គជប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ។

២.៥.៤ អគ្គលេខាធិការដ្ឋាន នៃរដ្ឋសភាត្រូវរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ដែលមានការបញ្ជាក់ឯកភាពពីប្រធានរដ្ឋសភាមក គជប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ។ បញ្ជីឈ្មោះនេះត្រូវរៀបចំដោយឡែកពីគ្នា ទៅតាមតំណាងរាស្ត្រក្នុងតំណែងនៃមណ្ឌលខេត្ត ក្រុងនីមួយៗ ។

២.៥.៥ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់ត្រូវរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង រួចចុះហត្ថលេខា បោះត្រា និងបញ្ជូនមក គជប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ដោយមានការបញ្ជាក់ឯកភាពពីអភិបាលស្រុក ខណ្ឌ និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធផង ។

២.៥.៦ ក្នុងករណី ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់និងជាមេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ណាមួយមិនបានរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងមក គជប ដូចមានចែងក្នុងចំណុច ២.៥.៥ ខាងលើ គជប ត្រូវធ្វើប្រតិភូកម្មអំណាចដល់អភិបាលស្រុក ខណ្ឌពាក់ព័ន្ធរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ រួចចុះហត្ថលេខាបោះត្រា និងបញ្ជូន មក គជប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានដោយមានការបញ្ជាក់ឯកភាពពីអភិបាលខេត្ត ក្រុងពាក់ព័ន្ធផង ។

**លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត**

**ប្រការ ២.៦** អ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ នៅទីប្រជុំជនខេត្ត ក្រុងណាមួយនៃភូមិភាគពាក់ព័ន្ធ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

២.៦.១ ជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្រុបខ័ណ្ឌនៃភូមិភាគនីមួយៗ ។

២.៦.២ មិនចាំបាច់បង្ហាញខ្លួន ឬអាចទៅបង្ហាញខ្លួនចំពោះមុខប្រធាន ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីសាមីអង្គបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីទទួលព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីការិយាល័យបោះឆ្នោត និងអំពីតម្រូវការឯកសារនៅពេលបោះឆ្នោត ។

**ការិយាល័យចុះឈ្មោះបោះឆ្នោត**

**ប្រការ** ២.៧ ការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សំរាប់អង្គបោះឆ្នោតរដ្ឋសភា និងការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សំរាប់អង្គបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។ ការិយាល័យចុះឈ្មោះបោះឆ្នោតគឺជាការិយាល័យស្ថិតនៅមួយកន្លែង ។

២.៧.១ ការិយាល័យចុះឈ្មោះបោះឆ្នោតសំរាប់តំណាងរាស្ត្រក្នុងតំណែងត្រូវមានទីតាំងនៅអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ។

២.៧.២ ការិយាល័យចុះឈ្មោះបោះឆ្នោតសំរាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ឬទីតាំងណាមួយសមស្របក្នុងឃុំ សង្កាត់ ។

**ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ** ២.៨ គជប ត្រូវកំណត់ក្នុងជំហានដំបូងនូវការិយាល័យបោះឆ្នោតចំនួនមួយ ឬច្រើនដែលមានទីតាំងនៅទីប្រជុំជននៃខេត្ត ក្រុងនីមួយៗ ចំណុះមណ្ឌលភូមិភាគពាក់ព័ន្ធ នៅក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ(១៥)ថ្ងៃ មុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត ។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតអាចនឹងកែសម្រួលជាចុងក្រោយនិងកំណត់ជាផ្លូវការដោយ គជប បន្ទាប់ពីការចុះឈ្មោះបោះឆ្នោតបានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់នៅរយៈពេលយ៉ាងយូរប្រាំពីរ(៧)ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ការិយាល័យបោះឆ្នោតទាំងអស់នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

២.៨.១ សម្រាប់ការចុះឈ្មោះបោះឆ្នោតបំរើការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការកំណត់ចំនួនការិយាល័យបោះឆ្នោតដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុងនីមួយៗ ត្រូវផ្អែកជាមូលដ្ឋានលើចំនួនសរុប នៃអ្នកបោះឆ្នោត ដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងនីមួយៗ ចំណុះភូមិភាគពាក់ព័ន្ធ ។

២.៨.២ ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ឬ/និង ការបង្កើតការិយាល័យបោះឆ្នោតថ្មីនៅទីប្រជុំជននៃខេត្ត ក្រុងនីមួយៗចំណុះមណ្ឌលភូមិភាគពាក់ព័ន្ធ ត្រូវគោរពតាមលក្ខខណ្ឌជាក់ស្ដែង និងសុវត្ថិភាពនៃកិច្ចប្រតិបត្តិការបោះឆ្នោត ។

២.៨.៣ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបំរើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់ ។ ការិយាល័យបោះឆ្នោត និងតំបន់បោះឆ្នោតស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែរួមបញ្ចូលនូវសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំណុះស្រុក ខណ្ឌមួយចំនួន ដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលខេត្ត ក្រុងនីមួយៗចំណុះមណ្ឌលភូមិភាគពាក់ព័ន្ធ និងអាចបន្ថែមតំណាងរាស្ត្រក្នុងតំណែងនៃមណ្ឌលខេត្ត ក្រុងពាក់ព័ន្ធ ។

២.៨.៤ គជប ត្រូវចាត់វាលវិធានការចាំបាច់ ដើម្បីបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើននៅទីប្រជុំជនខេត្ត ក្រុង សម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងខេត្ត ក្រុងនោះ និងតំណាងរាស្ត្រក្នុងតំណែងនៃមណ្ឌលខេត្ត ក្រុងពាក់ព័ន្ធ ដែលមានសិទ្ធិបោះឆ្នោត បានចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតទាំងអស់គ្នា ។

២.៨.៥ ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួនប្រាំពីររយ( ៧០០ )នាក់ ។

២.៨.៦ ការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យ ត្រូវបានផ្ដល់សុពលភាពជាផ្លូវការដោយ គជប នឹងត្រូវប្រើជាការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

២.៨.៧ ការិយាល័យបោះឆ្នោត គឺជាការិយាល័យនៅមួយកន្លែង ដែល គជប បង្កើតឡើងនៅទីតាំងជាក់លាក់មួយសំរាប់តំបន់បោះឆ្នោតមួយជាកំណត់ ហើយដែលត្រូវបើកទទួលអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ មកបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

២.៨.៨ ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត ត្រូវយកចិត្តទុកដាក់ចំពោះទីតាំងសាលារៀន ទីវត្តអារាម និងទីសាធារណៈ ។

២.៨.៩ ការិយាល័យបោះឆ្នោត មិនត្រូវបានបង្កើត នៅក្នុងបរិវេណទីធ្លា និងអាគាររបស់រាជរដ្ឋាភិបាលដូចជា សាលាខេត្ត ក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ ជាដើម ឬនៅបន្ទាយ ឬអាគារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬ/និង អាគាររបស់គណបក្សនយោបាយ នៅគ្រប់លំដាប់ថ្នាក់ ។

**វិធានការសន្តិសុខសំរាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ** ២.៩ ការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

២.៩.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអាគារ ដែលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខ័ណ្ឌដោយវ័ណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិចដប់ប្រាំ( ១៥ )ម៉ែត្រ ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។

២.៩.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខ័ណ្ឌដោយវ័ណ្ឌមណ្ឌល មានកាំប្រវែងមួយរយ( ១០០ )ម៉ែត្រ ឬមានកាំតូចជាងស្របតាមស្ថានភាពទីតាំងជាក់ស្តែងឬមានទម្រង់ផ្សេងពីនេះ ដូចជារបងខាងក្រៅបរិវេណនៃវត្តអារាម សាលារៀន សាល ឬទីធ្លាសាធារណៈជាដើម ។

២.៩.៣ ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ ចរាចរ និង សណ្តាប់ធ្នាប់ នៅទីប្រជុំជនខេត្ត ក្រុងនីមួយៗ គខ/កប អាចចាត់ចែងឱ្យមានបរិវេណសន្តិសុខសំរាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ដើម្បីបង្ការកុំឱ្យមានការរំខានដល់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

**ប្រការ** ២.១០ ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង នៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារឧបករណ៍សម្ភារៈទាំងអស់ក្នុងការិយាល័យទាំងនោះ គជប គខ/កប និងប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម ៖

២.១០.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត

និងរាប់សន្លឹកឆ្នោត ។ ក្នុងករណីដែលមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រធាន គជប ឬ/និងប្រធាន គខ/កប ឬ/និងប្រធាន គកប មានភារកិច្ចស្នើសុំអន្តរាគមន៍រក្សាសន្តិសុខ ពីអាជ្ញាធរមានសមត្ថកិច្ចនៅគ្រប់លំដាប់ថ្នាក់ ។

២.១០.១.១ ប្រធាន គជប និងប្រធាន គខ/កប ត្រូវប្រគល់សិទ្ធិអំណាចពេញលេញ ឱ្យដល់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងការទំនាក់ទំនងស្នើសុំអន្តរាគមន៍ ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដូចចែងក្នុងចំណុច ២.១០.១ ខាងលើ ។

២.១០.១.២ ក្នុងករណី មានសំណូមពរពីប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ភ្នាក់ងារសន្តិសុខ ដែលត្រូវបានបំពាក់អាវុធសមស្របអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ ។

២.១០.១.៣ គ្មាននាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និងកងនគរបាលជាតិណាម្នាក់អាចចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារ សន្តិសុខឡើយ លើកលែងតែ ពួកគេត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចចែងក្នុងប្រការ ២.១០ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ២.១០.១ ខាងលើ ។

២.១០.២ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គជប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

២.១០.២.១ សមាសភាព គកប ដែលបានទទួលការតែងតាំងពី គជប ។

២.១០.២.២ តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតនិងអ្នកសង្កេតការណ៍ ដែលទទួលបានការអនុញ្ញាតពី គជប ឬគណកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.១០.២.៣ អ្នកយកព័ត៌មានដែលទទួលបានការអនុញ្ញាតពី គជប ឬគណៈកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.១០.២.៤ អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.១០.២.៥ ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គកប សំណូមពរ ក្នុងករណីចាំបាច់ ។

២.១០.៣ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.១០.៣.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.១០.៣.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

២.១០.៣.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.១០.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គជប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

២.១០.៤.១ សមាសភាព គកប ដែលបានទទួលការតែងតាំងពី គជប និងដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅការិយាល័យនោះ ។

២.១០.៤.២ តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតនិងអ្នកសង្កេតការណ៍ ដែលទទួលបានការអនុញ្ញាតពី គជប ឬគណកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.១០.៤.៣ អ្នកយកព័ត៌មានដែលទទួលបានការអនុញ្ញាតពី គជប ឬគណៈកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.១០.៤.៤ ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គកប ដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅការិយាល័យនោះសំណូមពរ ក្នុងករណីចាំបាច់ ។

២.១០.៥ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.១០.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.១០.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យសមាសភាព គកប ដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោត រាប់គំនូសនៅលើសន្លឹកឆ្នោត គាំទ្រ ឬប្រឆាំង បញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.១០.៦ ក្នុងករណីចាំបាច់ គខ/កប ឬ/និងប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត អាចអនុវត្តលក្ខខណ្ឌដូចចែងក្នុងចំណុច ២.៩.៣ ខាងលើ ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

២.១០.៧ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវបានប្រគល់សិទ្ធិពេញលេញដោយ គជប ស្របតាមលក្ខខណ្ឌនៃច្បាប់ ។

**ប្រការ** ២.១១ ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ គជប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ដែលមានសុវត្ថិភាព ។ គជប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្ដីសម្រេចនេះ ។

**ប្រការ** ២.១២ សំណង់ អាគារ ឬទីធ្លាសាធារណៈ និងទីវត្តអារាមត្រូវបានផ្ដល់ដោយឥតគិតថ្លៃទៅ គជប សម្រាប់រៀបចំជាការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## ការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

**ប្រការ** ២.១៣ គជប ត្រូវបោះពុម្ពផ្សាយនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានបណ្ដុះបណ្ដាលនិងព័ត៌មានសាធារណៈនៃ គជប ត្រូវអនុវត្តដោយផ្ទាល់ឬ/និងសហការជាមួយអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា

លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬ គខ/កប ក្រុមប្រឹក្សាឃុំ សង្កាត់ និងសង្គមស៊ីវិល ក្នុងការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យខាងលើឱ្យបានយល់ជ្រួតជ្រាបដល់តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលជាអ្នកបោះឆ្នោត និងអង្គបោះឆ្នោត សំរាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

២.១៣.១ គជប ត្រូវណែនាំអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងសាលាឃុំ សង្កាត់ យ៉ាងតិចប្រាំពីរ( ៧ )ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។

២.១៣.២ នៅក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គជប នូវចំនួននិងទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គជប ត្រូវណែនាំ គខ/កប ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅលេខាធិការដ្ឋាននៃ គខ/កប នៅតាមទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនខេត្ត ក្រុង យ៉ាងតិចដប់( ១០ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១៣.៣ តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងគ្រប់រូប គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍ មានសិទ្ធិស្នើសុំពី គជប នូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតផ្លូវការនៃខេត្ត ក្រុងមួយឬច្រើន ឬនៃភូមិភាគមួយឬច្រើន ដោយត្រូវបង់ថ្លៃត្រឹមថ្លៃផលិត ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹងមួយរយ( ១០០ )ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

## សង្ខេបដំណាក់ការនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

**ប្រការ ២.១៤** ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រួមមានដំណាក់ការ ដូចខាងក្រោម ៖

២.១៤.១ ការចុះឈ្មោះបោះឆ្នោតជូនតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងគ្រប់រូប ដោយឡែកពីគ្នា នៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងនៃមណ្ឌលភូមិភាគនីមួយៗ ។

២.១៤.២ ការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង តាមលំដាប់ឋានានុក្រម មក គជប ដើម្បី គជប បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.១៤.៣ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅលេខាធិការដ្ឋាននៃ គខ/កប និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនខេត្ត ក្រុងនៃមណ្ឌលភូមិភាគពាក់ព័ន្ធ ។

២.១៤.៤ ការដាក់ពាក្យបណ្ដឹង និងការដោះស្រាយរាល់បណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ដែលទាក់ទងដល់ការចុះឈ្មោះបោះឆ្នោត ឬ/និង ការរៀបចំបញ្ជីបោះឆ្នោតដំបូងមិនត្រឹមត្រូវ ក្នុងគោលដៅនៃការកែតម្រូវបញ្ជីបោះឆ្នោតដំបូងដែលបានបិទផ្សាយ ។

២.១៤.៥ ការកែតម្រូវបញ្ជីបោះឆ្នោតដំបូង ការបោះពុម្ព និងការផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត តាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ**

**ប្រការ ២.១៥** គជប ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ យ៉ាងតិចដប់ប្រាំ ( ១៥ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ដើម្បីធានាឱ្យការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការប្ដឹងនិងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងការផ្ដល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ដំណើរការទៅយ៉ាងរលូន និងទាន់ពេលវេលាដែលកំណត់ដោយច្បាប់ គជប ត្រូវកំណត់រយៈពេលនិងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការិយាល័យចុះឈ្មោះនៅតាមអង្គបោះឆ្នោតនីមួយៗ ។

២.១៥.១ ការចុះឈ្មោះបោះឆ្នោត រួមនឹងការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងនៃមណ្ឌលភូមិភាគនីមួយៗ តាមលំដាប់ឋានានុក្រម មកដល់ គជប ត្រូវបានកំណត់រយៈពេលសរុបត្រឹមម្ភៃមួយ( ២១ )ថ្ងៃ ដោយមិនគិតបញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

២.១៥.១.១ រយៈពេលសំរាប់ការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះនៃអង្គបោះឆ្នោតនីមួយៗត្រូវបានកំណត់ស្មើនឹងដប់បួន(១៤)ថ្ងៃ ។

២.១៥.១.២ រយៈពេលសំរាប់ការបញ្ជាក់ឯកភាព និងការបញ្ជូនបញ្ជីឈ្មោះនៃអង្គបោះឆ្នោតពាក់ព័ន្ធ តាមលំដាប់ឋានានុក្រម មក គជប ត្រូវបានកំណត់រយៈពេលប្រាំពីរ( ៧ )ថ្ងៃ ។

២.១៥.១.៣ ក្នុងករណី ការិយាល័យណាមួយបានចុះឈ្មោះ ជូនតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងគ្រប់រូបរួចរាល់មុនរយៈពេលកំណត់ ការិយាល័យនោះអាចបន្តអនុវត្តជំហានបញ្ជាក់ឯកភាព និងបញ្ជូនបញ្ជីឈ្មោះនៃអង្គបោះឆ្នោតពាក់ព័ន្ធតាមលំដាប់ឋានានុក្រម មក គជប ដោយពុំចាំបាច់រង់ចាំទេ ។

២.១៥.២ ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស និងនៅអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ក្នុងថ្ងៃតែមួយ ដូចបានកំណត់ក្នុងប្រតិទិនការងាររបស់ គជប ។ ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ និងអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ត្រូវបើកអនុវត្តការចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលម៉ោងធ្វើការ នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។

២.១៥.៣ គជប ត្រូវណែនាំអគ្គលេខាធិការនៃរដ្ឋសភា លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល និងកាលបរិច្ឆេទដូចចែងក្នុងចំណុច ២.១៥.១ ខាងលើ ព្រមទាំងប្រតិទិនសំរាប់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះនៃអង្គបោះឆ្នោតនីមួយៗ ក្នុងរយៈពេលយ៉ាងតិចប្រាំពីរ( ៧ )ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។

**ការទទួលខុសត្រូវរបស់អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា**

**ប្រការ** ២.១៦ ដោយហេតុថា អ្នកបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាតំណាងរាស្ត្រក្នុងតំណែង និងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងនៃភូមិភាគនីមួយៗ គជប ត្រូវលើកសំណើសុំទៅប្រធានរដ្ឋសភា និងក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់អគ្គលេខាធិការ នៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត ក្នុងក្របខ័ណ្ឌការិយាល័យចុះឈ្មោះនៃអង្គបោះឆ្នោតនីមួយៗ ។ គជប ត្រូវណែនាំជាក់ស្តែង និងផ្តល់គំរូទម្រង់ បែបបទមួយចំនួនដល់អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តការទទួលខុសត្រូវនេះ ។

២.១៦.១ ដើម្បីធានារ៉ាប់រងការអនុវត្តសិទ្ធិអំណាចដែល គជប បានធ្វើប្រតិភូកម្មអំណាចឱ្យខ្លួន អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតួនាទីនិងភារកិច្ច ដូចខាងក្រោម ៖

២.១៦.១.១ អនុវត្តត្រឹមត្រូវតាមច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ញានិងនីតិវិធីរបស់ គជប ។ ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀងក្នុងពេលបំពេញការងារ និងធានាឱ្យដំណើរការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។

២.១៦.១.២ ចាត់វិធានការសមស្រប ដើម្បីធានាថាដំណើរការនៃការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង ។

២.១៦.១.៣ ធានាឱ្យអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយ ដែលមានការបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធររៀបចំការបោះឆ្នោត មានលទ្ធភាពសង្កេតការណ៍ក្នុងដំណើរការ នៃការចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

២.១៦.១.៤ ស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងក្របខ័ណ្ឌខេត្ត ក្រុងនៃភូមិភាគនីមួយៗម្នាក់ម្តងៗ និងត្រូវពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ប្រសិនបើឃើញថា ត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់បញ្ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ។

២.១៦.១.៥ មិនបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ចំពោះអ្នកដែលមិនបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៦ ខាងលើ ។

២.១៦.១.៦ ជំរាបជូនអ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រ ក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ក្នុងករណី គាត់មកបង្ហាញខ្លួន ឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងឱ្យគាត់យកទៅជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ដើម្បីបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

ប្រសិនបើគាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ត្រូវជំរាបគាត់ឱ្យត្រៀមស្នើសុំជាមុននូវលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អំពីអត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ចេញដោយមេឃុំ ចៅសង្កាត់ ។

២.១៦.១.៧ ជូនដំណឹងចំពោះអ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានមកបង្ហាញខ្លួន តាមមធ្យោបាយដែលមាន នូវខ្លឹមសារនិងព័ត៌មាន ដូចចែងក្នុងចំណុច ២.១៦.១.៦ ខាងលើ ។

២.១៦.១.៨ ធានាថាតំណាងរាស្ត្រក្នុងតំណែងគ្រប់រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែងគ្រប់រូប ក្នុងក្របខ័ណ្ឌខេត្ត ក្រុង នៃភូមិភាគនីមួយៗ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ។

២.១៦.១.៩ សំរបសំរួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចេញលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង មានបិទរូបថតសាមីខ្លួន តាមការស្នើសុំ ។ លិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ត្រូវចេញដោយប្រធាន នៃស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។ ដោយឡែក លិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ត្រូវចេញដោយមេឃុំ ចៅសង្កាត់ដែលតំណាងរាស្ត្រ ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះរស់នៅ ។

២.១៦.១.១០ រាយការណ៍ជូន គជប តាមលំដាប់ឋានានុក្រម នូវរាល់ហេតុការណ៍ដែលបានកើតមានក្នុងដំណើរការ នៃការចុះឈ្មោះបោះឆ្នោត ដើម្បីសំរបសំរួលនិងដោះស្រាយបញ្ហា ។

២.១៦.១.១១ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ និងរៀបចំបញ្ចូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង តាមលំដាប់ឋានានុក្រមមក គជប ដើម្បី គជប រៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.១៦.១.១២ ចូលរួមបំភ្លឺក្នុងរាល់សវនាការរបស់ គខ/កប គជប និងក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង ប្រសិនបើមានតម្រូវការជាចាំបាច់ ។

**សម្ភារៈឯកសារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត**

**ប្រការ ២.១៧** គជប ត្រូវធានាការផ្គត់ផ្គង់សម្ភារៈឯកសារគ្រប់គ្រាន់ សម្រាប់បំរើកិច្ចប្រតិបត្តិការ នៃការចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា ។

២.១៧.១ គជប ត្រូវផ្គត់ផ្គង់សម្ភារៈឯកសារឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីបន្តណែនាំសម្របសម្រួលក្នុងការងារចុះឈ្មោះបោះឆ្នោតនៅតាមអង្គបោះឆ្នោតនៃក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ចំណុះខេត្ត ក្រុង ។

២.១៧.២ គជប ត្រូវផ្គត់ផ្គង់សម្ភារៈឯកសារសម្រាប់បំរើការចុះឈ្មោះបោះឆ្នោត ឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលអនុវត្តការចុះឈ្មោះបោះឆ្នោត នៅតាមសាមីអង្គបោះឆ្នោត ។

**ការចុះឈ្មោះបោះឆ្នោត និងការរៀបចំនិងបញ្ជូនបញ្ជីឈ្មោះតាមអង្គបោះឆ្នោត មក គជប**

**ប្រការ ២.១៨** ផ្អែកតាមបទបញ្ញត្តិនិងនីតិវិធី និងការណែនាំរបស់ គជប ផ្អែកតាមការកំណត់រយៈពេលនិងកាលបរិច្ឆេទសំរាប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានទទួលសម្ភារៈឯកសារបំរើការចុះឈ្មោះបោះឆ្នោត អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ ពីសាមីអង្គបោះឆ្នោតនីមួយៗ ត្រូវចាត់ចែងបើកការិយាល័យចុះឈ្មោះបោះឆ្នោត តាមប្រតិទិនកំណត់ និងត្រូវអនុវត្តឱ្យបានរួចរាល់ឆាប់រហ័ស តាមដែលអាចធ្វើបាន ដើម្បីរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង តាមលំដាប់ឋានានុក្រម មក គជប ឱ្យបានទាន់ពេលវេលា ។ ក្នុងនោះ អគ្គលេខាធិការនៃរដ្ឋសភានិងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីសាមីអង្គបោះឆ្នោតនីមួយៗ ត្រូវ ៖

២.១៨.១ ចាត់ចែងរៀបចំឱ្យមានបន្ទប់មួយ ព្រមទាំងតុ និងកៅអីមួយចំនួនសំរាប់ប្រើប្រាស់ជាការិយាល័យចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៧ ខាងលើ ។

២.១៨.១.១ ការិយាល័យចុះឈ្មោះបោះឆ្នោត អាចតាំងនៅបន្ទប់ធ្វើការ របស់អគ្គលេខាធិការនៃរដ្ឋសភា ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីសាមីអង្គបោះឆ្នោតនីមួយៗ ។

២.១៨.២ បិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតពីសាមី

អង្គបោះឆ្នោតពាក់ព័ន្ធ យ៉ាងតិចប្រាំពីរ( ៧ )ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។ រក្សាទុកបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមួយ( ១ )ច្បាប់ សំរាប់ប្រើប្រាស់ក្នុងពេលចុះឈ្មោះបោះឆ្នោត ។

២.១៨.៣ បិទផ្សាយប្រតិទិនសំរាប់ការចុះឈ្មោះបោះឆ្នោតតាមអង្គបោះឆ្នោតពាក់ព័ន្ធ នៅខាងមុខការិយាល័យចុះឈ្មោះបោះឆ្នោត យ៉ាងតិចប្រាំពីរ( ៧ )ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។ ប្រតិទិននេះត្រូវតែមានបញ្ជាក់រយៈពេលនិងកាលបរិច្ឆេទសំរាប់ដំណាក់ការនីមួយៗ ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត ព្រមទាំងពេលម៉ោងនិងថ្ងៃធ្វើការផង ។

២.១៨.៤ ចាប់ផ្តើមបើកការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមអង្គបោះឆ្នោតនីមួយៗ នៅថ្ងៃតែមួយឯកភាពគ្នាក្នុងទូទាំងប្រទេស តាមកាលបរិច្ឆេទកំណត់ដោយ គជប ។

**ប្រការ២.១៩** អគ្គលេខាធិការនៃរដ្ឋសភា ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីសាមីអង្គបោះឆ្នោត ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ដើម្បីស្រង់និងចុះឈ្មោះបោះឆ្នោតជូនតំណាងរាស្ត្រក្នុងតំណែងទាំងអស់ និងបំពេញទម្រង់បញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង តាមគំរូផ្តល់ជូនដោយ គជប និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់តំណាងរាស្ត្រក្នុងតំណែងទាំងនោះ ។ អគ្គលេខាធិការនៃរដ្ឋសភា ឬ តំណាងត្រូវ ៖

២.១៩.១ ស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៦ ខាងលើ ក្នុងករណីមានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់ នៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្ត ក្រុងនីមួយៗ ដោយឡែកពីគ្នា ។

២.១៩.១.១ ការចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្ត ក្រុងនីមួយៗ អាចបំពេញដោយដៃ ឬអាចរៀបចំក្នុងកុំព្យូទ័រតាមគំរូទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គជប ។

២.១៩.១.២ នាមត្រកូល និងនាមខ្លួនរបស់តំណាងរាស្ត្រក្នុងតំណែង នៅលើឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោតត្រូវតែដូចគ្នាជាមួយនឹងនាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួនដែលចុះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្តក្រុង នីមួយៗ ។

២.១៩.២ ជំរាបជូនតំណាងរាស្ត្រក្នុងតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពី ៖

២.១៩.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជនខេត្ត ក្រុងពាក់ព័ន្ធដែល គជប បានកំណត់និងផ្តល់ជូនស្រាប់ ។

២.១៩.២.២ តម្រូវការជាចាំបាច់ នូវឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់សាមីខ្លួន ដើម្បីបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

២.១៩.២.៣ ការត្រៀមស្នើសុំទុកជាមុន នូវលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែងឬលិខិតបញ្ជាក់អត្តសញ្ញាណ ប្រសិនបើ គាត់គ្មានឯកសារបញ្ជាក់អំពីអត្តសញ្ញាណផ្លូវការណាមួយ ។ លិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែងមានបិទរូបថតសាមីខ្លួន ត្រូវចេញដោយប្រធាននៃស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។ ដោយឡែក លិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ត្រូវចេញដោយមេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ដែលតំណាងរាស្ត្រទាំងនោះរស់នៅ ។

២.១៩.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជំរាបជូនតំណាងរាស្ត្រក្នុងតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពីខ្លឹមសារនិងព័ត៌មានទាំងឡាយ ដូចចែងក្រោមចំណុច ២.១៩.២ ខាងលើ ។

២.១៩.៤ ចុះហត្ថលេខានិងកាលបរិច្ឆេទលើបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្ត ក្រុងនីមួយៗ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត រួចរៀបចំបញ្ជីឈ្មោះទាំងនេះដាក់ស្នើសុំបញ្ជាក់ការឯកភាពពីប្រធាននៃរដ្ឋសភា ។ ក្រោយទទួលបានការបញ្ជាក់ឯកភាពពីប្រធានរដ្ឋសភារួចហើយ ត្រូវថតចម្លងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្ត ក្រុងនីមួយៗ បន្ថែមចំនួនពីរ ( ២ )ច្បាប់ទៀត រួចបោះត្រា និងចុះកាលបរិច្ឆេទ ហើយចាត់ចែងប្រើប្រាស់ ដូចខាងក្រោម ៖

២.១៩.៤.១ ផ្ញើច្បាប់ដើមមួយ( ១ )ច្បាប់ និងច្បាប់ចម្លងមួយ( ១ )ច្បាប់ជូន គជប ។

២.១៩.៤.២ រក្សាទុកមួយ( ១ )ច្បាប់ ជាឯកសារ នៅអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ។

២.១៩.៥ ផ្ញើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតរដ្ឋសភា ចំនួនពីរ( ២ )ច្បាប់ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ហើយចាត់ចែងប្រើប្រាស់ ដូចខាងក្រោម ៖

២.១៩.៥.១ ផ្ញើមួយ( ១ )ច្បាប់ជូន គជប ។

២.១៩.៥.២ រក្សាទុកមួយ( ១ )ច្បាប់ ជាឯកសារ នៅអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ។

២.១៩.៦ បញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង តាមមណ្ឌលខេត្ត ក្រុងនីមួយៗ និងរបាយការណ៍សរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត នៃអង្គបោះឆ្នោតរដ្ឋសភា ដូចចែងក្នុងចំណុច ២.១៩.៤.១ និង ២.១៩.៥.១ ខាងលើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ឱ្យបានតាមការកំណត់ ដូចចែងក្រោមចំណុច ២.១៥.១ ខាងលើ ឬ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

២.១៩.៦.១ អគ្គលេខាធិការនៃរដ្ឋសភាត្រូវត្រៀមជាស្រេចនូវដីកាអមចំនួនពីរ( ២ ) ច្បាប់ សំរាប់ប្រើប្រាស់ក្នុងការប្រគល់ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ ដូចចែងក្នុងចំណុច ២.១៩.៦ ខាងលើ ដើម្បីបញ្ជាក់ថា គជប បានទទួលរួចហើយ ។

**ប្រការ២.២០** ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីសាមីអង្គបោះឆ្នោត ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដើម្បីទទួលចុះឈ្មោះបោះឆ្នោតជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងទាំងអស់ ដែលត្រូវបំពេញក្នុងទម្រង់បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង តាមគំរូផ្តល់ជូនដោយ គជប និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងទាំងនោះ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ត្រូវ ៖

២.២០.១ ស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៦ ខាងលើ ក្នុងករណីមានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់ នៅក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ។

២.២០.១.១ ការចុះឈ្មោះ ក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង អាចបំពេញដោយដៃ តាមទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គជប ឬអាចរៀបចំក្នុងកុំព្យូទ័រ ( ប្រសិនបើមាន ) ។

២.២០.១.២ នាមត្រកូល និងនាមខ្លួនរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង នៅលើឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោត ត្រូវតែដូចគ្នាជាមួយនឹងនាមត្រកូលនិងនាមខ្លួនរបស់សាមីខ្លួន ដែលចុះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ។

២.២០.២ ជំរាបជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពី ៖

២.២០.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជនខេត្ត ក្រុងពាក់ព័ន្ធដែល គជប បានកំណត់និងផ្តល់ជូនស្រាប់ ។

២.២០.២.២ តម្រូវការជាចាំបាច់ នូវឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់សាមីខ្លួន ដើម្បីបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

២.២០.២.៣ ការត្រៀមស្នើសុំទុកជាមុន នូវលិខិតសំគាល់ខ្លួន ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ឬ លិខិតបញ្ជាក់អត្តសញ្ញាណ ប្រសិនបើ គាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ។ លិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង មានបិទរូបថតសាមីខ្លួនត្រូវចេញដោយប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។ ចំពោះ លិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ត្រូវចេញដោយមេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះរស់នៅ ។

២.២០.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជំរាបជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពីខ្លឹមសារនិងព័ត៌មានទាំងឡាយ ដូចចែងក្រោមចំណុច ២.២០.២ ខាងលើ ។

២.២០.៤ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត ឬនៅពេលបានចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងទាំងអស់រួចរាល់ហើយ ត្រូវបំពេញបញ្ជីឈ្មោះសមាជិក

ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ចំនួនប្រាំ( ៥ )ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។ បន្ទាប់មក ត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ជូន គជប ដោយដាក់ស្នើសុំការបញ្ជាក់ឯកភាព តាមលំដាប់ឋានានុក្រម ពីអភិបាលស្រុក ខណ្ឌ និងអភិបាលខេត្ត ក្រុង ដែលក្នុងនោះត្រូវ ៖

២.២០.៤.១ រក្សាទុកមួយ( ១ )ច្បាប់ជាឯកសារនៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២០.៤.២ ផ្ញើបួន( ៤ )ច្បាប់ ដើម្បីស្នើសុំការបញ្ជាក់ឯកភាព តាមលំដាប់ឋានានុក្រម ពីអភិបាលស្រុក ខណ្ឌ និងអភិបាលខេត្ត ក្រុង ។

២.២០.៥ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ តាមគំរូទម្រង់ដែល គជប ផ្ដល់ជូន ចំនួនបី( ៣ )ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទនិងបោះត្រា ហើយចាត់ចែងប្រើប្រាស់ ដូចខាងក្រោម ៖

២.២០.៥.១ រក្សាទុកមួយ( ១ )ច្បាប់ជាឯកសារនៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.២០.៥.២ ផ្ញើមួយ( ១ )ច្បាប់ជូនលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត និងមួយ( ១ )ច្បាប់ជូន គជប តាមរយៈអភិបាលស្រុក ខណ្ឌនិងអភិបាលខេត្ត ក្រុង ។

២.២០.៦ បញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ២.២០.៤.២ និង ២.២០.៥.២ ខាងលើជូនអភិបាលស្រុក ខណ្ឌ ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ។

**ប្រការ ២.២១** អភិបាលស្រុក ខណ្ឌនិងអភិបាលខេត្ត ក្រុង មានភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែងនៃឃុំ សង្កាត់ទាំងអស់ចំណុះស្រុក ខណ្ឌ នៃខេត្ត ក្រុងពាក់ព័ន្ធ ក្នុងករណីបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗមានលក្ខណៈត្រឹមត្រូវពិតប្រាកដ ។ លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវសំរបសំរួលនិងសហការឱ្យបានជិតស្និទ្ធជាមួយសាលាស្រុក ខណ្ឌ ក្នុងការចុះទៅទទួលយកដោយផ្ទាល់នៅសាលាស្រុក ខណ្ឌ ឬក្នុងការចាត់ចែងបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះខេត្ត ក្រុង ជូនអភិបាលខេត្ត ក្រុង ដើម្បីពិនិត្យ

ផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់ទាំងអស់ចំណុះខេត្ត ក្រុងពាក់ព័ន្ធ សំរាប់បញ្ជូនទៅ គជប ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។

២.២១.១ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ពីឃុំ សង្កាត់នានា ចំណុះស្រុក ខ័ណ្ឌ អភិបាលស្រុក ខ័ណ្ឌត្រូវពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗនិងត្រូវចាត់ចែងជាបន្ទាន់ ៖

២.២១.១.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងពីឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ ។

២.២១.១.២ សុំឱ្យប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីអង្គបោះឆ្នោតពាក់ព័ន្ធ បកស្រាយបំភ្លឺ ឬ/និង កែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នោះ ។

២.២១.១.៣ រៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួនបី( ៣ )ច្បាប់ និងរបាយការណ៍ទាំងពីរ( ២ )ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ត្រៀមបញ្ជូនទៅសាលាខេត្ត ក្រុង ។ ត្រូវធ្វើដីកាអមបញ្ជូនបញ្ជីឈ្មោះនិងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះស្រុក ខ័ណ្ឌជូនអភិបាលខេត្ត ក្រុងផង ។

២.២១.១.៤ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួនមួយ( ១ )ច្បាប់ ជាឯកសារនៅសាលាស្រុក ខ័ណ្ឌ ។

២.២១.២ លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវទាក់ទងព័ត៌មានជាប្រចាំ ជាមួយសាលាស្រុក ខ័ណ្ឌ ដើម្បីឱ្យដឹងប្រាកដថា អភិបាលស្រុក ខ័ណ្ឌបានត្រៀមរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ចំណុះស្រុក ខ័ណ្ឌសំរាប់ការបញ្ជូនទៅសាលាខេត្ត ក្រុងរួចរាល់ហើយ ឬនៅ ។ លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចាត់ចែងមន្ត្រី ឱ្យចុះទៅទទួលយកបញ្ជីឈ្មោះ និងរបាយ

ការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះស្រុក ខ័ណ្ឌពាក់ព័ន្ធដោយផ្ទាល់ ដើម្បីដាក់ជូនអភិបាលខេត្ត ក្រុង ឬស្នើសុំឱ្យសាលាស្រុក ខ័ណ្ឌបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍ទាំងនោះមកសាលាខេត្ត ក្រុង ប្រសិនបើស្រុក ខ័ណ្ឌមានភារកិច្ចត្រូវឡើងមកទាក់ទងការងារស្របពេលគ្នានៅសាលាខេត្ត ក្រុង ។

២.២១.៣ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានាចំណុះខេត្ត ក្រុង អភិបាលខេត្ត ក្រុងត្រូវពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ដែលអភិបាលស្រុក ខ័ណ្ឌបានបញ្ជាក់ឯកភាពរួចហើយ និងត្រូវចាត់ចែងជាបន្ទាន់ ៖

២.២១.៣.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ ។

២.២១.៣.២ សុំឱ្យប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិពីអង្គបោះឆ្នោតពាក់ព័ន្ធ និងអភិបាលស្រុក ខ័ណ្ឌបកស្រាយបំភ្លឺ ឬ/និង កែតម្រូវក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នោះ ។

២.២១.៣.៣ រៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួនពីរ( ២ )ច្បាប់ និងរបាយការណ៍ទាំងពីរ( ២ )ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ត្រៀមបញ្ជូនទៅ គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

២.២១.៣.៤ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួនមួយ( ១ )ច្បាប់ ជាឯកសារនៅសាលាខេត្ត ក្រុង ។

២.២១.៤ ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវទាក់ទងព័ត៌មានជាប្រចាំជាមួយសាលាខេត្ត ក្រុង ដើម្បីទៅទទួលយកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលមានការបញ្ជាក់ឯកភាពពីអភិបាលខេត្ត ក្រុង និងរបាយការណ៍សរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់នានា ចំណុះខេត្ត

ក្រុង ។ ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវត្រៀមបែងចែក វេចខ្ចប់ និងប្រើប្រាស់បញ្ជីឈ្មោះ និងរបាយការណ៍ទាំងនេះ ដូចខាងក្រោម ៖

២.២១.៤.១ បញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗមួយ( ១ )ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់មួយ( ១ )ច្បាប់ ជូន គជប ។

២.២១.៤.២ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗមួយ( ១ )ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់មួយ( ១ )ច្បាប់ ជាឯកសារ នៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

២.២១.៥ ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងខេត្ត ក្រុងចំនួនពីរ( ២ ) ច្បាប់ ដែលក្នុងនោះ ត្រូវរក្សាទុកមួយ( ១ )ច្បាប់ជាឯកសារ និងបញ្ជូនមួយ( ១ )ច្បាប់ជូន គជប ។

២.២១.៦ ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមអង្គបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ដូចចែងក្នុងចំណុច ២.២១.៤.១ ខាងលើ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងខេត្ត ក្រុងមួយ( ១ )ច្បាប់ ជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ឱ្យបានតាមការកំណត់ ដូចចែងក្រោមចំណុច ២.១៥.១ ខាងលើ ឬ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

២.២១.៧ ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវត្រៀមជាស្រេច នូវលិខិតបញ្ជាក់ការប្រគល់ទទួលសំភារៈឯកសារបោះឆ្នោតចំនួនពីរ( ២ )ច្បាប់ សំរាប់ប្រើប្រាស់ក្នុងការប្រគល់ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ ដូចចែងក្នុងចំណុច ២.២១.៦ ខាងលើ ដើម្បីបញ្ជាក់ថា គជប បានទទួលរួចហើយ ។

**ការប្រគល់ទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយកុំព្យូទ័រនៅ គជប**

**ប្រការ២.២២** នៅពេលទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោត ពីអគ្គលេខាធិការដ្ឋានរដ្ឋសភា និងលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដូចចែងក្នុងចំណុច ២.១៩.៦ និង ២.២១.៦ ខាងលើ

មន្ត្រីទទួលឯកសារនៃនាយកដ្ឋានប្រតិបត្តិការ ត្រូវចាត់ចែងពិនិត្យសំណុំឯកសារ ដែលបានប្រគល់ រួចចុះហត្ថលេខាបញ្ជាក់ការទទួល ប្រសិនបើ ពិនិត្យឃើញថាគ្រប់គ្រាន់ហើយ ។ ប្រធាននាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវចាត់ចែងមន្ត្រីឱ្យផ្ទៀងផ្ទាត់របាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត តាមអង្គបោះឆ្នោតនីមួយៗ ជាមួយនឹងបញ្ជីឈ្មោះតាមអង្គបោះឆ្នោតពាក់ព័ន្ធ ។ ក្នុងករណី ត្រឹមត្រូវហើយ ត្រូវចាត់ចែងឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងកុំព្យូទ័រ ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។ ក្នុងដំណើរការនៃការរៀបចំបញ្ជីបោះឆ្នោតដំបូង ប្រធាននាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវ ៖

២.២២.១ ធានាថា នៅរាល់ពេលប្រគល់ទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោតនិងរបាយការណ៍សរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួលឯកសារបានចុះហត្ថលេខាលើដីកាអម ឬលិខិតប្រគល់ទទួលសំភារៈឯកសារបោះឆ្នោតទាំងពីរ( ២ )ច្បាប់ រួចប្រគល់ឱ្យមន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ឬលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដែលទទួលបន្ទុកបញ្ជូនសំណុំឯកសារវិញចំនួនមួយ( ១ )ច្បាប់ ដើម្បីបញ្ជាក់ថា បានទទួលគ្រប់ចំនួនមែន និងត្រូវរក្សាទុកមួយ( ១ )ច្បាប់ ជាឯកសារ ។ ក្នុងករណីសំណុំឯកសារ ដែលបានប្រគល់មានលក្ខណៈមិនទាន់គ្រប់គ្រាន់ មន្ត្រីទទួលឯកសារអាចស្នើសុំ ឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូន យកមកបន្ថែមនូវឯកសារដែលខ្វះ ។

២.២២.២ ធានាថា សំណុំឯកសារនៃការចុះឈ្មោះបោះឆ្នោតដែលបានទទួល ត្រូវបានបំបែករួចផ្គុំបញ្ចូលគ្នាទៅតាមខេត្ត ក្រុង ដោយឡែកពីគ្នា នូវបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលខេត្ត ក្រុងនិងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមខេត្ត ក្រុង ព្រមទាំងបានបែងចែកទៅតាមការិយាល័យបោះឆ្នោតនីមួយៗ ចំណុះខេត្ត ក្រុងពាក់ព័ន្ធ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ។

២.២២.៣ ធានាថា តួលេខនិងទិន្នន័យនៃបញ្ជីឈ្មោះតាមអង្គបោះឆ្នោតនីមួយៗ ត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់បន្ថែម ឱ្យបានម៉ត់ចត់និងត្រឹមត្រូវ ដើម្បីត្រៀមសំរាប់ការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់បន្ថែមនេះ ត្រូវផ្អែកជាមូលដ្ឋានលើបញ្ជីបេក្ខជនតំណាងរាស្ត្រ ឬ/និងបញ្ជីបេក្ខជនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្លូវការដែលមានរក្សាទុកជាឯកសារនៅ គជប ។ ក្នុងករណី មានភាពមិនប្រក្រតី ឬភាពមិនត្រឹមត្រូវពាក់ព័ន្ធនឹងចំនួន និងទិន្នន័យក្នុងបញ្ជីឈ្មោះ ត្រូវរាយការណ៍ជាបន្ទាន់ តាមឋានានុក្រមទៅ គជប ដើម្បីសុំយោបល់ណែនាំ ។

២.២២.៤ ចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមបញ្ជីឈ្មោះ និងរបាយការណ៍ដែលបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវរួច ។ ក្នុងនោះ ត្រូវធានាថា ៖

២.២២.៤.១ មន្ត្រីបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រមានការទទួលខុសត្រូវខ្ពស់ ក្នុងការវាយបញ្ចូលឈ្មោះអ្នកបោះឆ្នោតនិងទិន្នន័យពាក់ព័ន្ធ បានយ៉ាងត្រឹមត្រូវ និងឆាប់រហ័ស ។

២.២២.៤.២ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗ ក្នុងកុំព្យូទ័រ ត្រូវតែស្មើគ្នានឹងចំនួនដែលមានក្នុងបញ្ជីឈ្មោះតាមអង្គបោះឆ្នោត ដែលបានកំណត់សំរាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.២២.៤.៣ បញ្ជីបោះឆ្នោតដំបូងតាមការិយាល័យបោះឆ្នោតនីមួយៗ ក្នុងកុំព្យូទ័រត្រូវតែបានរៀបចំក្នុងទម្រង់ឯកភាពគ្នាតែមួយ ដែលរួមមាន ៖ លេខរៀងមណ្ឌលភូមិភាគ ឈ្មោះខេត្ត ក្រុង លេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត កូនប្រអប់សម្រាប់គូសសំគាល់លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត នាមត្រកូលនិងនាមខ្លួនដែលរៀបចំតាមអក្ខរក្រមខ្មែរ ភេទ ថ្ងៃខែឆ្នាំកំណើត ឋានៈក្នុងតំណែងតាមអង្គបោះឆ្នោត អាសយដ្ឋាននៃអ្នកបោះឆ្នោត និងខ្ទង់ទំនេរសម្រាប់ចារសម្គាល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលបានប្រើនៅពេលបោះឆ្នោត ។

២.២២.៤.៤ នៅគ្រប់ទំព័រ នៃបញ្ជីបោះឆ្នោតដំបូង តាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតដំបូងសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ហើយនៅទំព័រចុងក្រោយ នៃបញ្ជីបោះឆ្នោតដំបូងនេះ ត្រូវរៀបចំឱ្យមានប្រឡោះ សម្រាប់ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប ។ នៅគ្រប់ទំព័រផ្សេងទៀត នៃបញ្ជីបោះឆ្នោតដំបូង របស់ការិយាល័យបោះឆ្នោតនីមួយៗ ក៏ត្រូវមានបោះត្រា គជប ផងដែរ ។

២.២២.៤.៥ ឈ្មោះអ្នកបោះឆ្នោតនិងរាល់ទិន្នន័យពាក់ព័ន្ធ នៅលើបញ្ជីបោះឆ្នោតដំបូង ត្រូវតែបានត្រួតពិនិត្យនិងកែតម្រូវយ៉ាងម៉ត់ចត់ និងត្រឹមត្រូវមុនពេលបោះពុម្ព និងដាក់ជូន គជប ផ្តល់សុពលភាពក្នុងជំហានដំបូងជាបញ្ជីបោះឆ្នោតដំបូងសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

**ប្រការ២.២៣** នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវបោះពុម្ពបញ្ជីបោះឆ្នោតដែលបានរៀបចំរួចស្រេចចំនួនពីរ ( ២ )ច្បាប់ និងដាក់ជូន គជប ផ្តល់សុពលភាពក្នុងជំហានដំបូង ជាបញ្ជីបោះឆ្នោតដំបូង សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ត្រូវធានាថា បញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានថតចម្លងបន្ថែមក្នុងចំនួនគ្រប់គ្រាន់ សំរាប់វេចខ្ចប់និងបញ្ជូនទៅ គខ/កប ប្រើប្រាស់ក្នុងការបិទផ្សាយ ដើម្បីបំរើគោលដៅនៃការពិនិត្យកែតម្រូវតាមរយៈការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនោះ ។

២.២៣.១ នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវរក្សាទុកច្បាប់ដើមនៃបញ្ជីបោះឆ្នោតដំបូងដែល គជប បានផ្តល់សុពលភាពក្នុងជំហានដំបូង មួយ( ១ )ច្បាប់ ជាឯកសារនៅ គជប និងត្រូវវេចខ្ចប់តាមការិយាល័យបោះឆ្នោតនីមួយៗដោយឡែកពីគ្នា នូវបញ្ជីបោះឆ្នោតដំបូងច្បាប់ដើមមួយ( ១ )ច្បាប់ និងច្បាប់ចម្លងបួន( ៤ )ច្បាប់ រួចបញ្ជូនទៅ គខ/កប ឱ្យបានទាន់ពេលវេលា មុនការកំណត់ឱ្យបិទផ្សាយ ។

២.២៣.២ ពេលទទួលបានកញ្ចប់បញ្ជីបោះឆ្នោតដំបូង គខ/កប ត្រូវដករក្សាទុកបញ្ជីបោះឆ្នោតដំបូងច្បាប់ដើមមួយ( ១ )ច្បាប់ ជាឯកសារ និងត្រូវចាត់ចែងបិទផ្សាយបញ្ជីបោះឆ្នោតដំបូងច្បាប់ចម្លង យ៉ាងតិចសែសិបប្រាំបី( ៤៨ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយត្រូវបិទផ្សាយ ដូចខាងក្រោម ៖

២.២៣.២.១ នៅលេខាធិការដ្ឋាននៃ គខ/កប មួយ( ១ )ច្បាប់ ។

២.២៣.២.២ នៅកន្លែងបីផ្សេងគ្នាក្នុងទីប្រជុំជនខេត្ត ក្រុង ក្នុងកន្លែងនីមួយៗ មួយ( ១ )ច្បាប់ ។

២.២៣.៣ នៅពេលដែលត្រូវបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ គខ/កប ត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ដោយមានបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងនៃការបិទផ្សាយ ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាផង ។ គខ/កប ត្រូវបិទផ្សាយកំណត់ហេតុនេះមួយ(១)ច្បាប់ អមជាមួយនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅតាមទីតាំងដូចដែលបានបញ្ជាក់ក្រោមចំណុច ២.២៣.២ ខាងលើ រួចផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ ) ច្បាប់ ។

២.២៣.៤ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺដើម្បីបំរើគោលដៅនៃការពិនិត្យកែតម្រូវតាមរយៈការប្តឹងតវ៉ា ឬ/និង ការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនេះ ។ បញ្ជី

បោះឆ្នោតដំបូងត្រូវបានបិទផ្សាយជាសាធារណៈក្នុងរយៈពេលប្រាំ(៥)ថ្ងៃ ដែលក្នុងរយៈពេលកំណត់នេះ ជនណាក៏ដោយ ក៏មានសិទ្ធិប្ដឹងតវ៉ាឬ/និងប្ដឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនេះបានដែរ ។ ការដាក់ពាក្យបណ្ដឹងត្រូវធ្វើនៅលេខាធិការដ្ឋាននៃ គខ/កប ។

២.២៣.៥ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងគណបក្សនយោបាយនានា ដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិស្នើសុំពី គជប នូវបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតមួយ ឬច្រើនចំនួនមួយ( ១ )ច្បាប់ ដោយបង់ថ្លៃត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។ ការផ្ដត់ផ្ដង់ចំពោះការស្នើសុំខាងលើនេះត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំ តម្រូវឱ្យបង់ប្រាក់ជាមុនស្មើនឹងមួយរយ( ១០០ )ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

២.២៣.៦ គខ/កប អាចទទួលថតចម្លងបញ្ជីបោះឆ្នោតដំបូងដោយផ្ទាល់ តាមលទ្ធភាពជាក់ស្ដែងរបស់ខ្លួន ដើម្បីផ្ដត់ផ្ដង់តាមសំណើសុំ ដូចចែងក្នុងចំណុច ២.២៣.៥ ខាងលើ ប្រសិនបើមាន ហើយមិនត្រូវអនុញ្ញាតឱ្យអ្នកស្នើសុំ ខ្ចីបញ្ជីបោះឆ្នោតដំបូងច្បាប់ដើមយកទៅថតចម្លងដោយខ្លួនឯងឡើយ ។

**ការដាក់ពាក្យបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់នៅ គខ/កប និងការបើកសវនាការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ២.២៤** គោលបំណងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ គឺដើម្បីធ្វើសុក្រឹតភាពបញ្ជីបោះឆ្នោត ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងនេះ ទៅ គខ/កប ក្នុងរយៈពេលប្រាំ( ៥ )ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។

២.២៤.១ ប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងប្ដឹងតវ៉ាឬ/និងប្ដឹងជំទាស់ អាចទៅទទួលយកនៅលេខាធិការដ្ឋាននៃ គខ/កប នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការនូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ។ អ្នកប្ដឹងឬតំណាង ត្រូវបំពេញពាក្យបណ្ដឹងតវ៉ាចំនួនបួន( ៤ )ច្បាប់ ឬ/និងបណ្ដឹងជំទាស់ចំនួនប្រាំ( ៥ )ច្បាប់ រួចដាក់ពាក្យបណ្ដឹងនោះនៅលេខាធិការដ្ឋាននៃ គខ/កប ។

២.២៤.២ គខ/កប ត្រូវចាត់សមាជិកឬមន្ត្រីរបស់ខ្លួន ឱ្យទទួលពាក្យបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់ ក្នុងរយៈពេលកំណត់ ដូចចែងក្នុងប្រការ ២.២៤ ខាងលើ ។

២.២៤.៣ នៅក្នុងរយៈពេលប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រសិនបើពុំមានបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ណាមួយ ត្រូវបានដាក់នៅ គខ/កប ទេ គខ/កប ត្រូវធ្វើរបាយការណ៍ស្តីពីករណីគ្មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នេះ រួចត្រូវធ្វើរបាយការណ៍នេះជាបន្ទាន់ទៅ គជប ( នាយកដ្ឋានប្រតិបត្តិការ ) ។

២.២៤.៤ អ្នកប្តឹងតវ៉ាឬតំណាងត្រូវបំពេញពាក្យបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនបួន(៤)ច្បាប់ ដោយបញ្ជាក់ច្បាស់អំពីកម្មវត្ថុ និងភស្តុតាងនៃការតវ៉ាក្នុងករណីណាមួយ ដូចខាងក្រោម ៖

២.២៤.៤.១ សាមីអ្នកប្តឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងពិតប្រាកដ ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតណាមួយនៅខេត្ត ក្រុងពាក់ព័ន្ធ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនៅខេត្ត ក្រុងផ្សេង ។

២.២៤.៤.២ សាមីអ្នកប្តឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់និងទិន្នន័យពាក់ព័ន្ធដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូង មានភាពមិនច្បាស់លាស់ ឬមិនស៊ីគ្នានឹងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ហើយដែលគាត់ទាមទារសុំឱ្យកែតម្រូវឡើងវិញ ។

២.២៤.៥ អ្នកប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនប្រាំ(៥)ច្បាប់ ដោយបញ្ជាក់ច្បាស់អំពីកម្មវត្ថុនៃការជំទាស់ក្នុងករណីណាមួយ ដូចខាងក្រោម ៖

២.២៤.៥.១ ជំទាស់ទៅនឹងជនណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងខេត្ត ក្រុង ប៉ុន្តែជននោះគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោត ដោយមិនបំពេញបានតាមលក្ខខណ្ឌ មាត្រា ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងលក្ខខណ្ឌដូចចែងក្រោមប្រការ ២.៦ ខាងលើ ។

២.២៤.៥.២ ជំទាស់ទៅនឹងជនណាម្នាក់ ដែលទោះបីមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ឬ គ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ប៉ុន្តែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពីរ ឬច្រើន ។

២.២៨.៦ បណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ដែលពុំបានបំពេញតាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.២៨.៤ និង ២.២៨.៥ ខាងលើ គខ/កប ត្រូវបដិសេធពាក្យបណ្តឹងនោះ ឬទាំងនោះ ដោយមិនទទួលបើកសវនាការឡើយ ។

២.២៨.៧ គខ/កប ត្រូវធានាថា រាល់បណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ទាក់ទិននឹងបញ្ជីបោះឆ្នោតដំបូង ដូចចែងក្នុងចំណុច ៤.២៨.៤ និង ៤.២៨.៥ ខាងលើ ដែលបានដាក់ប្តឹងក្នុងរយៈពេលប្រាំ( ៥ )ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបាន គខ/កប បើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរបី(៣)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២.២៨.៨ គខ/កប ត្រូវធានាថា កាលបរិច្ឆេទនៃការបើកសវនាការជាសាធារណៈ ត្រូវតែបានជូនដំណឹងចំពោះភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង យ៉ាងតិចម្ភៃបួន( ២៤ )ម៉ោងមុនពេលបើកសវនាការ ។ ផ្អែកតាមការណែនាំរបស់ គខ/កប សមាជិកឬមន្ត្រីនៃ គខ/កប ដែលត្រូវបានប្រគល់សិទ្ធិឱ្យទទួលពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទិននឹងបញ្ជីបោះឆ្នោតដំបូង ត្រូវបំពេញកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការបើកសវនាការជាសាធារណៈរបស់ គខ/កប លើពាក្យបណ្តឹងតវ៉ាបួន( ៤ ) ច្បាប់ ឬពាក្យបណ្តឹងជំទាស់ប្រាំ( ៥ )ច្បាប់ ហើយត្រូវចាត់ចែងពាក្យបណ្តឹងទាំងនោះ ដូចខាងក្រោម ៖

២.២៨.៨.១ ប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ ឬតំណាងវិញ នៅកន្លែងដាក់ពាក្យបណ្តឹង មួយ( ១ )ច្បាប់ ។

២.២៨.៨.២ បញ្ជូនឱ្យអ្នកដែលត្រូវគេប្តឹងជំទាស់ មួយ( ១ )ច្បាប់ ( ករណីប្តឹងជំទាស់ ) ។

២.២៨.៨.៣ បិទផ្សាយនៅលេខាធិការដ្ឋាននៃ គខ/កប មួយ( ១ )ច្បាប់ជាសេចក្តីជូនដំណឹងពីការបើកសវនាការរបស់ គខ/កប លើបណ្តឹងពាក់ព័ន្ធ ។

២.២៨.៨.៤ ត្រៀមទុកចំនួនពីរ( ២ )ច្បាប់ សម្រាប់ គខ/កប ប្រើក្នុងការបើកសវនាការដោះស្រាយបណ្តឹងពាក់ព័ន្ធ ។

២.២៨.៩ ចំពោះករណី បណ្តឹងជំទាស់ ដែលមានការពាក់ព័ន្ធនឹងអ្នកដែលត្រូវគេប្តឹងជំទាស់ គខ/កប ត្រូវណែនាំសមាជិកឬមន្ត្រីនៃ គខ/កប ដែលបានប្រគល់សិទ្ធិ ឱ្យបំពេញ

កាលបរិច្ឆេទនៃការបើកសវនាការជាសាធារណៈ ក្នុងលក្ខណៈសមស្រប ដែលអាចមានពេលវេលាគ្រប់គ្រាន់ ក្នុងការជូនដំណឹងដល់អ្នកដែលត្រូវគេប្តឹងជំទាស់នោះ ដោយអនុលោមតាមរយៈពេលដែលច្បាប់បានកំណត់ ។

២.២៨.១០ សវនាការជាសាធារណៈរបស់ គខ/កប ដោះស្រាយលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ត្រូវបើកធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជំរះដែលដឹកនាំដោយប្រធាន គខ/កប ឬអនុប្រធាន ឬសមាជិក គខ/កប ដែលបានប្រគល់សិទ្ធិ ។

២.២៨.១១ លក្ខណៈវិនិច្ឆ័យដែល គខ/កប ត្រូវប្រកាន់យកជាមូលដ្ឋាន ដើម្បីសម្រេចលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ គឺផ្អែកលើលក្ខខណ្ឌសំរាប់ការចុះឈ្មោះបោះឆ្នោតជូនតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដូចមានចែងក្រោមប្រការ ២.៦ ខាងលើ ។

២.២៨.១២ គខ/កប ពុំមានសិទ្ធិអំណាចណាមួយ ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យណាផ្សេង ក្រៅអំពីលក្ខណៈវិនិច្ឆ័យ ដែលបានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជានិងនីតិវិធីរបស់ គជប ឡើយ ។

២.២៨.១៣ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬអគ្គលេខាធិការនៃរដ្ឋសភា ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ អាចមានវត្តមាននៅក្នុងការបើកសវនាការជាសាធារណៈរបស់ គខ/កប ដើម្បីផ្តល់ព័ត៌មានទាំងឡាយ ដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ដោយចំហាជូន គខ/កប ។

២.២៨.១៤ នៅក្នុងការបើកសវនាការជាសាធារណៈរបស់ គខ/កប អ្នកប្តឹងតវ៉ាឬអ្នកប្តឹងជំទាស់ ឬតំណាងត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់អំពីការតវ៉ា ឬការចោទប្រកាន់ស្របច្បាប់របស់ខ្លួន ។ ភស្តុតាងអាចជាកសិណសាក្សី ការដឹងឮ ឬឯកសារ ។ ប្រសិនបើ មានការស្នើសុំដោយ គខ/កប អ្នកប្តឹងតវ៉ា ឬ អ្នកប្តឹងជំទាស់ ឬតំណាងត្រូវផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងការតវ៉ា ឬការចោទប្រកាន់នោះ ។ ប្រសិនបើ អ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ ឬតំណាងពុំបានបង្ហាញភស្តុតាងណាមួយបញ្ជាក់លើការតវ៉ាឬការចោទប្រកាន់របស់ខ្លួន ឬ បានត្រឹមបង្ហាញភស្តុតាងដែល

គខ/កប យល់ថាមានលក្ខណៈមិនគ្រប់គ្រាន់ បណ្តឹងតវ៉ាឬបណ្តឹងជំទាស់នោះត្រូវតែបានបដិសេធ ។

២.២៨.១៥ ជនដែលត្រូវគេប្តឹងជំទាស់ អាចបដិសេធពាក្យចោទប្រកាន់របស់ដើមបណ្តឹងជំទាស់បាន ដោយការបង្ហាញរាល់ឯកសារដែលបញ្ជាក់ថា ខ្លួនពិតជាមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ស្របទៅតាមច្បាប់ និងពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតលើសពីមួយទេ ។

២.២៨.១៦ ក្នុងករណី គខ/កប សម្រេចបដិសេធលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៨.១៦.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៨.១៦.២ ចាត់ចែងបំពេញសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

២.២៨.១៦.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា លើសេចក្តីសម្រេចបដិសេធដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងតវ៉ាឬតំណាងមួយ( ១ )ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៨.១៦.៤ ប្រគល់ជូនអ្នកប្តឹងតវ៉ា ឬតំណាងតាមសំណើសុំនូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចបដិសេធរបស់ គខ/កប ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ាអំពីករណីនេះទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ។

២.២៨.១៧ ក្នុងករណី គខ/កប សម្រេចយល់ព្រមលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៨.១៧.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៩.១៧.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងតវ៉ា ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ។

២.២៩.១៧.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬតំណាងមួយ( ១ ) ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៩.១៨ ក្នុងករណីគខ/កប សម្រេចបដិសេធលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៩.១៨.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៩.១៨.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចបដិសេធ លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបួន( ៤ )ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

២.២៩.១៨.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ឬតំណាងមួយ( ១ ) ច្បាប់ ផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់មួយ( ១ )ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៩.១៨.៤ ប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងតាមសំណើសុំ នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចបដិសេធរបស់ គខ/កប ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងជំទាស់បន្ត អំពីករណីនេះទៅ គជប យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងជំទាស់ ។

២.២៩.១៩ ក្នុងករណី គខ/កប សម្រេចយល់ព្រមលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៩.១៩.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ឬតំណាង មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៤.១៩.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ )ចំនួនបួន( ៤ )ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការយល់ព្រមនោះផង ។

២.២៤.១៩.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីសម្រេចយល់ព្រមដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ឬតំណាង មួយ( ១ )ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹងជំទាស់ មួយ( ១ ) ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារ មួយ( ១ )ច្បាប់ ។

២.២៤.១៩.៤ ប្រគល់ជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬ តំណាងតាមសំណើសុំនូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ( ២ )ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គឃ/កប ដែលបានបដិសេធការចុះឈ្មោះបោះឆ្នោតរបស់គាត់ទៅ គជប និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ាអំពីករណីនេះទៅ គជប យ៉ាងយូរប្រាំ( ៥ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រមលើបណ្តឹងជំទាស់ ។

**ការដាក់ពាក្យបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់នៅ គជប និងការបើកសវនាការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ២.២៥** អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ គឃ/កប លើពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គជប ក្នុងរយៈពេលប្រាំ( ៥ ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង ។

២.២៥.១ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យប្តឹងតវ៉ាឬប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ គឃ/កប ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនពីរ( ២ )ច្បាប់ រួចដាក់ពាក្យបណ្តឹងនេះនៅ គជប ។ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងដែល គឃ/កប បានប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាឬប្តឹងជំទាស់រួចហើយ ដូចចែងក្នុងចំណុច ២.២៤.១៦.៤ ២.២៤.១៨.៤ និង ២.២៤.១៩.៤ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងរបស់ខ្លួននៅ គជប តាមពេលវេលាកំណត់ ដូចចែងក្នុងប្រការ ២.២៥ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ឬមិនប្តឹងជំទាស់ ។

២.២៥.២ ប្រសិនបើ គ្មានពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុងណាមួយ ត្រូវបានគេដាក់នៅ គជប ក្នុងអំឡុងពេល ដូចចែងក្នុងប្រការ ២.២៥ ខាងលើទេ គជប ត្រូវបង្គាប់ទៅនាយកដ្ឋានប្រតិបត្តិការឱ្យចាត់ចែងរៀបចំសេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការជាបន្ទាន់ដើម្បីដាក់ជូន គជប ពិនិត្យសំរេចនិងផ្តល់សុពលភាព ។ ចំពោះខេត្ត ក្រុងណាដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ គជប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចចែងចាប់ពីចំណុច ២.២៥.៣ ដល់ ២.២៥.៩ ខាងក្រោម ។

២.២៥.៣ គជប ត្រូវធានាថា រាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ២.២៥.១ ខាងលើ ដែលបានដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលកំណត់ ដូចចែងក្នុងប្រការ ២.២៥ ខាងលើ ត្រូវបាន គជប បើកសវនាការសម្រេច ក្នុងរយៈពេលយ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ទាំងនោះ ។

២.២៥.៤ សាធារណជនមានសិទ្ធិក្នុងការចូលរួមស្តាប់សវនាការរបស់ គជប ដើម្បីដោះស្រាយរាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

២.២៥.៥ ដើម្បីបង្កលក្ខណសម្បត្តិ សម្រាប់ការបើកសវនាការរបស់ គជប ដោះស្រាយលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ២.២៥.៣ នៅរាល់ពេលទទួលពាក្យបណ្តឹងទាំងនោះ គជប ត្រូវណែនាំនិងធានាថា ៖

២.២៥.៥.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មបានប្រមូលផ្តុំ រាល់សេចក្តីសំរេចរបស់ គឃ/កប បដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងយល់ព្រមឬបដិសេធលើបណ្តឹងជំទាស់ពាក់ព័ន្ធដែលបានផ្ញើជូន គជប ។

២.២៥.៥.២ នៅពេលទទួលពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ដែលត្រូវបានប្រគល់សិទ្ធិ ត្រូវបំពេញលើពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាំងពីរ( ២ )ច្បាប់ នូវពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកប្តឹងជំទាស់ ឬតំណាងមួយ( ១ )ច្បាប់ និងត្រូវជំរាបគាត់ថា កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលនឹងត្រូវបើកសវនាការដោះស្រាយបណ្តឹង

តវ៉ា ឬ/និងបណ្ដឹងជំទាស់នោះ នឹងជូនដំណឹងជាក្រោយតាមការកំណាត់របស់ គជប ក្នុងរយៈពេលយ៉ាងតិចម្ភៃបួន( ២៤ )ម៉ោងមុនពេលបើកសវនាការ ។

២.២៥.៥.៣ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ដែលត្រូវបានប្រគល់សិទ្ធិ ត្រូវថតចម្លងពាក្យបណ្ដឹងដែលបានទទួល និងបំពេញរួចហើយនោះបន្ថែមចំនួនបី( ៣ )ច្បាប់សម្រាប់បណ្ដឹងតវ៉ា និងចំនួនបួន( ៤ )ច្បាប់សម្រាប់បណ្ដឹងជំទាស់ ដែលក្នុងនោះ ត្រូវរក្សាទុកច្បាប់ចម្លងមួយ( ១ )ច្បាប់ជាឯកសារ នៅនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម បិទផ្សាយជាសេចក្ដីជូនដំណឹងមួយ( ១ )ច្បាប់នៅទីស្ដីការ គជប និងត្រៀមពាក្យបណ្ដឹងពីរ( ២ )ច្បាប់ទៀត សម្រាប់ប្រើប្រាស់ក្នុងសវនាការរបស់ គជប ។ ចំពោះករណីបណ្ដឹងជំទាស់ ត្រូវផ្ញើជូនអ្នកដែលត្រូវគេប្ដឹងជំទាស់មួយ( ១ )ច្បាប់ ។

២.២៥.៦ ក្នុងករណី គជប សម្រេចបដិសេធលើបណ្ដឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៥.៦.១ ចារបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្ដឹងតវ៉ានោះរួចប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៦.២ ចាត់ចែង ឱ្យបំពេញសេចក្ដីសម្រេចបដិសេធ លើបណ្ដឹងតវ៉ា( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

២.២៥.៦.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្ដីសម្រេច ដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាងមួយ( ១ )ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៦.៤ ប្រគល់ឱ្យអ្នកប្ដឹងតវ៉ា ឬតំណាង នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ( ២ )ច្បាប់ តាមសំណើសុំសម្រាប់បំពេញពាក្យបណ្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គជប ដែលបដិសេធលើបណ្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្ដឹងតវ៉ាអំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ( ៥ )ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ។

២.២៥.៧ ក្នុងករណី គជប សម្រេចយល់ព្រមលើបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៥.៧.១ ចារយល់ព្រម ចុះហត្ថលេខា និងកាលបរិច្ឆេទលើបណ្តឹងតវ៉ានោះ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ា ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៧.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងតវ៉ា (ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ។

២.២៥.៧.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីសំរេច ដែលបានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹងតវ៉ាឬតំណាងមួយ( ១ )ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយ( ១ )ច្បាប់និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៨ ក្នុងករណី គជប សម្រេចបដិសេធលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៥.៨.១ ចារបដិសេធ និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៨.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចបដិសេធ លើបណ្តឹងជំទាស់ ( ទម្រង់បែបទលេខ ១២០៣ ) ចំនួនបួន( ៤ )ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះផង ។

២.២៥.៨.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា លើសេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយ ( ១ )ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់មួយ( ១ )ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ ( ១ )ច្បាប់ ។

២.២៥.៨.៤ ប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងតាមសំណើសុំនូវទម្រង់បែបបទលេខ១២០២ ចំនួនពីរ( ២ )ច្បាប់សម្រាប់បំពេញពាក្យបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចបដិសេធរបស់ គជប ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងជំទាស់បន្តអំពីករណីនេះ ទៅក្រុមប្រឹក្សាធម្មនុញ្ញ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើបណ្តឹងជំទាស់ ។

២.២៥.៩ ក្នុងករណី គជប សម្រេចយល់ព្រមលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃអង្គសវនាការ ត្រូវ ៖

២.២៥.៩.១ ចារយល់ព្រម និងចុះហត្ថលេខាលើបណ្តឹងជំទាស់នោះ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៩.២ ចាត់ចែង ឱ្យបំពេញសេចក្តីសម្រេចយល់ព្រម លើបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបួន( ៤ )ច្បាប់ ។

២.២៥.៩.៣ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីសម្រេចយល់ព្រមដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងជំទាស់ឬតំណាងមួយ( ១ )ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹងជំទាស់មួយ( ១ )ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាឃុំសង្កាត់មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

២.២៥.៩.៤ ប្រគល់ជូនអ្នកត្រូវគេប្តឹងជំទាស់ ឬ តំណាងតាមសំណើសុំ នូវទម្រង់បែបបទលេខ ១២០២ ចំនួនពីរ( ២ )ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គជប ដែលបដិសេធការចុះឈ្មោះបោះឆ្នោតរបស់គាត់ ទៅក្រុមប្រឹក្សាឃុំសង្កាត់ និងជម្រាបគាត់ថា គាត់មានសិទ្ធិប្តឹងតវ៉ាអំពីករណីនេះ ទៅក្រុមប្រឹក្សាឃុំសង្កាត់ យ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រមលើបណ្តឹងជំទាស់ ។

## ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នៅក្រុមប្រឹក្សាឃុំសង្កាត់ និងការបើកសវនាការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង

**ប្រការ ២.២៦** អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ដែលមានបំណងប្តឹងចំពោះសេចក្តីសម្រេចរបស់ គជប លើពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់របស់ខ្លួនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង មានសិទ្ធិប្តឹងតវ៉ាឬប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងរយៈពេលប្រាំ( ៥ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចយល់ព្រម ឬ បដិសេធលើពាក្យបណ្តឹងពាក់ព័ន្ធ ។

២.២៦.១ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងត្រូវបំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់ គជប ( ទម្រង់បែបបទលេខ ១២០២ ) ចំនួនពីរ( ២ )ច្បាប់ រួចដាក់ពាក្យបណ្តឹងរបស់ខ្លួននៅក្រុមប្រឹក្សាឃុំសង្កាត់ ។ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬ

តំណាងដែល គជប បានប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ា ឬ ប្តឹងជំទាស់ រួចហើយ ដូចចែងក្នុងចំណុច ២.២៥.៦.៤ ២.២៥.៨.៤ និង ២.២៥.៩.៤ ខាងលើ ប៉ុន្តែមិនបានមកដាក់ពាក្យបណ្តឹងរបស់ខ្លួន នៅក្រុមប្រឹក្សាឃុំសង្កាត់តាមការកំណត់ ដូចចែងក្នុងប្រការ ២.២៦ ត្រូវបានចាត់ទុកថា មិនប្តឹងតវ៉ា ឬមិនប្តឹងជំទាស់ ។

២.២៦.២ ប្រសិនបើ គ្មានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុងណាមួយ ត្រូវបានគេដាក់នៅក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងអំឡុងពេល ដូចចែងក្នុងប្រការ ២.២៦ ខាងលើទេ គជប ត្រូវបង្គាប់ទៅនាយកដ្ឋានប្រតិបត្តិការ ឱ្យរៀបចំសេចក្តីព្រាងបញ្ជីបោះឆ្នោត ដើម្បីដាក់ជូន គជប ពិនិត្យសំរេច និងផ្តល់សុពលភាពជាផ្លូវការ ។

២.២៦.៣ អនុលោមតាមមាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាឃុំសង្កាត់នឹងបើកសវនាការជាសាធារណៈសម្រេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងសេចក្តីសំរេចរបស់ គជប ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងអំឡុងពេលយ៉ាងយូរដប់( ១០ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នោះ ឬទាំងនោះ ។

២.២៦.៤ នៅពេលបើកសវនាការជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំសង្កាត់ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងមានសិទ្ធិបង្ហាញភស្តុតាងជាឯកសារផ្សេងៗ ដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃការតវ៉ា ឬការចោទប្រកាន់របស់ខ្លួន ស្របតាមច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់ គជប ។

២.២៦.៥ ក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តការទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ ដោយផ្អែកតាមសិទ្ធិអំណាចនិងនីតិវិធីរបស់ខ្លួន រួចជូនដំណឹងទៅ គជប អំពីសេចក្តីសំរេចរបស់ខ្លួន ។

២.២៦.៦ ក្នុងករណី ក្រុមប្រឹក្សាឃុំសង្កាត់សម្រេចបដិសេធលើបណ្តឹងតវ៉ា ឬបដិសេធលើបណ្តឹងជំទាស់ ក្រុមប្រឹក្សាឃុំសង្កាត់ នឹង ៖

២.២៦.៦.១ ចេញសេចក្ដីសំរេចបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធនោះ និងបញ្ជាក់ថា សេចក្ដីសំរេចនេះជាសេចក្ដីសំរេចចុងក្រោយ ។

២.២៦.៦.២ ប្រគល់ ឬផ្ញើសេចក្ដីសំរេចបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ជូនអ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងមួយ( ០១ )ច្បាប់ ។

២.២៦.៦.៣ ផ្ញើសេចក្ដីសំរេចបដិសេធបណ្ដឹងតវ៉ា ឬ បដិសេធបណ្ដឹងជំទាស់ ជូន គជប មួយ( ០១ )ច្បាប់ ។

២.២៦.៧ ក្នុងករណី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមតាមបណ្ដឹងតវ៉ា ឬយល់ព្រមតាមបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញ នឹង ៖

២.២៦.៧.១ ចេញសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការយល់ព្រមនោះផង ។

២.២៦.៧.២ ប្រគល់ ឬផ្ញើសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ា ឬ យល់ព្រមបណ្ដឹងជំទាស់ជូនអ្នកប្ដឹងតវ៉ា ឬ អ្នកប្ដឹងជំទាស់ ឬ អ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងមួយ( ០១ )ច្បាប់ ។

២.២៦.៧.៣ ផ្ញើសេចក្ដីសម្រេចយល់ព្រមបណ្ដឹងតវ៉ាឬយល់ព្រមបណ្ដឹងជំទាស់ ជូន គជប មួយ( ០១ )ច្បាប់ ។

**ការកែតម្រូវបញ្ជីបោះឆ្នោតដំបូង ការរៀបចំ និងការបោះពុម្ព ដើម្បីដាក់ជូន គជប សំរេចផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ**

**ប្រការ២.២៧** បន្ទាប់ពីការប្ដឹងតវ៉ា ឬ/និង ការប្ដឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបានដោះស្រាយតាមលំដាប់ថ្នាក់រួចរាល់ជាស្ថាពរហើយ គជប ត្រូវណែនាំនាយកដ្ឋានប្រតិបត្តិការ ឱ្យកែតម្រូវបញ្ជីបោះឆ្នោតដំបូង ដោយផ្អែកលើរាល់សេចក្ដីសំរេចរបស់ គខ/កប គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ។ នាយកដ្ឋានប្រតិបត្តិការត្រូវរៀបចំនិងបោះពុម្ពបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ រួចដាក់ជូន គជប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

២.២៧.១ អគ្គលេខាធិការនៃ គជប ត្រូវធានាថា រាល់សេចក្ដីសំរេចរបស់ គខ/កប គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានយល់ព្រមលើបណ្ដឹងតវ៉ាឬយល់ព្រមលើបណ្ដឹង

ជំទាស់ ឬដែលបានបដិសេធលើបណ្តឹងតវ៉ា ឬបដិសេធលើបណ្តឹងជំទាស់ ត្រូវបានថតចម្លងចំនួនពីរ( ២ )ច្បាប់ និងចាត់ចែងឱ្យនាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុវត្តតាមមុខការរៀងខ្លួន ដូចដែលបានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ។

២.២៧.២ នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវធានាថា រាល់សេចក្តីសំរេចរបស់ គខ/កប គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានយល់ព្រមលើបណ្តឹងតវ៉ា ឬយល់ព្រមលើបណ្តឹងជំទាស់ ឬដែលបានបដិសេធលើបណ្តឹងតវ៉ា ឬបដិសេធលើបណ្តឹងជំទាស់ ត្រូវតែបានអនុវត្តយ៉ាងត្រឹមត្រូវ និងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ដើម្បីកែតម្រូវបញ្ជីបោះឆ្នោតដំបូង ឱ្យមានលក្ខណៈសុក្រឹត ។ ផ្អែកតាមសេចក្តីសម្រេចសវនាការរបស់ គខ/កប គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះករណីនីមួយៗ នាយកដ្ឋានប្រតិបត្តិការត្រូវចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនិងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតក្នុងកុំព្យូទ័រ ដូចខាងក្រោម ៖

២.២៧.២.១ ករណីបដិសេធបណ្តឹងតវ៉ា ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។

២.២៧.២.២ ករណីបដិសេធបណ្តឹងជំទាស់ ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។

២.២៧.២.៣ ករណីយល់ព្រមបណ្តឹងតវ៉ា ត្រូវធ្វើការកែតម្រូវឈ្មោះ និងទិន្នន័យពាក់ព័ន្ធ ឬចុះបន្ថែមនូវឈ្មោះរបស់សាមីអ្នកប្តឹងតវ៉ាដែលបានបាត់ឈ្មោះ ឬចុះឡើងវិញនូវឈ្មោះអ្នកត្រូវគេប្តឹងជំទាស់ដែលបានឈ្នះការប្តឹងតវ៉ានៅ គជប ឬនៅក្រុមប្រឹក្សាធម្មនុញ្ញ ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.២៧.២.៤ ករណីយល់ព្រមបណ្តឹងជំទាស់ ត្រូវលុបឈ្មោះអ្នកដែលត្រូវគេប្តឹងជំទាស់ ឬលុបឈ្មោះដែលស្ទួនលើស ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.២៧.៣ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងអគ្គលេខាធិការនៃរដ្ឋសភា ត្រូវលើកសំណើដោយមានការបញ្ជាក់ឯកភាព តាមលំដាប់ឋានានុក្រមមក គជប ដើម្បីសុំកែតម្រូវបញ្ជីបោះឆ្នោត ក្នុងករណីមានអ្នកបោះឆ្នោតម្នាក់ឬច្រើននាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងតំណែងជាតំណាងរាស្ត្រ ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តទៅទៀត និងដែលមានតំណាងរាស្ត្រក្នុងតំណែងថ្មី ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងថ្មី ចូលជំនួសជាផ្លូវការ ។

២.២៧.៤ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ដោយផ្អែកតាមករណី ដូចមានចែងក្នុងចំណុច ២.២៧.៣ ខាងលើ ប្រសិនបើមាន ត្រូវតែបានបញ្ជូនមកដល់ គជប ក្នុងចន្លោះពេលចាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង រហូតដល់យ៉ាងតិចមួយ( ១ )ថ្ងៃ មុនថ្ងៃដែល គជប ត្រូវប្រកាសសុពលភាពបញ្ជីបោះឆ្នោតផ្លូវការ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោតនេះ ត្រូវតែមានភ្ជាប់មកជាមួយនូវ ៖

២.២៧.៤.១ ឯកសារជាភស្តុតាងបញ្ជាក់អំពីករណីពាក់ព័ន្ធនៃអ្នកបោះឆ្នោត ដែលត្រូវស្នើលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង ។

២.២៧.៤.២ ឯកសារផ្លូវការតែងតាំងអ្នកថ្មីជំនួស ដែលត្រូវស្នើបញ្ចូលឈ្មោះទៅក្នុងបញ្ជីបោះឆ្នោតដំបូង ។

២.២៧.៥ គជប ត្រូវពិនិត្យសំរេចជាបន្ទាន់ លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.២៧.៤ ខាងលើ ប្រសិនបើមាន និងត្រូវចាត់ចែងឱ្យនាយកដ្ឋានប្រតិបត្តិការកែតម្រូវបញ្ជីបោះឆ្នោតដំបូងជាបន្ទាន់ តាមការសំរេចរបស់ គជប នៅមុនពេល គជប ប្រកាសសុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ ។

២.២៧.៦ នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវធានាថា ផ្អែកតាមការសំរេចរបស់ គជប លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត តាមករណីនីមួយៗ មន្ត្រីក្រោមឱវាទបានកែតម្រូវឈ្មោះ និងទិន្នន័យបញ្ជីបោះឆ្នោតដំបូងក្នុងកុំព្យូទ័រ ដោយត្រូវ ៖

២.២៧.៦.១ លុបចេញពីបញ្ជីបោះឆ្នោត នូវឈ្មោះនិងទិន្នន័យអ្នកដែលត្រូវបាន គជប សំរេចលុប ដូចចែងក្នុងចំណុច ២.២៧.៤.១ ខាងលើ ។

២.២៧.៦.២ បញ្ចូលក្នុងបញ្ជីបោះឆ្នោតដំបូង នូវឈ្មោះនិងទិន្នន័យអ្នកបោះឆ្នោតថ្មី ដែលត្រូវបាន គជប សំរេចឱ្យបញ្ចូលជំនួស ដូចចែងក្នុងចំណុច ២.២៧.៤.២ ខាងលើ ។

២.២៧.៧ នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវសេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការ តាមការិយាល័យបោះឆ្នោតនីមួយៗ ក្នុងទម្រង់ឯកភាពគ្នាតែមួយ ដែលក្នុងនោះ រួមមាន ៖

២.២៧.៧.១ លេខរៀងមណ្ឌលភូមិភាគ ឈ្មោះខេត្ត ក្រុង ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតនៅទីប្រជុំជនខេត្ត ក្រុងពាក់ព័ន្ធ ។

២.២៧.៧.២ កូនប្រឡោះតូចសម្រាប់គូសសំគាល់ ពេលមកបោះឆ្នោត ។

២.២៧.៧.៣ លេខរៀងនៃឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។

២.២៧.៧.៤ នាមត្រកូល និងនាមខ្លួន ( រៀបចំតាមអក្ខរក្រមខ្មែរ ) ភេទ ថ្ងៃខែឆ្នាំកំណើត តំណែងតាមអង្គបោះឆ្នោតនីមួយៗ និង អាសយដ្ឋានបច្ចុប្បន្ននៃអ្នកបោះឆ្នោត ។

២.២៧.៧.៥ ខ្ទង់ទំនេរសម្រាប់ចារសម្គាល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលបានប្រើនៅពេលបោះឆ្នោត ។

២.២៧.៧.៦ ការបញ្ជាក់ចំនួនអ្នកបោះឆ្នោតសរុប ក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗ ។

២.២៧.៧.៧ ការបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅគ្រប់ទំព័រ ។

២.២៧.៧.៨ ចន្លោះបំរុងទុកសម្រាប់ការចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប នៅលើទំព័រចុងក្រោយ ។

២.២៧.៨ គជប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតទាំងអស់ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្នុងរយៈពេលយ៉ាងតិច ដប់ប្រាំ ( ១៥ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ នាយកដ្ឋានប្រតិបត្តិការនៃ គជប ត្រូវធានាថា សេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងទម្រង់ឯកភាពតែមួយ ដែលបានពិនិត្យកែតម្រូវរួចក្នុងកុំព្យូទ័រ ត្រូវតែបានបោះពុម្ពដោយឡែកពីគ្នាតាមការិយាល័យបោះឆ្នោតនីមួយៗ និងដាក់ជូន គជប ពិនិត្យសម្រេច ។

២.២៧.៨.១ សេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ២.២៧.៧ ខាងលើ ត្រូវតែបានដាក់ជូន គជប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គជប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ នៅលើទំព័រចុងក្រោយ ។ ដោយឡែក នៅគ្រប់ទំព័រផ្សេងទៀត នៃបញ្ជីបោះឆ្នោតផ្លូវការនេះ ក្រៅពីទំព័រចុងក្រោយ ក៏ត្រូវមានបោះត្រារបស់ គជប ផងដែរ ។

២.២៧.៨.២ ច្បាប់ដើម នៃបញ្ជីបោះឆ្នោតផ្លូវការ តាមការិយាល័យបោះឆ្នោតនីមួយៗ មួយ( ១ )ច្បាប់ ត្រូវរក្សាទុកជាឯកសារនៅ គជប ។

២.២៧.៨.៣ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ២ បញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ២.២៧.៨.២ ខាងលើ ត្រូវតែបានថតចម្លងបន្ថែម

ចំនួនប្រាំ( ៥ )ច្បាប់ទៀត ដែលត្រូវរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោត ដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុង និងវេចខ្ចប់ដោយឡែកពីគ្នាតាមខេត្ត ក្រុងនីមួយៗ ។ ក្នុងការវេចខ្ចប់បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវតែត្រៀមលក្ខណៈសម្រាប់បែងចែកជាស្រេចឱ្យដល់ គខ/កប ចំនួនបី( ៣ )ច្បាប់ និង គកប នីមួយៗ ចំនួនពីរ( ២ )ច្បាប់ ។

២.២៧.៨.៤ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការ ដែលវេចខ្ចប់និងបញ្ជូនខាងលើនេះ ត្រូវតែមានសរសេរសម្គាល់ លេខរៀងមណ្ឌលភូមិភាគ ឈ្មោះខេត្ត ក្រុង ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើប្រាស់បញ្ជីបោះឆ្នោតនោះផង ។

២.២៧.៩ បញ្ជីបោះឆ្នោតផ្លូវការ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលត្រូវបាន គជប ផ្តល់សុពលភាពរួចហើយ មិនអាចកែប្រែបានឡើយ ។

២.២៧.១០ គជប ត្រូវធានាថា នាយកដ្ឋានប្រតិបត្តិការនៃ គជប បានចាត់វិធានការម៉ត់ចត់ក្នុងការថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតផ្លូវការ ដូចចែងក្នុងចំណុច ២.២៧.៨.២ ជាឯកសាររបស់ គជប និង រក្សាសុវត្ថិភាពទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការនេះ ក្នុងកុំព្យូទ័របានល្អប្រសើរ ។

២.២៧.១១ គណបក្សនយោបាយ និង អង្គការមិនមែនរដ្ឋាភិបាលនានា មានសិទ្ធិស្នើសុំពី គជប នូវច្បាប់ចម្លងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតមួយ ឬច្រើន ចំនួនមួយ(១)ច្បាប់ ដោយបង់ថ្លៃត្រឹមតម្លៃផលិត ។ ការផ្តត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកលើលទ្ធភាពផលិតនិងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំ តម្រូវឱ្យបង់ប្រាក់ជាមុនស្មើនឹងមួយរយ( ១០០ )ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

**ប្រការ២.២៨** តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងគណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ អាចចូលរួមសង្កេតការណ៍ ក្នុងគ្រប់ដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង

ការបើកសវនាការដោះស្រាយបណ្ដឹងនៅគ្រប់លំដាប់ថ្នាក់ និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ដែលចូលរួមសង្កេតការណ៍ ត្រូវតែមានការអនុញ្ញាតពី គជប ឬ អាជ្ញាធររៀបចំការបោះឆ្នោត ដែលត្រូវបានប្រគល់សិទ្ធិ ។

**ប្រការ២.២៩** នីតិវិធីនៃការដាក់ពាក្យបណ្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបានចែងលំអិតរួចហើយក្នុងជំពូកទី ២ នៃបទបញ្ជានិងនីតិវិធីរបស់ គជប ។ ទោះបីយ៉ាងនេះក្ដី ការអនុវត្តនីតិវិធីដែលចែងក្នុងជំពូកទី ២ នេះ ត្រូវតែគួបផ្សំជាមួយនឹងនីតិវិធីនៃការដាក់ពាក្យបណ្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ដូចចែងក្នុងជំពូកទី ៨ នៃបទបញ្ជានិងនីតិវិធីរបស់ គជប ។

## សិទ្ធិបោះឆ្នោត និងលក្ខខណ្ឌសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**ប្រការ២.៣០** អ្នកបោះឆ្នោត សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង ទាំងស្រី ទាំងប្រុស ក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។ គជប ត្រូវណែនាំដល់អ្នកបោះឆ្នោត អង្គបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ អំពីសិទ្ធិបោះឆ្នោតនិងលក្ខខណ្ឌសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

២.៣០.១ ដើម្បីមានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងទាំងពីរភេទត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ សំរាប់ប្រើនៅថ្ងៃបោះឆ្នោត ។

២.៣០.២ នៅថ្ងៃបោះឆ្នោត តំណាងរាស្ត្រក្នុងតំណែងឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងណាដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬ លិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

២.៣០.៣ នៅថ្ងៃបោះឆ្នោត តំណាងរាស្ត្រក្នុងតំណែងឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក៏ដោយ ប៉ុន្តែប្រសិនបើគ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រ

ក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

២.៣០.៤ ឈ្មោះអ្នកបោះឆ្នោតនៅលើឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ត្រូវតែដូចគ្នានឹងឈ្មោះនៃអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២.៣០.៥ ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ឬលិខិតសំគាល់ខ្លួនតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ត្រូវតែមានបិទរូបថតសាមីខ្លួន ។

# ជំពូកទី ៣
# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
# និងបញ្ជីបេក្ខជនឈរឈ្មោះ

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**ប្រការ ៣.១** ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើមកៅសិប ( ៩០ ) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

## លក្ខខណ្ឌ និងបែបបទក្នុងការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ

**ប្រការ ៣.២** ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាផ្លូវការ គណបក្សនយោបាយ ត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ទៅ គជប យ៉ាងយូរបំផុតចិតសិប (៧០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.២.១ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតគឺ ជាទម្រង់បែបបទ ដែល គជប ផ្តល់ជូនដោយឥតគិតថ្លៃ ។ គណបក្សនយោបាយ ដែលមានបំណង ឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបំពេញពាក្យសុំចុះបញ្ជីនេះជា ពីរ ( ២ )ច្បាប់ ។

៣.២.២ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបាន ទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

៣.២.៣ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវភ្ជាប់មកជាមួយនូវ ៖

៣.២.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ស្តីពីការចុះបញ្ជីគណបក្សនយោបាយ នៅ ក្រសួងមហាផ្ទៃមួយ (១)ច្បាប់ ។

៣.២.៣.២ ឈ្មោះគណបក្សនយោបាយជាអក្សរខ្មែរ និងឡាតាំងឈ្មោះពេញ និងអក្សរកាត់ ព្រមទាំងសញ្ញាសម្គាល់គណបក្សនយោបាយ ។

៣.២.៣.៣ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ ។

៣.២.៣.៤ បញ្ជីបេក្ខជនឈរឈ្មោះសរុបទូទាំងប្រទេស ។ បញ្ជីនេះត្រូវមាន បេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិចមួយភាគបី (១/៣) នៃចំនួនអាសនៈក្នុង

ព្រឹទ្ធសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ (មិនគិតអាសនៈដែលត្រូវតែងតាំងទេ) ។

៣.២.៣.៥ មណ្ឌលភូមិភាគ ដែលគណបក្សនយោបាយ មានបំណងទៅឈរឈ្មោះនិងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលភូមិភាគទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលភូមិភាគ ត្រូវមានបេក្ខជនគ្រប់តាមចំនួនអាសនៈ និងបំពេញតាមគំរូដែល គជប ផ្ដល់ជូន ។

៣.២.៣.៦ សេចក្ដីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយនៅធនាគារក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៣.២.៣.៧ លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ស្ដីពីការបង្កើតគណបក្សនយោបាយ ។

៣.២.៣.៨ សេចក្ដីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និង ទទួលយកលទ្ធផលបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្តច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធី ក្រមសីលធម៌របស់ គជប និងច្បាប់ស្ដីពីគណបក្សនយោបាយ ។

៣.២.៣.៩ បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

៣.២.៣.១០ បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួនដប់ប្រាំលាន (១៥.០០០.០០០)រៀល ដែលចេញដោយរតនាគារជាតិ ។

**ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ**

**ប្រការ ៣.៣** គជប ត្រូវកំណត់កាលបរិច្ឆេទ នៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៣.៣.១ គជប ត្រូវផ្សព្វផ្សាយជាសាធារណៈ នូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

៣.៣.២ ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេលម្ភៃ (២០)ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧ម៉០០ ដល់ ១១ម៉៣០ និងពេលរសៀលចាប់ពីម៉ោង ២ម៉០០ ដល់ ៥ម៉៣០ (លើកលែងថ្ងៃបុណ្យផ្លូវការ) ។

៣.៣.៣ គជប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនសាមីគណបក្ស ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជីទុកជាឯកសារ ។

៣.៣.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារ ដែលបានទទួលដោយត្រូវចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខាអមនៃអ្នកប្រគល់ ទទួល ។

**ការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ**

**ប្រការ ៣.៤** គជប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

៣.៤.១ ក្នុងករណី គជប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គជប ត្រូវចេញលិខិតបញ្ជាក់ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្ស ។

៣.៤.២ ក្នុងករណី គជប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៤.១ និង ៤.៣ ក្នុងជំពូកទី ៤ គជប ត្រូវជូនដំណឹងទៅសាមីគណបក្សនោះវិញដើម្បីបំពេញបន្ថែម ។

៣.៤.២.១ គណបក្សនយោបាយនោះ ត្រូវបំពេញលក្ខខណ្ឌខ្វះខាតយ៉ាងយូរប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃ ដែលសាមីគណបក្សបានទទួលលិខិតជូនដំណឹង ។

៣.៤.២.២ ផុតកំណត់រយៈពេលដូចមានចែងក្នុងចំណុច ៣.៤.២.១ ខាងលើនេះ គជប ចាត់ទុកថា គណបក្សនយោបាយនោះបានបោះបង់ចោលការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជាស្ថាពរ ។

៣.៤.៣ ក្នុងការសម្រេចបដិសេធ គជប ត្រូវ ៖

៣.៤.៣.១ បំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេច បដិសេធចំនួនបី (៣)ច្បាប់ រួចផ្ញើជូន ៖

- គណបក្សនយោបាយសាមី មួយ (១)ច្បាប់

- ក្រុមប្រឹក្សាធម្មនុញ្ញ មួយ ( ១ )ច្បាប់
- រក្សាទុកឯកសារ មួយ ( ១ )ច្បាប់ ។

៣.៤.៣.២ ផ្តល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរប្រាំ ( ៥ )ថ្ងៃ
បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធនេះ ។

៣.៤.៣.៣ ប្រគល់ទម្រង់បែបបទលេខ ១២០២ ចំនួនបួន ( ៤ )ច្បាប់ជូនដល់សាមីគណបក្សនយោបាយដែលត្រូវបានបដិសេធ សម្រាប់ប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**ការប្តឹងតវ៉ាពាក់ព័ន្ធនឹងសេចក្តីសម្រេចបដិសេធរបស់ គជប**

**ប្រការ ៣.៥** គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គជប; សាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរប្រាំ ( ៥ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

៣.៥.១ ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាហើយ ប៉ុន្តែសាមីគណបក្ស ពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលាដូចចែងក្នុងប្រការ ៣.៥ ទេនោះ ត្រូវចាត់ទុកថា សាមីគណបក្សបានបោះបង់ចោលការសុំចុះបញ្ជីគណបក្សនយោបាយជាស្ថាពរ ។

៣.៥.២ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេលដប់ ( ១០ )ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។ ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចចុងក្រោយ ។

**ករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើបណ្តឹងតវ៉ា**

**ប្រការ ៣.៦** ប្រសិនបើយល់ព្រមនឹងបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចយល់ព្រម និងជូនដំណឹងទៅអ្នកប្តឹងតវ៉ា ហើយបង្គាប់ឱ្យ គជប ចុះឈ្មោះសាមីគណបក្សនយោបាយ ឬ/និងទទួលយល់ព្រមបេក្ខភាពជាបន្ទាន់ ។

៣.៦.១ បន្ទាប់ពីបានទទួលសេចក្តីសម្រេចយល់ព្រមពីក្រុមប្រឹក្សាធម្មនុញ្ញ គជប ត្រូវចេញលិខិតបញ្ជាក់ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះជូនទៅសាមីគណបក្សនយោបាយនោះភ្លាម ។

៣.៦.២ គជប ត្រូវផ្ញើលិខិតបញ្ជាក់នេះមួយច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**ករណីក្រុមប្រឹក្សាធម្មនុញ្ញបដិសេធលើបណ្តឹងតវ៉ា**

**ប្រការ ៣.៧** ប្រសិនបើបដិសេធនឹងបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចចុងក្រោយ ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

៣.៧.១ ផ្តល់សេចក្តីសម្រេចបដិសេធនេះមួយច្បាប់ទៅសាមីគណបក្សនយោបាយ ឬអ្នកប្តឹងតវ៉ា ។

៣.៧.២ ផ្ញើសេចក្តីសម្រេចបដិសេធមួយច្បាប់ទៅ គជប ។

**ការបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ**

**ប្រការ ៣.៨** បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងក្រោយពេលដែលបណ្តឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គជប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគរបស់គណបក្សនយោបាយទាំងនោះ ដូចមានចែងក្នុងប្រការ ៣.៩ ខាងក្រោម ។

**សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន**

**ប្រការ ៣.៩** គជប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមភូមិភាគជាផ្លូវការ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.៩.១ បេក្ខជនម្នាក់ៗមានសិទ្ធិទទួលការការពារសន្តិសុខ និងសុវត្ថិភាពដូចមានចែងក្នុងជំពូកទី ៣ មាត្រា ៣២ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៣.៩.២ នៅពេលដែលការស៊ើបអង្កេត រកឃើញភស្តុតាងស្តីពីការគំរាមកំហែងដល់សន្តិសុខ និងសុវត្ថិភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំពូកទី ១១ នៃ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប ឬបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមជំពូកទី ៨ នៃបទបញ្ជា និង នីតិវិធី គជប ។

**ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោត**

**ប្រការ** ៣.១០ គជប ត្រូវរៀបចំពិធីចាប់ឆ្នោតមួយ ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយ ដែលនឹងត្រូវបោះពុម្ពលើសន្លឹកឆ្នោត ។

៣.១០.១ ផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ គជប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

៣.១០.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ ។ គជប ត្រូវបិទផ្សាយជាសាធារណៈ អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ម្ភៃបួន ( ២៤ )ម៉ោង មុនការចាប់ផ្តើមពិធីចាប់ឆ្នោត ។

៣.១០.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតយ៉ាងហោចណាស់ម្ភៃបួន ( ២៤ )ម៉ោង មុនពិធីចាប់ឆ្នោតចាប់ផ្តើម ។ លិខិតអញ្ជើញនេះត្រូវមានចុះហត្ថលេខារបស់អ្នកទទួលដើម្បីទុកជាឯកសារ ។

៣.១០.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ ៖

៣.១០.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គជប ។

៣.១០.៤.២ ការបង្ហាញសន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ ។

៣.១០.៤.៣ ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។

៣.១០.៤.៤ ការបិទពិធីចាប់ឆ្នោត ។

៣.១០.៥ គជប ត្រូវរៀបចំសន្លឹកឆ្នោត មួយសន្លឹកសម្រាប់គណបក្សនយោបាយមួយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតរួចហើយ ។

៣.១០.៥.១ សន្លឹកឆ្នោតនេះ មានប្រភេទ និងទំហំដូចគ្នា ។

៣.១០.៥.២ ត្រូវសរសេរ ឬបោះពុម្ពឈ្មោះគណបក្សជាអក្សរដែលមានពណ៌ និងប្រភេទតួអក្សរដូចគ្នា និងមានទំហំដូចគ្នានៅលើសន្លឹកឆ្នោតនេះ ។

៣.១០.៥.៣ សន្លឹកឆ្នោតដែលមានឈ្មោះ គណបក្សនយោបាយ ត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានទំហំប៉ុនគ្នា ពណ៌ដូចគ្នា ។

៣.១០.៦ មុនចាប់ផ្តើមធ្វើការចាប់ឆ្នោត គជប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធី ។

៣.១០.៦.១ សន្លឹកឆ្នោតនីមួយៗ ត្រូវបត់ជាពីរផ្នត់ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិត ។

៣.១០.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងហិបឆ្នោតហើយត្រូវក្រឡុកហិបឆ្នោតនោះ ។

៣.១០.៧ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនដែលចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចចំណុច ៣.១០.៤.៣ ចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗ ពីហិបឆ្នោត ។

៣.១០.៧.១ ស្រោមសំបុត្រឆ្នោតដែលចាប់បាន ត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោមពីរនាក់ ។

៣.១០.៧.២ មន្ត្រីបោះឆ្នោតមួយរូប ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។

៣.១០.៧.៣ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ នៅលើសន្លឹកឆ្នោតឱ្យបានឮៗ និងសរសេរលេខរៀង "លេខ១" នៅលើសន្លឹកឆ្នោតនោះ ហើយត្រូវបន្តធ្វើការចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

៣.១០.៧.៤ លទ្ធផលនៃការចាប់ឆ្នោត ត្រូវសរសេរនៅលើក្តារខៀនដាក់បង្ហាញក្នុងអង្គពិធី ។

៣.១០.៨ លេខាធិការនៃអង្គពិធីចាប់ឆ្នោត ត្រូវធានាបំពេញកំណត់ហេតុនៃអង្គប្រជុំឱ្យបានរួចរាល់ដោយភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងដូចមានចែងក្នុងចំណុច ៣.១០.៧.៣ ។

៣.១០.៩ គជប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់មណ្ឌលភូមិភាគនីមួយៗ ។

៣.១០.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកតាមចំនួនគណបក្សនយោបាយ ដែលមានបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ នៅតាមមណ្ឌលភូមិភាគ ។ សន្លឹកឆ្នោតសម្រាប់មណ្ឌលភូមិភាគណា ប្រើប្រាស់បានតែនៅក្នុងមណ្ឌលភូមិភាគនោះតែប៉ុណ្ណោះ ។

៣.១០.៩.២ ឈ្មោះ រូបសញ្ញាគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀង តាមលទ្ធផលនៃការចាប់ឆ្នោត ។

**ប្រការ** ៣.១១ បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**ប្រការ** ៣.១២ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរពក្រមសីលធម៌ដែលកំណត់ដោយ គជប ។

# ជំពូកទី ៤
# បេក្ខជនសមាជិកព្រឹទ្ធសភា

**លក្ខខណ្ឌឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា**

**ប្រការ** ៤.១ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពលរដ្ឋម្នាក់ៗ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

៤.១.១ មានសញ្ជាតិខ្មែរពីកំណើត ។

៤.១.២ មានអាយុ ៤០ (សែសិប)ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។

៤.១.៣ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ។

៤.១.៤ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤.១.៥ មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា**

**ប្រការ** ៤.២ ជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភាគឺ ៖

៤.២.១ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនាឬ

៤.២.២ ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៤.២.៣ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៤.២.៤ ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ

៩.២.៥ ជនដែលត្រូវដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដោយ គជប ឬ

៩.២.៦ សមាជិក គជប និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬ

៩.២.៧ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៩.២.៨ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

**ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស**

**ប្រការ** ៩.៣ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនាដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិចប្រាំពីរ (៧ ) ថ្ងៃមុនថ្ងៃបើកការឃោសនាបោះឆ្នោត ។

៩.៣.១ ប្រសិនបើជាប់ឆ្នោត សាមីជនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬអង្គភាពរបស់ខ្លួនទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីជនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

៩.៣.២ នៅពេលចប់អាណត្តិ សាមីជនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៩.៣.៣ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាពត្រូវផ្ញើជូន គជប ក្នុងរយៈពេលយ៉ាងតិចប្រាំពីរ ( ៧ )ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកការឃោសនាបោះឆ្នោត ។

៩.៣.៣.១ លិខិតបញ្ជាក់ការអនុញ្ញាតនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជនដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាពដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំក្រសួង ឬអង្គភាពសាមីដែលអាចបញ្ជាក់បាន ។

**ការប្រកាសបេក្ខភាពបេក្ខជនគណបក្សនយោបាយ**

**ប្រការ** ៨.៤ សេចក្តីប្រកាសបេក្ខភាព ៖

៨.៤.១ គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ ស្តីពីគណបក្សនយោបាយ ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនតាមមណ្ឌលភូមិភាគនីមួយៗ ។

៨.៤.២ គណបក្សនយោបាយដែលបានតែងតាំងបេក្ខជន ត្រូវបំពេញបែបបទសេចក្តីប្រកាសបេក្ខភាពដែលផ្តល់ដោយ គជប ។

៨.៤.៣ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគត្រូវ ៖

៨.៤.៣.១ ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។

៨.៤.៣.២ មានសេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះ បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសកល ។

៨.៤.៣.៣ ភ្ជាប់សេចក្តីប្រកាស របស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមមណ្ឌលភូមិភាគ របស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

៨.៤.៤ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់មណ្ឌលភូមិភាគតែមួយគត់ ។ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌលភូមិភាគ ត្រូវបានប្រកាសថា បាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គជប ទោះបីជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតក៏ដោយ ។

# ជំពូកទី ៥

## ការឃោសនាបោះឆ្នោត

**បញ្ញត្តិទូទៅ**

**ប្រការ ៥.១** អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោតគឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។

សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ឬរិះគន់គោលនយោបាយ ឬកម្មវិធីនយោបាយគណបក្សណាមួយ មានដូចជា ៖

៥.១.១ ការប្រជុំមីទីញជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៥.១.២ ការជួបជុំ ឬក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ឬការឃោសនាតាមផ្ទះដើម្បីគាំទ្រគណបក្ស ឬ/និងគោលនយោបាយគណបក្ស ឬការសំដែងមតិសំដៅស្វែងរកសំលេងឆ្នោត ។

៥.១.៣ ការផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារពត៌មានដើម្បីគាំទ្របេក្ខជនណាម្នាក់ ឬគោលនយោបាយគណបក្សណាមួយ ឬរិះគន់គោលនយោបាយ ឬកម្មវិធីនយោបាយគណបក្សណាមួយ ។

៥.១.៤ ការផ្សព្វផ្សាយតាមរលកអាកាស ឬស្រែកជាពាក្យស្លោកខ្លីៗតាម ឧបករណ៍បំពងសម្លេង ឬតាមម៉ាញ៉េដែលអាចឱ្យប្រជាពលរដ្ឋស្តាប់បាននូវសារនយោបាយ ។

៥.១.៥ ការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយកាស្សែតវីដេអូក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

៥.១.៦ សកម្មភាពបិទផ្សាយនូវរូបភាពឃោសនានៅតាមទីសាធារណៈ ។

៥.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីអោយអ្នកបោះឆ្នោតបោះឆ្នោតអោយខ្លួន ឬគណបក្សរបស់ខ្លួន ។

៥.១.៨ សកម្មភាពចែកចាយមួក សំលៀកបំពាក់ អាវយឺត ផ្លាកសញ្ញា ឬសម្ភារៈផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដើម្បីគាំទ្រគណបក្សណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៥.១.៩ សកម្មភាពលើកបដា នៅទីសាធារណៈណាមួយ និងតម្លើង បន្ទះក្តារបិទប្រកាសផ្សាយពីគោលនយោបាយរបស់គណបក្ស ឬបេក្ខជន ។

៥.១.១០ ការប្រគំតន្ត្រីដោយដើរជាក្បួន ឬនៅកន្លែងណាមួយ ឬច្រៀង ចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោតដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ គណបក្សណាមួយ ឬរិះគន់គោលនយោបាយ ឬកម្មវិធីនយោបាយគណបក្សណាមួយ ។

**ប្រការ ៥.២** ការឃោសនាត្រូវបើករយៈពេលម្ភៃពីរ ( ២២ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៥.២.១ ការឃោសនាបោះឆ្នោតត្រូវដំណើរការក្នុងរយៈពេលម្ភៃមួយ ( ២១ ) ថ្ងៃ ។

៥.២.២ ការឃោសនាត្រូវបញ្ឈប់ក្នុងរយៈពេលម្ភៃបួន (២៤) ម៉ោងមុនថ្ងៃបោះឆ្នោត ។

៥.២.៣ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងទៅនឹងដំណើរការបោះឆ្នោត ត្រូវបញ្ឈប់ប្រាំ (៥) ថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ការស្ទង់មតិ គឺជាការប្រើបញ្ជីសំនួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត ។ ការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិត្រូវបញ្ជាក់អំពីប្រភពពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានស្ទង់មតិ និងកំរិតលំអៀងនៃលទ្ធផល ។

៥.២.៤ មិនអនុញ្ញាតឱ្យធ្វើសកម្មភាពឃោសនាអ្វីទាំងអស់ក្នុងអំឡុងពេល ២៤ ម៉ោងមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។ ជនណាប្រព្រឹត្តល្មើសនឹងបំរាមនេះនឹងត្រូវទទួលការពិន័យតាមច្បាប់បោះឆ្នោត ។

**ប្រការ ៥.៣** គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ អាចរៀបចំកិច្ចប្រជុំអំពីកម្មវិធីនយោបាយរបស់ខ្លួននៅទីកន្លែងឯកជនបានគ្រប់ពេល

និងមានសិទ្ធិលើកផ្លាកគណបក្សគ្រប់ពេលនៅលើទីតាំងឯកជន ឬផ្ទះឯកជន ដោយមានការអនុញ្ញាតពីម្ចាស់ទីកន្លែងនោះ ។

៥.៣.១ ផ្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំសង្កាត់ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់ ។

៥.៣.២ ផ្លាកសញ្ញាគណបក្ស និងសម្ភារៈឃោសនាសំរាប់គណបក្សនយោបាយមិនត្រូវអនុញ្ញាតអោយលើក ឬបិទនៅលើអាគារ និងការិយាល័យរបស់រដ្ឋ ។

៥.៣.៣ ផ្លាកសញ្ញា ឬសម្ភារៈឃោសនារបស់គណបក្សនយោបាយដែលស្ថិតនៅក្នុងរង្វង់ ១០០ ម៉ែត្រ ពីការិយាល័យបោះឆ្នោតត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែផ្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

**ប្រការ ៥.៤** ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនេះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និង មិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៥.៤.១ ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

៥.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា ៖ រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ផ្លាកសញ្ញារាជការ ឬរដ្ឋ ន.ប ខ.ម រាជរដ្ឋាភិបាល ។

**ប្រការ ៥.៥** ការស្លៀកពាក់(អាវយឺត_មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះឋិតក្នុងការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬខាងក្រៅនៃការិយាល័យបោះឆ្នោត ។

**ប្រការ ៥.៦** មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ៖

- មិនត្រូវប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬដោយចំពោះទៅលើដំណើរការបោះឆ្នោត ។
- មិនត្រូវប្រមូលផ្តុំមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការមកធ្វើការបញ្ចុះបញ្ចូលក្នុងចេតនាស្វែងរកសំលេងឆ្នោតនៅក្នុងអាគារ និងការិយាល័យរបស់រដ្ឋ ។
- មិនត្រូវចូលរួមសកម្មភាពក្នុងការឃោសនាបោះឆ្នោត ក្នុងម៉ោងធ្វើការ សំរាប់គណបក្សនយោបាយណាឡើយ ។

ការចូលរួមក្នុងសកម្មភាពដែលត្រូវបានហាមឃាត់របស់មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

៥.៦.១ ជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកពត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

៥.៦.២ ការចូលរួមក្នុងក្បួនដង្ហែ ការជួបជុំ និងក្បួនព្យុហយាត្រាដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៥.៦.៣ ការសួង់មតិសំរាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៥.៦.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៥.៦.៥ ការធ្វើសកម្មភាពចែកចាយសម្ភារៈដល់អ្នកបោះឆ្នោតក្នុងគោលដៅគាំទ្រ គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៥.៦.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈក្នុងការគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៥.៦.៧ ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗតាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**ប្រការ ៥.៧** មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការបន្ទាប់ពីបញ្ចប់ម៉ោងធ្វើការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះ បេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ ប៉ុន្តែពុំត្រូវស្លៀកពាក់ឯកសណ្ឋាន និង មិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលប្រព្រឹត្តផ្ទុយពីប្រការ ៥.៦ និង ៥.៧ ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ១៣១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

**ប្រការ ៥.៨** មុននឹងបើកការឃោសនាបោះឆ្នោត គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្នុងចំណុច ៥.៦ និង ៥.៧ ខាងលើ តាមរយៈ អាជ្ញាធរ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការ ទាក់ទិនដល់ការឃោសនាបោះឆ្នោត ។

**ប្រការ ៥.៩** គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និង ប្រជុំបន្ថែមតាមការចាំបាច់ជាមួយនឹងតំណាង គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានាដើម្បី ៖

- ជំរាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត ។
- ជំរាបជូនជាសង្ខេបពីបទបញ្ជា និងនីតិវិធី ។
- ស្តាប់ការកត់សំគាល់ផ្សេងៗ ។
- ពិភាក្សាលើបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត ។

**ប្រការ ៥.១០** គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៥.១០.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវតែគោរពច្បាប់បោះឆ្នោត ។

៥.១០.២ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវតែគោរពបទបញ្ជា នីតិវិធី និងសេចក្តីណែនាំផ្សេងៗដែលបានអនុម័តដោយ គជប ។

៥.១០.៣ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។

៥.១០.៤ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវតែអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចដែលបានរៀបរាប់ក្នុងជំពូកទី ៣ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៥.១០.៥ គណបក្សនយោបាយ ឬតំណាង បេក្ខជន មិនត្រូវបង្អាប់បញ្ឆោឱ្យអ្នកគាំទ្ររបស់ខ្លួន ទៅហែកចោលនូវក្រដាសផ្សាយរបស់គណបក្ស ឬ/និងបេក្ខជនដទៃទៀតឡើយ ។

៥.១០.៦ គណបក្សនយោបាយ ឬតំណាង បេក្ខជន មិនត្រូវជម្រុញឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបំភិតបំភ័យ ក្នុងអំឡុងពេលធ្វើការឃោសនាបោះឆ្នោតឡើយ ។

៥.១០.៧ គណបក្សនយោបាយ ឬតំណាង បេក្ខជន ឬជនណាម្នាក់មិនត្រូវផ្តល់វិភាគទានជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ទោះបីតាមមធ្យោបាយណាក៏ដោយដល់អង្គបោះឆ្នោត និងអ្នកបោះឆ្នោត ក្នុងគោលបំណងទិញសន្លឹកឆ្នោត ។

៥.១០.៨ គណបក្សនយោបាយ ឬតំណាង បេក្ខជន មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលនេះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្តរួមមាន ៖

៥.១០.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិតរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៥.១០.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម ។

៥.១០.៨.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។

៥.១០.៨.៤ ការរំលោភដោយពាក្យសំដីថានឹងធ្វើទុក្ខទោសដល់រាងកាយ ។

៥.១០.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

៥.១០.៨.៦ ការនិយាយដោយផ្ទាល់មាត់ ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែល យោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជា ឃាដកម្ម ការវាយដំ ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៥.១០.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៥.១០.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៥.១០.៨.៩ ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៥.១០.៨.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៥.១០.៨.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

៥.១០.៨.១២ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថ ឬបង្ខំអោយផ្តិតមេដៃ អោយគេបោះឆ្នោតអោយគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។

៥.១០.៨.១៣ ការប្រមូល ឬដកហូតឯកសារបញ្ជាក់អត្តសញ្ញាណ សំរាប់បោះឆ្នោត ។

**ប្រការ ៥.១១** គណបក្សនយោបាយ ឬតំណាង ឬបេក្ខជន ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៥.១០ នឹងត្រូវទទួលទោសតាមមាត្រា ១២៤ថ្មី និងមាត្រា ១៣១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## សម្ភារៈអប់រំអ្នកបោះឆ្នោត

**ប្រការ ៥.១២** នាយកដ្ឋានបណ្ដុះបណ្ដាល និងពត៌មានសាធារណៈ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត និងក្នុងការលើកកំពស់ការយល់ដឹងអំពីបញ្ហាបោះឆ្នោត ។

៥.១២.១ គជប អំពាវនាវ និងលើកទឹកចិត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់ ។

៥.១២.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានបំណងសហការជាមួយ គជប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជន អាចទាក់ទងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងពត៌មានសាធារណៈនៃ គជប ។

៥.១២.៣ សម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែមានលក្ខណៈអព្យាក្រឹត និងមិនលំអៀង ។ សម្ភារៈនេះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយណាមួយ ហើយត្រូវគោរពទៅតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គជប ។

៥.១២.៤ សម្ភារៈពត៌មានសាធារណៈ និងសម្ភារៈអប់រំដែលផលិតដោយ គជប និងសម្ភារៈដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិដែលទទួលលិខិតយល់ព្រមពី គជប ត្រូវបានរក្សាសិទ្ធិហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គជប ឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិ និង គជប ដែលបានសហការជាមួយគ្នា ក្នុងការផលិតសម្ភារៈអប់រំសាធារណជន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវការប្រព្រឹត្តខុសពីកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ។

៥.១២.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារៈអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រឹមត្រូវតាមបច្ចេកទេស និងតាមច្បាប់បោះឆ្នោត ហើយនឹងតាមបទបញ្ជា និងនីតិវិធីនៃ គជប គជប នឹងជួយផ្តល់សេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម និងណែនាំដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារៈអប់រំនេះ ។

៥.១២.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រមចាំបាច់ពី គជប ឡើយ ។

៥.១២.៧ ទោះបីជាសម្ភារៈអប់រំបានទទួល ឬមិនបានទទួលលិខិតយល់ប្រមពី គជប ក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារៈអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។

៥.១២.៨ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពដែលមានចែងក្នុងចំណុច ៥.១៣.៥.៦ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម ក្នុងរយៈពេលយ៉ាងយូរចិតសិបពីរ (៧២) ម៉ោងបន្ទាប់ពីទទួលបានសំណើពីអង្គការក្រៅរដ្ឋាភិបាលនានាសុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារៈអប់រំនោះ ។ ក្នុងករណីពិនិត្យឃើញថាសម្ភារៈ ឬខ្លឹមសារអប់រំមិនសមស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីទេ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យកែតំរូវតាមមធ្យោបាយណាមួយដែលប្រសើរបំផុត ។ ក្នុងករណីគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពធ្វើការពិនិត្យផ្ទៀងផ្ទាត់សម្ភារៈអប់រំរបស់អង្គការក្រៅរដ្ឋាភិបាលហួសរយៈពេលចិតសិបពីរ (៧២) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតអោយធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។

៥.១២.៩ សម្ភារៈអប់រំដែលអាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងអាចទទួលបានលិខិតយល់ព្រមពី គជប ដូចជា ៖

៥.១២.៩.១ ស្ប៉តវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។

៥.១២.៩.២ កាសែ្សតម៉ាញ៉េ ឬខ្សែអាត់សម្លេង ។

៥.១២.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា ។

៥.១២.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។

៥.១២.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារពត៌មាន ។

៥.១២.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើអាវ ឬមួក ។

៥.១២.១០ សម្ភារៈដែលបានពិនិត្យផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គជប ត្រូវតម្កល់ទុក នៅ គជប មួយមុខមួយច្បាប់សម្រាប់ជាឯកសារ ។

៥.១២.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម ដែលផ្តល់ឱ្យដោយ គជប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិច្បាប់បោះឆ្នោត។ ប្រសិនបើពត៌មានដែលមានក្នុងសម្ភារៈអប់រំដែលខ្លួនបានផលិតនោះត្រូវបានរកឃើញថា ពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា នីតិវិធី លំអៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ឬធ្វើឱ្យសាធារណជនយល់

ខុសពីច្បាប់ បទបញ្ជា និងនីតិវិធី គជប អាចសុំឱ្យធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារៈនោះទាំងស្រុងតែម្តង ។ សម្ភារៈដែលត្រូវរកឃើញថា ពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី គជប លំអៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចក្នុងចំណុច ៥.១៣.៨ ។

៥.១២.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ ត្រូវបានអនុញ្ញាតអោយផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោតដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ សៀវភៅអប់រំអ្នកបោះឆ្នោតនោះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋាន មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ។ ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតប៉ុណ្ណោះ ។

៥.១២.១៣ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងរៀបចំឱ្យមានកម្មវិធីស្មើភាពគ្នាក្នុងប្រព័ន្ធផ្សព្វផ្សាយសម្រាប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតក្នុងអំឡុងពេលឃោសនាបោះឆ្នោតអាចពិគ្រោះ កម្មវិធី លំអិត សហប្រតិបត្តិការជាមួយ គជប ។ សកម្មភាពដែលត្រូវបានកំណត់ថា ជាកម្មវិធីស្មើភាពមានដូចខាងក្រោម ៖

៥.១២.១៣.១ កម្មវិធីមួយ ឬកម្មវិធីជាភាគ ដែលផ្តល់ឱកាសដល់គណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតផ្សព្វផ្សាយកម្មវិធី ឬទស្សនៈនយោបាយក្នុងការពិភាក្សា កិច្ចសម្ភាសន៍ ការពិភាក្សាសួរដេញដោល ការពិភាក្សាតុមូល វេទិកា ឬកម្មវិធីដដែកជាសាធារណៈ ដោយឈរលើមូលដ្ឋាននៃការផ្តល់ពេលវេលាស្មើភាពគ្នាចំពោះអ្នកចូលរួមទាំងអស់ ។

៥.១២.១៣.២ ដើម្បីសំរបសំរួលឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាតាមគោលការណ៍ស្មើភាពដែលធានាពេលវេលាស្មើគ្នា និងការអនុវត្តចំណុច ៥.១៣.៨ ហើយអនុលោមតាមមាត្រា ៧៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការផ្សព្វផ្សាយកម្មវិធីស្មើភាពនេះត្រូវមានលិខិតយល់ព្រមពី គជប ។

៥.១២.១៤ គជប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬទាំងអស់នៃសម្ភារៈអប់រំដែលមិនគោរពទៅតាមចំណុច ៥.១២.៣ ៥.១២.១២ និង ៥.១៣.៨ ។ សាមីអង្គការត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គជប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាមមាត្រា ១២៨ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៥.១២.១៥ គជប មានសិទ្ធិបញ្ជាឱ្យដកហូត ឬមានសិទ្ធិបញ្ឈប់ការផ្សព្វផ្សាយទាំងស្រុងចំពោះកម្មវិធីស្មើភាពទាំងឡាយណាដែលមិនគោរពទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងចំណុច ៥.១២.៣ ៥.១២.១២ និងចំណុច ៥.១៣.៨ ។

**ការឃោសនាផ្សព្វផ្សាយ**

**ប្រការ ៥.១៣** យោងតាមប្រការ ៥.២ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារៈឃោសនាផ្សព្វផ្សាយបានដូចជា ៖

៥.១៣.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។

៥.១៣.២ សារពត៌មាន ( ការផ្សព្វផ្សាយ គំនូរជីវចល ការជូនពត៌មាន សេចក្តីថ្លែងការណ៍ សារនយោបាយ រូបសញ្ញា ) ។

៥.១៣.៣ ការឃោសនាតាម វិទ្យុ និងទូរទស្សន៍

- ៥.១៣.៣.១ អត្ថបទឃោសនា ។
- ៥.១៣.៣.២ បទភ្លេងចម្រៀងជាពាក្យស្លោកខ្លីៗ ។
- ៥.១៣.៣.៣ ការសូត្រពាក្យកំណាព្យ ។
- ៥.១៣.៣.៤ ការប្រគំតន្ត្រី ។
- ៥.១៣.៣.៥ កិច្ចសម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់ ។
- ៥.១៣.៣.៦ ការសម្តែងសិល្បៈ ។
- ៥.១៣.៣.៧ ការចាក់កាសែ្សតវីដេអូសាធារណៈ ។

៥.១៣.៤ ដោយយោងលើរូបភាពនិងសម្ភារៈឃោសនាបោះឆ្នោតដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតរួមមាន ៖

៥.១៣.៤.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្ត វីដេអូ ។

៥.១៣.៤.២ ប៉េងប៉ោង ឬបង្គោះខ្លែង ។

៥.១៣.៤.៣ សម្ភារៈបោះពុម្ព ដូចជា រូបភាពបិទផ្សាយ សំលៀកបំពាក់ អាវយឺត មួក ផ្លាកសញ្ញា ពាក្យស្លោក ឬរូបភាព បិទតាមរថយន្ត ផ្លាកសញ្ញាលោហៈខ្វាស់ បដា ។ល។

៥.១៣.៤.៤ ការស្រែកតាមទីសាធារណៈ ។

៥.១៣.៥ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានក្នុងការឃោសនាបោះឆ្នោត

៥.១៣.៥.១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវបានអនុញ្ញាតអោយចំណាយទៅលើការផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍ និងបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយឯកជននៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

៥.១៣.៥.២ ប្រព័ន្ធផ្សព្វផ្សាយឯកជន ដែលមានបំណងទទួលយកការជួលផ្សាយរបស់គណបក្សនយោបាយ ត្រូវលៃលកទុកពេលវេលានិង ម៉ោងផ្សាយដើម្បីផ្តល់ជូនសំរាប់ផ្សព្វផ្សាយ ដោយឈរលើមូលដ្ឋានឱកាសស្មើភាពគ្នាក្នុងតំលៃស្មើៗគ្នាសំរាប់គណបក្សនយោបាយទាំងអស់ ។

៥.១៣.៥.៣ ប្រព័ន្ធផ្សព្វផ្សាយឯកជនអាចមិនចុះផ្សាយ ឬមិនផ្សព្វផ្សាយការជួលអោយផ្សព្វផ្សាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ បើសិនជាប្រព័ន្ធផ្សព្វផ្សាយឯកជនណាមួយសំរេចមិនចុះផ្សាយ ឬមិនផ្សព្វផ្សាយការជួលអោយផ្សព្វផ្សាយរបស់គណបក្សណាមួយ ប្រព័ន្ធផ្សព្វផ្សាយនោះត្រូវបដិសេធការជួលផ្សព្វផ្សាយនិងចុះផ្សាយរបស់គណបក្សនយោបាយទាំងអស់។

៥.១៣.៥.៤ ដើម្បីអនុវត្តមាត្រា ៧៤ ៧៥ និង ៧៦ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គជប ត្រូវដឹកនាំការធ្វើកម្មវិធីតុមូលនិងការត្រួតពិនិត្យស្ប៉ត គណបក្សនយោបាយ និងអត្ថបទឃោសនាគណបក្ស ដោយចាត់ចែងឱ្យមានកំរិតស្មើគ្នាជាមូលដ្ឋានសម្រាប់គណបក្សនយោបាយក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានរដ្ឋក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៥.១៣.៥.៥ គជប បង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពមួយ ដើម្បីសម្របសម្រួលលើការងារធ្វើកម្មវិធីតុមូល និងត្រួតពិនិត្យស្បៀត និងអត្ថបទគណបក្សនយោបាយដែលបញ្ជូនមក គជប ដោយផ្អែកលើគោលការណ៍ស្មើភាព និងសម្ភារៈអប់រំដែលស្នើសុំលិខិតយល់ព្រមពី គជប ។

៥.១៣.៥.៦ សមាសភាពគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព មានដូចខាងក្រោម ៖

១. អគ្គលេខាធិការរង ជាប្រធាន

២. ជំនួយការ គជប មួយរូប ជាអនុប្រធាន

៣. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងពត៌មានសាធារណៈ ជាសមាជិក

៤. ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសមាជិក

៥. អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងពត៌មានសាធារណៈទទួលបន្ទុកពត៌មានសាធារណៈ ជាសមាជិក ។

៥.១៣.៥.៧ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីកំណត់លើភាពស្មើគ្នាជាមូលដ្ឋាន ហើយត្រូវមានបទបញ្ជាមួយដោយឡែកទៀតដែលអនុម័តដោយ គជប ដើម្បីឱ្យដំណើរការរៀបចំកម្មវិធីស្មើភាពនេះប្រព្រឹត្តទៅបាន ។

៥.១៣.៥.៨ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាពរបស់ គជប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ។

៥.១៣.៥.៩ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវជួបប្រជុំជាមួយអ្នកគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយពត៌មានទាំងរដ្ឋ និងឯកជន ដើម្បីពិភាក្សារកវិធានការផ្សេងៗ ក្នុងការអនុវត្តមាត្រា ៧៤ ៧៥ ៧៦ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៥.១៣.៥.១០ គជប ត្រូវសហការជាមួយក្រសួងព័ត៌មាន ក្នុងការជួបប្រជុំពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយពត៌មានរដ្ឋ និងឯកជន ដើម្បីពន្យល់ណែ

នាំអំពីបទបញ្ជា និងនីតិវិធី ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ និងគោលការណ៍ណែនាំផ្សេងៗរបស់ គជប ។

៥.១៣.៥.១១ គោលការណ៍ស្មើភាពជាមូលដ្ឋានត្រូវបានកំណត់តាមរូបភាព ដូចខាងក្រោម ៖

៥.១៣.៥.១១.១ ស្ប៉តគណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍ ។

៥.១៣.៥.១១.២ កិច្ចពិភាក្សាតុមូល សម្រាប់គណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍ ។

៥.១៣.៥.១១.៣ ការចុះផ្សាយអត្ថបទឃោសនាលើព្រឹត្តិបត្ររបស់ គជប អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុង របស់បេក្ខជនឈរឈ្មោះបោះឆ្នោត ។

៥.១៣.៥.១២ ដើម្បីពិនិត្យបញ្ជាក់ឱ្យច្បាស់ថា សម្ភារៈផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ មានលក្ខណៈសមស្របអនុលោមតាមចំណុច៥.១៣.៨ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពត្រូវត្រួតពិនិត្យ ៖

- សម្ភារៈផ្សព្វផ្សាយផលិតដោយ គជប ។
- សម្ភារៈផ្សព្វផ្សាយផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សហការជាមួយ គជប ។
- សម្ភារៈឃោសនារបស់គណបក្សនយោបាយក្នុងកម្មវិធីស្មើភាព

៥.១៣.៥.១៣ សម្ភារៈឃោសនារបស់គណបក្សនយោបាយដែលមិនពាក់ព័ន្ធនឹងកម្មវិធីស្មើភាពមិនត្រូវបានត្រួតពិនិត្យដោយ គជប ទេ ។ តែសម្ភារៈឃោសនាទាំងនេះត្រូវគោរពតាមចំណុច ៥.១៣.៨ ។

៥.១៣.៦ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត គជប ត្រូវស្នើនាយកដែសារពត៌មាន វិទ្យុ និងទូរទស្សន៍ ផ្តល់នូវកម្មវិធីផ្សព្វផ្សាយប្រចាំសប្តាហ៍ ឬប្រចាំខែ និងតារាងតំលៃផ្សាយមកឱ្យ គជប ។

៥.១៣.៧ គ្រប់សម្ភារៈឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយ ដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសំគាល់របស់គណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន) ។

៥.១៣.៨ សម្ភារៈអប់រំ និងសម្ភារៈឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទំរង់អត្ថបទបោះពុម្ព ឬតាមប្រព័ន្ធផ្សព្វផ្សាយ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយដូចខាងក្រោម ៖

៥.១៣.៨.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសំងាត់នៃការបោះឆ្នោត ។

៥.១៣.៨.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សំដែងការមាក់ងាយ ឬអសីលធម៌ ។

៥.១៣.៨.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភ័ន្តច្រឡំ និងខូចរបៀបរបបសង្គម ។

៥.១៣.៨.៤ ប្រើប្រាស់រូបភាព ឬភាសាដែលមានពត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត ។

៥.១៣.៩ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារៈអប់រំ និងសម្ភារៈឃោសនាដែលត្រូវបានរកឃើញថា រំលោភបញ្ញត្តិខាងលើ គជប អាចបញ្ជាអោយដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារៈខុសច្បាប់ទាំងនោះ ។

៥.១៣.១០ គណបក្សនយោបាយត្រូវទទួលខុសត្រូវ ចំពោះសម្ភារៈដែលខ្លួនផ្សព្វផ្សាយចំពោះមុខច្បាប់ យោងតាមមាត្រា ១៣១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៥.១៣.១១ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារស្នាព្រះហស្ត និងព្រះនាមព្រះមហាវរក្សត្រ ព្រះមហាក្សត្រ រូបសញ្ញា គជប ទៅប្រើប្រាស់ដើម្បីរកសំលេងឆ្នោត ។

៥.១៣.១២ ហាមលើកបដាឃោសនា ផ្លាកសញ្ញាគណបក្ស និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សឬបេក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ ។

**ប្រការ ៥.១៤** អ្នកគ្រប់គ្រងមហោស្រព រោងសិល្បៈ មជ្ឈមណ្ឌលកីឡា និងទីកន្លែងសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួន ដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត

ដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាពតាមលំដាប់មុន ក្រោយ និងតាមកាលបរិច្ឆេទនៃការស្នើសុំ ។ ពាក្យស្នើសុំទាំងនេះអាចធ្វើឡើងចាប់ពីរយៈពេលប្រាំពីរ ( ៧ )ថ្ងៃ មុនការចាប់ផ្តើមការឃោសនាបោះឆ្នោត ។ អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំរបស់គណបក្សនយោបាយមិនឱ្យលើសពីម្ភៃបួន (២៤) ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។

៥.១៤.១ គណបក្សនយោបាយ ឬ/និងបេក្ខជនត្រូវតែជូនដំណឹង ដោយចំលងពាក្យសុំមួយច្បាប់ទៅ គឃ/កប ឱ្យបានបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំឃោសនា ។ សកម្មភាពប្រជុំឃោសនាជាសាធារណៈ ត្រូវបានកំណត់ជាសកម្មភាព បើកទូលាយដល់សាធារណជនទូទៅដូចជា ៖

៥.១៤.១.១ ការដង្ហែក្បួនដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ។

៥.១៤.១.២ ការជួបជុំជាសាធារណៈ ។

៥.១៤.១.៣ ការប្រគំតន្ត្រី ការលេងភ្លេង ឬការរាំកំសាន្ត ។

៥.១៤.១.៤ រឿងល្ខោនខ្លីៗ ការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្ត វីដេអូ ។

៥.១៤.១.៥ ក្បួនព្យុហយាត្រា ។

៥.១៤.១.៦ ព្រឹត្តិការណ៍កីឡា ដើម្បីប្រមូលប្រាក់គាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

៥.១៤.២ បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹង ដូចមានចែងក្នុងចំណុច ៥.១៤.១ គឃ/កប ត្រូវមានវិធានការសម្របសម្រួលអំពីការងារសន្តិសុខ និងសណ្តាប់ធ្នាប់សម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនា ។

**ប្រការ ៥.១៥** គណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតអាចធ្វើ សកម្មភាពឃោសនានៅលើទីកន្លែងឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការ ព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ/កប យ៉ាងតិច បី (៣) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ។

**ប្រការ ៥.១៦** គណបក្សនយោបាយ និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះ រួមមាន ៖

៥.១៦.១ ការនិយាយដៀមដាម ប្រមាថមើលងាយ ។

៥.១៦.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

៥.១៦.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

៥.១៦.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ។

៥.១៦.៥ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ថយបង្អាក់មិនឱ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត ។

៥.១៦.៦ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។

៥.១៦.៧ ការប្រើឧបករណ៍បំពងសម្លេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀតកំពុងធ្វើការឃោសនា ឬការជួបប្រជុំ ។

**ប្រការ ៥.១៧** បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៥.១៧.១ កងយោធពលខេមរភូមិន្ទ នគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាស សុវត្ថិភាពសម្រាប់ការបោះឆ្នោត ។

៥.១៧.២ កងយោធពលខេមរភូមិន្ទ នគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខនិងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៥.១៧.៣ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ ។

៥.១៧.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គខ/កប ត្រូវតាមដានរាល់សកម្មភាពសន្តិសុខ និងសុវត្ថិភាពក្នុងខេត្ត ក្រុងរបស់ខ្លួន និងត្រូវរាយការណ៍ជូន គជប ជារៀងរាល់ថ្ងៃ ។

**ប្រការ ៥.១៨** គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ត្រាប្រាក់ចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសំរាប់ការឃោសនាបោះឆ្នោត ។

៥.១៨.១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចត្រួតពិនិត្យសៀវភៅគណនីនេះ នៅពេលមានការចាំបាច់ ។

៥.១៨.២ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបានត្រូវបញ្ចូលក្នុងគណនី នៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាត្រូវតែចេញពីគណនីតែមួយនេះ ។

**ប្រការ ៥.១៩** រាល់បណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ៨ នៃបទបញ្ជា និងនីតិវិធីរបស់ គជប ។

**ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន**

**ប្រការ ៥.២០** ផ្អែកតាមសារៈសំខាន់ក្នុងការផ្សព្វផ្សាយពត៌មានជូនដល់អ្នកបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយពត៌មានអេឡិចត្រូនិចទាំងរដ្ឋ ទាំងឯកជន ត្រូវបំពេញតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការបោះឆ្នោតសេរី និងយុត្តិធម៌ ។

៥.២០.១ អ្នកបោះឆ្នោតមានសិទ្ធិធ្វើការជ្រើសរើសទៅតាមពត៌មានដែលខ្លួនទទួលបាន ។ សិទ្ធិនេះតម្រូវឱ្យប្រព័ន្ធផ្សព្វផ្សាយពត៌មាន ទាំងរដ្ឋ និងឯកជនមានកាតព្វកិច្ចអនុវត្តតាមគោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ដូចមានចែងក្នុងឧបសម្ព័ន្ធគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ដើម្បីអោយការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ ។

៥.២០.២ គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ និងឯកជនត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មានក្នុងអំឡុងពេលបោះឆ្នោត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធីរបស់ គជប ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះ មុខច្បាប់ ។

៥.២០.៣ ដោយសារប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋ មានការទទួលខុសត្រូវ ពិសេសក្នុងដំណើរការបោះឆ្នោត គជប ត្រូវណែនាំក្រសួងពត៌មាន ដើម្បីប្រតិបត្តិ និងអនុវត្តជាពិសេស សំរាប់ការផ្សព្វផ្សាយពត៌មានអំពីការបោះឆ្នោត តាមគោលការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ។

# ជំពូកទី ៦

# តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកពត៌មាន

## តំណាងគណបក្សនយោបាយ

**ប្រការ ៦.១** អនុលោមតាមមាត្រា ២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តំណាងគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យសង្កេតមើលដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៦.១.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម គឺជាសេនាធិការរបស់ គជប ក្នុងការងារទាក់ទងទៅនឹងគណបក្សនយោបាយ និងតំណាងគណបក្សនយោបាយ ។

៦.១.២ គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងតំណាងពេញសិទ្ធិរបស់ខ្លួនមួយ (១)រូប និងតំណាងបម្រុងមួយ (១)រូប តាមការិយាល័យនីមួយៗ ដើម្បីសង្កេតមើលដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅតាមខេត្ត ក្រុងនៃមណ្ឌលភូមិភាគដែលកំណត់ដោយ គជប ។

៦.១.២.១ ក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត តំណាងគណបក្សនយោបាយនៃគណបក្សនយោបាយដែលត្រូវបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិពេញលេញក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។

៦.១.២.២ ក្នុងដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត តំណាងគណបក្សនយោបាយនៃគណបក្សនយោបាយដែលពុំត្រូវបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចជាអ្នកសង្កេតការណ៍ជាតិ ដែលមានសិទ្ធិនិងភារកិច្ចដូចមានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ។

៦.១.៣ គណបក្សនយោបាយដែលមានបំណងដាក់តំណាងរបស់ខ្លួន ដើម្បីសង្កេតមើលក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំចុះឈ្មោះតំណាងរបស់ខ្លួនទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត(លខ/កប)

ឬគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត(គខ/កប) ចាប់ពីដប់ (១០)ថ្ងៃមុនថ្ងៃស្រង់ឈ្មោះអ្នកបោះឆ្នោតរហូតដល់បី (៣)ថ្ងៃមុនថ្ងៃបោះឆ្នោត ។

៦.១.៣.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះតំណាងគណបក្សនយោបាយទម្រង់បែបបទ គជប លេខ ១០០៧ ជូនដល់គណបក្សនយោបាយដោយឥតគិតថ្លៃ ហើយគណបក្សអាចថតចម្លងគំរូពាក្យសុំនេះ ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះជាតំណាងគណបក្សនយោបាយ ។ ពាក្យសុំត្រូវធ្វើជាបី (៣)ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយ (១)ច្បាប់
- បញ្ជីឈ្មោះតំណាងពេញសិទ្ធិ និងបម្រុង ដែលជានីតិជនដោយបញ្ជាក់នាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំ កំណើត និងអាសយដ្ឋានបច្ចុប្បន្នរបស់តំណាងនោះ
- សេចក្តីប្រកាសគោរពច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គជប និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ។

៦.១.៣.២ តំណាងគណបក្សនយោបាយត្រូវ ៖

- មានសមត្ថភាពអាចបំពេញការងារបាន
- បានទទួលហ្វឹកហ្វឺន ស្តីពីច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដោយគណបក្សនយោបាយសាមី ។

៦.១.៣.៣ ពាក្យសុំចុះឈ្មោះតំណាងគណបក្សនយោបាយត្រូវចុះហត្ថលេខាដោយប្រធានឬតំណាងនៃគណបក្សនយោបាយដែលទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។

៦.១.៣.៤ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) ត្រូវពិនិត្យពាក្យសុំចុះឈ្មោះតំណាងគណបក្សនយោបាយ និងសម្រេចក្នុងរយៈពេលយ៉ាងយូរបី (៣)ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។ បន្ទាប់ពីពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះតំណាងគណបក្សនយោបាយរួចហើយ គខ/កប ត្រូវចុះហត្ថលេខា និងបោះត្រាលើគ្រប់ទំព័រ ទាំងបី (៣)ច្បាប់ ដើម្បី ៖

- ផ្ញើទៅសាមីគណបក្សនយោបាយ មួយ (១)ច្បាប់

- ផ្ញើមក គជប មួយ (១)ច្បាប់
- រក្សាទុកឯកសារ មួយ (១)ច្បាប់ ។

៦.១.៣.៥ ប្រសិនបើ គខ/កប ពិនិត្យលើពាក្យស្នើសុំឃើញថា តំណាងគណបក្សនយោបាយណាមួយ ពុំមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ៦.១.៣.១ គខ/កប ត្រូវជម្រាបទៅតំណាងគណបក្សនយោបាយនោះឱ្យធ្វើការកែតម្រូវ ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនៅតែពុំព្រមកែតម្រូវនោះ; គខ/កប ត្រូវសម្រេចយកតែឈ្មោះតំណាងគណបក្សណា ដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ ។

៦.១.៣.៦ បន្ទាប់ពី គខ/កប សម្រេចអនុញ្ញាតលើពាក្យស្នើសុំចុះឈ្មោះតំណាងគណបក្សនយោបាយរួចហើយ គខ/កប ត្រូវផ្តល់ជូនបណ្ណសម្គាល់តំណាងគណបក្សនយោបាយ ដើម្បីឱ្យបំពេញ និងបិទរូបថត ។ គខ/កប ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រានៅលើជ្រុងខាងស្តាំនៃរូបថតលើបណ្ណសម្គាល់តំណាងគណបក្សនយោបាយ និងផ្តល់ជូនដើម្បីពាក់បំពេញការងារ ។

៦.១.៣.៧ តំណាងគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យចូលសង្កេតការណ៍ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

៦.១.៣.៨ តំណាងពេញសិទ្ធិរបស់គណបក្សនយោបាយត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតតែម្នាក់ប៉ុណ្ណោះ ។ តំណាងបម្រុងត្រូវបានអនុញ្ញាតឱ្យចាំនៅបរិវេណខាងក្រៅ ដើម្បីចាំជំនួសតំណាងពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

៦.១.៣.៩ តំណាងគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីពិនិត្យមើលដំណើរការផ្ទៀងផ្ទាត់និងការរាប់សន្លឹកឆ្នោត ។

៦.១.៣.១០ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរៀបចំគំរូ និងខ្លឹមសារនៃពាក្យស្នើសុំចុះឈ្មោះតំណាងគណបក្សនយោបាយ , បណ្ណសម្គាល់តំណាងពេញសិទ្ធិ និងតំណាងបម្រុងគណបក្សនយោបាយ ។ គខ/កប ត្រូវផ្តល់បណ្ណសម្គាល់ជូនតំណាង គណបក្សដោយឥតគិតថ្លៃដើម្បីបំពេញ និងបិទរូបថត ។

៦.១.៣.១០.១ បណ្ណសម្គាល់តំណាងគណបក្សពេញសិទ្ធិ និង បម្រុង គឺជាបណ្ណដែលមានគំរូ និងពណ៌តែមួយដូចគ្នា និងមានប្រអប់ សម្រាប់គូសពាក្យ ពេញសិទ្ធិ ឬបម្រុង ។

៦.១.៣.១១ គណបក្សនយោបាយនីមួយៗមានសិទ្ធិផ្លាស់ប្តូរតំណាងរបស់ខ្លួនក្នុងអំឡុងពេលសង្កេតមើលការរៀបចំការបោះឆ្នោតរហូតដល់ថ្ងៃ សៅរ៍ ម៉ោង ១៧:៣០ នាទី មុនថ្ងៃបោះឆ្នោត ។

៦.១.៤ តំណាងគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ។

៦.១.៥ តំណាងគណបក្សនយោបាយ ដែលរំលោភលើច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គជប និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ នឹងត្រូវទទួលទោស និងពិន័យទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៦.១.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ។

៦.១.៧ គណៈកម្មការការិយាល័យបោះឆ្នោតត្រូវរាយការណ៍ទៅ គខ/កប អំពីវត្តមាន និងសកម្មភាពនានា របស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## អ្នកសង្កេតការណ៍បោះឆ្នោត

**ប្រការ ៦.២** អ្នកសង្កេតការណ៍បោះឆ្នោតរួមមានអ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ ៖

- អ្នកសង្កេតការណ៍ជាតិ គឺជាសមាជិកជាតិ ឬបរទេសនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬជនបរទេសដែលត្រូវបានអញ្ជើញដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គជប ។
- អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គជប ផង ។

### អ្នកសង្កេតការណ៍ជាតិ

៦.២.១ គជប ត្រូវធ្វើសេចក្ដីជូនដំណឹងជាសាធារណៈ អំពីប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គជប ។ ការទទួលពាក្យចាប់ពីដប់ (១០)ថ្ងៃ មុនថ្ងៃស្រង់ឈ្មោះអ្នកបោះឆ្នោតរហូតដល់មួយ ( ១ )សប្ដាហ៍ មុនថ្ងៃបោះឆ្នោត ។

៦.២.១.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១. មានលិខិតបញ្ជាក់ស្ដីពីការចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាយ៉ាងហោចណាស់ប្រាំពីរ ( ៧ )ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

២. មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់ការពារ អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម ។

៣. មានកម្មវិធីបណ្ដុះបណ្ដាលអប់រំស្ដីពីការបោះឆ្នោតជូន សមាជិកសង្កេតការណ៍របស់ខ្លួន ។

៤. មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន ។

៦.២.១.២ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោត អ្នកសង្កេតការណ៍ជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៦.២.១.១ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនទៅ គជប ។

៦.២.១.២.១ នាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្មនៃ គជប ត្រូវផ្ដល់គំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតដោយឥតគិតថ្លៃ ។

ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតត្រូវធ្វើជាបី ( ៣ )ច្បាប់ ដោយភ្ជាប់មកជាមួយនូវ៖

១. ឯកសារបញ្ជាក់លក្ខខណ្ឌដូចចំណុច ៦.២.១.១

២. បញ្ជីឈ្មោះអ្នកសង្កេតការណ៍តាមខេត្ត ក្រុង ដែលត្រូវធ្វើការសង្កេតការណ៍

៣. សេចក្តីប្រកាសស្តីពីការគោរពច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធី និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ ។

៦.២.១.២.២ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវ ៖

- មានសមត្ថភាពបំពេញការងារបាន
- បានទទួលការហ្វឹកហ្វឺនអំពីច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវិធីទាក់ទងដល់ការបោះឆ្នោតនិងក្រមសីលធម៌អ្នកសង្កេតការណ៍។

៦.២.១.៣ គជប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិនៃសមាគមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលប្រាំពីរ (៧)ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះឈ្មោះ ។

៦.២.១.៣.១ គជប ត្រូវពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំមកដោយត្រូវ ៖

- រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ ដែលបំពេញលក្ខខណ្ឌគ្រប់គ្រាន់
- គូសបន្ទាត់លុបលើឈ្មោះ ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ និងចារ “បដិសេធ” នៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ។

៦.២.១.៣.២ គជប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរចំពោះអ្នកសង្កេតការណ៍ណាដែលបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់ ហើយចេញសេចក្តីសម្រេចបដិសេធឈ្មោះអ្នកសង្កេតការណ៍ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ។

៦.២.១.៣.៣ សេចក្តីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើជាបី(៣)ច្បាប់ ៖

- រក្សាទុកនៅ គជប មួយ (១)ច្បាប់
- ផ្ញើទៅ គខ/កប មួយ (១)ច្បាប់
- ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មួយ (១)ច្បាប់ ។

៦.២.១.៣.៤ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលត្រូវបានសម្រេច ត្រូវបោះត្រាលើគ្រប់ទំព័ររួចផ្ញើបញ្ជីឈ្មោះនោះ ទៅ គខ/កប ពាក់ព័ន្ធ ។

៦.២.១.៤ គខ/កប ត្រូវផ្តល់បណ្ណសម្គាល់សម្រាប់អ្នកសង្កេតការណ៍ជាតិបំពេញការងារសង្កេតការណ៍បោះឆ្នោតនៅខេត្ត ក្រុង (ភូមិភាគ)របស់ខ្លួន ។ គខ/កប ត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលតំណាងរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលសាមីបង្ហាញជូនជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលផ្ញើជូនជាផ្លូវការដោយ គជប ។

៦.២.១.៤.១ ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ គខ/កប ត្រូវប្រគល់បណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ដែលមាននៅក្នុងបញ្ជីឈ្មោះ ដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបំពេញ និងបិទរូបថត ដើម្បីទទួលបានសុពលភាពជាផ្លូវការ ។

៦.២.១.៤.២ បណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលអាចយកជាផ្លូវការបានក្នុងដំណើរការសង្កេតការណ៍បោះឆ្នោតលុះត្រាតែ ៖

- បណ្ណសម្គាល់ចេញដោយ គខ/កប ដែលត្រូវបានប្រគល់សិទ្ធិដោយ គជប ជាបណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់
- ត្រូវបាន គខ/កប បោះត្រានៅលើជ្រុងខាងស្តាំផ្នែកខាងក្រោមនៃរូបថតភ្ជាប់ទៅនឹងបណ្ណសម្គាល់អ្នកសង្កេតកាណ៍ជាតិ ។

៦.២.១.៥ ប្រធាន ឬតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវចុះហត្ថលេខា លើការធានា និងការទទួលខុសត្រូវលើបញ្ជីអ្នកសង្កេតការណ៍របស់ខ្លួន ជាពិសេស គឺការទទួលខុសត្រូវ

ចំពោះមុខច្បាប់អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍ម្នាក់ៗដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

៦.២.១.៦ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំបណ្ណអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសសម្រាប់ថ្នាក់ដឹកនាំរបស់ខ្លួន ។ បណ្ណចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណអ្នកសង្កេតការណ៍ជាតិ ។ បណ្ណនេះត្រូវបានចេញឱ្យដោយ គជប ។ អ្នកសង្កេតការណ៍ចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុងក្រមសីលធម៌ ។

**អ្នកសង្កេតការណ៍អន្តរជាតិ**

៦.២.២ អ្នកសង្កេតការណ៍អន្តរជាតិនៅពេលអញ្ជើញចូលមកដល់ ព្រះរាជាណាចក្រកម្ពុជា ត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីទទួលពត៌មានផ្សេងៗ ។

៦.២.២.១ អ្នកសង្កេតការណ៍បរទេស ឬអង្គការសង្កេតការណ៍អន្តរជាតិត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិទៅ គជប ក្នុងរយៈពេលចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។

នាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិជូនអ្នកសង្កេតការណ៍បរទេស ឬអង្គការមិនមែនរដ្ឋាភិបាលដោយឥតគិតថ្លៃដើម្បីបំពេញ និងបិទរូបថត ។

៦.២.២.២ គជប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះ និងបណ្ណសម្គាល់ ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍អន្តរជាតិក្នុងរយៈពេលយ៉ាងយូរបី(៣) ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

៦.២.២.៣ ក្រោយពីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះពុំទាន់បានត្រឹមត្រូវ គជប ត្រូវណែនាំអ្នកសង្កេតការណ៍បរទេស ឬអង្គការអន្តរជាតិនោះ ឱ្យបំពេញកែតម្រូវឡើងវិញភ្លាមៗដើម្បី គជប ចេញសេចក្តីសម្រេចអនុញ្ញាត ។

៦.២.២.៤ ក្នុងករណីពិនិត្យឃើញថាពាក្យសុំចុះឈ្មោះមានលក្ខណៈគ្រប់គ្រាន់ហើយ គជប ត្រូវជូនបណ្ណអ្នកសង្កេតការណ៍អន្តរជាតិឱ្យសាមីខ្លួន

ឬតំណាងដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនបណ្ណនោះមក គជប វិញ ។

៦.២.២.៥ បន្ទាប់ពីទទួលបណ្ណដែលបានបំពេញបានត្រឹមត្រូវហើយ គជប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខានិងបោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោម នៃរូបថតភ្ជាប់ទៅ នឹងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ រួចហើយជូនទៅអ្នកសង្កេតការណ៍នោះវិញដើម្បីពាក់បំពេញការងារ ។

៦.២.២.៦ បណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ អនុញ្ញាតឱ្យអ្នកសង្កេតការណ៍អន្តរជាតិសង្កេតដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់ការ និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦.២.៣ អ្នកបកប្រែរបស់អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយអ្នកសង្កេតការណ៍អន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង ។ អ្នកបកប្រែភាសាមានសិទ្ធិត្រឹមតែជាអ្នកបកប្រែភាសាតែប៉ុណ្ណោះ ។

៦.២.៤ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំគំរូបណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ ។

- បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ ត្រូវផ្ញើទៅខេត្ត ក្រុងតាមចំនួនសមស្រប និងតម្រូវការប្រើប្រាស់ដើម្បីផ្តល់ជូនអ្នកសង្កេតការណ៍ជាតិ ។
- បណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិត្រូវរក្សាទុកនៅ គជប សម្រាប់ផ្តល់ជូនអ្នកសង្កេតការណ៍អន្តរជាតិ ។

## អ្នកយកពត៌មានជាតិ និងអន្តរជាតិ

**ប្រការ ៦.៣** សមាគមវិជ្ជាជីវៈអ្នកសារពត៌មាន ឬអង្គភាពសារពត៌មាន ឬអ្នកយកពត៌មានឯករាជ្យអន្តរជាតិ និងជាតិដែលមានបំណងចូលរួមយកពត៌មានក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ទៅ គជប ។

៦.៣.១ នាយកដ្ឋានបណ្តុះបណ្តាល និងពត៌មានសាធារណៈ គឺជាសេនាធិការ របស់ គជប ក្នុងការងារគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងអ្នកយកពត៌មានជាតិ និងអន្តរជាតិ ដែលចូលរួមក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៦.៣.១.១ ពាក្យសុំចុះឈ្មោះជាអ្នកយកពត៌មាន ត្រូវបានផ្តល់ជូនដល់សមាជិកសមាគមវិជ្ជាជីវៈសារពត៌មាន ឬអង្គភាពសារពត៌មាន អ្នកយកពត៌មានឯករាជ្យ ដោយឥតគិតថ្លៃ ។

- រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកយកពត៌មានជាតិ គឺចាប់តាំងពីប្រកាសកាលបរិច្ឆេទនៃ ការបោះឆ្នោតរហូតដល់ប្រាំពីរ (៧) ថ្ងៃមុនថ្ងៃបោះឆ្នោត
- រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកយកពត៌មានអន្តរជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។

៦.៣.១.២ ពាក្យសុំចុះឈ្មោះជាអ្នកយកពត៌មានជាតិ និងអន្តរជាតិត្រូវធ្វើជាពីរ (២) ច្បាប់ ដោយត្រូវភ្ជាប់ជាមួយនូវ ៖

- ទិដ្ឋាការចេញដោយក្រសួងពត៌មាន
- លិខិតបញ្ជាក់ពីសាមីអង្គភាពផ្ទាល់ខ្លួន
- ច្បាប់ចម្លងនៃប័ណ្ណពត៌មានដែលចេញដោយក្រសួងពត៌មាន/សាមីអង្គភាព ឬសមាគមវិជ្ជាជីវៈអ្នកសារពត៌មានជាតិ ឬអន្តរជាតិណាមួយ
- ច្បាប់ថតចំលងនៃលិខិតឆ្លងដែនសំរាប់អ្នកយកពត៌មានអន្តរជាតិ ។

៦.៣.១.៣ សម្រាប់អ្នកយកពត៌មានឯករាជ្យ ត្រូវភ្ជាប់ច្បាប់ចម្លងនៃប័ណ្ណពត៌មានដែលចេញដោយក្រសួងពត៌មាន ឬសមាគមវិជ្ជាជីវៈអ្នកសារពត៌មានជាតិ ឬអន្តរជាតិណាមួយ ។

ក្នុងករណីគ្មានប័ណ្ណពត៌មាន អ្នកសុំចុះឈ្មោះ ត្រូវបង្ហាញអត្ថបទចុងក្រោយដែលខ្លួនសរសេរបានចំនួនដប់ (១០) អត្ថបទ ដែលចុះផ្សាយក្នុងសារពត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំ២០០៤ និង២០០៥ ។

៦.៣.១.៤ គជប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកយកពត៌មានក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃយ៉ាងយូរសម្រាប់អ្នកយកពត៌មានជាតិ ។

ក្នុងករណី គជប បដិសេធអ្នកយកពត៌មានជាតិដែលពុំមានលក្ខណៈគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីជនអ្នកយកពត៌មានអាចបំពេញ

ឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ ក្រោយទទួលលិខិតបដិសេធ ។

៦.៣.១.៥ គជប ត្រូវត្រួតពិនិត្យសំរេចលើពាក្យសុំចុះឈ្មោះរបស់អ្នកយកពត៌មានអន្តរជាតិ ក្នុងរយៈពេលពីរ (២) ថ្ងៃ យ៉ាងយូរ ។ ក្នុងករណី គជប បដិសេធអ្នកយកពត៌មានអន្តរជាតិដែលពុំមានលក្ខណៈគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីជនអ្នកយកពត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀតក្នុងរយៈពេលពីរ (២) ថ្ងៃយ៉ាងយូរ ក្រោយទទួលបានលិខិតបដិសេធ ។

៦.៣.២ គជប ត្រូវបោះពុម្ពប័ណ្ណសំគាល់អ្នកយកពត៌មានជាតិ និងប័ណ្ណសំគាល់អ្នកយកពត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកយកពត៌មាន ដែលត្រូវបានអនុញ្ញាតឱ្យយកពត៌មានដោយ គជប ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

៦.៣.៣ អ្នកយកពត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារពត៌មាន ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធី គជប ក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារពត៌មាន ។

៦.៣.៤ អ្នកយកពត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គជប អាចយកពត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់ការនៃការបោះឆ្នោត ដោយត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធីរបស់ គជប និងគោរពក្រមសីលធម៌សំរាប់អ្នកយកពត៌មាន ។

៦.៣.៤.១ អ្នកយកពត៌មានជាតិ និងអន្តរជាតិ មានសិទ្ធិថត និងយកពត៌មានពី ៖

- សកម្មភាពរបស់មហាជនចូលរួមចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត
- សកម្មភាព និងការប្រព្រឹត្តទៅរបស់មន្ត្រីចុះឈ្មោះបោះឆ្នោតមន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ។

៦.៣.៤.២ អ្នកយកពត៌មានជាតិ និងអន្តរជាតិ មិនមានសិទ្ធិ ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត
- ធ្វើការសំភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ធ្វើអោយរំខានដល់ការងារក្នុងការិយាល័យ ធ្វើអោយប៉ះពាល់ដល់ការសំងាត់នៃការបោះឆ្នោត និងប៉ះពាល់ដល់សិទ្ធិបុគ្គល ។

៦.៣.៤.៣ ការយកពត៌មានដោយរូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវសុំការអនុញ្ញាតពីប្រធានការិយាល័យនោះ ។

៦.៣.៤.៤ អ្នកយកពត៌មាន មិនត្រូវប្រើប្រាស់តួនាទីយកពត៌មាន (ទោះឯកជន ឬរដ្ឋ) មកប្រើប្រាស់ ឬគាបសង្កត់លើមន្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ចុះឈ្មោះបោះឆ្នោត ឬមន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬតំណាងគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោត ។

# ជំពូកទី ៧

# ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត

**សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត**

**ប្រការ** ៧.១ គជប ជាអង្គការឯករាជ្យ និងអព្យាក្រឹត ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។ អនុលោមតាមមាត្រា ២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប មានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

៧.១.១ គជប ប្រើប្រាស់សិទ្ធិអំណាចដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សំរាប់គ្រប់គ្រងការរៀបចំបែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.១.២ គជប ត្រូវកំណត់បទបញ្ជានិងនីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បន្ថែមលើភារកិច្ចបច្ចុប្បន្នរបស់ខ្លួន ។

**សមាសភាពនៃ គជប**

**ប្រការ** ៧.២ គជប រួមមានសមាសភាព ដូចខាងក្រោម ៖

៧.២.១ ឥស្សរជនខ្មែរមួយរូប ជាប្រធាន ។

៧.២.២ ឥស្សរជនខ្មែរមួយរូប ជាអនុប្រធាន ។

៧.២.៣ ឥស្សរជនខ្មែរបីរូប ជាសមាជិក ។

**ករណីបាត់បង់មុខតំណែងក្នុងសមាសភាពនៃ គជប**

**ប្រការ** ៧.៣ ការសម្រេចបណ្តេញពីប្រធាន ឬអនុប្រធាន ឬសមាជិក គជប ជាសមត្ថកិច្ចរបស់រដ្ឋសភា ។ ប្រធាន ឬអនុប្រធាន ឬសមាជិកនៃ គជប ត្រូវបាត់បង់មុខតំណែង ក្នុងករណីណាមួយដូចខាងក្រោម ៖

៧.៣.១ សាមីខ្លួនទទួលមរណភាព ។

៧.៣.២ សាមីខ្លួនលាឈប់ជាលាយលក្ខណ៍អក្សរ ។

៧.៣.៣ សាមីខ្លួនបានបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

៧.៣.៤ សាមីខ្លួនប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គជប ។

**លក្ខណៈវិនិច្ឆ័យ និងការតែងតាំងសមាជិក គជប**

**ប្រការ ៧.៤** លក្ខណៈវិនិច្ឆ័យ ដើម្បីជ្រើសរើសសមាជិករបស់ គជប ត្រូវបានកំណត់ដោយមាត្រា ១៣ ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៧.៤.១ ប្រធាន អនុប្រធាន និងសមាជិក គជប ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរ ដែលមានសមត្ថភាពខាងនយោបាយ មានពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

៧.៤.២ ប្រធាន អនុប្រធាន និងសមាជិក គជប ដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និង ជាអ្នកស្ថិតនៅក្នុងជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងជាមន្ត្រីរាជការ ក្រោយពីទទួលបានការតែងតាំងក្នុង គជប ត្រូវសុំលាលែងជាស្ថាពរពីគណបក្សនយោបាយ ឬ/និង ពីជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និង ដាក់ពាក្យសុំទៅបំរើការងារនៅក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

៧.៤.៣ បន្ទាប់ពីការតែងតាំងរួចហើយ ប្រធាន អនុប្រធាន និងសមាជិក គជប ទាំងអស់ មិនត្រូវតំណាងឱ្យទស្សនៈបក្សសម្ពន្ធ័នៃក្រុមមនុស្សរបស់សង្គម ដែលបានតែងតាំងខ្លួនឡើយ ។

**ប្រការ ៧.៥** សេចក្តីព្រាងសមាសភាពនៃ គជប ត្រូវបានលើកឡើងដោយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីបន្តលើកសំណើសុំការទុកចិត្តពីរដ្ឋសភា ។

៧.៥.១ ប្រធាន អនុប្រធាន និងសមាជិក គជប ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់គណៈរដ្ឋមន្ត្រីក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

៧.៥.២ ប្រធាន អនុប្រធាន និងសមាជិកនៃ គជប ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

**រចនាសម្ព័ន្ធនៃ គជប**

**ប្រការ** ៧.៦ រចនាសម្ព័ន្ធរបស់ គជប រួមមាន គជប និងអគ្គលេខាធិការដ្ឋាននៃ គជប ៖

៧.៦.១ គជប ត្រូវបង្កើតអនុគណៈកម្មការសម្របសម្រួល និងអនុគណៈកម្មការចំពោះកិច្ច ដើម្បីត្រួតពិនិត្យការងាររបស់អគ្គលេខាធិការដ្ឋាន ហើយត្រូវរាយការណ៍ជូន គជប ។ អនុគណៈកម្មការនេះត្រូវបង្កើតឡើងស្របតាមប្រការ ៨ នៃបទបញ្ជាផ្ទៃក្នុងរបស់ គជប ។

៧.៦.២ គជប ត្រូវតែងតាំងអគ្គលេខាធិការ ដែលមិនមែនជាសមាជិក គជប ហើយត្រូវទទួលខុសត្រូវចំពោះមុខ គជប ។

៧.៦.៣ គជប ត្រូវបង្កើតនាយកដ្ឋានចំនួនប្រាំ( ៥ ) ដើម្បីអនុវត្តការងារបោះឆ្នោត ។

៧.៦.៤ នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ( ១ )រូប និងមានអនុប្រធានយ៉ាងតិចមួយ( ១ )រូបជាជំនួយ ។

៧.៦.៥ ប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ ។

៧.៦.៦ អនុប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន ។

៧.៦.៧ នាយកដ្ឋាននីមួយៗត្រូវបែងចែកជាការិយាល័យ ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយ( ១ )រូប និងអនុប្រធានជាជំនួយតាមការកំណត់របស់ គជប ។

**សិទ្ធិអំណាចរបស់ គជប**

**ប្រការ** ៧.៧ គជប មានសិទ្ធិពេញលេញក្នុងការអនុវត្តការងារទាក់ទងនឹងរាល់ការបោះឆ្នោតដែលតម្រូវដោយច្បាប់ ក្នុងសមត្ថកិច្ចរបស់ខ្លួន ។ ផ្អែកលើសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវដែលមានស្រាប់បច្ចុប្បន្ននេះ សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងទៅនឹងការកសាងផែនការ ការរៀបចំបែបបទ ការចាត់ចែង និងការត្រួតពិនិត្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មានដូចតទៅ ៖

៧.៧.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

៧.៧.២ រៀបចំគំរោងផែនការការងារ ថវិកា និងសម្ភារៈបំរើឱ្យការបោះឆ្នោត ព្រមទាំងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

៧.៧.៣ តែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ( គខ/កប ) និងគណៈកម្មការការិយាល័យបោះឆ្នោត ( គកប ) ។

៧.៧.៤ ធ្វើបទបញ្ជានិងនីតិវិធី និងសេចក្តីណែនាំនានា សម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៧.៧.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៧.៧.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧.៧.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៧.៧.៨ ចេញសេចក្តីសំរេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧.៧.៩ ផលិត និងបែងចែកសម្ភារៈបរិក្ខារបំរើឱ្យការងារបោះឆ្នោត ។

៧.៧.១០ លើកសំណើដាក់ជូនស្ថាប័នមានសមត្ថកិច្ចតាមអង្គបោះឆ្នោតនីមួយៗ ដើម្បីធ្វើប្រតិភូកម្មអំណាច ដល់មន្ត្រីនៅតាមអង្គបោះឆ្នោតទាំងនោះ ឱ្យជួយបំពេញការងារចុះឈ្មោះបោះឆ្នោត ស្របតាមបទបញ្ជានិងនីតិវិធីរបស់ គជប និងច្បាប់ ។

៧.៧.១១ រៀបចំបញ្ជីបោះឆ្នោត និងបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

៧.៧.១២ ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ។

៧.៧.១៣ ទទួល និងសំរេចលើពាក្យសុំឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និងការឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភារបស់គណបក្សនយោបាយ ។

៧.៧.១៤ ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

៧.៧.១៥ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

៧.៧.១៦ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោតឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។ ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។ លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះឡើងវិញ ។

៧.៧.១៧ ត្រួតពិនិត្យ ចំណូល និងចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

៧.៧.១៨ ចាត់វិធានការ និងសម្របសម្រួល ដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោលការណ៍ស្មើភាព ។

៧.៧.១៩ ផ្តល់ព័ត៌មានអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

៧.៧.២០ ធានាឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចដំណើរការបោះឆ្នោត រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

៧.៧.២១ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

៧.៧.២២ លើកកំពស់ការយល់ដឹងរបស់អ្នកបោះឆ្នោត តាមអង្គបោះឆ្នោត និងអ្នកពាក់ព័ន្ធអំពីការងារបោះឆ្នោត តាមរយៈការអប់រំនិងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងតាមមធ្យោបាយផ្សេងៗទៀត ។

៧.៧.២៣ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

៧.៧.២៤ ពិនិត្យសំរេច និងចេញប័ណ្ណសម្គាល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

៧.៧.២៥ ត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី នៃការអនុវត្តការងារបោះឆ្នោត ។

៧.៧.២៦ សំរេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

៧.៧.២៧ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

៧.៧.២៨ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាតាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះ រយៈពេលបួន( ៤ )ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយដែលមានអាសនៈក្នុងព្រឹទ្ធសភា ។

៧.៧.២៩ អនុវត្តការងារដទៃទៀតដែលច្បាប់ និងបទបញ្ជាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

## ការប្រគល់សិទ្ធិអំណាចរបស់ គជប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

**ប្រការ ៧.៨** យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ គជប និងច្បាប់ គជប អាចប្រគល់សិទ្ធិទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោតណាម្នាក់ ។

៧.៨.១ គជប អាចប្រគល់សិទ្ធិទៅ គខ/កប ឬមន្ត្រីបោះឆ្នោតណាម្នាក់ដែលបានតែងតាំង ។ ក្នុងករណី គខ/កប ពុំទាន់ត្រូវបានបង្កើត និងតែងតាំង គជប អាចប្រគល់សិទ្ធិទៅលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតដើម្បីបំពេញការងារមួយចំនួនតាមការចាំបាច់ ។

៧.៨.២ គជប ត្រូវធ្វើប្រតិភូកម្មអំណាចដល់អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ឱ្យជួយអនុវត្តការចុះឈ្មោះបោះឆ្នោត សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៨.៣ ផ្អែកតាមការចាំបាច់ គជប អាចប្រគល់សិទ្ធិទៅ គកប ដែលត្រូវបានតែងតាំងតាមសំណើរបស់ គខ/កប ។

**រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់គជប ក្នុងដំណាក់ការចុះឈ្មោះបោះឆ្នោតដែលគខ/កប ពុំទាន់ត្រូវបានតែងតាំង**

**ប្រការ ៧.៩** លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតជាអង្គភាពរដ្ឋបាលថ្នាក់ក្រោមរបស់ គជប នៅក្នុងដំណាក់ការបន្តនិរន្តរភាព និងការចុះឈ្មោះបោះឆ្នោត សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ដោយឡែក នៅក្នុងការចុះឈ្មោះបោះឆ្នោត សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា អគ្គលេខាធិការនៃរដ្ឋសភា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ នឹងអនុវត្តសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មដោយ គជប និងដែលមានការឯកភាពពីប្រធានរដ្ឋសភា និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

៧.៩.១ ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត និងក្នុងពេលដែល គខ/កប ពុំទាន់ត្រូវបានជ្រើសរើស និងតែងតាំង លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត គឺជាផ្នែករដ្ឋបាលថ្នាក់ក្រោមមួយរបស់ គជប ដែលបំពេញការងារតាមការប្រគល់សិទ្ធិដោយ គជប ។

៧.៩.១.១ មន្ត្រី បុគ្គលិកនៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោតដែលត្រូវបានតែងតាំង ឱ្យបន្តនិរន្តរភាពការងារបោះឆ្នោត ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត មានសិទ្ធិត្រូវទទួលការតែងតាំងថ្មីដោយ គជប សម្រាប់ដំណាក់ការរៀបចំការបោះឆ្នោត ។

៧.៩.១.២ គជប ត្រូវជ្រើសតាំងមន្ត្រីបុគ្គលិក សម្រាប់លេខាធិការដ្ឋានខេត្ត ក្រុង រៀបចំការបោះឆ្នោតមួយចំនួនបន្ថែមទៀតតាមការចាំបាច់តាមសំណូមពរនៃការងារដែលត្រូវបានប្រគល់សិទ្ធិ ។

៧.៩.១.៣ គជប ត្រូវតែងតាំងមន្ត្រីមួយរូបនៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ដែលមានសមត្ថភាពជាប្រធានលេខាធិការដ្ឋានរហូតដល់ពេលដែល គខ/កប ត្រូវបានតែងតាំង ។

៧.៩.២ ក្នុងដំណាក់ការចុះឈ្មោះបោះឆ្នោត អគ្គលេខាធិការនៃរដ្ឋសភា ឬតំណាងដែលត្រូវបាន គជប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត ត្រូវទទួលការណែនាំ និងការសម្របសម្រួលអនុវត្តការងារពី គជប ។

៧.៩.៣ ក្នុងដំណាក់ការចុះឈ្មោះបោះឆ្នោត ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបាន គជប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការចុះឈ្មោះបោះឆ្នោត ត្រូវទទួលការណែនាំ និងការសម្របសម្រួលអនុវត្តការងារពី គជប តាមរយៈលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

**រចនាសម្ព័ន្ធនៃ គខ/កប**

**ប្រការ** ៧.១០ គខ/កប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់ខេត្ត ក្រុងដែលបង្កើតដោយ គជប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំ ចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត ។

៧.១០.១ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គខ/កប ត្រូវមានសមាសភាពប្រាំ( ៥ )នាក់ ។

៧.១០.២ សមាសភាពនៃ គខ/កប ត្រូវបានជ្រើសរើសនិងតែងតាំងដោយ គជប ដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិកដូចចែងក្នុងប្រការ ៧.១៧ និង ៧.១៨ នៃបទបញ្ជានិងនីតិវិធីនេះ ។

៧.១០.៣ គខ/កប ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដែលមានផ្នែកជំនាញចំនួនប្រាំ( ៥ )។

៧.១០.៣.១ ផ្នែកជំនាញទាំងប្រាំ( ៥ )នោះរួមមាន ៖ ផ្នែកប្រតិបត្តិការនិងភស្តុភារ ផ្នែករដ្ឋបាល ផ្នែកហិរញ្ញវត្ថុ ផ្នែកបណ្តុះបណ្តាលនិងព័ត៌មានសាធារណៈ និងផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

៧.១០.៤ ប្រធាន គខ/កប មានភារៈទទួលខុសត្រូវការងាររួម ។ អនុប្រធាន គខ/កប ជាជំនួយឱ្យប្រធាន គខ/កប និងទទួលភារៈជំនួសប្រធាន ពេលប្រធានអវត្តមាន ។ សមាសភាពម្នាក់ៗនៃ គខ/កប ត្រូវបានបែងចែកឱ្យទទួលបន្ទុកផ្នែកជំនាញមួយ( ១ )ក្នុងចំណោមផ្នែកជំនាញទាំងប្រាំ( ៥ ) ។

៧.១០.៤.១ ប្រធាន និងអនុប្រធាន អាចបែងចែកឱ្យទទួលបន្ទុកផ្នែកជំនាញមួយ( ១ )ក្នុងចំណោមផ្នែកជំនាញពីរ( ២ )គឺ ផ្នែកប្រតិបត្តិការនិងភស្តុភារ និងផ្នែកសេវាកម្មច្បាប់និងវិវាទកម្ម ។

៧.១០.៥ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប មិនតម្រូវឱ្យមានរចនាសម្ព័ន្ធនៃ គឃ/សប ទេ ។

**លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គខ/កប**

**ប្រការ៧.១១** លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គខ/កប ត្រូវបានកំណត់ ដូចខាងក្រោម ៖

៧.១១.១ សមាសភាព គខ/កប ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងខេត្ត ក្រុង ។

៧.១១.១.១ ដើម្បីគោរពឯករាជ្យភាព និង អព្យាក្រឹតភាពនៃ គជប សមាជិក គខ/កប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ។

៧.១១.១.២ ក្រុមទាំងអស់ នៃសង្គមកម្ពុជាទាំងមូល ត្រូវបានកំណត់ជា មន្ត្រីរាជការ បំរើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និង សង្គមស៊ីវិល ។

៧.១១.១.៣ សង្គមស៊ីវិលត្រូវបានកំណត់ជាអង្គការនានា មិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរាជរដ្ឋាភិបាលដូចជា សមាគមគណៈមេធាវី អង្គការមិនមែនរដ្ឋាភិបាល សមាគមផ្នែកអប់រំ វប្បធម៌ និង អង្គការ ឬសមាគមមិនគិតផលចំណេញដទៃទៀត ។

៧.១១.១.៤ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺ ប្រជាពលរដ្ឋទូទៅ មន្ត្រីរាជការ និងអ្នកមុខអ្នកការនៅក្នុងខេត្ត ក្រុងដែលមានសិទ្ធិបោះឆ្នោត ។

៧.១១.១.៥ អ្នកដែលពុំមានសិទ្ធិត្រូវបានជ្រើសរើស គឺ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោត ជាសមាជិកព្រឹទ្ធសភា និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

៧.១១.១.៦ សមាសភាព គខ/កប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ ហើយត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ពីប្រជាពលរដ្ឋ ។

៧.១១.១.៧ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ ត្រូវមានស្ត្រីមួយ ( ១ )នាក់ ជាសមាជិកនៃ គខ/កប ។ នៅតំបន់ណាដែល

មានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើទៅបាន សមាជិកមួយ( ១ )នាក់ នៃ គខ/កប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

៧.១១.១.៤ មន្ត្រីបន្តនិរន្តរភាពការងារបោះឆ្នោតនៅតាមខេត្ត ក្រុង អាចត្រូវបានផ្តល់អាទិភាពជាបេក្ខជនសម្រាប់ការជ្រើសរើសនេះ ។

៧.១១.២ សមាជិក និងបុគ្គលិកនៃ គខ/កប ត្រូវបានជ្រើសរើស ដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងប្រការ ៧.១៧ និង ៧.១៨ ខាងក្រោម ។

៧.១១.៣ អនុលោមតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់ គជប សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សមាសភាព គខ/កប នៃខេត្ត ក្រុងនីមួយៗ មានចំនួនប្រាំ ( ៥ )រូប ។

៧.១១.៤ ប្រសិនបើ ពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានតែងតាំងជាសមាជិក គខ/កប ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្តឹងជំទាស់នឹងការតែងតាំងនេះទៅ គជប ។

៧.១១.៤.១ ប្រសិនបើមានការប្តឹងជំទាស់ គជប ត្រូវដោះស្រាយបណ្តឹងនោះដោយអនុលោមទៅតាមបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.១១.៤.២ សេចក្តីសម្រេចរបស់ គជប គឺជាសេចក្តីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវនៃ គខ/កប**

**ប្រការ** ៧.១២ ក្រោមការគ្រប់គ្រង និងការណែនាំនៃ គជប គខ/កប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុងរបស់ខ្លួន ។ គខ/កប ត្រូវ ៖

៧.១២.១ ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងការជ្រើសរើសឆ្នោតជាសម្ងាត់ ។

៧.១២.២ អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារៈបរិក្ខារសម្រាប់ការបោះឆ្នោត និងគោរពប្រតិទិនការងារបោះឆ្នោត ។

៧.១២.៣ គោរព និងអនុវត្តបទបញ្ជា និងនីតិវិធី និងគោលការណ៍ណែនាំរបស់ គជប ។

៧.១២.៤ ចាត់វិធានការពាក់ព័ន្ធទៅនឹងសន្តិសុខនិងសណ្តាប់ធ្នាប់នៅក្នុងដំណើរការបោះឆ្នោត ។

៧.១២.៥ លើកគំរោងជូន គជប អំពីចំនួន និងទីតាំងការិយាល័យបោះឆ្នោត ( ប្រសិនបើ គខ/កប មិនទាន់ត្រូវបានតែងតាំង លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវបំពេញកិច្ចការនេះ ) ។

៧.១២.៦ បែងចែកនិងបញ្ជូនសម្ភារៈឯកសារចុះឈ្មោះបោះឆ្នោត ជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សំរបសំរួលការអនុវត្តការចុះឈ្មោះបោះឆ្នោត និងបញ្ជូនបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃអង្គបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ជូន គជប ។

៧.១២.៧ ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត ។

៧.១២.៨ លើកគំរោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ស្តីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌខេត្ត ក្រុង ដោយយោងតាមការណែនាំរបស់ គជប ។

៧.១២.៩ លើកស្ទួយការយល់ដឹងរបស់អ្នកបោះឆ្នោត អំពីដំណើរការបោះឆ្នោតដោយធ្វើការសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោត នៅក្នុងក្របខ័ណ្ឌខេត្ត ក្រុង ដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលនានា ។

៧.១២.១០ ត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមខេត្ត ក្រុង ។

៧.១២.១១ ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យស្មើភាពគ្នា ក្នុងការប្រើប្រាស់អាគារសាធារណៈដល់គណបក្សនយោបាយទាំងអស់ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

៧.១២.១២ ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន ។

៧.១២.១៣ លើកសំណើសុំ គជប តែងតាំងសមាសភាព គកប ក្នុងខេត្ត ក្រុង ។ ធ្វើតារាងប្រាក់កំរៃសំរាប់សមាជិកនិងមន្ត្រីនៃ គខ/កប និងសមាសភាព គកប តាមការណែនាំរបស់ គជប ។

៧.១២.១៤ សំរេចនិងផ្តល់ប័ណ្ណសម្គាល់ជូនតំណាងគណបក្សនយោបាយ ។

៧.១២.១៥ ផ្តល់ប័ណ្ណសម្គាល់ជូនអ្នកសង្កេតការណ៍ជាតិ ។

៧.១២.១៦ តាមដានការងារគ្រប់គ្រង និងចាត់ចែងរបស់ គកប ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧.១២.១៧ បែងចែកនិងប្រគល់បញ្ជីបោះឆ្នោតផ្លូវការ និងសម្ភារៈឯកសារបោះឆ្នោត ជូន គកប ។

៧.១២.១៨ ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមការិយាល័យបោះឆ្នោតដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុងរបស់ខ្លួន និងបិទផ្សាយលទ្ធផលនៃការបោះឆ្នោតនៅក្នុងខេត្ត ក្រុងនោះ ។

៧.១២.១៩ រៀបចំរវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង ព្រមទាំងសម្ភារៈ និងឯកសារបោះឆ្នោតពាក់ព័ន្ធជូនទៅ គជប ។

៧.១២.២០ ទទួលពាក្យបណ្តឹងតវ៉ា ឬជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬជំទាស់ ។

៧.១២.២១ ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចដែលបានណែនាំដោយ គជប ។

៧.១២.២២ ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ។

៧.១២.២៣ សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងខេត្ត ក្រុង ។

៧.១២.២៤ ជូនយោបល់ដល់ គជប អំពីបរិយាកាសក្នុងខេត្ត ក្រុង ដើម្បីចាត់វិធានការនានា ធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅ ដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព ។

៧.១២.២៥ វាយតម្លៃសមាជិកទាំងឡាយនៃ គកប ។

៧.១២.២៦ អនុវត្តការងារដទៃទៀត ដែលច្បាប់បោះឆ្នោតអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

៧.១២.២៧ អនុវត្តការងារដទៃទៀត ឬអនុវត្តសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គជប ។

**រចនាសម្ព័ន្ធនៃគណៈកម្មការការិយាល័យបោះឆ្នោត (គកប)**

**ប្រការ** ៧.១៣ គកប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោត និងទទួលខុសត្រូវ ក្នុងការរាប់សន្លឹកឆ្នោតដោយផ្ទាល់នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលតែងតាំងដោយ គជប តាមសំណើរបស់ គខ/កប ។

៧.១៣.១ គកប ត្រូវមានសមាសភាពប្រាំ( ៥ )នាក់ ដែល រួមមានប្រធានមួយ( ១ )នាក់ អនុប្រធានមួយ( ១ )នាក់ លេខាធិការមួយ ( ១ )នាក់ ជំនួយការមួយ( ១ )នាក់ និងសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់មួយ( ១ )នាក់ ។

៧.១៣.១.១ ប្រធាន មានភារៈទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៧.១៣.១.២ អនុប្រធាន មានភារៈជាជំនួយរបស់ប្រធាន និងទទួលខុសត្រូវក្នុងការផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនៅពេលបោះឆ្នោត និងក្នុងការកត់ត្រាសម្លេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

៧.១៣.១.៣ លេខាធិការមានភារៈទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៣.១.៤ ជំនួយការ មានភារៈទទួលខុសត្រូវពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបលាងមិនជ្រះ និងទទួលគូសសម្លេងឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

៧.១៣.១.៥ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ មានភារៈទទួលខុសត្រូវការងារសណ្តាប់ធ្នាប់ របៀបរៀបរយ និងថែរក្សាសំភារៈឯកសារបោះឆ្នោត នៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

៧.១៣.២ គកប ត្រូវទទួលខុសត្រូវចំពោះមុខ គខ/កប ។

៧.១៣.៣ គកប ទទួលសេចក្តីណែនាំពី គជប តាមរយៈ គខ/កប ។

**លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប**

**ប្រការ៧.១៤** សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប មិនចាំបាច់ជ្រើសរើស និងតែងតាំង គឃ/សប នៅតាមឃុំ សង្កាត់ចំណុះ គខ/កប ទេ ។

**ប្រការ៧.១៥** លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស សមាសភាព គកប ត្រូវបានកំណត់ ដូចខាងក្រោម ៖

៧.១៥.១ សមាសភាព គកប ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋទូទៅដែលមានសិទ្ធិបោះឆ្នោត និងរស់នៅក្នុងខេត្ត ក្រុង ។

៧.១៥.២ ដើម្បីគោរពឯករាជ្យភាព និងអព្យាក្រឹតភាពនៃ គជប សមាសភាព គកប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ដែលត្រូវបានកំណត់ជាមន្ត្រីរាជការបំរើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និងសង្គមស៊ីវិល ។

៧.១៥.៣ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកមុខអ្នកការដែលមានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងខេត្ត ក្រុង ។

៧.១៥.៤ អ្នកដែលពុំមានសិទ្ធិត្រូវបានជ្រើសរើស គឺ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ ព្រះសង្ឃ បព្វជិតសាសនា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មេភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោត ជាសមាជិកព្រឹទ្ធសភា និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

៧.១៥.៥ សមាសភាព គកប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់និងសុចរិតទៀងត្រង់ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយប្រជាពលរដ្ឋ ។

៧.១៥.៦ ប្រសិនបើអាចធ្វើបាន ប្រធាន និងអនុប្រធានត្រូវជ្រើសរើសក្នុងចំណោមជនចូលនិវត្តន៍ ដែលមានគតិបណ្ឌិត មានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងខេត្ត ក្រុង ។

៧.១៥.៧ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ( ១ )នាក់ ជាសមាជិកនៃ គកប ។ នៅតំបន់ណាដែលមានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើបាន សមាជិកមួយ( ១ )នាក់នៃ គកប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

៧.១៥.៨ សមាសភាព គកប ត្រូវតែជ្រើសរើស ដោយផ្អែកតាមប្រព័ន្ធជ្រើសរើស និង គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងប្រការ ៧.១៧ និង ៧.១៨ ខាងក្រោម ។

៧.១៥.៩ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សមាសភាព គកប នីមួយៗ ត្រូវមានចំនួនប្រាំ( ៥ )រូប ។

៧.១៥.១០ ប្រសិនបើ ពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានជ្រើសតាំងក្នុងសមាសភាព គកប ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្ដឹងជំទាស់នឹងការតែងតាំងនេះទៅ គជប ។

៧.១៥.១០.១ ប្រសិនបើមានការប្ដឹង គជប ត្រូវដោះស្រាយបណ្ដឹងនោះដោយអនុលោមតាមបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.១៥.១០.២ សេចក្ដីសម្រេចរបស់ គជប គឺជាសេចក្ដីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប**

**ប្រការ** ៧.១៦ គកប នីមួយៗ មានភារកិច្ចគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធ តាមការណែនាំរបស់ គជប និង គខ/កប ។

៧.១៦.១ ប្រធាន គកប ត្រូវទទួលខុសត្រូវ និងមានភារកិច្ចចាត់តាំងគ្រប់គ្រង នូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ដែលគាត់ត្រូវបានតែងតាំង ហើយត្រូវ ៖

៧.១៦.១.១ ចូលរួមវគ្គបណ្ដុះបណ្ដាលនិងម្ចាស់ការអនុវត្តរាល់នីតិវិធីក្នុងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៦.១.២ ទទួល និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារៈឯកសារបោះឆ្នោត សម្រាប់បំរើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៦.១.៣ ត្រួតពិនិត្យរាល់សម្ភារៈឯកសារបោះឆ្នោត សម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៦.១.៤ បោះទីតាំង បំពាក់គ្រឿងសង្ហារិមនិងធ្វើគំរូប្លង់ការិយាល័យបោះឆ្នោត។

៧.១៦.១.៥ ត្រួតពិនិត្យការបំពេញការងារនៃសមាជិក គកប នៅថ្ងៃបោះឆ្នោត ។

៧.១៦.១.៦ ដាក់ជំនួសតំណែងសមាជិក គកប ដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ។

៧.១៦.១.៧ ចាត់តាំង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។

៧.១៦.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ ។

៧.១៦.១.៩ ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់តំណាងគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ដែល ត្រូវចូលរួមសង្កេតការណ៍ក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧.១៦.១.១០ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោត ដល់អ្នកដែលមានវត្តមាននៅក្នុង ការិយាល័យបោះឆ្នោត ។

៧.១៦.១.១១ បើកនិងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ។

៧.១៦.១.១២ ធានារបៀបរៀបរយក្នុងនិងក្រៅបរិវេណការិយាល័យបោះឆ្នោត ។

៧.១៦.១.១៣ ចាក់សោឃ្លុំការពារហិបឆ្នោត ។

៧.១៦.១.១៤ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានណែនាំឱ្យចេះអំពី របៀបបោះឆ្នោត ។

៧.១៦.១.១៥ ធានាឱ្យប្រាកដថា ទឹកខ្មៅលុបលាងមិនជ្រះ ត្រូវតែបានអនុវត្តតាម ការណែនាំ ។

៧.១៦.១.១៦ ត្រួតពិនិត្យសមាជិក គកប ក្នុងអាណត្តិការងាររបស់ខ្លួន ។

៧.១៦.១.១៧ ធានាឱ្យប្រាកដថា ការលើកយោបល់ជំទាស់ និងការប្តឹងតវ៉ាឬប្តឹង ជំទាស់ក្នុងការិយាល័យបោះឆ្នោត ត្រូវបានដោះស្រាយភ្លាម ដោយ អនុវត្តស្របតាមបទបញ្ញានិងនីតិវិធី និងការណែនាំរបស់ គជប ។

៧.១៦.១.១៨ ជួយអ្នកបោះឆ្នោតជាជនពិការ ប្រសិនបើមាន និងប្រសិនបើ គាត់ ស្នើសុំឱ្យជួយគាត់ក្នុងការបោះឆ្នោត ។

៧.១៦.១.១៩ ធានាឱ្យប្រាកដថា សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ត្រូវបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងម៉ត់ចត់ និងត្រឹមត្រូវ ហើយកំណត់ ហេតុនៃការបោះឆ្នោត ត្រូវបានបំពេញ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ។

៧.១៦.១.២០ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយា ល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំរបស់ គខ/កប ។ ត្រួត ពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោ បាយដែលបានទទួលសម្លេងឆ្នោត ។

៧.១៦.១.២១ ធានាឱ្យប្រាកដថា កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ត្រូវបានបំពេញ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ហើយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតមួយ ( ១ )ច្បាប់ ត្រូវបានបិទផ្សាយ នៅមុខទីតាំងការិយាល័យបោះឆ្នោត ។

៧.១៦.១.២២ ប្រគល់ជូន គខ/កប នូវកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ហិបឆ្នោត និងរាល់សម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ។

៧.១៦.១.២៣ បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលំអៀង ។

៧.១៦.២ អនុប្រធាន គកប ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែកដូចខាងក្រោម ៖

៧.១៦.២.១ ចូលរួមវគ្គបណ្ដុះបណ្ដាលនិងម្ចាស់ការអនុវត្តរាល់នីតិវិធីក្នុងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៦.២.២ ជំនួសតំណែងប្រធាន ប្រសិនបើ ប្រធានមិនអាចមកបំពេញការងារដែលគាត់ទទួលខុសត្រូវ ។

៧.១៦.២.៣ ហែកសន្លឹកឆ្នោតផ្ដាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បត់ជាផ្នត់តាមការណែនាំនិងបោះត្រាសម្ងាត់លើផ្នែកខាងខ្នង រួចប្រគល់ជូនអ្នកបោះឆ្នោត ។

៧.១៦.២.៤ ផ្ដល់ការណែនាំស្ដីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត ។

៧.១៦.២.៥ ជួយប្រធានក្នុងការពិនិត្យផ្ទៀងផ្ទាត់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតរបស់ខ្លួន ។

៧.១៦.២.៦ ជួយប្រធានក្នុងការចាត់ចែង និងការត្រួតពិនិត្យកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំរបស់ គខ/កប ។ កត់ត្រាសម្លេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ ទទួលបានលើតារាងកត់ត្រាសម្លេងឆ្នោត ។

៧.១៦.២.៧ អមដំណើរប្រធាន ក្នុងការប្រគល់កំណត់ហេតុ នៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ហិបឆ្នោត និងរាល់សម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ជូន គខ/កប ។

៧.១៦.២.៨ បំពេញរាល់ភារកិច្ចដែល គខ/កប និងប្រធាន គកប តម្រូវ ។

៧.១៦.៣ លេខាធិការនៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៧.១៦.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលនិងម្ចាស់ការអនុវត្តរាល់នីតិវិធីក្នុងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.១៦.៣.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈឯកសារបោះឆ្នោត ។

៧.១៦.៣.៣ ជួយប្រធានក្នុងការលើកគំរូប្លង់និងរៀបចំការិយាល័យបោះឆ្នោត ។

៧.១៦.៣.៤ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបលាងមិនជ្រះ នៅលើម្រាមដៃអ្នកបោះឆ្នោត ជាពិសេសនៅគល់ក្រចក ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត នៅមុនពេលពិនិត្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

៧.១៦.៣.៥ ត្រួតពិនិត្យភាពត្រូវគ្នារវាងទិន្នន័យ ក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត ។

៧.១៦.៣.៦ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធាន គកប ចុះហត្ថលេខា បន្ទាប់មក ដាក់ជូនតំណាងគណបក្សនយោបាយចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

៧.១៦.៣.៧ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬជំទាស់ ឬករណីប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ ។

៧.១៦.៣.៨ ចូលរួមអនុវត្តក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំរបស់ គខ/កប ។ កត់ត្រាសម្លេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសម្លេងឆ្នោត ។ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដាក់ជូនប្រធាន គកប ចុះហត្ថលេខា បន្ទាប់មក ដាក់ជូនតំណាងគណបក្សនយោបាយ ចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

៧.១៦.៣.៩ បំពេញរាល់ភារកិច្ចដែល គខ/កប និងប្រធាន គកប តម្រូវ ។

៧.១៦.៤ ជំនួយការនៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកត្រួតពិនិត្យការស៊កបញ្ចូលសន្លឹកឆ្នោតនៃអ្នកបោះឆ្នោត ទៅក្នុងហិបឆ្នោត ព្រមទាំងត្រួតពិនិត្យ និងជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតហើយទៅក្នុងទឹកខ្មៅលុបលាងមិនជ្រះ ដល់គល់ក្រចក ហើយត្រូវ ៖

៧.១៦.៤.១ ចូលរួមវគ្គបណ្ដុះបណ្ដាល ។

៧.១៦.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈឯកសារបោះឆ្នោត ។

៧.១៦.៤.៣ ជួយប្រធានក្នុងការលើកគំរូប្លង់និងរៀបចំការិយាល័យបោះឆ្នោត ។

៧.១៦.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងអំឡុងពេលនៃការបោះឆ្នោត ។

៧.១៦.៤.៥ ត្រួតពិនិត្យនិងជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោតម្នាក់ៗ ដែលបានបោះឆ្នោតរួចហើយទៅក្នុងទឹកខ្មៅលុបលាងមិនជ្រះ ដល់គល់ក្រចក និងណែនាំគាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

៧.១៦.៤.៦ ចូលរួមអនុវត្តក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំរបស់ គឃ/កប ។ នៅពេលរាប់សន្លឹកឆ្នោត មានភារកិច្ចគូសសម្លេងឆ្នោតនៅលើផ្ទាំងក្រដាសធំ ឬក្ដារខៀន ។

៧.១៦.៤.៧ បំពេញរាល់ភារកិច្ចដែល គឃ/កប និងប្រធាន គកប តម្រូវ ។

៧.១៦.៥ សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានហើយត្រូវ ៖

៧.១៦.៥.១ ចូលរួមវគ្គបណ្ដុះបណ្ដាល ។

៧.១៦.៥.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈឯកសារបោះឆ្នោត ។

៧.១៦.៥.៣ ជួយប្រធានក្នុងការលើកគំរូប្លង់និងរៀបចំការិយាល័យបោះឆ្នោត ។

៧.១៦.៥.៤ ត្រួតពិនិត្យរាល់ឯកសារបញ្ជាក់អត្តសញ្ញាណ របស់អ្នកបោះឆ្នោតដែលនឹងប្រើប្រាស់សម្រាប់បោះឆ្នោត និងសួរគាត់ដើម្បីផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត រួចណែនាំគាត់ឱ្យឈរបន្តកន្ទុយគ្នា ប្រសិនបើ គាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ ។

៧.១៦.៥.៥ ផ្ដល់អាទិភាពក្នុងការបោះឆ្នោតដល់អ្នកបោះឆ្នោត ជាមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ជនពិការ និងអ្នកមានជម្ងឺ ។

៧.១៦.៥.៦ ត្រួតពិនិត្យច្រកផ្លូវចូល នៃការិយាល័យបោះឆ្នោត ហៅអ្នកបោះឆ្នោតឱ្យចូលបោះឆ្នោត និងត្រួតពិនិត្យស្នាមទឹកខ្មៅលុបលាងមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ជាពិសេសនៅគល់ក្រចក ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយឬមិនទាន់បានបោះឆ្នោត ។

៧.១៦.៥.៧ ចាត់ចែង និងថែរក្សារបៀបរៀបរយ ក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការរំខានជូនប្រធាន គកប ។

៧.១៦.៥.៨ ប្រមូលឯកសារបញ្ជាក់អត្តសញ្ញាណពីអ្នកបោះឆ្នោត ដែលឈរជាជួរ នៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោត ។

៧.១៦.៥.៩ ការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់ ។

៧.១៦.៥.១០ ចូលរួមអនុវត្តក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំរបស់ គឃ/កប ។ ទទួលបន្ទុកការពារសន្តិសុខនិងសណ្តាប់ធ្នាប់ នៅច្រកផ្លូវចូល និងខាងក្នុងការិយាល័យបោះឆ្នោត និងជួយប្រធាន គកប ក្នុងការថែរក្សាសម្ភារៈឯកសារបោះឆ្នោត ក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោត ។

៧.១៦.៥.១១ បំពេញរាល់ភារកិច្ចដែល គឃ/កប និងប្រធាន គកប តម្រូវ ។

## ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គជប សមាជិកនិងបុគ្គលិកនៃ គឃ/កប និងសមាសភាព គកប

**ប្រការ ៧.១៧** ប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គជប សមាជិកនិងបុគ្គលិកនៃ គឃ/កប និងសមាសភាព គកប ត្រូវឈរលើគោលការណ៍ស្មើភាពគ្នា សមត្ថភាព និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុងប្រការ ១៩ ដល់ ប្រការ ២៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ គជប ។

៧.១៧.១ លក្ខខណ្ឌការងារត្រូវបានកំណត់ក្នុងជំពូកទី៧ នៃបទបញ្ជាផ្ទៃក្នុងរបស់ គជប ។

៧.១៧.២ សេចក្តីពណ៌នាអំពីការទទួលខុសត្រូវភារកិច្ច និងលក្ខណសម្បត្តិតម្រូវសម្រាប់បុគ្គលិកនៃ គជប សមាជិកនិងបុគ្គលិកនៃ គឃ/កប និងសមាសភាព គកប ត្រូវបានចែងលំអិតក្នុងជំពូកទី១ ទី៣ និងទី៥ នៃបទបញ្ជាផ្ទៃក្នុងរបស់ គជប ។

៧.១៧.៣ គ្រប់តួនាទីត្រូវតែបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេលប្រាំ( ៥ )ថ្ងៃ តាមប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋ ឬ/និងឯកជន និងបិទផ្សាយនៅទីសាធារណៈ ឬទីប្រជុំជននៃឃុំ សង្កាត់ក្នុងខេត្ត ក្រុង ឬ/និងក្នុងទីប្រជុំជននៃខេត្ត ក្រុង ។

៧.១៧.៣.១ ដំណឹងផ្សព្វផ្សាយការងារ ត្រូវលើកឡើងអំពីតួនាទី សេចក្តីពណ៌នាអំពីការទទួលខុសត្រូវ ភារកិច្ច លក្ខណសម្បត្តិនិងលក្ខណៈវិនិច្ឆ័យ ។ ដំណឹងនេះក៏ត្រូវជម្រាបសាធារណជនផងដែរនូវទីកន្លែង និងពេលវេលាចែកពាក្យសុំចូលបំរើការងារ ព្រមទាំងពេលវេលា ទីកន្លែង និងកាលបរិច្ឆេទចុងក្រោយនៃការទទួលពាក្យសុំ ។

៧.១៧.៣.២ សម្រាប់ការជ្រើសរើសសមាជិកនិងបុគ្គលិកនៃ គខ/កប ពាក្យសុំត្រូវបានរៀបចំនិងផ្តល់ដោយ គជប ។ សម្រាប់ការជ្រើសរើសសមាសភាពនៃ គកប ពាក្យសុំត្រូវផ្តល់ដោយ គខ/កប ។ ពាក្យសុំចូលបំរើការងារត្រូវផ្តល់ជូនអ្នកសុំ ដោយឥតគិតថ្លៃ ។

៧.១៧.៣.៣ នៅពេលឈប់ទទួលពាក្យសុំបំរើការងារ គណៈកម្មការជ្រើសរើសបុគ្គលិក ត្រូវជ្រើសរើសសំរាំងពាក្យសុំចូលបំរើការងារដើម្បីកំណត់ថា តើពាក្យសុំមួយណា ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌបច្ចេកទេស ។

៧.១៧.៣.៤ លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាពនៃ គខ/កប និងសមាសភាពនៃ គកប រួមមាន ៖

- មានសិទ្ធិបោះឆ្នោត
- មានឆន្ទៈបំរើការងារក្នុងគោលជំហរអព្យាក្រឹត និងមិនលំអៀង
- មានសុឆន្ទៈលាឈប់ ឬមានច្បាប់អនុញ្ញាតឈប់ពីការងារក្នុងតំណែងចាស់ ក្នុងរយៈពេលនៃអាណត្តិការងារ
- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការ ក្នុងក្របខ័ណ្ឌការងារ ( ចៅក្រមព្រះរាជអាជ្ញា និងក្រឡាបញ្ជី )
- មិនមែនជាព្រះសង្ឃ បព្វជិតសាសនា
- មិនមែនជាប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងខេត្ត ក្រុង ស្រុក ខ័ណ្ឌ មេឃុំ ចៅសង្កាត់ឬជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោតសមាជិកព្រឹទ្ធសភា និងសមាជិកគណៈកម្មាធិការនាយក នៃគណបក្សនយោបាយ
- មកពីជនជាតិភាគតិច ប្រសិនបើមាន
- មានលទ្ធភាពចូលរួម ក្នុងការបណ្តុះបណ្តាល និងការបំពេញការងារពេញម៉ោង និងពេញអាណត្តិការងារ ។
- មានសុខភាពល្អ
- មានកិត្តិស័ព្ទជាអ្នកមានកិរិយាមារយាទល្អ ស្មោះត្រង់ សុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.១៧.៣.៥ លក្ខខណ្ឌបច្ចេកទេសដោយឡែកដែលទាមទារសំរាប់ការបំពេញការងារជាក់លាក់មួយ រួមមានលក្ខខណ្ឌ ៖

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរ
- ប្រសិនបើអាចធ្វើបាន ប្រធាន គខ/កប ឬប្រធាន គកប ត្រូវជាអ្នកចូលនិវត្តន៍ ដែលមានគតិបណ្ឌិត
- មានចំណេះដឹង ឬបទពិសោធន៍ប្រហាក់ប្រហែល ដែលទាក់ទងជាមួយនឹងតួនាទី
- សម្រាប់តួនាទីមួយចំនួន ទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ស្ម័គ្រចិត្តធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងខេត្ត ក្រុង ឬក្នុងឃុំ សង្កាត់ ។

៧.១៧.៣.៦ ពាក្យសុំណា ដែលឆ្លើយតបនឹងលក្ខខណ្ឌបច្ចេកទេស ត្រូវធ្វើការសំរាំងជាលើកទីពីរ ដើម្បីជ្រើសរើសយកបេក្ខជនល្អ ។

៧.១៧.៣.៧ បេក្ខជនល្អចំនួនបី( ៣ )នាក់សម្រាប់មុខតំណែងនីមួយៗ ត្រូវបានអញ្ជើញមកធ្វើសម្ភាសន៍ ពេលនោះ ចំណេះដឹង លក្ខណសម្បត្តិ និងសមត្ថភាពក្នុងការបំពេញការងាររបស់បេក្ខជន នឹងត្រូវបានសាកល្បង និងត្រួតពិនិត្យ ។

៧.១៧.៣.៨ ការសម្ភាសន៍ត្រូវបានផ្តល់ពិន្ទុ ៖

- **A** : សម្រាប់បេក្ខជនដែលឆ្លើយបានល្អត្រឹមត្រូវជាងគេ
- **B** : សម្រាប់បេក្ខជនដែលឆ្លើយបានល្អត្រឹមត្រូវបន្ទាប់
- **C** : សម្រាប់បេក្ខជនដែលលទ្ធផលចម្លើយបានទាបជាងគេ

ចំពោះអ្នកដែលមានសមត្ថភាពស្មើគ្នា ជម្រើសដែលប្រសើរ គឺត្រូវផ្តល់ជូនបេក្ខជនណាដែលមានបទពិសោធន៍ខាងការងារបោះឆ្នោតពីមុន ។

៧.១៧.៣.៩ បេក្ខជនល្អបី( ៣ )នាក់ និងលទ្ធផលនៃការសម្ភាសន៍ សម្រាប់មុខតំណែងនីមួយៗត្រូវបានលើកយោបល់ជូន គជប តាមរយៈអគ្គលេខាធិការ ។ គជប ត្រូវជ្រើសរើសយកមួយ( ១ )នាក់ ដើម្បីឱ្យបំពេញកិច្ចសន្យាការងារ ។

៧.១៧.៣.១០ រាល់ឯកសាររបស់អ្នកសុំបំរើការងារ ត្រូវបានចាត់ទុកជាការសម្ងាត់ ហើយត្រូវតម្កល់ទុកជាឯកសារ ។

៧.១៧.៣.១១ បេក្ខជនដែលត្រូវបានជ្រើសរើស ត្រូវតែទទួលបាននូវការជូនដំណឹង និងការផ្តល់កិច្ចសន្យាការងារ តាមការកំណត់របស់ គជប ។

៧.១៧.៣.១២ សមាសភាព គខ/កប និងសមាសភាព គកប ដែលបានតែងតាំងទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចាប់ផ្តើមបំពេញការងារ ។

## ការតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក

**ប្រការ** ៧.១៨ ដើម្បីអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិកនៃ គជប សមាជិកនិងបុគ្គលិកនៃ គខ/កប និងសមាសភាព គកប តាមការកំណត់ គជប ត្រូវបង្កើតឱ្យមានគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិកនៅតាមថ្នាក់នីមួយៗ ។

៧.១៨.១ គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដែលមានសមាជិកយ៉ាងតិចបី( ៣ )នាក់ ត្រូវបានតែងតាំងដោយ គជប ដើម្បីជ្រើសរើសមន្ត្រីបុគ្គលិកនៃ គជប ឬជ្រើសរើសសមាជិកនិងបុគ្គលិកនៃ គខ/កប ។

៧.១៨.១.១ គជប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដោយឡែកពីគ្នា ដើម្បីជ្រើសរើសមន្ត្រី បុគ្គលិកនៃ គជប ឬ ដើម្បីជ្រើសរើសសមាជិកនិងបុគ្គលិកនៃ គខ/កប ។

៧.១៨.១.២ គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិកនីមួយៗ រួមមានសមាសភាព អគ្គលេខាធិការ ឬតំណាង ប្រធាន ឬ អនុប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានការិយាល័យបុគ្គលិក ប្រធានឬអនុប្រធាននាយកដ្ឋាន និងប្រធាន ឬអនុប្រធានការិយាល័យ ។

៧.១៨.១.៣ ក្នុងការជ្រើសរើសមន្ត្រីបុគ្គលិកសម្រាប់នាយកដ្ឋានជំនាញនៅ គជប គណៈកម្មការនេះត្រូវមានបន្ថែមសមាសភាពប្រធាន ឬអនុប្រធាននាយកដ្ឋានពាក់ព័ន្ធ ។

៧.១៨.២ គណៈកម្មការជ្រើសរើសដែលមានសមាសភាពយ៉ាងតិចបី( ៣ )នាក់នៅ គខ/កប ត្រូវបានតែងតាំងដោយ គខ/កប ដើម្បីជ្រើសរើសសមាសភាព គកប ក្នុងខេត្តក្រុង ។

៧.១៨.៣ ករណីចាំបាច់ ប្រធានគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក អាចចាត់តាំងអនុគណៈកម្មការមួយក្នុងចំណោមសមាជិក ដែលមានឈ្មោះក្នុងគណៈកម្មការជ្រើសរើស ដើម្បីពិនិត្យជំរុះលើកទី ១ នូវបេក្ខជន ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌជ្រើសរើស ។

៧.១៨.៤ សមាជិកនៃគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ត្រូវបំពេញការងារ ក្នុងជំហរអព្យាក្រឹត យុត្តិធម៌ និងមិនលំអៀង ។

៧.១៨.៥ ប្រសិនបើ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា សមាជិកណាម្នាក់នៃគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក បានល្មើសនឹងនីតិវិធីនៃការជ្រើសរើសមន្ត្រីបុគ្គលិករបស់ គជប នោះ យោងតាមកំរិតធ្ងន់ឬស្រាល អ្នកនោះនឹងត្រូវទទួលពិន័យពី គជប ។ រូបភាពពិន័យ រួមមានចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

## ការលើកសំណើសុំតែងតាំងសមាសភាព គកប

**ប្រការ៧.១៩** គខ/កប ត្រូវធានាថា គណៈកម្មការជ្រើសរើសបានអនុវត្តយ៉ាងត្រឹមត្រូវ តាមនីតិវិធីនៃប្រព័ន្ធជ្រើសរើសមន្ត្រីបុគ្គលិករបស់ គជប ហើយបេក្ខជនដែលគណៈកម្មការជ្រើសរើសបានសំរេចជ្រើសយកសំរាប់មុខតំណែងក្នុងសមាសភាព គកប ត្រូវបានលើកស្នើសុំ គជប តែងតាំងជាផ្លូវការ ។ គខ/កប ត្រូវគ្រប់គ្រងនិងណែនាំ គកប ទាំងអស់ក្នុងខេត្ត ក្រុង និងត្រូវចាត់ចែងវាយតម្លៃសមាសភាព គកប ម្នាក់ៗ នៅពេលដែល គកប បានបញ្ចប់ការងាររបស់ខ្លួន ។

៧.១៩.១ គខ/កប ត្រូវធានាថា បេក្ខជនដែលត្រូវបានជ្រើសរើស និងស្នើសុំតែងតាំងក្នុងសមាសភាព គកប បាន ៖

៧.១៩.១.១ ឆ្លងកាត់ដោយជោគជ័យនូវការធ្វើតេស្ត ដែលគ្រប់គ្រងពិនិត្យដោយគណៈកម្មការជ្រើសរើសនៃ គខ/កប ។

៧.១៩.១.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាមច្បាប់ ព្រមទាំងបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.១៩.១.៣ យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀង ។

៧.១៩.១.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កំរៃ ។

៧.១៩.១.៥ មានលក្ខណៈវិនិច្ឆ័យស្របតាមតម្រូវការ ដែលបានចែងក្នុងប្រការ ៧.១៥ នៃបទបញ្ជានិងនីតិវិធីនេះ ។

៧.១៩.១.៦ ទទួលការបណ្តុះបណ្តាល ។

៧.១៩.១.៧ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបំរើការងារ ក្នុងសមាសភាព គកប ។

៧.១៩.២ គខ/កប ត្រូវធានាថា បេក្ខជនដែលត្រូវបានជ្រើសរើស និងស្នើសុំតែងតាំងក្នុងសមាសភាព គកប គឺជាបេក្ខជនដែលបានទទួលជោគជ័យក្នុងការធ្វើតេស្ត និង

បានចុះហត្ថលេខាលើកិច្ចសន្យាបំរើការងារ ( ទម្រង់បែបបទលេខ ១០០២ ) នៅក្រោយពេលបានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង ។ ក្នុងការជ្រើសរើសនេះ គប្បីយកចិត្តទុកដាក់ចំពោះបេក្ខជន ដែលមានបទពិសោធន៍លើការងារបោះឆ្នោត ។

៧.១៩.២.១ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្តុះបណ្តាល ត្រូវដាក់ជំនួសជាបន្ទាន់ ដោយអ្នកបំរុង ។

៧.១៩.២.២ ប្រសិនបើ គ្មានបេក្ខជនបំរុងសម្រាប់ជំនួស គខ/កប ត្រូវចាត់ចែងជ្រើសរើសអ្នកជំនួសជាបន្ទាន់ ។

៧.១៩.៣ ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យារវាង គជប និងសមាសភាព គកប ត្រូវមានបញ្ជាក់ខ្លឹមសារដូចខាងក្រោម ៖

៧.១៩.៣.១ នាមត្រកូលនិងនាមខ្លួន លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំអាងបញ្ជាក់ភាពមានសិទ្ធិបោះឆ្នោត និងអាសយដ្ឋាននៃអ្នកដែលត្រូវតែងតាំង ។

៧.១៩.៣.២ មុខតំណែងក្នុង គកប នៃអ្នកដែលត្រូវតែងតាំង ។

៧.១៩.៣.៣ ឈ្មោះខេត្ត ក្រុង ព្រមទាំងឈ្មោះទីតាំងនិងលេខកូដការិយាល័យបោះឆ្នោត ដែលបេក្ខជននោះត្រូវបានតែងតាំង ។

៧.១៩.៣.៤ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវនៃអ្នកដែលត្រូវតែងតាំង ។

៧.១៩.៣.៥ ប្រាក់កំរៃដែលត្រូវទទួល ។

៧.១៩.៣.៦ ការសន្យាយល់ព្រមទទួលយកភារកិច្ច លក្ខខណ្ឌការងារ និងប្រាក់កំរៃ ។

៧.១៩.៣.៧ ការសន្យាថា នឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលំអៀង ។

៧.១៩.៣.៨ ការសន្យាថា នឹងអនុវត្តតាមច្បាប់ បទបញ្ជា និងនីតិវិធី និងរាល់សេចក្តីណែនាំរបស់ គជប ។

៧.១៩.៣.៩ ការសន្យាថា នឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត ។

៧.១៩.៣.១០ ហត្ថលេខារបស់អ្នកដែលត្រូវតែងតាំង ព្រមទាំងហត្ថលេខារបស់ប្រធាននៃ គខ/កប ។

៧.១៩.៤ គខ/កប ត្រូវលើកសំណើសុំតែងតាំងសមាសភាព គកប ទាំងអស់ក្នុងខេត្ត ក្រុង របស់ខ្លួន ដោយភ្ជាប់ជាមួយនូវ បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំង និងកិច្ចសន្យារវាង គជប និងសមាសភាព គកប ( ទម្រង់បែបបទលេខ ១០០២ ) ដែលបានបំពេញនិងចុះហត្ថលេខារួចម្នាក់ៗមួយ( ១ )ច្បាប់ ដើម្បីជូន គជប ពិនិត្យសម្រេចនិងតែងតាំងជាផ្លូវការ ។

៧.១៩.៤.១ នៅពេលទទួលបានសំណើតែងតាំងដូចចែងក្នុងចំណុច ៧.១៩.៤ ខាងលើ គជប ត្រូវពិនិត្យ និងចេញសេចក្តីសម្រេចតែងតាំងសមាសភាព គកប ជាបន្ទាន់ ហើយត្រូវរក្សាទុកបញ្ជីឈ្មោះ និងកិច្ចសន្យាបំរើការងារទាំងនោះជាឯកសារ ។

៧.១៩.៤.២ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ គជប ភ្លាម គខ/កប ត្រូវបំពេញនិងផ្តល់ប័ណ្ណសម្គាល់ខ្លួនសម្រាប់សមាសភាព គកប ម្នាក់ៗ សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។

៧.១៩.៥ សមាសភាព គកប ត្រូវចូលរួមក្នុងការបណ្តុះបណ្តាល ការទទួល និងការត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោត ការរៀបចំការិយាល័យបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ព្រមទាំងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ហិបឆ្នោត និងសម្ភារៈឯកសារបោះឆ្នោតជូន គខ/កប ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាសភាព គកប ម្នាក់ៗនឹងទទួលបានប្រាក់កំរៃជាប្រាក់រៀលសម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារនិងថ្លៃធ្វើដំណើរផង ។

៧.១៩.៥.១ ទឹកប្រាក់ ដែលត្រូវផ្តល់ជាកំរៃជូនសមាសភាព គកប ត្រូវបានកំណត់សម្រាប់ការបំពេញការងាររយៈពេលបី( ៣ )ថ្ងៃ ។

៧.១៩.៥.២ ក្នុងករណី សមាសភាព គកប ណាមួយ ដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ ដូចចែងក្នុងប្រការ ៧.២២ ខាងក្រោម មន្ត្រីទាំងនោះនឹងត្រូវទទួលបានប្រាក់កំរៃបន្ថែមតាមសេចក្តីសម្រេចរបស់ គជប ។

៧.១៩.៦ គខ/កប ត្រូវអនុវត្តការវាយតម្លៃសមាសភាពម្នាក់ៗនៃ គកប ទាំងអស់ក្រោមឱវាទ ក្នុងរយៈពេលពីរ( ២ )សប្តាហ៍យ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

៧.១៩.៦.១ គខ/កប ត្រូវផ្ញើកំណត់ហេតុវាយតម្លៃសមាសភាព គកប ទាំងអស់ក្នុងខេត្ត ក្រុង ម្នាក់ៗមួយ( ១ )ច្បាប់ជូន គជប ( នាយកដ្ឋានរដ្ឋបាល ) ។

៧.១៩.៦.២ គជប ត្រូវកត់ត្រាបន្ថែម នូវទិន្នន័យដែលមានបញ្ជាក់ក្នុងកំណត់ហេតុវាយតម្លៃសមាសភាព គកប ទាំងអស់ ទៅក្នុងឯកសារនៃបញ្ជីឈ្មោះសមាសភាព គកប ដែលមានរក្សាទុកនៅ គជប ។

**ប្រាក់កំរៃរបស់សមាជិកនិងបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់**

**ប្រការ ៧.២០** ប្រាក់កំរៃរបស់សមាជិក និងបុគ្គលិកនៃគណៈកម្មាធិការ និងសមាជិក និងបុគ្គលិកនៃគណៈកម្មការគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ គជប ។

៧.២០.១ ប្រាក់កំរៃត្រូវតែបានពិនិត្យជារៀងរាល់ឆ្នាំ ។

៧.២០.២ ប្រាក់កំរៃត្រូវបើកជារៀងរាល់ខែចំពោះមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកម៉ៅការ ក្រោយការបញ្ចប់ការងារ ។

៧.២០.៣ ប្រាក់កំរៃត្រូវបើកជូនជាប្រាក់រៀលទៅតាមលទ្ធភាពបើកប្រាក់របស់រតនាគារជាតិ។

**អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់**

**ប្រការ ៧.២១** អាណត្តិរបស់គណៈកម្មាធិការ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មាន ៖

៧.២១.១ គកប ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់បានប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ហិបឆ្នោត និងរាល់សំភារៈឯកសារបោះឆ្នោតជូន គខ/កប រួចរាល់ហើយ ។

៧.២១.២ គខ/កប ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងរយៈពេលមួយដែលកំណត់ដោយ គជប និងដែលផ្អែកតាមតម្រូវការចាំបាច់នៃការងារជាក់ស្តែងរបស់ គខ/កប ។

៧.២១.៣ ប្រធាន អនុប្រធាន និងសមាជិក គជប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

**ការតែងតាំងក្នុងរយៈពេលមានកំណត់**

**ប្រការ ៧.២២** គជប មានសិទ្ធិតែងតាំង គខ/កប ឬ គកប ក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោត ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី ។

៧.២២.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ នីតិវិធីអំពីការជ្រើសរើសរចនាសម្ព័ន្ធសមាសភាព លក្ខណៈវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ ប្រាក់កំរៃ ត្រូវអនុលោមតាមបទបញ្ជា និងនីតិវិធីនេះ និងតាមការសម្រេចរបស់ គជប ។

៧.២២.២ អាណត្តិរបស់ គខ/កប និង គកប ដែលត្រូវបានតែងតាំង ក្នុងរយៈពេលមានកំណត់នេះ ត្រូវបញ្ចប់នៅពេលចប់ភារកិច្ច តាមការកំណត់របស់ គជប ។

**ការដាក់វិន័យ ការព្យួរការងារ ការបណ្តេញចេញពីការងារចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ**

**ប្រការ៧.២៣** សមាជិក ឬបុគ្គលិកនៃគណៈកម្មការថ្នាក់ណាមួយ ដែលធ្វើល្មើសនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជានិងនីតិវិធីរបស់ គជប ឬអ្នកដែលបដិសេធ មិនព្រមប្រតិបត្តិតាមសេចក្តីណែនាំរបស់ គជប ត្រូវទទួលការដាក់ពិន័យ ដោយអនុលោមតាមទំហំនៃអំពើល្មើស ។ វិធានការដាក់ពិន័យត្រូវចាប់ផ្តើមពីការព្រមានរហូតដល់ការបណ្តេញចេញពីការងារ ។

**គោលការណ៍នៃការប្រើប្រាស់សម្ភារៈ និងបរិក្ខារនៃ គជប**

**ប្រការ៧.២៤** សម្ភារៈ និងបរិក្ខារនៃ គជប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោតលើកលែងតែមានការសម្រេចរបស់ គជប ។

៧.២៤.១ គ្មានសមាជិក ឬបុគ្គលិកនៃ គជប ឬនៃគណៈកម្មការថ្នាក់ណាមួយអាចប្រើប្រាស់បរិក្ខារ និង/ឬសម្ភារៈនៃ គជប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ ។ ត្រូវបានកំណត់ជាបរិក្ខារនិងសម្ភារៈមានដូចជា រថយន្ត សម្ភារៈការិយាល័យ សម្ភារៈចុះឈ្មោះបោះឆ្នោត សម្ភារៈបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ឬសម្ភារៈផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ ។ល។

៧.២៤.២ ប្រសិនបើ សមាជិកឬបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ណាល្មើសនឹងចំណុច ៧.២៤.១ ជននោះនឹងត្រូវដាក់ពិន័យ ។ វិធានការដាក់ពិន័យគឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

៧.២៤.៣ សមាជិក ឬបុគ្គលិកនៃ គជប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមដែលល្មើសក្នុងការប្រើប្រាស់សម្ភារៈបរិក្ខារទាំងនេះ ត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គជប ។

៧.២៤.៤ ប្រសិនបើ សមាជិក ឬបុគ្គលិកណាម្នាក់នៃគណៈកម្មាធិការ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ធ្វើឱ្យសម្ភារៈបរិក្ខារត្រូវបាត់បង់ ឬខូចខាតក្នុងពេលប្រើប្រាស់ខុសច្បាប់ បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារៈបរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ ។

៧.២៤.៥ គជប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋានសម្រាប់ការប្រើប្រាស់សម្ភារៈបរិក្ខារ ។

**ប្រតិទិនការងារបោះឆ្នោត**

**ប្រការ** ៧.២៥ គជប ត្រូវបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.២៥.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប ត្រូវចាត់ចែងធ្វើប្រតិទិនការងារបោះឆ្នោត និងបោះពុម្ពផ្សាយជាបន្ទាន់ ។

៧.២៥.២ ការបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោត ត្រូវធ្វើឡើងឱ្យបានមុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត ។

៧.២៥.៣ ប្រតិទិនការងារបោះឆ្នោតត្រូវកំណត់ ៖

- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត
- ថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងថ្ងៃបញ្ឈប់ទទួលពាក្យ
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលជាផ្លូវការ ។

**ការងារសន្តិសុខ**

**ប្រការ** ៧.២៦ ក្រសួងឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយ គជប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាកិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅគ្រប់ដំណាក់ការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.២៦.១ គជប និងក្រសួងមហាផ្ទៃត្រូវសហការរៀបចំបង្កើតផែនការឬ/និងសេចក្តីណែនាំផ្សេងៗស្តីពីការការពារសន្តិសុខ សុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដោយត្រូវកំណត់ឱ្យបានច្បាស់នូវយន្តការផ្នែកសន្តិសុខ ព្រមទាំងដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែង និងការចាត់តាំងកងកម្លាំងនគរបាលជាតិ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថក្នុងក្របខណ្ឌនៃអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ។

៧.២៦.២ នាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតឱ្យ គជប មានភារកិច្ចសម្របសម្រួលនិងសហការជាមួយអង្គភាពជំនាញរបស់ក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំខ្លឹមសារនៃសេចក្តីព្រាងផែនការស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាមការកំណត់ ដូចចែងក្នុងចំណុចទី ៧.២៦.១ ខាងលើ ។

៧.២៦.៣ យន្តការផ្នែកសន្តិសុខត្រូវបានរៀបចំដូចខាងក្រោម ៖




(ការិ.បោះឆ្នោត/រាប់សន្លឹកឆ្នោត)

៧.២៦.៤ គជប លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬ គខ/កប និងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវសហការ តាមលំដាប់ឋានានុក្រម និងគ្រប់យន្តការទាំងអស់ ជាមួយក្រសួងមហាផ្ទៃ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ដើម្បីបំពេញភារកិច្ចការពាររក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.២៦.៥ កងកម្លាំងនគរបាលជាតិ ឬ/និងកងកម្លាំងប្រដាប់អាវុធផ្សេងទៀត ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ ឬឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធផ្សេងទៀត និងមានពាក់ផ្លាកសញ្ញាឬបណ្ណសំគាល់ភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលកំណត់ដោយ គជប

ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការដឹកជញ្ជូនកំណត់ហេតុនៃការបោះឆ្នោតនិង ការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅ គខ/កប និងការដឹកជញ្ជូនកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងសម្ភារៈឯកសារបោះឆ្នោតពី គខ/កប ទៅ គជប ។

៧.២៦.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវពិនិត្យរៀបចំគម្រោងផលិតឯកសារ និងសំភារៈសន្តិសុខសំខាន់ៗ រួមមាន ៖ សៀវភៅក្រមសីលធម៌ ខិត្តបណ្ណផ្សព្វផ្សាយផ្សេងៗទាក់ទងការងារសន្តិសុខ និងផ្លាកសញ្ញា ឬបណ្ណសំគាល់ភ្នាក់ងារសន្តិសុខបោះឆ្នោត ដើម្បីសុំគោលការណ៍សម្រេចពី គជប ។

៧.២៦.៧ ដើម្បីការពារកុំឱ្យមានការរំខានអុកឡុក ការបំភិតបំភ័យ និង ការគំរាមកំហែង ឬក៏ហេតុការណ៍ផ្សេងៗ ដែលនឹងអាចកើតមាន ហាមជនគ្រប់រូបយកអាវុធជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧.២៦.៨ នៅពេលបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនមួយ( ១ ) នាក់ ចល័តការពារជុំវិញបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ស្ថិតនៅក្នុងចម្ងាយពី ១៥ម៉ែត្រ ទៅ ៥០ម៉ែត្រ គ្មានសិទ្ធិប្រើអាវុធទេ ។ ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនពីរ( ២ )នាក់ ចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ស្ថិតនៅក្នុងចម្ងាយពី ១០០ម៉ែត្រ ទៅ ១៥០ម៉ែត្រ មានសិទ្ធិប្រើប្រាស់អាវុធវែង ១ដើម បង់១ មានគ្រាប់យ៉ាងច្រើនចំនួនសាមសិប( ៣០ )គ្រាប់ ។

៧.២៦.៩ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះអាចចូលអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតបាន ក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គជប ឬ ប្រធាន គខ/កប ឬពីប្រធាន គកប ពាក់ព័ន្ធ ។

## ការរៀបចំ និងការគ្រប់គ្រងដំណើរការនៃការបោះឆ្នោត

**ប្រការ៧.២៧** អនុវត្តមាត្រា ១២ និងមាត្រា ១៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប ត្រូវកែសម្រួលជាចុងក្រោយនិងកំណត់ជាផ្លូវការ នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត យ៉ាងយូរប្រាំពីរ(៧)ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ហើយត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតនេះ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅលេខាធិការដ្ឋាននៃ គខ/កប នៅតាមទីតាំងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតនីមួយៗ និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនខេត្ត ក្រុង យ៉ាងតិចដប់( ១០ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៧.២៧.១ នាយកដ្ឋានប្រតិបត្តិការត្រូវបោះពុម្ព និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងលេខាធិការដ្ឋាននៃ គខ/កប សំរាប់បំរើការបិទផ្សាយ និងប្រើប្រាស់ដូចខាងក្រោម ៖

៧.២៧.១.១ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃគ្រប់ខេត្ត ក្រុង ចំណុះមណ្ឌលភូមិភាគទាំងអស់ មួយ( ១ )ច្បាប់ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

៧.២៧.១.២ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃខេត្ត ក្រុងពាក់ព័ន្ធមួយ( ១ )ច្បាប់ នៅលេខាធិការដ្ឋាននៃ គខ/កប ។

៧.២៧.១.៣ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធមួយ( ១ )ច្បាប់ នៅទីតាំងការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោតនោះ ។

៧.២៧.១.៤ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃខេត្ត ក្រុងពាក់ព័ន្ធមួយ( ១ )ច្បាប់នៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនខេត្ត ក្រុងនោះ ។

៧.២៧.១.៥ រក្សាបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃខេត្ត ក្រុងពាក់ព័ន្ធមួយ( ១ )ច្បាប់ នៅលេខាធិការដ្ឋាននៃ គខ/កប ដើម្បីទុកជាឯកសារនិងបំរើការផ្សព្វផ្សាយជាសាធារណៈ ។

៧.២៧.១.៦ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញមួយ( ១ )ច្បាប់ ។

៧.២៧.២ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ជូននាយកដ្ឋានរដ្ឋបាលមួយ( ១ )ច្បាប់ ដើម្បីរៀបចំបែបបទ

សំរាប់ការជ្រើសរើសសមាសភាព គកប ដែលត្រូវបំពេញការងារបោះឆ្នោតនិងរាប់សន្លឹកឆ្នោត នៅតាមការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ។

**សម្ភារៈឯកសារបោះឆ្នោតដែល គជប ត្រូវផ្គត់ផ្គង់ និងការត្រួតពិនិត្យរបស់ គកប លើសម្ភារៈឯកសារបោះឆ្នោតដែលបានទទួល និងទីតាំងការិយាល័យបោះឆ្នោត**

**ប្រការ៧.២៨** គជប ត្រូវទទួលខុសត្រូវក្នុងការផ្គត់ផ្គង់សម្ភារៈបរិក្ខារ និងឯកសារគ្រប់គ្រាន់ សម្រាប់បំពេញការបណ្តុះបណ្តាលនិងកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនិងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ។ គជប ត្រូវធានាថា ហិបបរិក្ខារបោះឆ្នោតត្រូវបានបញ្ជូនទៅដល់ គកប បានទាន់ពេលវេលា ។ ដើម្បីធានាប្រសិទ្ធភាពការងារ ប្រធាន គកប ត្រូវកោះប្រជុំសមាជិកទាំងអស់នៃ គកប ឱ្យមកជួបជុំគ្នា នៅពេលព្រឹកថ្ងៃសៅរ៍ មួយ(១)ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមានសមាសភាព គកប ចុះពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារៈឯកសារបោះឆ្នោតដែលបានទទួល ។

៧.២៨.១ នាយកដ្ឋានប្រតិបត្តិការ ត្រូវផ្គត់ផ្គង់ និងបញ្ជូនសម្ភារៈបរិក្ខារនិងឯកសារសម្រាប់បំពេញការបណ្តុះបណ្តាល និងសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ឱ្យបានគ្រប់គ្រាន់ និងដល់គោលដៅ គខ/កប និង គកប នីមួយៗក្នុងទីប្រជុំជនខេត្ត ក្រុង ។

៧.២៨.២ នាយកដ្ឋានប្រតិបត្តិការត្រូវទទួលខុសត្រូវក្នុងការបោះពុម្ព វេចខ្ចប់ និងដឹកជញ្ជូនបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗចំនួនប្រាំ( ៥ )ច្បាប់ ដែលត្រូវបែងចែកជូន គខ/កប និង គកប ទាំងអស់ចំណុះខេត្ត ក្រុង សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ ២០០៦ ។

៧.២៨.២.១ បញ្ជីបោះឆ្នោតផ្លូវការ ត្រូវតែបានវេចខ្ចប់ដោយឡែកពីគ្នា តាមខេត្ត ក្រុង ដោយរៀបចំតាមលំដាប់លេខកូដ នៃការិយាល័យបោះឆ្នោតដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុង និងត្រៀមលក្ខណសម្បត្តិសម្រាប់បែងចែកជាស្រេចឱ្យដល់ គខ/កប ចំនួនបី( ៣ )ច្បាប់ និង គកប ចំនួនពីរ( ២ )ច្បាប់ ។

៧.២៨.២.២ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការ ដែលវេចខ្ចប់និងបញ្ជូនខាងលើនេះត្រូវតែមានសរសេរសម្គាល់ឈ្មោះខេត្ត ក្រុង និងលេខកូដការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើបញ្ជីបោះឆ្នោតទាំងនោះផង ។

៧.២៨.២.៣ នាយកដ្ឋានប្រតិបត្តិការ អាចផលិតស៊ីឌីមានផ្ទុកបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតចំណុះខេត្ត ក្រុងដោយឡែកពីគ្នា ជាបន្ថែមសម្រាប់ផ្តល់ជូន គឃ/កប ពាក់ព័ន្ធ ប្រសិនបើចាំបាច់ ។

៧.២៨.៣ គជប ត្រូវធានាថា គឃ/កប បានចាត់ចែង និងណែនាំប្រើប្រាស់បញ្ជីបោះឆ្នោត ដូចចែងក្រោមចំណុច ៧.២៨.២ ខាងលើ ដូចខាងក្រោម ៖

៧.២៨.៣.១ បិទផ្សាយនៅលេខាធិការដ្ឋាននៃ គឃ/កប មួយ( ១ )ច្បាប់ និងនៅទីកន្លែងណាមួយក្នុងទីប្រជុំជនខេត្ត ក្រុង មួយ( ១ )ច្បាប់ មួយ( ១ )ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៧.២៨.៣.២ រក្សាមួយ( ១ )ច្បាប់ និងស៊ីឌីមានផ្ទុកបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតចំណុះខេត្ត ក្រុង ប្រសិនបើមាន នៅលេខាធិការដ្ឋាននៃ គឃ/កប ដើម្បីទុកជាឯកសារ និងបំរើសាធារណជន ។

៧.២៨.៣.៣ ចាត់ គកប ឱ្យបិទផ្សាយនៅមុខទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗមួយ( ១ )ច្បាប់ មួយ( ១ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៧.២៨.៣.៤ ណែនាំ គកប ឱ្យរក្សាទុកមួយ( ១ )ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត នៅការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។

៧.២៨.៤ នាយកដ្ឋានប្រតិបត្តិការត្រូវរៀបចំផែនការ និងត្រៀមសម្ភារៈបរិក្ខារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឱ្យបានគ្រប់គ្រាន់ជាមុន ។ សម្ភារៈបរិក្ខារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវបានរៀបចំដាក់ក្នុងហិបបរិក្ខារដែលរួមមានបី( ៣ )ប្រភេទ ។ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ទទួលហិបបរិក្ខារបោះឆ្នោត មន្ត្រីទទួលបន្ទុកការបញ្ជូននៅតាមលំដាប់ថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) និងត្រូវឱ្យមន្ត្រីទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខាបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។ ហិបបរិក្ខារទាំងបី( ៣ )ប្រភេទរួមមាន ៖

៧.២៨.៤.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាល ( Training Kit ) ដែលត្រូវប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ និង គឃ/កប ។

៧.២៨.៤.២ ហិបបរិក្ខារ គខ/កប ( PEC Kit ) ដែលអាចមានមួយ ឬច្រើន ហើយដែលត្រូវបញ្ជូន និងប្រគល់ជូន គខ/កប ។

៧.២៨.៤.៣ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ( Polling and Counting Kit ) ដែលរួមមានសម្ភារៈបរិក្ខារនិងឯកសារបី( ៣ )កញ្ចប់ សម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវបញ្ជូន និងប្រគល់ជូន គកប នីមួយៗ ។

៧.២៨.៥ ហិបបរិក្ខារ គខ/កប ( PEC Kit ) ដែលត្រូវបញ្ជូន និងប្រគល់ជូន គខ/កប សម្រាប់ប្រើប្រាស់ក្នុងរាល់កិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និង សម្រាប់បន្តផ្តល់ជូន គកប ។ សម្ភារៈឯកសារទាំងនោះ រួមមាន ៖

៧.២៨.៥.១ បញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងខេត្ត ក្រុង ចំនួនប្រាំ( ៥ )ច្បាប់ដែល គខ/កប ត្រូវប្រើប្រាស់ចំនួនបី( ៣ )ច្បាប់ និងបន្តប្រគល់ជូន គកប ចំនួនពីរ( ២ )ច្បាប់ ។

៧.២៨.៥.២ កញ្ចប់សន្លឹកឆ្នោតធំមួយដែលរួមមានកញ្ចប់សន្លឹកឆ្នោតដោយឡែកពីគ្នាសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗក្នុងខេត្ត ក្រុង ដែល គខ/កប ត្រូវប្រគល់ជូន គកប ដោយមានអមជាមួយ នូវស្រោមសំបុត្រដាក់ត្រាសម្ងាត់សម្រាប់ការិយាល័យនោះ ។ គខ/កប ត្រូវប្រើទម្រង់បែបបទលេខ ១១០៦ សម្រាប់ជាការតាមដាននិងត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោតទៅ គកប ចំណុះខេត្ត ក្រុង ។

៧.២៨.៥.៣ ហិបឆ្នោតមិនទាន់តម្លើងនិងវេចខ្ចប់ដោយឡែក ចំនួនស្មើនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ដែលត្រូវបន្តផ្តល់ជូនចំនួនមួយ( ១ ) សម្រាប់ គកប នីមួយៗ ។

៧.២៨.៥.៤ បន្ទប់សម្ងាត់ស័ង្កសីបីផ្នត់សម្រាប់គូសសន្លឹកឆ្នោតចំនួនពីរ( ២ ) វេចខ្ចប់ច្រកក្នុងការុងមួយ ចំនួនការុងស្មើនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ដែលត្រូវបន្តផ្តល់ជូនចំនួនមួយ( ១ )ការុង និងអមដោយស្កុតមួយ( ១ )ដុំ សម្រាប់ គកប នីមួយៗ ។

៧.២៨.៥.៥ ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ( ២ )ដប គុណានឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ដែលត្រូវបន្តផ្តល់ជូនចំនួនពីរ ( ២ )ដប សម្រាប់ គកប នីមួយៗ ។

៧.២៨.៥.៦ សម្ភារៈឯកសារសម្រាប់ប្រើប្រាស់ ក្នុងរាល់កិច្ចប្រតិបត្តិការបោះឆ្នោតនៅលេខាធិការដ្ឋាននៃ គខ/កប ដែលត្រូវបានដាក់ក្នុងកេសមួយ ឬច្រើន ។ សម្ភារៈឯកសារទាំងនេះរួមមាន ៖

- ប័ណ្ណសំគាល់សមាសភាពនៃ គកប ចំនួនប្រាំ( ៥ )សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង (ត្រូវបញ្ជូនមុន) ។
- ប័ណ្ណសំគាល់តំណាងគណបក្សនយោបាយ ចំនួនម្ភៃ(២០)សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្តក្រុង(ត្រូវបញ្ជូនមុន)។
- ប័ណ្ណសំគាល់អ្នកសង្កេតការណ៍ជាតិចំនួនម្ភៃ( ២០ )សន្លឹកគុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង (ត្រូវបញ្ជូនមុន) ។
- ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបំពេញការងាររបស់សមាសភាពនៃ គកប ចំនួនដប់( ១០ )គុណនឹងការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ( ត្រូវបញ្ជូនមុន ) ។
- ទម្រង់បែបបទលេខ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាននិងប្រាក់កំរៃសមាសភាពនៃ គកប ចំនួនបី( ៣ )ច្បាប់ ។
- ទម្រង់បែបបទលេខ ១១០៦ ចំនួនបី( ៣ )ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោត ។
- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ចំនួនប្រាំបួន( ៩ )ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ។
- ទម្រង់បែបបទលេខ ១១១០ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំនួនបី( ៣ )ច្បាប់និងថាសទន់ផ្ទុកទម្រង់បែបបទលេខ ១១១០ ចំនួនមួយ( ១ ) ។
- ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុងចំនួនប្រាំ(៥)ច្បាប់។
- ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញការវាយតម្លៃសមាសភាពនៃ គកប ចំនួនដប់( ១០ )ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ។
- ទម្រង់បែបបទលេខ ១១១៤ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ចំនួនប្រាំ( ៥ )ច្បាប់ ។

- ទម្រង់បែបបទលេខ ១២០២ ចំនួនប្រាំ( ៥ )ក្បាល ក្នុងមួយក្បាលមានម្ភៃ( ២០ )ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាឬបណ្តឹងជំទាស់ ។
- ទម្រង់បែបបទលេខ ១២០៣ ចំនួនប្រាំ( ៥ )ក្បាល ក្នុងមួយក្បាលមានម្ភៃ( ២០ )ច្បាប់ សម្រាប់បំពេញសេចក្តីសំរេចលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។
- ស្រោមសំបុត្រធំពីរ( ២ )គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ស្រោមសំបុត្រមធ្យមប្រាំពីរ( ៧ ) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតសមាមាត្រនឹងកញ្ចប់ " ឃ " ដែលត្រូវប្រើនៅ គខ/កប ។
- ម៉ាស៊ីនគិតលេខមួយ( ១ )គ្រឿង ។
- ប៊ិចហ្វឺតធំលុបមិនជ្រះ ចំនួនពីរ( ២ )ដើម ។
- កញ្ចប់សុវត្ថិភាព " ឃពិសេស " ចំនួនមួយ( ១ ) ។
- កញ្ចប់ " ឃ " ចំនួនពីរ( ២ )ទៅបួន( ៤ ) យោងតាមខេត្តក្រុងតូច ឬធំ ។
- សោឃ្លុំជ័រធំ សម្រាប់ឃ្លុំកញ្ចប់ " ឃ " ចំនួនស្មើនឹងកញ្ចប់ " ឃ " ។

៧.២៨.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ( Polling and Counting Kit ) ដែល គខ/កប ត្រូវបញ្ជូន និងប្រគល់ជូន គកប នីមួយៗ រួមមាន ៖

៧.២៨.៦.១ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចំនួនពីរ(២)ច្បាប់។

៧.២៨.៦.២ សន្លឹកឆ្នោតមួយ( ១ )កញ្ចប់ ដែលត្រូវបានវេចខ្ចប់ដោយខ្សែក និងអមដោយត្រាសម្ងាត់មួយ( ១ )សម្រាប់បោះលើខ្នងសន្លឹកឆ្នោតដែលដាក់ក្នុងស្រោមសំបុត្របិទជិត ។

៧.២៨.៦.៣ ហិបឆ្នោតមួយដែលមិនទាន់តម្លើង និងវេចខ្ចប់ដោយខ្សែក ។

៧.២៨.៦.៤ បន្ទប់សម្ងាត់ស័ង្កសីបិផ្តត់សម្រាប់គូសសន្លឹកឆ្នោតចំនួនពីរ( ២ ) ដែលមិនទាន់តម្លើង និងវេចខ្ចប់ច្រកក្នុងការុងនីឡុងមួយ ដោយខ្សែក និងអមដោយស្កុតមួយ( ១ )ដុំផង ។

៧.២៨.៦.៥ ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ( ២ )ដប ។

៧.២៨.៦.៦ សម្ភារៈឯកសារបំរើកិច្ចប្រតិបត្តិការបោះឆ្នោត និងសម្ភារៈឯកសារបំរើកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតផ្សេងទៀត ដែលត្រូវបានដាក់ក្នុងហិបបរិក្ខារតែមួយ ។ សម្ភារៈឯកសារទាំងនេះរួមមាន ៖

- ផ្លាកសញ្ញា " ការិយាល័យបោះឆ្នោត " បោះពុម្ពលើកំណាត់ផ្លាស្ទិកចំនួនមួយ( ១ ) ។
- ត្រាការិយាល័យបោះឆ្នោត ចំនួនមួយ( ១ ) ។
- តាំប៉ុងពណ៌ក្រហម ចំនួន( ១ )ប្រអប់ ប្រើសម្រាប់ត្រាការិយាល័យបោះឆ្នោត និងត្រាសម្ងាត់បោះលើខ្នងសន្លឹកឆ្នោត ។
- ប៊ិចមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងប៊ិចធម្មតាសម្រាប់គកប សរុបទាំងពីរមុខ ចំនួនប្រាំបី( ៨ )ដើម ។
- ប៊ិចហ្វឺតធំលុបមិនជ្រះចំនួនមួយ( ១ )ដើម ។
- ប៊ិចហ្វឺតធំចំនួនមួយ( ១ )ដើម សម្រាប់កត់ត្រាសម្លេងឆ្នោតលើផ្ទាំងក្រដាសធំ ឬលើក្តារខៀន ។
- ក្រដាសស្តើង សម្រាប់បិទពាសសន្ទះបិទប្រឡោះស៊កសន្លឹកឆ្នោតចំនួនបួន( ៤ )សន្លឹក ។
- ក្រដាសរ៉ាម សម្រាប់សរសេរសម្គាល់លេខការិយាល័យបោះឆ្នោតបិទលើហិបឆ្នោតនិងកាត់តូចៗសរសេរលេខរៀងចែកជូនអ្នកបោះឆ្នោតឈរជាជួរនៅបរិវេណខាងក្នុង ចំនួនម្ភៃ( ២០ )សន្លឹក ។
- ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោតចំនួនពីរ( ២ )ផ្ទាំង ។
- ផ្ទាំងក្រដាសធំទំហំ ៨០ស.ម គុណនឹង១២០ ស.មចំនួនមួយ( ១ )ផ្ទាំង សម្រាប់កត់ត្រាសម្លេងឆ្នោត ។
- ម៉ាស៊ីនគិតលេខមួយ( ១ )គ្រឿង ។
- បន្ទាត់ជ័រចំនួនមួយ( ១ )ដើម ។
- ជ័រការពារមួយ( ១ )ដប ។
- កៅស៊ូកង មួយចំនួនសំរាប់ចងសន្លឹកឆ្នោតតាមគណបក្ស ។
- ទម្រង់បែបបទលេខ ១១០១ ចំនួនប្រាំមួយ(៦)ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ។

- ទម្រង់បែបបទលេខ ១១០២ ចំនួនប្រាំ( ៥ )ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។
- ទម្រង់បែបបទលេខ ១១០៤ ចំនួនដប់ប្រាំ( ១៥ )ច្បាប់ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ ។
- ទម្រង់បែបបទលេខ ១១០៧ ចំនួនប្រាំមួយ(៦)ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ។
- ទម្រង់បែបបទលេខ ១១០៨ ចំនួនបួន( ៤ )ច្បាប់ សម្រាប់កត់ត្រាសម្លេងឆ្នោត ។
- ទម្រង់បែបបទលេខ ១១១២ ចំនួនបួន( ៤ )ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោត ដែល គកប បានទទួល ។
- ទម្រង់បែបបទលេខ ១១១៥ ចំនួនពីរ( ២ )ច្បាប់ សម្រាប់បំពេញបញ្ជីវត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត ។
- ទម្រង់បែបបទលេខ ១២០២ ចំនួនពីរ(២)ក្បាល ក្នុងមួយក្បាលមានម្ភៃ(២០)ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។
- ស្រោមសំបុត្រធំចំនួនមួយ( ១ ) មធ្យមចំនួនប្រាំបួន( ៩ ) និងតូចចំនួនពីរ( ២ ) ។
- ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ចំនួនមួយ( ១ ) ។
- ស្បោងផ្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលប្រើហើយ ចំនួនមួយ( ១ ) ។
- កញ្ចប់សុវត្ថិភាព " ក " សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ចំនួនមួយ( ១ ) ។
- កញ្ចប់ " ខ " សម្រាប់ដាក់កញ្ចប់សុវត្ថិភាព " ក " និងសម្ភារៈឯកសារបោះឆ្នោត ចំនួនមួយ( ១ ) ។
- សោឃ្លុំជ័រមានលេខសម្រាប់ឃ្លុំបិទគំរបខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួនបី( ៣ ) ។
- សោឃ្លុំជ័រមានលេខសម្រាប់ឃ្លុំបិទកញ្ចប់ " ខ" ចំនួនមួយ(១) ។

៧.២៨.៧ គជប និង គខ/កប ត្រូវធានាក្នុងការបញ្ជូន និងប្រគល់សម្ភារៈឯកសារបោះឆ្នោត ដូចចែងក្រោមចំណុច ៧.២៨.៦ ខាងលើ ឱ្យបានគ្រប់គ្រាន់ជូន គកប នៅមុនថ្ងៃបោះឆ្នោត ប៉ុន្តែមិនត្រូវឱ្យលើសពីសាមសិបប្រាំមួយ( ៣៦ )ម៉ោង មុនថ្ងៃបោះឆ្នោតទេ ។

៧.២៨.៨ សមាជិកគ្រប់រូបនៃ គកប ត្រូវតែមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោតតាមការអញ្ជើញរបស់ប្រធាន គកប និងត្រូវធានាថានឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

៧.២៨.៨.១ ប្រសិនបើ មានសមាជិកណាម្នាក់នៃ គកប មិនអាចមកបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធាន គកប ត្រូវតែជូនដំណឹងដល់ គខ/កប ជាបន្ទាន់ ដើម្បីដាក់អ្នកថ្មីជំនួស ។

៧.២៨.៨.២ ប្រសិនបើ គខ/កប មិនអាចត្រូវបានជូនដំណឹងអំពីការដាក់អ្នកថ្មីជំនួសទាន់ពេលវេលាដោយសារយថាហេតុណាមួយ ប្រធាន គកប ព្រមទាំងសមាជិកដទៃទៀតនៃ គកប ត្រូវធ្វើការជ្រើសរើសអ្នកជំនួសតំណែងសមាជិក គកប ដែលអវត្តមាននោះ ។

៧.២៨.៨.៣ ប្រសិនបើប្រធាន គកប មិនអាចមកបំពេញការងារបានដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយជំនួយការចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មី ត្រូវចូលកាន់តំណែងជំនួសជំនួយការ ។

៧.២៨.៨.៤ ប្រសិនបើ អនុប្រធាន គកប មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងជំនួយការជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងចូលកាន់តំណែងជំនួសជំនួយការ ។

៧.២៨.៨.៥ ប្រសិនបើ លេខាធិការមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងជំនួយការជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងចូលកាន់តំណែងជំនួសជំនួយការ ។

៧.២៨.៨.៦ សមាសភាពទាំងអស់នៃ គកប ត្រូវសិក្សានីតិវិធីឡើងវិញ រួមជាមួយសមាជិកដែលទើបតែជ្រើសរើសថ្មី និងរួមគ្នាសិក្សាសៀវភៅណែនាំសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.២៨.៨.៧ សមាជិកតែងតាំងថ្មីទាំងអស់ ត្រូវតែបានទទួលការបណ្តុះបណ្តាលដូចដែលបានចែងក្នុងចំណុច ៧.២៨.៨.៦ ខាងលើ ។

៧.២៨.៨.៤ ប្រធាន គកប ត្រូវជូនដំណឹងជាបន្ទាន់ដល់ គខ/កប អំពីអ្វីដែលបានអនុវត្ត ពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងសមាសភាពណាម្នាក់នៃ គកប ។

៧.២៨.៩ បន្ទាប់ពីអនុវត្តចំណុច ៧.២៨.៨ រួច គកប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារៈឯកសារបោះឆ្នោតដែល គខ/កប បានបន្តផ្តល់ជូន ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ។ ក្នុងនោះត្រូវ ៖

៧.២៨.៩.១ ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារៈឯកសារបោះឆ្នោត ដោយកត់ត្រាក្នុងតារាងត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១១២ ) ។

៧.២៨.៩.២ ចុះហត្ថលេខា នៅលើតារាងត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១១២ ) ប្រសិនបើ សម្ភារៈឯកសារបោះឆ្នោត ដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ និងត្រូវថែរក្សាទុកឱ្យបានហ្មត់ចត់ ។

៧.២៨.៩.៣ បំពេញត្រង់ផ្នែកសម្ភារៈឯកសារបោះឆ្នោតដែលបាត់បង់ នៅលើតារាងត្រួតពិនិត្យសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១១២ ) ប្រសិនបើ មានសម្ភារៈឯកសារបោះឆ្នោតណាមួយ ឬច្រើនត្រូវបាត់បង់ និងត្រូវធ្វើតារាងត្រួតពិនិត្យនេះមួយ( ១ )ច្បាប់ ជាបន្ទាន់ទៅ គខ/កប ។

៧.២៨.៩.៤ ចាត់សមាជិក គកប ចំនួនពីរ( ២ )រូប ឱ្យធ្វើដំណើរទៅកាន់លេខាធិការដ្ឋាននៃ គខ/កប ដើម្បីទទួលសម្ភារៈថ្មីជំនួសសម្ភារៈ ដែលបានបាត់បង់ ប្រសិនបើ សម្ភារៈដែលបាត់បង់ទៅនោះជាសម្ភារៈសំខាន់សម្រាប់ការបោះឆ្នោត លើកលែងតែមានមធ្យោបាយបញ្ជូនព័ត៌មានស្នើសុំ គខ/កប ដោះស្រាយបញ្ហាខាងលើបាន ។

៧.២៨.៩.៥ ក្នុងការត្រួតពិនិត្យឡើងវិញ នូវសម្ភារៈឯកសារបោះឆ្នោតខាងលើនេះ គកប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារៈដូចខាងក្រោម ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួននិងលេខរៀងដែលមានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតឡើយ ។

- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត។

៧.២៨.១០ សម្ភារៈសំខាន់ៗ ដែលការិយាល័យបោះឆ្នោតមិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

៧.២៨.១០.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៧.២៨.១០.២ ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៧.២៨.១០.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

៧.២៨.១០.៤ ហិបឆ្នោត និង សោឃ្លុំមានលេខ ។

៧.២៨.១០.៥ ទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ ។

៧.២៨.១១ សម្ភារៈដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គជប និង គខ/កប នោះ គកប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

៧.២៨.១១.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

៧.២៨.១១.២ ក្រដាសសំរាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុជាគំរូដែលមិនបានទទួល ។

៧.២៨.១១.៣ ប៊ិចសរសេរ បន្ទាត់ ខ្សែសម្រាប់ចងផ្លាកសំគាល់ការិយាល័យបោះឆ្នោត ។ល។

៧.២៨.១២ នៅពេលដែលសម្ភារៈឯកសារបោះឆ្នោតមានចំនួនគ្រប់គ្រាន់ហើយ ប្រធាន គកប ត្រូវបង្គាប់ជំនួយការ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យនោះ មួយ (១)ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត តាមការកំណត់ដូចចែងក្នុងចំណុច ៧.២៣.៣.៣ ខាងលើ ។ បន្ទាប់មក ប្រធាន គកប រួមជាមួយសមាជិក គកប ត្រូវរក្សាការពារសម្ភារៈឯកសារទាំងនោះឱ្យបានហ្មត់ចត់ នៅមុនពេលបោះឆ្នោត ។

៧.២៨.១២.១ សម្ភារៈឯកសារបោះឆ្នោតអាចនឹងរក្សាទុក នៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គកប ឯកភាពគ្នាថាមានសុវត្ថិភាព ។

៧.២៨.១២.២ យ៉ាងហោចណាស់ ត្រូវមានសមាជិក គកប បី( ៣ )នាក់ គិតទាំងប្រធានផង សំរាកនៅផ្ទះ ឬទីតាំង ដែលទទួលរក្សាសម្ភារៈឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

៧.២៨.១២.៣ ប្រធាន គកប ត្រូវស្នើសុំឱ្យមានកំលាំងសន្តិសុខដើម្បីរួមសហការ ការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារៈ ឯកសារបោះឆ្នោត ។

៧.២៨.១៣ បន្ទាប់ពីបានអនុវត្តចំណុច ៧.២៨.៩ រួចហើយ គកប ត្រូវចុះត្រួតពិនិត្យទីតាំង ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថា ទីតាំង នោះអាចដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតបាន ហើយដែលអាចរៀបចំឱ្យ រួចស្រេច នៅម៉ោងប្រាំមួយ( ៦ )ព្រឹកនៃថ្ងៃបោះឆ្នោត ។

៧.២៨.១៣.១ គកប ត្រូវគូរគំរូប្លង់ការិយាល័យបោះឆ្នោតឯកភាពគ្នាមួយ ដោយ ត្រូវគោរពតាមគោលការណ៍ដូចដែលបានចែងក្នុងសៀវភៅណែនាំ គខ/កប និង គកប ។

៧.២៨.១៣.២ ប្រសិនបើ គ្មានគ្រឿងសង្ហារិមគ្រប់គ្រាន់នៅទីតាំងការិយាល័យបោះ ឆ្នោតទេ ប្រធាន គកប ត្រូវធ្វើសំណើទៅអាជ្ញាធរមូលដ្ឋានជាបន្ទាន់ ដើម្បីសុំខ្ចីគ្រឿងសង្ហារិមចាំបាច់មួយចំនួន សម្រាប់បំរើការបោះ ឆ្នោតនិងការរាប់សន្លឹកឆ្នោតដូចជា តុ កៅអីនិងសម្ភារៈដទៃទៀត ។

៧.២៨.១៣.៣ ប្រសិនបើអាចធ្វើបាន ប្រធាន គកប ត្រូវបិទទ្វារចាក់សោបន្ទប់ឬ អាគារទីតាំងការិយាល័យបោះឆ្នោតដែលបានរៀបចំរួចនោះ និងត្រូវ ស្នើសុំឱ្យមានកំលាំងសន្តិសុខយាមរក្សាសន្តិសុខផង ។

៧.២៨.១៣.៤ ប្រធាន គកប ត្រូវណាត់ជាមួយសមាជិកដទៃទៀត ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាព ដែលទទួលរក្សាទុកសម្ភារៈឯកសារបោះឆ្នោត នៅម៉ោងប្រាំកន្លះ( ៥:៣០ )ព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បី ដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោត ទៅកាន់ទីតាំងការិយាល័យបោះ ឆ្នោត ។

៧.២៨.១៣.៥ សមាជិកទាំងអស់នៃ គកប ត្រូវត្រៀមអាហារសម្រាប់ពេលមួយ ( ១ )ថ្ងៃ សម្រាប់ហូបនៅចន្លោះពេលទំនេរដែលពុំមានវត្តមាន អ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

**ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ៧.២៩** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាលនិងសន្តិសុខ ដែលមានបរិវេណ ខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្រោមប្រការ ២.៨ ២.៩ ២.១០ ២.១១ និង ២.១២ ក្នុងជំពូក ២ នៃបទបញ្ជានិងនីតិវិធីនេះ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងបំរើសុវត្ថិភាពនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត ។ គជប គខ/កប និងប្រធាន គកប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីរក្សាការពារសម្ភារៈឯកសារបោះឆ្នោតទាំងអស់ និងការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យពាក់ព័ន្ធ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង ។

៧.២៩.១ ការិយាល័យបោះឆ្នោតត្រូវបានបង្កើតឡើងដោយ គជប សំរាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

៧.២៩.២ ការិយាល័យបោះឆ្នោត នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត សំរាប់បំរើកិច្ចប្រតិបត្តិការ នៃការរាប់សន្លឹកឆ្នោត បន្ទាប់ពីការិយាល័យនោះបានបញ្ចប់ការបោះឆ្នោត លើកលែងតែ គជប សំរេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

## ការប្រព្រឹត្តទៅនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត

**ប្រការ** ៧.៣០ សមាសភាពទាំងអស់នៃ គកប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារៈឯកសារបោះឆ្នោត ឱ្យបានទាន់ពេលនៅវេលាម៉ោងប្រាំមួយ( ៦ )ព្រឹក នាថ្ងៃបោះឆ្នោត ជាកំហិត ។

៧.៣០.១ បន្ទាប់ពី គកប បានចូលដល់ក្នុងការិយាល័យភ្លាម ប្រធាន គកប ត្រូវប្រកាសឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យប្លាកសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ ។

៧.៣០.១.១ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យអ្នកដែលបានត្រួតពិនិត្យរួចហើយចូលក្នុងការិយាល័យបោះឆ្នោត និងប្រាប់ទីកន្លែង ដែលបំរុងទុកសម្រាប់ពួកគាត់ ដូចចែងក្នុងចំណុច ៧.៣០.២.៥ ខាងក្រោម ។

៧.៣០.២ ទន្ទឹមពេលអនុវត្តចំណុច ៧.៣០.១ ខាងលើ ប្រធាន គកប ត្រូវចាត់ចែងសមាជិក គកប ដទៃទៀតឱ្យរៀបចំគ្រឿងសង្ហារិមនិងដាក់សម្ភារៈឯកសារសម្រាប់ការបោះឆ្នោត ដូចបានកំណត់ឯកភាពគ្នាលើគំរូប្លង់ការិយាល័យបោះឆ្នោត ដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គខ/កប និង គកប ។

៧.៣០.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូល សម្រាប់ប្រធាន គកប ដែលនៅលើនោះ មានទម្រង់បែបបទលេខ ១២០២ ត្រៀមចែកជូនតំណាងគណបក្សនយោបាយសំរាប់បំពេញពាក្យបណ្ដឹង។

៧.៣០.២.២ តុវែងមួយដាក់នៅប៉ែកខាងស្ដាំដៃ បន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា ដែលនៅចំពីមុខលេខាធិការមានដាក់បញ្ជីបោះឆ្នោត ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំពីមុខអនុប្រធានមានដាក់កញ្ចប់សន្លឹកឆ្នោត និង ស្រោមសំបុត្រមានត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៧.៣០.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួនពីរ( ២ ) ដែលមានបិចចងខ្សែភ្ជាប់ស្រាប់ ត្រូវដាក់នៅក្បែរជ្រុងបន្ទប់ ឬ ជាប់ជញ្ជាំង ដែលមានចម្ងាយពីគ្នាយ៉ាងតិចមួយ( ១ )ម៉ែត្រ ដើម្បីរក្សាការសម្ងាត់ នៃការបោះឆ្នោត ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាសមួយ( ១ )សន្លឹកៗសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ ។

៧.៣០.២.៤ ហិបឆ្នោតដែលតម្លើងរួច ទឹកខ្មៅលុបលាងមិនជ្រះ និងកំណាត់សម្រាប់ជូត ត្រូវដាក់នៅលើតុវែងមួយ ដែលដាក់ឱ្យស្ថិតនៅត្រង់កណ្ដាលបន្ទប់ ទល់មុខនឹងតុរបស់ប្រធាន ។

៧.៣០.២.៥ តុ និងកៅអីសម្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ប្រសិនបើមាន ត្រូវដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន ។

៧.៣០.២.៦ ហិបបរិក្ខារបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ដែលមានសម្ភារៈឯកសារបោះឆ្នោតមិនទាន់ត្រូវប្រើប្រាស់ ត្រូវរក្សាទុកនៅក្បែរតុប្រធាន ។

៧.៣០.៣ នៅពេលអនុវត្តចំណុច ៧.៣០.១ រួចរាល់ ប្រធាន គកប ត្រូវពន្យល់ណែនាំជារួមដល់តំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលពួកគាត់ត្រូវធ្វើ ដូចខាងក្រោម ៖

៧.៣០.៣.១ ត្រូវគោរពច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជានិងនីតិវិធីរបស់ គជប ក្រមសីលធម៌គណបក្សនយោបាយបេក្ខជន និងតំណាងគណបក្ស នយោបាយ ឬ/និង ក្រមសីលធម៌អ្នកសង្កេតការណ៍ ដែលកំណត់ដោយ គជប ។

៧.៣០.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត ។

៧.៣០.៣.៣ ត្រូវលើកសំណួរ សំណូមពរផ្សេងៗឬ/និងយោបល់ជំទាស់ ដោយផ្ទាល់ទៅប្រធាន គកប ។

៧.៣០.៣.៤ មិនត្រូវណែនាំអ្វីដល់សមាជិក គកប ។

៧.៣០.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

៧.៣០.៣.៦ មិនត្រូវធ្វើអ្វីឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ។

៧.៣០.៤ នៅចន្លោះពីម៉ោងប្រាំមួយ( ៦:០០ )ដល់ម៉ោងប្រាំមួយកន្លះ( ៦:៣០ )ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវបំពេញកិច្ចការមួយចំនួន ដូចខាងក្រោម ៖

៧.៣០.៤.១ ប្រធាន គកប ត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថា ត្រូវបានតម្លើងត្រឹមត្រូវហើយ ។

៧.៣០.៤.២ ប្រធាន គកប ត្រូវបើកគំរបក្រៅ និងគំរបក្នុងនៃហិបឆ្នោត រួចបង្ហាញហិបឆ្នោតដែលទទេ ចំពោះអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ បន្ទាប់មក ត្រូវបិទគំរបក្នុងនៃហិបឆ្នោតទៅវិញ មួលភ្ជិតគំរបសន្ទះបិទប្រឡោះសម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះបិទគំរបក្នុងរួចចាក់សោឃ្លុំ និងបង្គាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំនេះ នៅលើកំណត់ហេតុនៃការបោះឆ្នោត ។

៧.៣០.៤.៣ ប្រធាន គកប ត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតនោះ និងបោះត្រាលើក្រដាសចំនួនពីរ( ២ )សន្លឹក រួចបិទភ្ជាប់នៅលើជញ្ជាំងសងខាងនៃហិបឆ្នោត ហើយបន្ទាប់មក អនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលនិងកត់ចំណាំហិបឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ។

៧.៣០.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោង នៃការពិនិត្យហិបឆ្នោត នៅលើកំណត់ហេតុនៃការបោះឆ្នោត ។

៧.៣០.៥ ហិបឆ្នោតដែលបានបិទផ្លាកសម្គាល់លេខកូដការិយាល័យនិងចាក់សោឃ្លុំរួចហើយដូចចែងក្រោមចំណុច ៧.៣០.៤ ខាងលើ ត្រូវហាមដូចខាងក្រោម ៖

៧.៣០.៥.១ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត នៅក្នុងអំឡុងពេលទាំងមូលនៃកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

៧.៣០.៥.២ មិនអនុញ្ញាតឱ្យបើកចំហជាដាច់ខាត លើកលែងតែតម្រូវឱ្យអនុវត្តតាមបទបញ្ជានិងនីតិវិធីរបស់ គជប ស្តីពីការផ្ទៀងផ្ទាត់សន្លឹកឆ្នោត និងការរាប់សន្លឹកឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធ ។

៧.៣០.៦ ប្រសិនបើ សម្ភារៈឯកសារបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានប្រគល់ទទួលនៅក្រោយម៉ោងប្រាំមួយកន្លះ( ៦:៣០ ) ប៉ុន្តែមិនហួសពីម៉ោងប្រាំពីរ( ៧:០០ )ព្រឹក ប្រធាន គកប ត្រូវព្យួរការអនុវត្តនីតិវិធីបន្ទាប់ៗ នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្នសិន រហូតទាល់តែបទបញ្ជា និងនីតិវិធី ដូចចែងក្រោមចំណុច ៧.៣០.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ឱ្យបានច្បាស់លាស់ ។

៧.៣០.៧ នៅចន្លោះពីម៉ោងប្រាំមួយកន្លះ( ៦:៣០ )ដល់ម៉ោងប្រាំពីរ( ៧:០០ )ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវបំពេញកិច្ចការមួយចំនួន ។ ក្នុងនោះ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលរួមសង្កេតមើលការអនុវត្តនីតិវិធី និងកត់ចំណាំសម្ភារៈឯកសារបោះឆ្នោត ដូចខាងក្រោម ៖

៧.៣០.៧.១ អនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចត្រួតពិនិត្យមើល និងធានាថា សន្លឹកឆ្នោតនេះជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលពាក់ព័ន្ធប្រាកដមែន ។ ក្នុងករណី មានការភាន់ច្រឡំដោយអចេតនាណាមួយ សន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ គកប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គខ/កប មក គជប ដើម្បីមានវិធានការដោះស្រាយ ។

៧.៣០.៧.២ បន្ទាប់មក អនុប្រធានត្រូវរាប់សន្លឹកឆ្នោត ដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ៥០ ដល់ ៩៩ សន្លឹក ។

៧.៣០.៧.៣ លេខាធិការ ត្រូវកត់ត្រាចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងដើមដំបូងបង្អស់ និងលេខរៀងចុងបញ្ចប់នៃសន្លឹកឆ្នោត នៅលើកំណត់ហេតុនៃការបោះឆ្នោត ។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ប្រៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការ ត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះនៅលើកំណត់ហេតុនៃការបោះឆ្នោតដែរ ។

៧.៣០.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះនៅលើកំណត់ហេតុនៃការបោះឆ្នោត ។

៧.៣០.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រានោះ មកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស ដើម្បីឱ្យអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់បានឃើញច្បាស់ និងចំណាំបានរូបសញ្ញា នៃត្រានោះ ។

៧.៣០.៨ ប្រធាន គកប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោងប្រាំពីរ( ៧:០០ ) ព្រឹក នៃថ្ងៃបោះឆ្នោត ។ ផ្អែកតាម ករណីដូចចែងក្នុងចំណុច ៧.៣០.៦ ខាងលើ ប្រសិនបើមានប្រធាន គកប អាចប្រកាសបើកការិយាល័យបោះឆ្នោត នៅក្រោយម៉ោងប្រាំពីរ( ៧:០០ )ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោងប្រាំបី( ៨:០០ ) ឡើយ ។

៧.៣០.៩ បន្ទាប់ពីអនុវត្តលក្ខខណ្ឌនៃចំណុច ៧.៣០.៨ ចប់សព្វគ្រប់ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ត្រូវជម្រាបអ្នកបោះឆ្នោតឱ្យឈរជាជួរបន្តកន្ទុយគ្នា តម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោត ។ សមាជិកទទួលសណ្តាប់ធ្នាប់អាចសរសេរលេខរៀងលើសន្លឹកក្រដាសតូចៗ ចែកជូនអ្នកបោះឆ្នោតដែលឈរក្នុងជួរតាមលំដាប់លំដោយ ប្រសិនបើចាំបាច់ ។ សមាជិកទទួលសណ្តាប់ធ្នាប់ត្រូវផ្តល់អាទិភាពតាមលំដាប់លំដោយ ចំពោះអ្នកបោះឆ្នោតដែលជាជនមានវ័យចំណាស់ ស្ត្រីមានផ្ទៃពោះ អ្នកមានជម្ងឺ ជនពិការនិងអ្នកជំនួយជានីតិជនម្នាក់ដែលគាត់ជ្រើសរើសមកជាមួយ ។ អ្នកបោះឆ្នោតដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

៧.៣០.៩.១ ត្រូវបង្ហាញជូនសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ នូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដែលកំណត់ដោយច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់ គជប និងដែលអ្នកបោះឆ្នោតត្រូវប្រើប្រាស់សម្រាប់បោះឆ្នោត ។ ឯកសារបញ្ជាក់អត្តសញ្ញាណអាចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬប័ណ្ណសំគាល់គ្រួសារមានបិទរូបថតសាមីខ្លួន ឬសៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល / កងយោធពលខេមរភូមិន្ទ / នគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬលិខិតសំគាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង មានបិទរូបថតសាមីខ្លួន ឬលិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ។

៧.៣០.៩.២ មិនទាន់បានបោះឆ្នោតនៅថ្ងៃបោះឆ្នោតនោះនៅឡើយ និងយល់ព្រម ឱ្យសមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ ពិនិត្យមើលម្រាមដៃរបស់ខ្លួន ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបលាងមិនជ្រះ ។

៧.៣០.១០ បន្ទាប់ពី បានអនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលក្នុងការិយាល័យបោះឆ្នោត សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់ត្រូវជំរាបអ្នកបោះឆ្នោត ឱ្យដើរតម្រង់ទៅរកតុវែង ដែលលេខាធិការ និងអនុប្រធានកំពុងអង្គុយ ។

៧.៣០.១០.១ អ្នកបោះឆ្នោតត្រូវបង្ហាញលេខាធិការ នូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយរបស់ខ្លួនដូចចែងក្នុងចំណុច ៧.៣០.៩.១ ខាងលើ ។

៧.៣០.១០.២ លេខាធិការត្រូវត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបលាងមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

៧.៣០.១០.៣ លេខាធិការត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឈ្មោះនិងទិន្នន័យ ក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ជាមួយនឹងបញ្ជីបោះឆ្នោត ដោយដាក់បន្ទាត់តាមបណ្ដោយជួរឈ្មោះគាត់លើបញ្ជីបោះឆ្នោត ។

៧.៣០.១០.៤ ប្រសិនបើ ឈ្មោះនិងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតត្រូវគ្នានឹងឈ្មោះនិងទិន្នន័យក្នុងបញ្ជីបោះឆ្នោត លេខាធិការ ត្រូវគូសសញ្ញាមួយក្នុងប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ បន្ទាប់មក កត់ត្រាសំគាល់ប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់នៅខ្ទង់ពាក់ព័ន្ធ រួចហុចឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់បន្តទៅឱ្យអនុប្រធាន ។

៧.៣០.១០.៥ ជំរាបអ្នកបោះឆ្នោតឱ្យទៅជួបអនុប្រធានដើម្បីទទួលសន្លឹកឆ្នោត ។

៧.៣០.១១ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ៧.៣០.១០.២ លេខាធិការបានរកឃើញថាមានស្នាមប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះ ជាប់នៅនឹងម្រាមដៃអ្នកបោះឆ្នោត ត្រូវជូនអ្នកបោះឆ្នោតនោះ ទៅជួបប្រធាន និងរាយការណ៍អំពីករណីនេះជូនប្រធាន ។

៧.៣០.១១.១ ប្រធានត្រូវអញ្ជើញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ធ្វើការពន្យល់អំពីស្នាមទឹកខ្មៅលុបលាងមិនជ្រះ ដែលជាប់នឹងម្រាមដៃរបស់គាត់ ។

៧.៣០.១១.២ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបាន សមហេតុផលអំពីបញ្ហាទឹកខ្មៅនេះទេ នោះគាត់នឹងត្រូវបានសន្និដ្ឋាន ថា មានបំណងបោះឆ្នោតលើសពីមួយដង ហើយត្រូវទទួលទោស តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៣០.១១.៣ ប្រធានត្រូវដកហូតលិខិតបញ្ជាក់អត្តសញ្ញាណរបស់គាត់ ជាបណ្តោះ អាសន្ន ហើយត្រូវបញ្ជូនករណីនេះទៅ គខ/កប ដើម្បីចាត់វិធាន ការបន្ត ។

៧.៣០.១១.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុ នៃការបោះឆ្នោត និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពីលិខិតបញ្ជាក់ អត្តសញ្ញាណរបស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

៧.៣០.១១.៥ ប្រសិនបើ អ្នកបោះឆ្នោតរូបនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធី នេះ ប្រធាន គកប ឬ/និង គខ/កប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថ កិច្ច ឱ្យឃាត់ខ្លួនជននោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

៧.៣០.១២ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ៧.៣០.១០.៣ លេខាធិការរកមិនឃើញមាន ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន និងរាយការណ៍ អំពីករណីនេះជូនប្រធាន ។

៧.៣០.១២.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិ យាល័យបោះឆ្នោតនេះបានទេ ព្រោះគាត់មិនបានបំពេញគ្រប់គ្រាន់ តាមលក្ខខណ្ឌកំណត់ ដូចចែងក្រោមប្រការ ២.៣០ នៃបទបញ្ជា និងនីតិវិធីនេះ ។

៧.៣០.១២.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធានត្រូវណែនាំ អ្នកបោះឆ្នោតនោះ អំពីទីតាំងការិយាល័យបោះឆ្នោតមួយផ្សេងទៀត ដែលមានទីតាំងក្នុងទីប្រជុំជនខេត្ត ក្រុង ។

៧.៣០.១២.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

៧.៣០.១៣ បន្ទាប់ពីអនុវត្តនីតិវិធីដែលចែងក្រោមចំណុច ៧.៣០.១០ រួចហើយ អនុប្រធាន ត្រូវហែកសន្លឹកឆ្នោតមួយ( ១ )សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រា សម្ងាត់នៅលើផ្នែកខាងខ្នងតាមការកំណត់របស់ គជប និងបត់ជាបួន( ៤ )ផ្នត់ ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់

ផង ។ អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតមិនទាន់ទំនេរនៅឡើយ ។ នៅពេលប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតហើយ អនុប្រធានមិនត្រូវចង្អុលប្រាប់គាត់ឱ្យគូសត្រង់គណបក្សនយោបាយណាមួយឡើយ ប៉ុន្តែត្រូវណែនាំជាសង្ខេបចំពោះអ្នកបោះឆ្នោត អំពីខ្លឹមសារដូចខាងក្រោម ៖

៧.៣០.១៣.១ នេះគឺជាសន្លឹកឆ្នោត ។

៧.៣០.១៣.២ អ្នកត្រូវដើរទៅបន្ទប់សម្ងាត់ ដាក់សន្លឹកឆ្នោតលើផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ហើយជាមួយនឹងប៊ិច ដែលមាននៅទីនោះស្រាប់ ឬប៊ិច ឬស្លាបប៉ាកាផ្ទាល់ខ្លួន ពណ៌អ្វីក៏បាន អ្នកត្រូវគូសសញ្ញាមួយនៅក្នុងប្រអប់បួនជ្រុង ដែលស្ថិតនៅទន្ទឹមនឹងគណបក្សនយោបាយណាមួយ ដែលអ្នកពេញចិត្ត ។ អ្នកមិនអាចប្រើខ្មៅដៃក្នុងការគូសសន្លឹកឆ្នោតបានទេ ។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់ មុននឹងគូសសញ្ញាដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសសញ្ញារួច ។

៧.៣០.១៣.៣ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ ដើម្បីឱ្យសញ្ញា ដែលអ្នកបានគូសបត់ចូលក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

៧.៣០.១៤ ប្រសិនបើ នៅពេលប្រគល់សន្លឹកឆ្នោត អ្នកបោះឆ្នោតសួរអនុប្រធានឱ្យបង្ហាញអំពីគណបក្សនយោបាយជាក់លាក់ណាមួយ នៅលើសន្លឹកឆ្នោត អនុប្រធានត្រូវផ្តល់ដំបូន្មានដល់គាត់ថា គាត់បានរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោត ។

៧.៣០.១៤.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

៧.៣០.១៤.២ ជាទូទៅ អ្នកបោះឆ្នោតមិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ ។ ដោយឡែក អ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ប្រសិនបើមាន មានសិទ្ធិជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយឬស្នើសុំជំនួយពីប្រធានគកប ។

៧.៣០.១៤.៣ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលស្ថិតក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតស្នើសុំឱ្យជួយក៏ដោយ ។

៧.៣០.១៥ បន្ទាប់ពីអ្នកបោះឆ្នោតបានទទួលសន្លឹកឆ្នោត និងបានអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចចែងក្នុងចំណុច ៧.៣០.១៣.២ និង ៧.៣០.១៣.៣ រួចហើយ គកប ត្រូវធានាថា អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយកាន់សន្លឹកឆ្នោតដែលបានគូសសញ្ញានិងបត់ជាផ្នត់ ដើរតម្រង់ទៅកាន់តុដាក់ហិបឆ្នោត ។

៧.៣០.១៥.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចនោះ ដោយដាក់បែរផ្នែក ដែលមានបោះត្រាសម្ងាត់ ទៅរកជំនួយការ និងស៊កវាដោយខ្លួនឯង តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។ ក្នុងករណី អ្នកបោះឆ្នោតជាជនពិការដែលមានអ្នកជំនួយជានីតិជន ឬបានស្នើសុំជំនួយពីប្រធាន គកប នោះ អ្នកជំនួយជានីតិជន ឬប្រធាន គកប ជាអ្នកជួយស៊កសន្លឹកឆ្នោតជំនួសគាត់ ។

៧.៣០.១៥.២ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រម ឱ្យជំនួយការជ្រលក់ផុតក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ ចូលទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ដូចដែលបានចែងក្រោមចំណុច ៧.៣០.១៧ ខាងក្រោម ។

៧.៣០.១៦ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបានគូសសញ្ញានិងបត់ជាផ្នត់រួច បំរុងនឹងស៊កទៅក្នុងហិបឆ្នោត ដូចចែងក្នុងចំណុច ៧.៣០.១៥.១ ខាងលើ ជំនួយការត្រូវពិនិត្យឱ្យប្រាកដថា សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតតែមួយសន្លឹកដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ ។

៧.៣០.១៦.១ ជំនួយការត្រូវរាយការណ៍ ជាបន្ទាន់ជូនប្រធាន គកប ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ត្រូវបានជំនួយការចាប់ភស្តុតាងបានថាមានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និង សន្លឹកឆ្នោតលើសពីមួយ( ១ )សន្លឹក ទៅក្នុងហិបឆ្នោត ។

៧.៣០.១៦.២ ក្នុងករណីដូចចែងក្នុងចំណុច ៧.៣០.១៦.១ ប្រធាន គកប ត្រូវឃាត់អ្នកបោះឆ្នោតនោះមិនឱ្យបោះឆ្នោត រួចចាត់ចែងឱ្យដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវនោះ ឬទាំងនោះ និងដាក់ទៅក្នុងស្រោមសំបុត្រដោយកាខ្វងថា" សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត"

បន្ទាប់មក ត្រូវដកហូតឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ និង ត្រូវចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទ ប្រកាន់ជនល្មើសទៅ គ.ខ/កប ។

៧.៣០.១៦.៣ ប្រសិនបើ ជនដែលបានប្រព្រឹត្តល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គ.ខ/កប ត្រូវបន្តប្តឹងចំពោះជនល្មើសទៅ គ.ជ.ប ដើម្បីចាត់វិធានការតាមច្បាប់ ។

៧.៣០.១៦.៤ ជនល្មើសក្នុងករណីដូចចែងក្នុងចំណុច ៧.៣០.១៦.១ ខាងលើ ត្រូវតែមានទោស ដោយផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៣០.១៧ ទឹកខ្មៅលុបលាងមិនជ្រះ ដែលអាចមើលឃើញច្បាស់ ត្រូវបានបញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ ២០០៦ សម្រាប់បង្ការមិនឱ្យមានការបោះឆ្នោតលើសពីមួយដង ។

៧.៣០.១៧.១ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះចំនួនពីរ( ២ )ដប ។

៧.៣០.១៧.២ ដបទឹកខ្មៅលុបលាងមិនជ្រះមួយ( ១ )ដបត្រូវបានបើកគំរបនៅពេលបើកកិច្ចប្រតិបត្តិការបោះឆ្នោត នៅថ្ងៃបោះឆ្នោត និងបំរុងទុកមួយ( ១ )ដប សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

៧.៣០.១៧.៣ បន្ទាប់ពី អ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួន ទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យជំនួយការជ្រលក់ម្រាមចង្អុលដៃស្តាំរបស់ខ្លួន ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ យ៉ាងហោចណាស់ឱ្យលិចក្រចកម្រាមដៃ ហើយត្រូវទទួលការណែនាំពីជំនួយការ ឱ្យទុករហូតដល់ស្ងួតស្រួលបួល ក្នុងរយៈពេលសាមសិប( ៣០ )វិនាទី ទើបចេញពីការិយាល័យបោះឆ្នោត ។

៧.៣០.១៧.៤ ក្នុងករណីម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើ គាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ

រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ ។

៧.៣០.១៧.៥ រៀងរាល់សាមសិប( ៣០ )នាទីម្តង ដបទឹកខ្មៅលុបលាងមិនជ្រះត្រូវតែបានបិទគម្របយ៉ាងជិត ហើយក្រឡុក ។

៧.៣០.១៧.៦ ប្រសិនបើ គ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម ជំនួយការត្រូវបិទគំរបដបទឹកខ្មៅ ដើម្បីការពារកុំឱ្យវាហួត ។

៧.៣០.១៨ គ្មានជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត អាចជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ ។ អ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយដែលបានជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬបានស្នើសុំជំនួយពីប្រធាន គកប ក្នុងការបោះឆ្នោត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៧.៣០.១៨.១ បន្ទាប់ពី បានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់ តាមនីតិវិធី ដូចចែងក្រោមចំណុច ៧.៣០.១០ ៧.៣០.១៣ និង ៧.៣០.១៥ ខាងលើ ។

៧.៣០.១៨.២ បន្ទាប់ពី បានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយដែលមានបំណងស្នើសុំជំនួយពីប្រធាន គកប ត្រូវទៅជួបប្រធានដោយផ្ទាល់ ។ បន្ទាប់មក ប្រធាន ត្រូវអមដំណើរអ្នកបោះឆ្នោតពិការនោះ អនុវត្តនីតិវិធីជាបន្តបន្ទាប់ដូចចែងក្រោមចំណុច ៧.៣០.១០ ៧.៣០.១៣ និង ៧.៣០.១៥ ខាងលើ ។ ក្នុងករណីនេះ ប្រធានអាចចាត់សមាជិក គកប ណាម្នាក់ឱ្យជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួនផង ។

៧.៣០.១៨.៣ អ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវស្នូរនាំ ឬ/និងប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គកប ឬអ្នកជំនួយដែលខ្លួនជ្រើសរើស តែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

៧.៣០.១៨.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬ សមាជិក គកប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតពិការក្នុងការបោះឆ្នោត

ត្រូវសួរអ្នកបោះឆ្នោតពិការនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗ ធ្វើយ៉ាងណាកុំឱ្យមនុស្សនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ ។ បន្ទាប់មក ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទន្ទឹមនឹងគណបក្សនយោបាយមួយលើសន្លឹកឆ្នោត ដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតពិការ ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចត្រូវនាំអ្នកបោះឆ្នោតពិការទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

៧.៣០.១៨.៥ ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយ ដែលបានជួយអ្នកបោះឆ្នោតពិការ ដូចលក្ខខណ្ឌក្រោមចំណុច ៧.៣០.១៨ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

៧.៣០.១៩ ក្នុងអំឡុងពេលនៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ប្រសិនបើ ក្នុងការិយាល័យបោះឆ្នោតគ្មានអ្នកបោះឆ្នោតទេនោះ ជំនួយការត្រូវមួលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតជាបណ្ដោះអាសន្ន ហើយត្រូវបើកឡើងវិញ នៅពេលមានវត្តមានអ្នកបោះឆ្នោត ។

៧.៣០.២០ គ្មានជនណាម្នាក់ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោត ជាជនពិការដូចចែងក្រោមចំណុច ៧.៣០.១៨ ខាងលើ ។

៧.៣០.២០.១ ជនណាក៏ដោយដូចចែងក្នុងចំណុច ៧.៣០.២០ ខាងលើ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញា នៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គកប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ចរខ្ចាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោត នឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើច្បាប់បោះឆ្នោត ហើយជនល្មើសពាក់ព័ន្ធត្រូវតែបានបណ្ដេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៣០.២០.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

៧.៣០.២០.៣ ប្រសិនបើ ជនប្រព្រឹត្តល្មើសគោលការណ៍សម្ងាត់នៃការបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៧.៣០.២០.១ ខាងលើ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រធាន គកប ត្រូវបញ្ជូនកំណត់ហេតុនៃហេតុការណ៍នោះទៅ គខ/កប ។

៧.៣០.២០.៤ ពេលបានទទួលកំណត់ហេតុ ដូចចែងក្នុងចំណុច ៧.៣០.២០.៣ ភ្លាម គខ/កប ត្រូវធ្វើការស៊ើបអង្កេតអំពីករណីរំលោភនោះ ជាបន្ទាន់ ហើយប្រសិនបើ មានភស្តុតាងបញ្ជាក់ថា ពិតប្រាកដមែន គខ/កប ត្រូវប្តឹងចំពោះជនល្មើសទៅ គជប ដើម្បីចាត់វិធានការតាមច្បាប់ ។

៧.៣០.២១ អ្នកបោះឆ្នោតណាម្នាក់ដែលបានធ្វើឱ្យខូច ឬរហែកសន្លឹកឆ្នោតដោយអចេតនា ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោតមួយ( ១ )សន្លឹកផ្សេងទៀត ពីប្រធាន គកប ។

៧.៣០.២១.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោតមួយ( ១ )សន្លឹកផ្សេងទៀត ត្រូវបត់សន្លឹកឆ្នោតខូចតាមផ្នត់ ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គកប ។

៧.៣០.២១.២ ប្រធាន គកប ត្រូវស៊កសន្លឹកឆ្នោត ដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយ ដែលមានសរសេរបញ្ជាក់នៅខាងក្រៅថា « សន្លឹកឆ្នោតខូច » ។

៧.៣០.២១.៣ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យអនុប្រធាន ផ្តល់សន្លឹកឆ្នោតមួយ( ១ )សន្លឹកផ្សេងទៀតចំពោះអ្នកបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៣០.២១ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

៧.៣០.២១.៤ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយក្នុងប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត តាមការណែនាំ ដូចចែងក្នុងចំណុច ៧.៣០.១០.៤ ខាងលើ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ។

៧.៣០.២១.៥ ក្នុងករណី មានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នា សុំសន្លឹកឆ្នោតមួយ( ១ )សន្លឹកផ្សេងទៀត ដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ប្រធាន គកប អាចសម្រេចមិនព្រមផ្តល់សន្លឹក

ឆ្នោតមួយ( ១ )សន្លឹកផ្សេងទៀតតាមការស្នើសុំទេ និងត្រូវរំលឹក អនុប្រធានឱ្យណែនាំអ្នកបោះឆ្នោត ឱ្យបានច្បាស់លាស់អំពីខ្លឹមសារ ដូចចែងក្រោមចំណុច ៧.៣០.១៣ ខាងលើ ។

៧.៣០.២២ ប្រសិនបើ តំណាងគណបក្សនយោបាយណាម្នាក់ជំទាស់នឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬសេចក្តីសម្រេចណាមួយរបស់ គកប គាត់ត្រូវលើកការជំទាស់នោះដោយផ្ទាល់ទៅប្រធាន គកប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យគាត់ជឿថា មានភាពមិនប្រក្រតី ឬ ការរំលោភច្បាប់ ឬ/និងការរំលោភបទបញ្ជា និងនីតិវិធីក្នុងការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ។

៧.៣០.២២.១ ប្រសិនបើ យល់ឃើញថាសមហេតុសមផល ប្រធាន គកប ត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់របស់តំណាងគណបក្សនយោបាយនោះ ហើយបន្ទាប់មក ពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គកប ដទៃទៀត ។

៧.៣០.២២.២ បន្ទាប់ពីបានពិនិត្យករណីដែលបានលើកជំទាស់ឡើងវិញ ប្រសិនបើ ប្រធាន គកប យល់ព្រមតាមការជំទាស់ ប្រធានត្រូវណែនាំ និងរំលឹកសមាជិក គកប និងអ្នកដែលមានវត្តមាន អំពីខ្លឹមសារពាក់ព័ន្ធ ដែលចែងក្នុងបទបញ្ជានិងនីតិវិធីរបស់ គជប ហើយត្រូវរិះរកវិធីណាមួយដើម្បីដោះស្រាយភាពមិនប្រក្រតីនោះ ។

៧.៣០.២២.៣ ប្រសិនបើ ប្រធាន គកប បដិសេធការជំទាស់ គាត់ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធ ហើយតំណាងគណបក្សនយោបាយមានសិទ្ធិសុំឱ្យកត់ត្រាករណីនៃការជំទាស់នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ប្រសិនបើតំណាងនោះយល់ព្រមផ្តិតមេដៃលើកំណត់ហេតុ ។

៧.៣០.២២.៤ ប្រសិនបើ តំណាងនោះមិនយល់ព្រមផ្តិតមេដៃទេ ករណីនៃការជំទាស់នោះមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតទេ។

៧.៣០.២២.៥ សេចក្តីសម្រេចរបស់ប្រធាន គកប ត្រូវតែមានប្រសិទ្ធភាព ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត ។

៧.៣០.២២.៦ ចំណុច ៧.៣០.២២.៥ ខាងលើ មិនបានច្រានចោលជាមុននូវការដែលតំណាងគណបក្សនយោបាយណាម្នាក់ ចង់បន្តប្តឹងជំទាស់ទៅ គខ/កប អំពីករណីដែលគាត់បានលើកជំទាស់ក្នុងការិយាល័យបោះ

ឆ្នោតនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គកប ហើយមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

៧.៣០.២២.៧ ប្រធាន គកប ត្រូវផ្តល់ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ប្រសិនបើ តំណាងគណបក្សនយោបាយស្នើសុំ សម្រាប់ប្តឹងទៅ គខ/កប ។

៧.៣០.២៣ ប្រសិនបើ អ្នកបោះឆ្នោតណាម្នាក់រំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬ កំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្តី ប្រធាន គកប ត្រូវបញ្ជាអ្នកបោះឆ្នោតរូបនោះឱ្យចេញក្រៅការិយាល័យបោះឆ្នោត និងចេញផុតពីបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ។

៧.៣០.២៣.១ ប្រសិនបើអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន គកប ត្រូវស្នើសុំកម្លាំងសន្តិសុខ ឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនេះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

៧.៣០.២៤ ប្រធាន គកប អាចស្នើសុំកងកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយនៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ប្រសិនបើ កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កំរិត ដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬមានការគំរាមបំភ័យក្នុងការបោះឆ្នោត ឬមានការភ័យខ្លាចដោយសារតែបញ្ហាសន្តិសុខផ្ទាល់ខ្លួន ឬមានអារម្មណ៍ថា ការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានគឺជាសកម្មភាពទាំងឡាយណា ដែលរារាំងអ្នកបោះឆ្នោតមិនឱ្យបោះឆ្នោតបានដោយសេរី ឬធ្វើឱ្យអ្នកបោះឆ្នោតខឹងមួម៉ៅ ឬភិតភ័យ ដូចខាងក្រោមនេះ ៖

៧.៣០.២៤.១ ការបញ្ចេញពាក្យសំដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ ។

៧.៣០.២៤.២ ការបញ្ចេញសម្រែកខ្លាំងៗដែលធ្វើឱ្យអ្នកបោះឆ្នោតមិនអាចស្តាប់ឮសេចក្តីណែនាំ ។

៧.៣០.២៤.៣ ការរុញច្រានដោយប្រើកម្លាំងដៃធ្ងន់ ។

៧.៣០.២៤.៤ ការគប់របស់ផ្សេងៗសំដៅអ្នកបោះឆ្នោតឬការិយាល័យបោះឆ្នោត។

៧.៣០.២៤.៥ ភាពស្រវឹងដែលរំខានដល់អ្នកបោះឆ្នោត ។

៧.៣០.២៤.៦ ការប្រើអាកប្បកិរិយា និងភាសាមិនសមរម្យ ។

៧.៣០.២៤.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ ។

៧.៣០.២៥ ប្រសិនបើ ការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោងដប់ប្រាំ( ១៥:០០ ) រសៀល ហើយនៅតែមានអ្នកបោះឆ្នោតឈរតម្រង់ជួរក្នុងបរិវេណខាងក្នុង ឬឈរខាងក្នុងការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

៧.៣០.២៥.១ ប្រសិនបើ អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គកប មិនអាចបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅមុនម៉ោងដប់ប្រាំ( ១៥:០០ )រសៀលនៃថ្ងៃបោះឆ្នោតបានឡើយ ។

៧.៣០.២៥.២ ប្រសិនបើ អ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គកប អាចប្រកាសបញ្ចប់ការបោះឆ្នោត នៅការិយាល័យរបស់ខ្លួន នៅមុនម៉ោងដប់ប្រាំ( ១៥:០០ )រសៀល ។

៧.៣០.២៦ សមាជិក គកប ទទួលបន្ទុកសណ្តាប់ធ្នាប់ត្រូវដើរប្រមូលយកឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវប្រើសម្រាប់ការបោះឆ្នោត ពីអ្នកបោះឆ្នោតដែលកំពុងឈរក្នុងជួរនៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្នុងជួរនៅខាងក្រោយគេបង្អស់ ។

៧.៣០.២៧ សមាជិក គកប ទទួលបន្ទុកសណ្តាប់ធ្នាប់ត្រូវហៅអ្នកបោះឆ្នោតម្នាក់ម្តងៗ ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោត ។

៧.៣០.២៨ អ្នកបោះឆ្នោតណាក៏ដោយ ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត នៅបរិវេណខាងក្នុងការិយាល័យបោះឆ្នោត នៅវេលាចុងក្រោយនាម៉ោងដប់ប្រាំ( ១៥:០០ )រសៀលទេ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

៧.៣០.២៩ ក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងបរិវេណនៃការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត ប្រធាន គកប អាចសម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោតរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គជប ដូចចែងក្រោមប្រការ ៧.៣២ ខាងក្រោម ។

## ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត

**ប្រការ** ៧.៣១ នៅពេលដែលអ្នកមានសិទ្ធិបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គកប ត្រូវចាត់ឱ្យសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ចាត់វិធានការចាំបាច់ណាមួយ ដើម្បីការពារផ្លូវចូលការិយាល័យបោះឆ្នោត កុំឱ្យមានមនុស្សចេញចូល ។ ប្រធាន គកប ត្រូវប្រកាសបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មក ត្រូវចាត់ចែងការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនិងការបំពេញកំណត់ហេតុនៃការបោះឆ្នោត ដើម្បីត្រៀមអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ព្រមទាំងការវេចខ្ចប់ និងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀតទៅ គខ/កប ។

៧.៣១.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោត ប្រធាន គកប ត្រូវចាត់ការតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោត ដែលក្នុងនោះ ៖

៧.៣១.១.១ ប្រធានត្រូវមូលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ។

៧.៣១.១.២ ប្រធានត្រូវបិទក្រដាសស្តើងមួយ( ១ )សន្លឹកដែលមានចុះហត្ថលេខា របស់ប្រធាន គកប និងតំណាងនៃគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនោះ ។

៧.៣១.១.៣ ប្រធានត្រូវបិទគំរបខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត រួចអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោតនោះ ។

៧.៣១.១.៤ លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) នូវពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់និងលេខនៃសោឃ្លុំទាំងពីរដែលបានចាក់ ដូចចែងក្នុងប្រការ ៧.៣១.១.៣ ខាងលើ ។

៧.៣១.១.៥ ប្រធានត្រូវចាត់វិធានការ ឱ្យសមាជិកទទួលសណ្តាប់ធ្នាប់ការពារឱ្យបានហ្មត់ចត់នូវហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ត្រៀមសំរាប់កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដែលនឹងត្រូវអនុវត្តជាបន្ទាប់ នៅនឹងកន្លែង ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គជប ។

៧.៣១.២ បន្ទាប់មក ស្ថិតនៅចំពោះមុខវត្តមានសមាសភាពទាំងអស់នៃ គកប តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គកប ត្រូវចាត់ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច ដែលក្នុងនោះ ៖

៧.៣១.២.១ លេខាធិការ ត្រូវកំណត់ចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោត ដោយផ្អែកតាមចំនួនគំនូស ដែលគាត់បានគូសនៅក្នុងប្រអប់លើបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៣០.១០.៤ ខាងលើ ។

៧.៣១.២.២ អនុប្រធាន ត្រូវច័ណ្ឌសំគាល់រវាងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើ បន្ទាប់មក រាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូច ដោយឡែកពីគ្នា ។ ប្រសិនបើ ចំនួនសន្លឹកឆ្នោតដែលបានទទួលដូចបញ្ជាក់ក្នុងចំណុច ៧.៣០.៧.២ ខាងលើ ដកចំនួនសន្លឹកឆ្នោតខូច រួមនឹងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៧.៣១.២.១ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) ។

៧.៣១.២.៣ ប្រសិនបើ ក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរ នូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត ហើយអនុប្រធានក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនសន្លឹកឆ្នោត ដែលបានប្រើ សន្លឹកឆ្នោតខូច និងសន្លឹកឆ្នោតមិនបានប្រើ ។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវតួលេខនៃចំនួនដែលខុសគ្នានោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) ។

៧.៣១.២.៤ ភាពខុសគ្នារវាងតួលេខ ដូចបានបញ្ជាក់ក្នុងចំណុច ៧.៣១.២.៣ ខាងលើ មិនត្រូវបានកំណត់ជាភាពមិនប្រក្រតីមួយនោះទេ ។

៧.៣១.២.៥ អនុប្រធានត្រូវដាក់សន្លឹកឆ្នោតមិនទាន់ប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ទៅក្នុងស្បោងជ័រផ្លាស្ទិកឬស្រោមសំបុត្រតែមួយ រួចបិទឱ្យជិត ។

៧.៣១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមជាចាំបាច់ នូវលេខសោឃ្លុំ ដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់កញ្ចប់ " ខ " ដូចចែងក្នុងចំណុច ៧.៣៦.៨.១ ខាងក្រោម ក្នុងកំណត់ហេតុនៃការបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) និងត្រូវបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើ នៃកំណត់ហេតុនេះផង ។ ប្រធាន គកប ត្រូវធានាថាកំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) ចំនួនពីរ( ២ )ច្បាប់ ដែលលេខាធិការបានបំពេញរួច ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងប្រធានផ្ទាល់ ព្រមទាំងមានបោះត្រាផង ។

៧.៣១.៣.១ ប្រធាន គកប ត្រូវដាក់បង្ហាញកំណត់ហេតុ ដូចចែងក្នុងចំណុច ៧.៣១.៣ ខាងលើ ចំពោះតំណាងគណបក្សនយោបាយនិងអញ្ជើញតំណាងទាំងនោះឱ្យចូលរួមពិនិត្យ និងចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុនោះផង ។

៧.៣១.៣.២ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការបោះឆ្នោតពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ ។

៧.៣១.៤ ប្រធាន គកប ត្រូវរៀបចំកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០១ ) ដែលបានចុះហត្ថលេខារួច ដូចចែងក្រោមចំណុច ៧.៣១.៣ ខាងលើ តាមការកំណត់ដូចខាងក្រោម ៖

៧.៣១.៤.១ ដាក់មួយ( ១ )ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត...ផ្ញើជូន គជប " ។

៧.៣១.៤.២ ដាក់មួយ( ១ )ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត...ផ្ញើជូន គខ/កប " ។

៧.៣១.៥ បន្ទាប់មក ប្រធាន គកប ត្រូវរៀបចំដាក់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ដែលមានបោះពុម្ពសម្គាល់ថា " កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតលេខ... នូវ ៖

៧.៣១.៥.១ ស្រោមសំបុត្រមានដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៣១.៤.១ ខាងលើ ។

៧.៣១.៥.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។

៧.៣១.៥.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " ។

៧.៣១.៥.៤ ស្បោងផ្លាស្ទិកឬស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនទាន់ប្រើនិងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

៧.៣១.៥.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

៧.៣១.៥.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " ( ប្រសិនបើមាន ) ។

៧.៣១.៥.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត ( ប្រសិនបើមាន ) ។

៧.៣១.៦ ប្រធាន គកប ត្រូវពិនិត្យឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រនិងស្បោងផ្លាស្ទិកដាក់សម្ភារៈឯកសារ ដូចចែងក្រោមចំណុច ៧.៣១.៥ ខាងលើ ត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " ។ ប្រធាន គកប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " មិនទាន់ត្រូវបិទភ្ជិតនៅពេលនេះនៅឡើយ ហើយនឹងត្រូវបិទភ្ជិត ដោយការសុវត្ថិភាពបំរុងស្រាប់ លុះណាតែ គកប បានបញ្ចប់ការរាប់សន្លឹកឆ្នោតនិងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសំភារៈឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធរួចរាល់សិន ។

៧.៣១.៧ ប្រធាន គកប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " ដូចចែងក្នុងចំណុច ៧.៣១.៦ និងស្រោមសំបុត្រ ដូចចែងក្នុងចំណុច ៧.៣១.៤.២ ត្រូវបានបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

៧.៣១.៨ ប្រធាន គកប ត្រូវចាត់ចែងសមាជិក ឱ្យរៀបចំទុកដាក់ដបទឹកខ្មៅលុបលាងមិនជ្រះ និងសម្ភារៈឯកសារដែលនៅសល់ ព្រមទាំងវេចខ្ចប់ឱ្យបានល្អ ក្នុងកេសស័ង្កសីសម្រាប់ត្រៀមបញ្ជូនទៅ គខ/កប ។ ទន្ទឹមនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំងពីរ( ២ ) រួចច្រកដោយឡែក ទៅក្នុងការុងនីឡុងដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ ដូចនៅពេលប្រគល់ជូន គកប នាពេលដំបូង ។

**ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន**

**ប្រការ** ៧.៣២ មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ស្ថិតក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត គជប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះបាន ។ ប្រសិនបើ ករណីនេះកើតមាននៅថ្ងៃបោះឆ្នោត ប្រធាន គកប មានសិទ្ធិក្នុងការសំរេច ហើយ ត្រូវរាយការណ៍ជាបន្ទាន់មក គជប តាមរយៈ គខ/កប ។

៧.៣២.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ។ ប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ដូចជាករណីណាមួយ ក្នុងចំណោមករណីខាងក្រោម ៖

៧.៣២.១.១ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងទៀត ។

៧.៣២.១.២ អសន្តិសុខជាសាធារណៈ ។

៧.៣២.១.៣ ការដួលរលំអាគារសម្រាប់បំរើការបោះឆ្នោត ដោយយថាហេតុណាមួយ ឬអគ្គីភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នា ដែលនាំឱ្យមានគ្រោះថ្នាក់ ។

៧.៣២.១.៤ ការរាំងស្ទះផ្នែករដ្ឋបាល ដែលមិនអាចឱ្យការបោះឆ្នោតដំណើរការទៅបាន ។

៧.៣២.២ ប្រសិនបើនៅមុនថ្ងៃបោះឆ្នោត មានកើតករណីណាមួយនៃប្រធានស័ក្តិឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដូចមានចែងក្រោមចំណុច ៧.៣២.១ ប្រធាន គកប ត្រូវរាយការណ៍ជាបន្ទាន់អំពីស្ថានភាពជាក់ស្តែងទៅ គជប តាមរយៈ គខ/កប ។

៧.៣២.២.១ គខ/កប ត្រូវពិនិត្យនិងវាយតម្លៃសភាពការណ៍ច្បាស់លាស់ដោយផ្តល់យោបល់ និងរាយការណ៍ជាបន្ទាន់ជូន គជប ដើម្បី គជប សម្រេចអំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោតនោះ ។

៧.៣២.២.២ គជប ត្រូវសម្រេចបើកឬមិនបើកការិយាល័យបោះឆ្នោត និងត្រូវជូនដំណឹងបន្ទាន់ទៅ គខ/កប ដើម្បីចាត់ចែងបន្ត ។

៧.៣២.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើមានករណីណាមួយនៃប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដូចមានចែងក្រោមចំណុច ៧.៣២.១ ខាងលើ ប្រធាន គកប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត និងត្រូវរាយការណ៍ ជាបន្ទាន់ជូន គជប តាមរយៈ គខ/កប ។

៧.៣២.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានសម្រេចបិទក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដោយ គជប ឬ គកប ដែលបានប្រគល់សិទ្ធិ ត្រូវតែបិទរហូតពេញមួយថ្ងៃ ។

៧.៣២.៥ ក្នុងករណីការិយាល័យបោះឆ្នោតណាមួយត្រូវបានសម្រេចមិនបើក ឬ ត្រូវបិទក្នុងអំឡុងពេលបោះឆ្នោត ដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គជប ត្រូវរាយការណ៍ជាបន្ទាន់ទូលថ្វាយព្រះមហាក្សត្រ និងជូនព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល និងជូនក្រុមប្រឹក្សាធម្មនុញ្ញ ។

៧.៣២.៦ ក្នុងករណី មានការិយាល័យបោះឆ្នោតដែលមិនបានបើក ឬ ត្រូវបានបិទក្នុងអំឡុងពេលបោះឆ្នោត ដោយករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គខ/កប ត្រូវចាត់ចែងណែនាំអំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ ដោយត្រូវ ៖

៧.៣២.៦.១ ជូនដំណឹងដល់អ្នកបោះឆ្នោត ដែលត្រូវបោះឆ្នោតនៅការិយាល័យនោះ អំពីការមិនបើក ឬការបិទការិយាល័យដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។

៧.៣២.៦.២ ចាត់ឱ្យ គកប វេចខ្ចប់ហិបឆ្នោតមានសន្លឹកឆ្នោត ដែលបានបោះរួចនៅខាងក្នុង សន្លឹកឆ្នោតមិនទាន់ប្រើ ព្រមទាំងសម្ភារៈបរិក្ខារនិងឯកសារពាក់ព័ន្ធផ្សេងទៀត សម្រាប់បំរើការបោះឆ្នោត ដោយត្រូវបំពេញលិខិតប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ផង រួចត្រូវបញ្ជូនមករក្សាទុកនៅ គខ/កប ។

៧.៣២.៦.៣ ចាត់ឱ្យ គកប ធ្វើកំណត់ហេតុដោយឡែកស្តីពីការមិនបើកឬការបិទការិយាល័យបោះឆ្នោតនោះ ដែលត្រូវបញ្ជូនមក គខ/កប រួមនឹងសម្ភារៈឯកសារដូចចែងក្នុងចំណុច ៧.៣១.៦.២ ខាងលើ ។

៧.៣២.៦.៤ ផ្អែកលើកំណត់ហេតុរបស់ គកប គខ/កប ត្រូវរាយការណ៍ជាបន្ទាន់ជូន គជប ។

៧.៣២.៦.៥ ជូនដំណឹងដល់ គកប នៃការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬ/និងត្រូវបានបិទថា គកប ពាក់ព័ន្ធត្រូវរំសាយស្របតាមកិច្ចសន្យា ។

៧.៣២.៧ ក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោត នៅក្រោយពេលបិទការបោះឆ្នោត ព្រមទាំងបានធ្វើកំណត់ហេតុនៃការបោះឆ្នោត និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោតរួចហើយ ដូចចែងក្រោមប្រការ ៧.៣១ ខាងលើ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារពាក់ព័ន្ធនៅរក្សាបានល្អនោះ ប្រធាន គកប ត្រូវបញ្ជូនសម្ភារៈឯកសារបោះឆ្នោតទាំងនោះទៅ គខ/កប ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។

៧.៣២.៧.១ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកំណត់ហេតុ នៃការបោះឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៣២.៧ ខាងលើ គខ/កប ត្រូវចាត់ចែង គកប ពាក់ព័ន្ធ ឬមន្ត្រីបោះឆ្នោតផ្សេងទៀត ឱ្យបំពេញកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅលេខាធិការដ្ឋាននៃ គខ/កប ឬនៅកន្លែងមានសុវត្ថិភាព ដែលកំណត់ដោយ គជប ដោយត្រូវអនុវត្តតាមនីតិវិធីនិងការកំណត់ ដូចចែងក្រោមប្រការ ៧.៣៤ និង ៧.៣៥ ខាងក្រោម ។

៧.៣២.៨ ក្នុងករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត ព្រមទាំងបានធ្វើកំណត់ហេតុនៃការបោះឆ្នោត និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោតរួចហើយ ដូចចែងក្រោមប្រការ ៧.៣១ ខាងលើ ប៉ុន្តែហិបឆ្នោត និងសន្លឹកឆ្នោតនៅខាងក្នុង ព្រមទាំងកំណត់ហេតុនៃការបោះឆ្នោតនិងឯកសារពាក់ព័ន្ធត្រូវបំផ្លាញនិងខូចខាតនោះ ប្រធាន គកប ត្រូវបញ្ជូនសម្ភារៈឯកសារបោះឆ្នោតទាំងនោះទៅ គខ/កប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។ បន្ទាប់ពីបានទទួលហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុងនិងកំណត់ហេតុនៃការបោះឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោត ខាងលើ គខ/កប ត្រូវរក្សាទុកឱ្យបានល្អសំរាប់វេចខ្ចប់បញ្ជូនទៅ គជប និងត្រូវកំណត់សន្លឹកឆ្នោត ដែលបានបោះរួចមានក្នុងហិបឆ្នោត ដូចចែងក្នុងចំណុច ៧.៣២.៨ ខាងលើជាមោឃៈ ដោយមិនត្រូវរាប់និងបូកសរុបបញ្ចូលក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងឡើយ។

៧.៣២.៩ នៅពេលទទួលបានរបាយការណ៍ស្តីពីការមិនបើក ឬ/និងការបិទការិយាល័យបោះឆ្នោត ដោយមូលហេតុប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដូច

ចែងក្នុងចំណុច ៧.៣២.២ ៧.៣២.៣ និង ៧.៣២.៤ ខាងលើ គខ/កប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គជប ដើម្បីសុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ឬទាំងនោះ ។

៧.៣២.១០ ចំពោះការិយាល័យបោះឆ្នោតផ្សេង ដែលមិនត្រូវបានបិទនៅក្នុងខេត្ត ក្រុង គកបពាក់ព័ន្ធត្រូវចាត់ចែងអនុវត្តដំណើរការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យរបស់ខ្លួន ការវេចខ្ចប់ និងការបញ្ជូនសម្ភារៈឯកសារបោះឆ្នោតទៅ គខ/កបជាធម្មតា តាមការកំណត់ ដូចចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ។

៧.៣២.១១ គខ/កប ត្រូវចាត់ចែងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុង ពីគ្រប់ការិយាល័យបោះឆ្នោតដែលបានដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតជាធម្មតា និងវេចខ្ចប់បញ្ជូនកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនិងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គជប តាមការកំណត់និងនីតិវិធីដូចចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ទោះបីមានការិយាល័យបោះឆ្នោតមួយ ឬច្រើនត្រូវរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គខ/កប ក៏ដោយ ។ នៅក្រោយពេលការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតដែលមិនបានបើក ឬត្រូវបានបិទ ឬដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គជប ប្រសិនបើមានត្រូវបានអនុវត្តចប់សព្វគ្រប់ហើយ ប្រធាន គខ/កប ត្រូវចាត់ចែងបូកលទ្ធផលនៃការបោះឆ្នោតសាជាថ្មី បញ្ចូលទៅក្នុងលទ្ធផលសរុបនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ព្រមទាំងវេចខ្ចប់ និងបញ្ជូនសម្ភារៈឯកសារបោះឆ្នោតនៃការិយាល័យដែលបានបោះឆ្នោតសាជាថ្មីទៅ គជប តាមក្រោយ ។

**ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និងត្រូវបានបិទនៅថ្ងៃបោះឆ្នោតដោយសារករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ឬ/និងដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គជប**

**ប្រការ ៧.៣៣** ការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទតាមលក្ខខណ្ឌដូចចែងក្នុងចំណុច ៧.៣២.៩ ខាងលើ ឬដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គជប ដូចចែងក្នុងចំណុច ៧.៤៦.៦ ខាងក្រោម គជប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេលមិនលើសពីប្រាំបី( ៨ )ថ្ងៃបន្ទាប់ពីថ្ងៃដែល គជប ប្រកាសចាត់ទុកជាមោឃៈនូវដំណើរការនៃការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

គជប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីនៅទីតាំងការិយាល័យបោះឆ្នោតដដែល ឬនៅទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់ នៅទីប្រជុំជនខេត្ត ក្រុងដែល គជប យល់ថាមានសន្តិសុខ និងសុវត្ថិភាពល្អ ។ ក្នុងករណី មិនអាចរៀបចំការបោះឆ្នោតសាជាថ្មី តាមកាលកំណត់ខាងលើ ដោយមូលហេតុស្ថានភាពនៃប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន មិនទាន់វិលមករកប្រក្រតីភាពនៅឡើយ គជប មានសិទ្ធិសំរេចឱ្យបន្តរៀបចំ ឬមិនបាច់រៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យនោះ ឬទាំងនោះ ។

៧.៣៣.១ គជប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងនៃការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មី និងណែនាំ គខ/កប ឱ្យផ្សព្វផ្សាយ និងបិទផ្សាយនៅលេខាធិការដ្ឋាននៃ គខ/កប និងនៅទីតាំងការិយាល័យ ដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិចបី( ៣ )ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

៧.៣៣.២ ដើម្បីគ្រប់គ្រង និងចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី គជប ត្រូវណែនាំដោយឡែកចំពោះ គខ/កប និង គកប ពាក់ព័ន្ធអំពីការងារជាក់ស្តែងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី ។

៧.៣៣.៣ គជប ត្រូវប្រគល់ភារកិច្ចឱ្យ គខ/កប ធ្វើការជ្រើសរើសសមាសភាព គកប សម្រាប់ការបោះឆ្នោតសាជាថ្មី ដោយជ្រើសរើសសមាសភាព គកប ដែលបំរើការងារនៅការិយាល័យបោះឆ្នោត ដែលត្រូវបិទនោះ ឬធ្លាប់បំរើការងារនៅការិយាល័យបោះឆ្នោតផ្សេងទៀត ដើម្បីងាយស្រួលដោយពុំចាំបាច់ធ្វើការបណ្តុះបណ្តាលជាថ្មី ។

៧.៣៣.៤ អាណត្តិរបស់ គកប សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបញ្ចប់យោងតាមកិច្ចសន្យាបំរើការងារ ដែលកំណត់ដោយ គជប ។

៧.៣៣.៥ សិទ្ធិអំណាច និងភារកិច្ចរបស់ គខ/កប និង គកប សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវអនុលោមតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជានិងនីតិវិធីនេះ និងតម្រូវការជាក់ស្តែងនៃការបោះឆ្នោតសាជាថ្មី ដែលកំណត់ដោយ គជប ។

៧.៣៣.៦ អ្នកបោះឆ្នោតទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតសាជាថ្មី ទោះបីជាអ្នកទាំងនោះបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

៧.៣៣.៧ ដើម្បីបោះឆ្នោតបានក្នុងការបោះឆ្នោតសាជាថ្មី អ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែងនិងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងទាំងពីរភេទត្រូវមាន ៖

៧.៣៣.៧.១ ឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនោះ ។

៧.៣៣.៧.២ ឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដូចបានចែងនៅក្នុងចំណុច ៧.៣០.៩.១ ខាងលើ ។

៧.៣៣.៨ ចំពោះអ្នកបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មី ប៉ុន្តែបានបាត់និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត មានសិទ្ធិស្នើសុំ និងទទួលបានលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បោះឆ្នោត ដែលចេញដោយមេឃុំ ចៅសង្កាត់ ។ អាជ្ញាធរឃុំ សង្កាត់ត្រូវសំរួលចេញលិខិតបញ្ជាក់អត្តសញ្ញាណជូនអ្នកស្នើសុំរហូតដល់មួយ( ១ )ថ្ងៃមុន ថ្ងៃបោះឆ្នោតសាជាថ្មី ដោយមិនតម្រូវឱ្យបង់ប្រាក់ឡើយ ។

៧.៣៣.៩ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលប្រើប្រាស់ក្នុងការបោះឆ្នោតអសកល ត្រូវយកមកប្រើប្រាស់សម្រាប់ការបោះឆ្នោតសាជាថ្មី ។ គខ/កប និង គកប ពាក់ព័ន្ធ ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតនេះ នៅមួយ( ១ )ថ្ងៃមុនថ្ងៃបោះឆ្នោត នៅលេខាធិការដ្ឋាននៃ គខ/កប មួយ( ១ )ច្បាប់ នៅទីកន្លែងណាមួយក្នុងទីប្រជុំជនខេត្ត ក្រុងមួយ( ១ )ច្បាប់ និងនៅទីតាំងការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មីមួយ( ១ )ច្បាប់ ។

៧.៣៣.១០ សមាសភាពតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតនោះ នៅក្នុងការបោះឆ្នោតអសកល ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី ។

៧.៣៣.១១ គជប ត្រូវបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មី តាមគំរូសន្លឹកឆ្នោតលើកមុនសម្រាប់ខេត្ត ក្រុងនៃមណ្ឌលភូមិភាគពាក់ព័ន្ធ នៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ ។

៧.៣៣.១២ គជប ត្រូវផ្គត់ផ្គង់សម្ភារៈបរិក្ខារនិងឯកសារបំរើការបោះឆ្នោតសាជាថ្មី ឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ តាមរយៈ គខ/កប ។

៧.៣៣.១៣ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងខេត្ត ក្រុងនៃមណ្ឌលភូមិភាគពាក់ព័ន្ធ ត្រូវហាមឃាត់ ។

៧.៣៣.១៤ នីតិវិធីនៃការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តតាមនីតិវិធីនៃការបោះឆ្នោត ដូចបានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ និងដែលបានបញ្ញត្តិសម្រាប់ការបោះឆ្នោតអសកលដែរ ។ ដោយឡែក ការជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ ត្រូវធ្វើលើម្រាមដៃឆ្វេង ។

៧.៣៣.១៥ នៅពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតរបស់ខ្លួន គកប ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការបញ្ជូនសម្ភារៈឯកសារបោះឆ្នោតទៅ គខ/កប តាមនីតិវិធី ដូចដែលបានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ និងដែលបានបញ្ញត្តិសម្រាប់ការបោះឆ្នោតអសកលដែរ ។

៧.៣៣.១៦ គខ/កប ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យ ដែលត្រូវបោះឆ្នោតសាជាថ្មីដោយឡែក និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ដែលត្រូវបូកបញ្ចូលគ្នានូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យដែលបានបើកបោះឆ្នោតជាធម្មតា និងលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតសាជាថ្មី រួចបិទផ្សាយលទ្ធផលនេះ ស្របតាមបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.៣៣.១៧ គខ/កប ត្រូវវេចខ្ចប់និងបញ្ជូនកំណត់ហេតុនិងសំភារៈឯកសារនៃការិយាល័យមួយ ឬច្រើនក្នុងខេត្ត ក្រុងដែលបានបោះឆ្នោតសាជាថ្មីទៅ គជប ដោយភ្ជាប់ជាមួយនូវសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ និងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ។ ការវេចខ្ចប់និងបញ្ជូនកំណត់ហេតុ និងសំភារៈឯកសារនៃការិយាល័យមួយឬច្រើនដែលបានបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តតាមលំនាំការកំណត់ និងនីតិវិធី ដូចដែលត្រូវអនុវត្តសំរាប់ការវេចខ្ចប់និងបញ្ជូនកំណត់ហេតុនិងសំភារៈឯកសារនៃការិយាល័យ ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គខ/កប សំរេចព្យួរជាបណ្តោះអាសន្ន ។

៧.៣៣.១៨ ក្នុងចន្លោះពេលពីដំណើរការនៃការបោះឆ្នោតសាជាថ្មី រហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ និងសវនាការដោះស្រាយបណ្តឹងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តដូចគ្នានឹងការកំណត់សម្រាប់ការបោះឆ្នោតអសកល ដែលមានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ។

**ការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ** ៧.៣៨ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានបញ្ញត្តិឱ្យអនុវត្តបែបបទ និងនីតិវិធីក្នុងការរាប់សន្លឹកឆ្នោត ដោយអនុលោមតាមច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការរាប់សន្លឹកឆ្នោតត្រូវធ្វើដោយផ្ទាល់នៅការិយាល័យបោះឆ្នោតនីមួយៗដែលមានទីតាំងនៅទីប្រជុំជនខេត្ត ក្រុង នៅពេលបន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារសភាពការណ៍អសន្តិសុខ ហើយដែល គជប បានសម្រេចឱ្យ គខ/កប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យនោះនៅលេខាធិការដ្ឋាននៃ គខ/កប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព ។

៧.៣៨.១ ក្នុងករណីដែលការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គកប នីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ។ ក្នុងករណីនេះ ប្រធាន គកប ដែលទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោត ត្រូវចាត់វិធានការដោយអនុវត្តតាមប្រការ ៧.២៩ ខាងលើ និងត្រូវចាត់ចែងឱ្យប្រមូលទុកដាក់សម្ភារៈឯកសារ ដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ។ បន្ទាប់មក ប្រធាន គកប ត្រូវចាត់ចែងឱ្យរៀបចំឡើងវិញនូវគំរូប្លង់បន្ទប់សំរាប់គោលបំណងនៃការរាប់សន្លឹកឆ្នោត ដែលក្នុងនោះត្រូវ ៖

៧.៣៨.១.១ រៀបចំតុធំមួយឬតុតូចច្រើនផ្គុំគ្នា និងកៅអីបួនសម្រាប់សមាសភាព គកប ទទួលខុសត្រូវរាប់សន្លឹកឆ្នោត ដោយដាក់នៅចំកណ្តាលបន្ទប់ដើម្បីអាចឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុ ក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត ។

៧.៣៨.១.២ លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព " ក " ដូចបានបញ្ជាក់ក្នុងចំណុច ៧.៣១.៥ ខាងលើ និងរាល់សម្ភារៈឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតមកដាក់នៅលើតុ ត្រង់កន្លែងប្រធានអង្គុយ ។

៧.៣៨.១.៣ ចាត់សមាជិក គកប ទទួលបន្ទុកសណ្តាប់ធ្នាប់ ឱ្យការពារមាត់ទ្វារកុំឱ្យមានអ្នកចេញចូល និងមើលថែរក្សាសុវត្ថិភាពសម្ភារៈឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត ។

៧.៣៤.២ ការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ត្រូវធ្វើតែមួយកន្លែងសម្រាប់ការិយាល័យបោះឆ្នោតមួយ ដែលប្រសិនបើចាប់ផ្ដើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។ ប្រធាន គកប ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់ ។

៧.៣៤.២.១ ក្នុងដំណើរការនៃការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោត តំណាងនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោត ។

៧.៣៤.២.២ តំណាងគណបក្សនយោបាយឬអ្នកសង្កេតការណ៍ ដែលបានការអនុញ្ញាតចូលរួមសង្កេតមើលដំណើរការនៃការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតនៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ អាចផ្លាស់ប្ដូរតំណាងបំរុងរបស់ខ្លួន ប្រសិនមាន ឱ្យបំពេញភារកិច្ចជំនួស ។

៧.៣៤.៣ នៅក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គកប ត្រូវអង្គុយនៅចុងតុម្ខាងនិងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាននិងជំនួយការអង្គុយនៅអមសងខាងតុទល់មុខគ្នា ។ ស្ថិតនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងបន្ទប់ ប្រធាន គកប ត្រូវប្រកាសចាប់ផ្ដើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៧.៣៤.៣.១ បំរុងទុកនៅក្បែរខ្លួនគាត់នូវ ៖

- កញ្ចប់សុវត្ថិភាព " ក " ដែលមានស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងសំភារៈឯកសារបោះឆ្នោតផ្សេងទៀត ។
- ទម្រង់បែបបទលេខ ១១១៥ សម្រាប់ស្រង់វត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។
- ទម្រង់បែបបទលេខ ១២០២ សម្រាប់ចែកជូនតំណាងគណបក្សនយោបាយសម្រាប់បំពេញពាក្យបណ្ដឹងប្រសិនបើគាត់ស្នើសុំ ។
- ស្បោងផ្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
- ម៉ាស៊ីនគិតលេខ ។
- កៅស៊ូកង ។

៧.៣៨.៣.២ ហុចទៅឱ្យអនុប្រធាននូវតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) មួយ( ១ )ច្បាប់ ។

៧.៣៨.៣.៣ ហុចទៅលេខាធិការនូវទម្រង់បែបបទលេខ ១១០២ សំរាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត / រាប់សន្លឹកឆ្នោត តារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) មួយ( ១ )ច្បាប់ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " ក " ។

៧.៣៨.៣.៤ ប្រគល់ឱ្យជំនួយការនូវប៊ិចហ្វឺតធំមួយ( ១ )ដើម និងផ្ទាំងក្រដាសធំសំរាប់កត់ត្រាសម្លេងឆ្នោតចំនួនមួយ( ១ )ផ្ទាំង ។

៧.៣៨.៣.៥ ចាត់លេខាធិការឱ្យចាប់ផ្តើមបំពេញកំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត / រាប់សន្លឹកឆ្នោត ដោយចម្លងនូវតួលេខ នៃចំនួនសន្លឹកឆ្នោតដែលបានទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចហើយ ដូចចែងក្រោមចំណុច ៧.៣១.២ ខាងលើ និងមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ។

៧.៣៨.៤ ស្ថិតនៅចំពោះមុខ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គកប ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំងពីរដែលចាក់ជាប់នឹងគំរបខាងក្រៅនៃហិបឆ្នោតស្ថិតនៅដដែល រួចកាត់ផ្តាច់សោឃ្លុំទាំងនេះ ដោយកន្ត្រៃឬកូនកាំបិតដែលអាចរកបានដោយខ្លួនឯង និងបើកគំរបខាងក្រៅចេញ ។ បន្ទាប់មក ប្រធាន គកប ត្រូវបន្តត្រួតពិនិត្យផ្ទៀងផ្ទាត់សោឃ្លុំ ដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគំរបខាងក្នុងនៃហិបឆ្នោត និងក្រដាសស្តើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ រួចកាត់ផ្តាច់សោឃ្លុំនោះ និងហែកក្រដាសនេះចោល ។ ចុងក្រោយ ប្រធាន គកប ត្រូវបើកគំរបខាងក្នុងនៃហិបឆ្នោត និងចាក់សន្លឹកឆ្នោតចេញឱ្យអស់ពីហិបឆ្នោត ដាក់នៅលើតុត្រង់ចន្លោះអនុប្រធាននិងជំនួយការ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់ ។

៧.៣៨.៤.១ ជំនួយការ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត ប្រសិនបើមាន ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្រមួយដោយឡែក ។

៧.៣៤.៤.២ លេខាធិការត្រូវកត់ត្រាអំពីករណីដូចចែងក្នុងចំណុច ៧.៣៤.៤.១ ខាងលើ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) ។

៧.៣៤.៥ ប្រធាន គកប ត្រូវបង្គាប់អនុប្រធាន និងជំនួយការឱ្យលា និងតំរៀបសន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុងមួយ(១)បាច់ ម្ភៃប្រាំ(២៥)សន្លឹក នៅពំនូកទី ១ ហើយដាក់សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ប្រសិនបើមាន ក្នុងពំនូកទី ២ ។ បន្ទាប់មក អនុប្រធាននិងជំនួយការត្រូវរាប់សន្លឹកឆ្នោតទាំងពីរពំនូក រួចរាយការណ៍ជូនប្រធាន គកប អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ ។

៧.៣៤.៥.១ ក្នុងករណី ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងដែលបានរាប់ខាងលើ មានចំនួនសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬស្មើនឹងចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង ដកនឹងផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៧.៣៤.៥.២ ប្រសិនបើ ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួនតិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬម្យ៉ាងមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួនសន្លឹកឆ្នោតរួមដែលបានទទួលជាក់ស្តែង ដកនឹងផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនទាន់ប្រើនោះ ប្រធាន គកប ត្រូវរាប់សន្លឹកឆ្នោតដូចបញ្ជាក់ក្នុងចំណុច ៧.៣៤.៥ ខាងលើឡើងវិញជាលើកទីពីរ ។

៧.៣៤.៥.៣ ប្រសិនបើបន្ទាប់ពីប្រធាន គកប បានរាប់ឡើងវិញហើយ តួលេខនៃចំនួនសន្លឹកឆ្នោត នៅតែមានភាពខុសគ្នាដដែល ដូចបញ្ជាក់ក្នុងចំណុច ៧.៣៤.៥.២ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៧.៣៤.៥.៤ ប្រធាន គកប ត្រូវប្រកាសប្រាប់តំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់ដូចចែងក្នុងចំណុច

៧.៣៤.៥.១ ៧.៣៤.៥.២ និង ៧.៣៤.៥.៣ ខាងលើ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលនោះបាន។

៧.៣៤.៥.៥ អនុប្រធានហុចសន្លឹកឆ្នោតពំនូកទី ២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ប្រសិនបើមាន ជូនប្រធាន គកប ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់ ជាពំនូកសន្លឹកឆ្នោតមិនបានការនិងមិនទាន់ច្បាស់លាស់ ។

៧.៣៤.៥.៦ អនុប្រធានត្រូវហុចសន្លឹកឆ្នោតពំនូកទី ១ ដែលខ្ទាស់ជាបាច់ ក្នុងមួយបាច់ម្ភៃប្រាំ( ២៥ )សន្លឹក ជូនប្រធាន គកប ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់ ។

៧.៣៤.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គកប ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ដែលជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ហើយបន្ទាប់មក ត្រូវប្រកាសសន្លឹកឆ្នោត ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។ ប្រធាន គកប ត្រូវធានាថា កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវបានអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម ៖

៧.៣៤.៦.១ ប្រធាន គកប ត្រូវយកសន្លឹកឆ្នោតម្តងមួយ( ១ )សន្លឹក ពីពំនូកទី ១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការឬជាសន្លឹកឆ្នោតមិនបានការ ដោយផ្អែកតាមការកំណត់ ដូចចែងក្រោមប្រការ ៧.៣៥ ខាងក្រោម ព្រមទាំងត្រូវដាក់បង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចមើលឃើញច្បាស់ ។

៧.៣៤.៦.២ ប្រសិនបើ ប្រធាន គកប កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថាជាសន្លឹកឆ្នោតមិនបានការ រួចដាក់សន្លឹកឆ្នោតនោះ នៅពំនូកសន្លឹកឆ្នោតមិនបានការនិងមិនទាន់ច្បាស់លាស់ នៅខាងស្តាំដៃ ។

៧.៣៤.៦.៣ ប្រសិនបើ ប្រធាន គកប កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗ អំពីគណបក្សនយោបាយ ដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះ ទៅតាមពំនូកដោយឡែក សម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ ។

៧.៣៤.៦.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គកប អនុប្រធាន និងលេខាធិការត្រូវគូសពិន្ទុមួយ( ១ )សម្រាប់សន្លឹកឆ្នោតមួយ( ១ ) សន្លឹក ដែលគណបក្សនយោបាយណាមួយ ត្រូវបានទទួល តាមរបៀបដែល គជប បានណែនាំនៅលើតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) ។ ទន្ទឹមនឹងនេះ ជំនួយការត្រូវប្រើប៊ិចហ្វឺតគូសពិន្ទុមួយ( ១ ) នៅលើផ្ទាំងក្រដាសធំដែលអាចថ្មៃប្រឌិតបិទភ្ជាប់នឹងជញ្ជាំង ឬគូសនៅលើក្ដារខៀន ។

៧.៣៤.៦.៥ ក្នុងករណី មានការជំទាស់ចំពោះសន្លឹកឆ្នោតដែលបានផ្ទៀងផ្ទាត់រាប់តាមចំណុច ៧.៣៤.៦.៣ ខាងលើ ប្រធាន គកប ត្រូវដាក់សន្លឹកឆ្នោត ដែលមានការជំទាស់នោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការនិងមិនទាន់ច្បាស់លាស់ ដូចចែងក្នុងចំណុច ៧.៣៤.៦.២ ដែលនឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ និងកំណត់ម្ដងទៀត ជាចុងក្រោយដោយអនុវត្តតាមចំណុច ៧.៣៤.៦.៦ ខាងក្រោម ។

៧.៣៤.៦.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី ១ ប្រធាន គកប ត្រូវបន្តយកសន្លឹកឆ្នោតម្ដងមួយ( ១ )សន្លឹកៗពីពំនូកសន្លឹកឆ្នោតមិនបានការ និងមិនទាន់ច្បាស់លាស់ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្ដងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថា ជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។ ប្រសិនបើ ប្រធាន គកប សម្រេចថា ជាសន្លឹកឆ្នោតបានការវិញ ត្រូវបន្តអនុវត្តចំណុច ៧.៣៤.៦.៤ ខាងលើ ។

៧.៣៤.៧ ក្នុងអំឡុងពេលនៃការពិនិត្យផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោត ដូចចែងក្នុងចំណុច ៧.៣៤.៦.៣ និង ៧.៣៤.៦.៦ ខាងលើ ប្រសិនបើប្រធាន គកប កត់សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងទៅតាមសេចក្ដីណែនាំ ដូចបានបញ្ជាក់ក្នុងប្រការ ៧.៣៥ ខាងក្រោម គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គកប អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្ដងទៀត ដើម្បីកំណត់ចុងក្រោយថា ពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

៧.៣៤.៧.១ ទោះបីប្រធាន គកប កំណត់ថាជាសន្លឹកឆ្នោតបានការក្ដី ឬជាសន្លឹកឆ្នោតមិនបានការក្ដី ប្រធាន គកប ត្រូវប្រកាសឱ្យឮៗអំពីហេតុផល

សម្រាប់សន្លឹកឆ្នោតនោះនិងត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះនិងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធាន ចំពោះសន្លឹកឆ្នោតនោះ ។ ក្នុងករណីនេះ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ ។

៧.៣៤.៧.២ ប្រសិនបើ តំណាងគណបក្សនយោបាយណាម្នាក់ មិនឯកភាពជាមួយនឹងសេចក្តីសម្រេចរបស់ប្រធាន គគប ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការខាងលើ តំណាងនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារនិងហេតុផលនៃការជំទាស់នោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ករណីជំទាស់នោះ នឹងមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុទេ ប្រសិនបើតំណាងនោះមិនយល់ព្រមផ្តិតមេដៃលើកំណត់ហេតុ ។

៧.៣៤.៧.៣ សេចក្តីសម្រេចរបស់ប្រធាន គគប ត្រូវតែមានប្រសិទ្ធភាពហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត ។

៧.៣៤.៧.៤ ចំណុច ៧.៣៤.៧.៣ ខាងលើ មិនបានច្រានចោលជាមុននូវការដែលតំណាងគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ ទៅ គឃ/កប អំពីករណីដែលគាត់បានលើកជំទាស់ដូចចែងក្នុងចំណុច ៧.៣៤.៧.២ ខាងលើនោះទេ ប៉ុន្តែ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គគប និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ ។

៧.៣៤.៧.៥ ប្រធាន គគប ត្រូវផ្តល់ទម្រង់បែបបទលេខ ១២០២ ចំនួនបួន ( ៤ )ច្បាប់ ជូនតំណាងគណបក្សនយោបាយ តាមសំណើសុំសម្រាប់បំពេញពាក្យបណ្តឹងទៅ គឃ/កប ។

៧.៣៤.៨ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គគប ត្រូវចាត់អនុប្រធាននិងលេខាធិការ ឱ្យបូកសរុបនិងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ នៅលើតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) ព្រមទាំងបង្គាប់ឱ្យជំនួយការធ្វើកិច្ចការ

ស្រដៀងគ្នានេះ នៅលើផ្ទាំងក្រដាសធំ ឬក្ដារខៀនដែលបានប្រើសម្រាប់គូសសម្លេងឆ្នោត ។ ដោយឡែក ដោយមានការពិនិត្យសង្កេតមើលរបស់តំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍នានា ប្រធាន គកប និងជំនួយការត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការ តាមពំនូកដោយឡែក សម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញ ជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោត ដែលអនុប្រធាន និងលេខាធិការ ឬជំនួយការបានបូកសរុបឃើញខាងលើ ។

៧.៣៨.៨.១ ប្រធាន គកប ត្រូវធានាថាតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) ទាំងពីរ( ២ )ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសម្លេងឆ្នោតមួយ( ១ )សន្លឹក ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ។

៧.៣៨.៨.២ ប្រធាន គកប ត្រូវធានាថាតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) ត្រូវបានដាក់ក្នុងស្រោមសំបុត្រត្រៀមបំរុងស្រាប់ ដើម្បីផ្ញើជូន គជប មួយ( ១ )ច្បាប់ និងផ្ញើជូន គខ/កប មួយ( ១ )ច្បាប់ ។

៧.៣៨.៩ ប្រធាន គកប ត្រូវប្រកាសជាចំហ នូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោត ដែលបានអនុវត្តតាមចំណុច ៧.៣៨.៨ ខាងលើ និងត្រូវធ្វើការផ្ទៀងផ្ទាត់ដោយធ្វើប្រមាណវិធីបូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុប ដែលបោះគាំទ្រគណបក្សនយោបាយទាំងអស់និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ ។

៧.៣៨.៩.១ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ ស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ៧.៣៨.៥ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោត ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗនិងចំនួនសន្លឹកឆ្នោតមិនបានការ ទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) ។

៧.៣៨.៩.២ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ មានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ៧.៣៨.៥ ខាងលើ ប្រធាន គកប ត្រូវរាប់សន្លឹកឆ្នោត តាមពំនូកដោយឡែក ដែលបានបោះគាំទ្រ

គណបក្សនយោបាយនីមួយៗ និង ចំនួនសន្លឹកឆ្នោតមិនបានការ ឡើងវិញម្តងទៀត ។

៧.៣៤.៩.៣ ប្រសិនបើ បន្ទាប់ពីប្រធាន គកប បានរាប់ឡើងវិញនិងធ្វើប្រមាណវិធីបូក ឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ នៅតែមានភាពខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោត ត្រូវបានគេរកឃើញនៅលើកម្រាលដោយមូលហេតុជ្រុះទេនោះ គេអាចសន្មតថា ភាពខុសគ្នានេះបានកើតឡើងមុនដោយយថាហេតុ និងពុំមែនជាភាពមិនប្រក្រតីឡើយ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) ។

៧.៣៤.១០ ប្រធាន គកប ត្រូវធានាថា សន្លឹកឆ្នោតបានការ ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ ដោយឡែកពីគ្នា ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គខ/កប ។

៧.៣៤.១១ ប្រធាន គកប ត្រូវធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកងនិងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្លងថា " សន្លឹកឆ្នោតមិនបានការ " ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គខ/កប ។

៧.៣៤.១២ ប្រធាន គកប ត្រូវធានាថាសន្លឹកឆ្នោតបានការ ដែលបានចងនឹងកៅស៊ូកង ដូចចែងក្នុងចំណុច ៧.៣៤.១០ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ដូចចែងក្នុងចំណុច ៧.៣៤.១១ ផ្ទាំងក្រដាសកត់ត្រាសម្លេងឆ្នោត ដូចចែងក្នុងចំណុច ៧.៣៤.៨.១ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោតប្រសិនបើមាន ដូចចែងក្នុងចំណុច ៧.៣៤.៨.១ ខាងលើ ត្រូវបានដាក់ចូលរួមគ្នាក្នុងថង់ប្លាស្ទិកតែមួយ ដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា " សន្លឹកឆ្នោតបានការនិងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ... " បន្ទាប់មក ត្រូវចងភ្ជិតមាត់ថង់ផ្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិចហ្វឺតធំលុបមិនជ្រះ នៅលើផ្ទៃកខាងក្រៅនៃថង់ផ្លាស្ទិក ដើម្បីត្រៀមបញ្ជូននិងប្រគល់ជូន គខ/កប ។

## សន្លឹកឆ្នោតបានការ និង សន្លឹកឆ្នោតមិនបានការ

**ប្រការ៧.៣៥** ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គកប ជាពិសេស ប្រធាន និងអនុប្រធាន គកប ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

៧.៣៥.១ សន្លឹកឆ្នោតបានការគឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គជប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅតាមខេត្ត ក្រុងនៃមណ្ឌលភូមិភាគនីមួយៗ និងមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីបំណងរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងស្រប នឹងគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត ។

៧.៣៥.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និងដែលគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គកប ដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោតពុំអាចសន្និដ្ឋានថាបោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ឬ/និងដែលមានសញ្ញាធាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ/និងដែលមានរហែក ឬខូច ឬ/និងដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ ។ សន្លឹកឆ្នោតមិនបានការដែលត្រូវបានចាត់ទុកជាមោឃៈ រួមមានប្រាំ ( ៥ )ប្រភេទ ដូចខាងក្រោម ៖

**១_ សន្លឹកឆ្នោតក្លែងបន្លំ ដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ**

៧.៣៥.២.១ សន្លឹកឆ្នោតមានខ្នាតតូចជាងឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់គជប។

៧.៣៥.២.២ សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង ( ក្រាសជាងឬស្តើងជាង ) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គជប ។

៧.៣៥.២.៣ សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គជប ។

៧.៣៥.២.៤ សន្លឹកឆ្នោត ដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅតាមមណ្ឌលភូមិភាគពាក់ព័ន្ធ ។

៧.៣៥.២.៥ សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយ លើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅតាមមណ្ឌលភូមិភាគនីមួយៗ ។

៧.៣៥.២.៦ សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់មណ្ឌលភូមិភាគនីមួយៗ ។

៧.៣៥.២.៧ សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោត ដែល គជប បានបោះពុម្ពជាផ្លូវការនិងដែលមិនបានផ្តល់ឱ្យដោយ គកប ពាក់ព័ន្ធ ។

**២_ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូស ដែល គកប ពុំអាចសន្និដ្ឋានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ**

៧.៣៥.២.៨ សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ ( សន្លឹកឆ្នោតទំនេរ )។

៧.៣៥.២.៩ សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬ ចំលេខរៀង ទន្ទឹមនឹងគណបក្សនយោបាយលើសពីមួយគណបក្ស ។

៧.៣៥.២.១០ សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់គណបក្សនយោបាយ ឬមិនចំលេខរៀងនៃគណបក្សនយោបាយណាមួយ ទោះបីជាមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងគណបក្សនយោបាយណាមួយក៏ដោយ ។

**៣_ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ នាំឱ្យគេស្គាល់អ្នកបោះឆ្នោត**

៧.៣៥.២.១១ សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬ ឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង ។

៧.៣៥.២.១២ សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង ។

៧.៣៥.២.១៣ សន្លឹកឆ្នោតមានបិទតែមប្រ៉ិ ឬ ក្រដាសប្រាក់ ឬ ក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬ រូបសញ្ញាផ្សេងៗ ភ្ជាប់នៅត្រង់ប្រអប់គណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នង ។

៧.៣៥.២.១៤ សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ ។

៧.៣៥.២.១៥ សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត ។

**៤_ សន្លឹកឆ្នោតរហែក ឬខូច**

៧.៣៥.២.១៦ សន្លឹកឆ្នោតរហែក ដាច់បាត់លេខរៀង ឬ ប្រអប់នៃគណបក្សនយោបាយណាមួយ ។

៧.៣៥.២.១៧ សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។

៧.៣៥.២.១៨ សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរ ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ ។

**៥_ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការសំរាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ**

៧.៣៥.២.១៩ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៧.៣៥.២.២០ សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត**

**ប្រការ ៧.៣៦** នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៧.៣៤ ត្រូវបានបំពេញរួចរាល់ ប្រធាន គកប ត្រូវធានាថា កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) ចំនួនបួន( ៤ )ច្បាប់ ដែលលេខាធិការបានបំពេញត្រឹមត្រូវហើយ ត្រូវបានចុះហត្ថលេខា ដោយលេខាធិការនិងខ្លួនគាត់ផ្ទាល់ ។ ប្រធាន គកប ត្រូវចាត់ចែងវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតរបស់ខ្លួន ព្រមទាំងរាល់សម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គខ/កប ។

៧.៣៦.១ ប្រធាន គកប ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតដូចចែងក្នុងប្រការ ៧.៣៦ ខាងលើ ចំពោះតំណាងគណបក្សនយោបាយ និងអញ្ជើញតំណាងទាំងនោះឱ្យចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

៧.៣៦.១.១ ការបដិសេធមិនចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពីតំណាងគណបក្សនយោបាយមិនអាចចាត់ទុកជាមោឃៈនៃកំណត់ហេតុនេះបានទេ ។

៧.៣៦.២ ប្រធាន គកប ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីមួយ និងតារាងកត់ត្រាសម្លេងឆ្នោត ( ១១០៨ ) ដូចចែងក្នុងចំណុច ៧.៣៤.៨.២ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានការខ្លងថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោត ផ្ញើជូន គជប " ។ បន្ទាប់មក ប្រធាន គកប ត្រូវរៀបចំ វេចខ្ចប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេង

ឆ្នោត ព្រមទាំងរាល់ស្រោមសំបុត្រ ឬស្បោងផ្លាស្ទិកដាក់សំភារៈឯកសារបោះឆ្នោត ពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ហើយត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលបំរុងស្រាប់ និងបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ។ ប្រធាន គកប ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " ក " រួមមានសំភារៈឯកសារ ដូចខាងក្រោម ៖

៧.៣៦.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោត ផ្ញើជូន គជប ។

៧.៣៦.២.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។

៧.៣៦.២.៣ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

៧.៣៦.២.៤ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " ។

៧.៣៦.២.៥ ស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនទាន់ប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

៧.៣៦.២.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " ( ប្រសិនបើមាន ) ។

៧.៣៦.២.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត ( ប្រសិនបើមាន ) ។

៧.៣៦.២.៨ ថង់ប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសម្លេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត ប្រសិនបើមាន ដូចចែងក្នុងចំណុច ៧.៣៤.១២ ខាងលើ ។

៧.៣៦.៣ ប្រធាន គកប ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីពីរ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្វងថា " កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) " ។

៧.៣៦.៤ ប្រធាន គកប ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីបី និងតារាងកត់ត្រាសម្លេងឆ្នោត ( ទម្រង់បែបបទលេខ ១១០៨ ) មួយ( ១ )ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្វងថា " កំណត់ហេតុនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោតផ្ញើជូន គខ/កប " ។

៧.៣៦.៤.១ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាចំនួនសន្លឹកឆ្នោតខាងលើ នឹងត្រូវប្រើប្រាស់សម្រាប់ការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ដែលក្រោយមក ត្រូវរក្សាទុកជាឯកសារនៅ គខ/កប ។

៧.៣៦.៥ ប្រធាន គកប ត្រូវចាត់ជំនួយការ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតច្បាប់ទីបួន ជាសាធារណៈ នៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត / រាប់សន្លឹកឆ្នោត ។

៧.៣៦.៦ គកប ត្រូវបំពេញក្រដាសលទ្ធផលនៃការបោះ ឆ្នោតតាមការិយាល័យ ( ទម្រង់លេខ ១១០៤ ) ដោយស្រង់តួលេខលទ្ធផលចេញពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់លេខ ១១០២ ) រួចចុះហត្ថលេខានិងបោះត្រា សំរាប់ចែកជូនតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ តាមសំណើសុំ ។

៧.៣៦.៧ ប្រធាន គកប ត្រូវធានាក្នុងការវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខ " ដើម្បីបញ្ជូនទៅ គខ/កប នូវសម្ភារៈឯកសារបោះឆ្នោត ដូចខាងក្រោម ៖

៧.៣៦.៧.១ កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដូចចែងក្នុងចំណុច ៧.៣៦.២ ខាងលើ ។

៧.៣៦.៧.២ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ដូចចែងក្នុងចំណុច ៧.៣៦.៣ ខាងលើ ។

៧.៣៦.៧.៣ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោតផ្ញើជូន គខ/កប ដូចចែងក្នុងចំណុច ៧.៣៦.៤ ខាងលើ ។

៧.៣៦.៧.៤ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោតមួយ( ១ )ច្បាប់ ដូចចែងក្នុងចំណុច ៧.៣៦.៨.១ ខាងក្រោម ។

៧.៣៦.៧.៥ ស្រោមសំបុត្រតូចមួយដាក់ត្រា គកប ( ដាក់ក្រោយពេលបានបោះត្រាលើទម្រង់បែបបទលេខ ១១០៧ រួចរាល់ហើយ ) ។

៧.៣៦.៨ ប្រធាន គកប ត្រូវធានាថា លិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនបី( ៣ )ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារៈឯកសារបោះឆ្នោតដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធានផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូនកញ្ចប់ " ខ " ដូចចែងក្នុងចំណុច ៧.៣៦.៧ ខាងលើ ទៅ គខ/កប ។ បន្ទាប់មក ប្រធាន គកប ត្រូវ ៖

៧.៣៦.៨.១ ដាក់លិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោតមួយ ( ១ )ច្បាប់ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងកញ្ចប់ " ខ " រួចចងភ្ជិត និងចាក់សោឃ្លុំមានលេខ ។

៧.៣៦.៨.២ ដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតមួយ ( ១ )ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " និងត្រូវសរសេរសម្គាល់លេខកូដការិយាល័យបោះឆ្នោត / រាប់សន្លឹកឆ្នោតដោយប៊ិចហ្វឺតលុបមិនជ្រះ នៅលើកញ្ចប់ " ខ " នោះផង ។

៧.៣៦.៨.៣ រក្សាលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតមួយ ( ១ )ច្បាប់ សម្រាប់ប្រើក្នុងការចុះហត្ថលេខាប្រគល់ទទួលកញ្ចប់ " ខ " និងទុកជាឯកសារក្រោយពេលប្រគល់ទទួលរួច ។

៧.៣៦.៩ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្ស ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតពិនិត្យមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គខ/កប និងត្រូវអនុញ្ញាតឱ្យកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់កញ្ចប់ " ខ " ដូចចែងក្នុងចំណុច ៧.៣៦.៨.១ ខាងលើ ។

៧.៣៦.១០ ប្រធាន គកប ត្រូវចាត់ឱ្យវេចខ្ចប់រាល់សម្ភារៈឯកសារបោះឆ្នោតនៅសល់ ដែលតម្រូវផ្ញើជូន គជប វិញដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី គ្រឿងបរិក្ខារវិទ្យុទាក់ទង ទឹកខ្មៅលុបលាងមិនជ្រះ ផ្លាកសញ្ញាការិយាល័យបោះឆ្នោត ជាដើម ហើយត្រូវបញ្ជូននិងប្រគល់សម្ភារៈឯកសារបោះឆ្នោតទាំងនោះជូន គខ/កប អមជាមួយនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧.៣៦.១០.១ ប្រធាន គកប ត្រូវធានាថា លិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនបី(៣) ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារៈឯកសារនៅសល់ទាំងអស់ សម្រាប់ប្រើក្នុងពេលប្រគល់ទទួលនៅ គខ/កប ។

**ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតនៅសល់ទៅ គខ/កប**

**ប្រការ ៧.៣៧** បន្ទាប់ពីបានធ្វើការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសំភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតរួចសព្វគ្រប់ហើយ ប្រធាន គកប ត្រូវចាត់វិធានការចាំបាច់ទាំងឡាយ ក្នុងការបញ្ជូនជាបន្ទាន់នូវកញ្ចប់ " ខ " ដូចចែងក្នុងចំណុច ៧.៣៦.៧ និងសម្ភារៈឯកសារបោះឆ្នោតនៅសល់ ដូចចែងក្នុងចំណុច ៧.៣៦.១០ ខាងលើ ឱ្យបានទៅដល់លេខាធិការដ្ឋាននៃ គខ/កប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ជាកំហិត ។

៧.៣៧.១ ប្រធាន គកប ត្រូវប្រកាសអញ្ជើញតំណាងគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលមានវត្តមានឱ្យចូលរួមជាសាក្សី ក្នុងការបញ្ជូន និងការប្រគល់ទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៃការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ទទួលនៅលេខាធិការដ្ឋាននៃ គខ/កប ផង ។

៧.៣៧.២ ប្រធាន គកប ដែលអមដំណើរដោយអនុប្រធាន ត្រូវទទួលខុសត្រូវដឹកជញ្ជូនដោយផ្ទាល់ នូវកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោតនៃការិយាល័យរបស់ខ្លួន ទៅលេខាធិការដ្ឋាននៃ គខ/កប ។ ប្រធាន គកប ត្រូវចាត់បន្ថែមសមាជិកមួយចំនួននៃ គកប តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារៈឯកសារនៅសល់ផ្សេងទៀត ។

៧.៣៧.៣ ប្រសិនបើត្រូវការចាំបាច់ ប្រធាន គកប ត្រូវស្នើសុំកំលាំងសន្តិសុខពីរ( ២ )រូប ដើម្បីអមដំណើរការដឹកជញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត និងសម្ភារៈឯកសារបោះឆ្នោតនៅសល់ជូន គខ/កប ។

៧.៣៧.៤ នៅពេលប្រគល់ទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈឯកសារនៅសល់ផ្សេងទៀត គខ/កប ត្រូវធានាថាបានត្រួតពិនិត្យរាល់សម្ភារៈឯកសារទាំងអស់ និងបានចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ហើយត្រូវអញ្ជើញតំណាងគណបក្សនយោបាយចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីផង ។

៧.៣៧.៤.១ ក្នុងការត្រួតពិនិត្យទទួលសម្ភារៈឯកសារបោះឆ្នោតខាងលើ មន្ត្រីនៃ គឃ/កប ដែលមានភារកិច្ចទទួលសំភារៈមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព " ក " ឡើយ ។

៧.៣៧.៤.២ បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ មន្ត្រីនៃ គឃ/កប ដែលមានភារកិច្ចទទួលសំភារៈ ត្រូវដកយកលិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) មួយ( ១ )ច្បាប់ពីក្នុងកញ្ចប់ " ខ " មួយ( ១ )ច្បាប់ពីក្នុងហោប៉ៅកញ្ចប់ " ខ " និងមួយ( ១ )ច្បាប់ទៀតពីប្រធាន គកប ហើយចុះហត្ថលេខា រួចប្រគល់មួយ( ១ )ច្បាប់ ជូនប្រធាន គកប ពាក់ព័ន្ធ ស៊កមួយ( ១ )ច្បាប់ទៅក្នុងហោប៉ៅកញ្ចប់ " ខ " វិញ និងរក្សាទុកមួយ( ១ )ច្បាប់ ចងក្រងជាឯកសារ ។

៧.៣៧.៤.៣ ការបដិសេធមិនចុះហត្ថលេខា ឬផ្តិតមេដៃ លើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ពីតំណាងគណបក្សនយោបាយណាម្នាក់ មិនអាចចាត់ទុកជាមោឃៈ នូវលិខិតបញ្ជូន និងប្រគល់ទទួលនេះបានទេ ។

៧.៣៧.៥ រាល់កញ្ចប់ " ខ " ដែល គឃ/កប បានទទួលខាងលើ ត្រូវតែបានកត់ចំណាំនិងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយដាក់តាមការិយាល័យបោះឆ្នោត / ការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

៧.៣៧.៦ គឃ/កប ត្រូវចាត់វិធានការយ៉ាងម៉ត់ចត់ ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃបន្ទប់រក្សាទុកកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត និងត្រូវចាត់ចែងឱ្យមានកំលាំងសន្តិសុខយាមការពារបរិវេណលេខាធិការដ្ឋាននៃ គឃ/កប ឬអាគារដែលត្រូវរក្សាទុកកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារៈឯកសារបោះឆ្នោតទាំងនោះផង ។

**ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គឃ/កប ឬទីកន្លែងមានសុវត្ថិភាពដែលកំណត់ដោយ គជប**

**ប្រការ៧.៣៨** គឃ/កប ត្រូវចាត់ចែង គកប ពាក់ព័ន្ធ ឬមន្ត្រីបោះឆ្នោតផ្សេងទៀត ឱ្យបំពេញកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងខេត្ត ក្រុង ដែលមិនអាចរាប់សន្លឹកឆ្នោត

នៅការិយាល័យរបស់ខ្លួនបានដោយសារករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលកើតឡើង នៅក្រោយពេលបិទការបោះឆ្នោត ព្រមទាំងបានធ្វើកំណត់ហេតុនៃការបោះឆ្នោត និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោតរួចហើយ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារពាក់ព័ន្ធនៅរក្សាបានល្អ ដូចចែងក្នុងចំណុច ៧.៣២.៧ ខាងលើ ។

៧.៣៨.១ នៅពេលទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងសំភារៈឯកសារនៃការិយាល័យបោះឆ្នោត ដែលស្ថិតក្នុងករណីចែងក្នុងប្រការ ៧.៣៨ ខាងលើភ្លាម គខ/កប ត្រូវធ្វើការកត់ចំណាំនិងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយដាក់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗ ។

៧.៣៨.២ គខ/កប ត្រូវចាត់ចែង គកប ពាក់ព័ន្ធ ឬមន្ត្រីបោះឆ្នោតផ្សេងទៀត ( ប្រសិនបើមន្ត្រីនៃ គកប ពាក់ព័ន្ធអវត្តមាន ) ឱ្យបំពេញកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលស្ថិតក្នុងករណីចែងក្នុងប្រការ ៧.៣៨ ខាងលើនៅលេខាធិការដ្ឋាននៃ គខ/កប ឬនៅកន្លែងមានសុវត្ថិភាព តាមកំណត់របស់ គជប នៅព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

៧.៣៨.៣ សមាសភាពនៃ គកប ពាក់ព័ន្ធ ឬមន្ត្រីបោះឆ្នោត ដែលត្រូវបំពេញភារកិច្ចរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គខ/កប ឬនៅកន្លែងមានសុវត្ថិភាព តាមកំណត់របស់ គជប ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរនិងម្ហូបអាហារក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ ។

៧.៣៨.៤ នៅពេល គកប ឬមន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោត មានវត្តមាននៅទីតាំងការិយាល័យរាប់សន្លឹកឆ្នោតដែល គជប បានកំណត់រួចហើយ គខ/កប ត្រូវប្រគល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត សំភារៈឯកសារពាក់ព័ន្ធ ព្រមទាំងសំភារៈនិងទម្រង់បែបបទចាំបាច់ផ្សេងទៀត ឱ្យទៅប្រធាន គកប ឬក្រុមមន្ត្រីបោះឆ្នោតដែលទទួលបន្ទុករាប់សន្លឹកឆ្នោត ។ គខ/កប ត្រូវធានាថា ហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោតនិងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ដែលបានប្រគល់ពុំត្រូវបានគេរុះរើឡើយ ។

៧.៣៨.៥ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ រាល់បទបញ្ញានិងនីតិវិធីដែលបានចែងក្រោមប្រការ ៧.៣៤ ៧.៣៥ ៧.៣៦ និង ៧.៣៧ ខាងលើ ត្រូវតែបានអនុវត្ត ។ ប៉ុន្តែដោយសារការរាប់សន្លឹកឆ្នោតនេះ ត្រូវបានធ្វើនៅលេខាធិការដ្ឋាននៃ គខ/កប ឬនៅកន្លែងមានសុវត្ថិភាពតាមការកំណត់របស់ គជប ហេតុនេះប្រធាន គកប ពាក់ព័ន្ធ ឬប្រធានក្រុមមន្ត្រីបោះឆ្នោតដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតដែលស្ថិតក្នុងករណីចែងក្នុងប្រការ ៧.៣៨ ខាងលើ ត្រូវធានាថា ៖

៧.៣៨.៥.១ ជំនួយការបាននាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) មួយ( ១ )ច្បាប់ ទៅបិទផ្សាយនៅខាងមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៧.៣៨.៥.២ បន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់ស្រោមសំបុត្រ ឬស្បោងផ្លាស្ទិកដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងសំភារៈឯកសារបោះឆ្នោតផ្សេងទៀត កញ្ចប់សុវត្ថិភាព " ក " និងកញ្ចប់ " ខ " ត្រូវបានរៀបចំនិងវេចខ្ចប់ តាមលំដាប់លំដោយយ៉ាងត្រឹមត្រូវ តាមការកំណត់របស់ គជប ។

៧.៣៨.៥.៣ កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធដូចចែងក្នុងចំណុច ៧.៣៨.៥.២ ខាងលើ ដែលបានវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខ " ត្រូវបានប្រគល់ជូន គខ/កប ។

៧.៣៨.៥.៤ សំភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ក៏ត្រូវបានប្រគល់ជូន គខ/កប ។

៧.៣៨.៦ នៅក្នុងការប្រគល់ទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារនៅសល់ផ្សេងទៀត ដូចចែងក្នុងចំណុច ៧.៣៨.៥.៣ និង ៧.៣៨.៥.៤ ខាងលើ នៅលេខាធិការដ្ឋាននៃ គខ/កប មន្ត្រីទទួលបន្ទុកទទួលសំភារៈឯកសារបោះឆ្នោតត្រូវធានាថា លក្ខខណ្ឌ និងនីតិវិធីដូចចែងក្នុងចំណុច ៧.៣៧.៤ ៧.៣៧.៥ និង ៧.៣៧.៦ ត្រូវតែបានអនុវត្តយ៉ាងត្រឹមត្រូវ ។

**ការដាក់ពាក្យប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ ការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងការដោះស្រាយរបស់ គខ/កប លើបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត**

**ប្រការ៧.៣៩** តំណាងគណបក្សនយោបាយណា ដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គកប ពាក់ព័ន្ធនឹងការជំទាស់ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ដូចចែងក្រោមចំណុច ៧.៣០.២២ ឬ/និង ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ៧.៣៤.៧.៤ ខាងលើ ហើយដែលបានទទួលទម្រង់បែបបទសម្រាប់បំពេញពាក្យបណ្ដឹងរួចហើយ អាចដាក់ពាក្យប្ដឹងទៅ គខ/កប ។

៧.៣៩.១ ការដាក់ពាក្យប្ដឹងតវ៉ា ឬប្ដឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងជាបន្ទាន់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀតទៅ គខ/កប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬ យ៉ាងយូរបំផុតត្រឹមម៉ោងដប់មួយកន្លះ( ១១:៣០ )ព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ ប្រសិនបើ នៅក្នុងរយៈពេលដែលបានកំណត់ខាងលើនេះ គខ/កប មិនបានទទួលពាក្យប្ដឹងតវ៉ា ឬប្ដឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្ដឹងតវ៉ា ឬប្ដឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ។

៧.៣៩.២ តំណាងគណបក្សនយោបាយដែលមានបំណងប្ដឹង ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើពាក្យបណ្ដឹងតវ៉ាឬបណ្ដឹងជំទាស់ ( ទម្រង់បែបបទលេខ១២០២ ) ចំនួនបួន(៤)ច្បាប់ ដែលក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

៧.៣៩.២.១ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត ។

៧.៣៩.២.២ ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី ។

៧.៣៩.២.៣ កម្មវត្ថុនៃភាពមិនប្រក្រតី ។

៧.៣៩.២.៤ ប្រសិនបើអាចធ្វើបាន បញ្ជាក់អំពីមាត្រានៃច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានរំលោភ ។

៧.៣៩.២.៥ មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ ។

៧.៣៩.២.៦ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ។

៧.៣៩.២.៧ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង ប្រសិនបើមាន ។

៧.៣៩.៣ ចំពោះពាក្យបណ្ដឹង ដែលបានទទួលក្រោយពេលវេលាកំណត់ ដូចចែងក្នុងចំណុច ៧.៣៩.១ ខាងលើ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គខ/កប ត្រូវចុះពេលវេលានិង

កាលបរិច្ឆេទ ឱ្យបានច្បាស់លាស់ រួចចារបញ្ជាក់អំពីការហួសពេលទទួលពាក្យបណ្ដឹង និងចុះហត្ថលេខាលើពាក្យបណ្ដឹងនោះ ហើយប្រគល់ឱ្យអ្នកប្ដឹងវិញមួយ ( ១ )ច្បាប់ រក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ផ្ញើជូន គជប មួយ( ១ ) ច្បាប់ និងជំរាបអ្នកប្ដឹងថា ពាក្យបណ្ដឹងរបស់គាត់ ដែលបានដាក់នៅក្រោយពេលកំណត់ គខ/កប មិនអាចទទួលដោះស្រាយបានទេ ។

៧.៣៩.៤ នៅពេលបានទទួលពាក្យបណ្ដឹង ដែលត្រូវបានដាក់ក្នុងរយៈពេល ដូចចែងក្នុងចំណុច ៧.៣៩.១ ខាងលើ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គខ/កប ត្រូវចុះពេលវេលានិងកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹងនិងបំពេញពេលវេលា កាលបរិច្ឆេទ និងទីកន្លែង ដែលនឹងត្រូវបើកសវនាការដោះស្រាយពាក្យបណ្ដឹង រួចប្រគល់ជូនតំណាងគណបក្សនយោបាយដែលប្ដឹងមួយ(១)ច្បាប់ និងប្រាប់គាត់ថា គខ/កប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង ព្រមទាំងបើកសវនាការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធ នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ ក្នុងករណីនេះ មន្ត្រីទទួលពាក្យបណ្ដឹងត្រូវត្រៀមពាក្យបណ្ដឹងពីរ( ២ ) ច្បាប់សម្រាប់ គខ/កប ប្រើក្នុងសវនាការដោះស្រាយពាក្យបណ្ដឹង ។

៧.៣៩.៥ ប្រសិនបើ ក្នុងពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ និងគ្មានភស្តុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយទេ គខ/កប ត្រូវបដិសេធពាក្យបណ្ដឹងនោះ និងត្រូវចាត់ចែងបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង ជាធម្មតា តាមការណែនាំរបស់ គជប ។

៧.៣៩.៦ ប្រសិនបើ ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់មានពាក់ព័ន្ធនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលអាចប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ គខ/កប ត្រូវអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដោយផ្ទាល់ ។

៧.៣៩.៦.១ គខ/កប ត្រូវបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតដែលមានពាក្យបណ្ដឹងនោះ ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវអនុវត្តតាមការកំណត់និងនីតិវិធីពាក់ព័ន្ធ ដែលមានចែងក្នុងបទបញ្ជានិងនីតិវិធីនេះ ។

៧.៣៩.៦.២ ការត្រួតពិនិត្យនិងការរាប់សន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើនៅចំពោះមុខដើមបណ្ដឹង ព្រមទាំងតំណាងនៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។

៧.៣៩.៧ ក្នុងករណី មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ដែល គខ/កប តម្រូវបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដូចចែងក្នុងចំណុច ៧.៣៩.៦.១ ខាងលើ ប្រធាន គខ/កប ត្រូវ ៖

៧.៣៩.៧.១ ដកយកកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោតផ្ញើជូន គខ/កប ពីក្នុងកញ្ចប់ " ខ " មកដាក់នៅលើតុ រួចដាក់កញ្ចប់ " ខ " នៅក្បែរខ្លួនគាត់ ។

៧.៣៩.៧.២ បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយករាល់ស្រោមសំបុត្រ ឬស្បោងផ្លាស្ទិកដាក់សំភារៈឯកសារបោះឆ្នោត ដូចចែងចាប់ពីចំណុច ៧.៣៦.២.១ ដល់ ៧.៣៦.២.៤ ខាងលើ មកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់ ។

៧.៣៩.៨ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ គ្រប់គ្រាន់ហើយ ប្រធាន គខ/កប ត្រូវចាត់ចែងការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់សម្ភារៈឯកសារបោះឆ្នោតនៃការិយាល័យនោះឡើងវិញ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ និងបញ្ហាជារួម ដូចខាងក្រោម ៖

៧.៣៩.៨.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត ។

៧.៣៩.៨.២ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតនោះ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៧.៣៩.៨.៣ ពិនិត្យផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត ។

៧.៣៩.៨.៤ ពិនិត្យផ្ទៀងផ្ទាត់លេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ ។ ក្នុងនោះត្រូវពិនិត្យសន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ។

៧.៣៩.៨.៥ រាប់សន្លឹកឆ្នោតខូច ( ប្រសិនបើមាន ) ។

៧.៣៩.៨.៦ ពិនិត្យសន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត(ប្រសិនបើមាន) ។

៧.៣៩.៨.៧ បន្តអនុវត្តរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹងនោះ ដោយអនុវត្តតាមលំនាំនីតិវិធីនិងការកំណត់ ដូចចែងក្រោមប្រការ ៧.៣៤ និង ៧.៣៥ ខាងលើ ។

៧.៣៩.៩ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចចែងក្រោមចំណុច ៧.៣៩.៨ ខាងលើរួចរាល់ហើយ គខ/កប ត្រូវធ្វើការប្រៀបធៀបលទ្ធផលដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញនិងបានរាប់ឃើញ ជាមួយនឹងទិន្នន័យនិងតួលេខ ដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតនិងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៧.៣៩.៩.១ ធ្វើកំណត់ហេតុស្តីពីលទ្ធផល នៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ខាងលើព្រមទាំងកំណត់សម្រេចយល់ព្រមទទួលយក ឬ ព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ។ កំណត់ហេតុនេះត្រូវធ្វើជាពីរ( ២ )ច្បាប់ និងចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាលនិងប្រធាននៃ គខ/កប ។

៧.៣៩.៩.២ ប្រគល់កំណត់ហេតុនេះមួយ( ១ ) ច្បាប់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោត ក្នុងខេត្តក្រុង និងសម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធជូន គជប ( នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ) ។

៧.៣៩.៩.៣ រក្សាមួយ( ១ )ច្បាប់ ទុកជាឯកសាររបស់ គខ/កប ។

៧.៣៩.៩.៤ ដាក់ទៅក្នុងស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដដែលវិញ នូវកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោត ឬសម្ភារៈឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៣៩.៧.២ ខាងលើ តាមលំនាំដើមវិញ ។

៧.៣៩.៩.៥ ដាក់ស្បោងផ្លាស្ទិក និងស្រោមសំបុត្រនានាខាងលើ ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ឡើងវិញតាមលំនាំដើម ដូចចែងក្នុងចំណុច ៧.៣៦.២ ខាងលើ ។

៧.៣៩.៩.៦ ដាក់កញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រពាក់ព័ន្ធទៅក្នុងកញ្ចប់ " ខ " ឡើងវិញតាមលំនាំដើម ដូចចែងក្នុងចំណុច ៧.៣៦.៦ ខាងលើ រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមវេចខ្ចប់និងបញ្ជូនទៅ គជប ។

៧.៣៩.១០ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនិងការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ៧.៣៩.៧ ៧.៣៩.៨ និង ៧.៣៩.៩ ខាងលើ គខ/កប ពិនិត្យមិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងប្រតិបត្តិការនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គខ/កប ត្រូវផ្អែកលើការសំរេចរបស់ខ្លួនដែលបានទទួលយកលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ហើយត្រូវបើកសវនាការដោះស្រាយលើពាក្យបណ្តឹងពាក់ព័ន្ធ ។ នៅក្នុងសវនាការរបស់ គខ/កប ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវ ៖

៧.៣៩.១០.១ ចារបដិសេធលើពាក្យបណ្តឹង ដែលត្រូវប្រគល់ជូនអ្នកប្តឹងមួយ ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

៧.៣៩.១០.២ ចាត់សមាជិកដែលទទួលបន្ទុករដ្ឋបាល ឱ្យបំពេញសេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ដែលមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះផង ។

៧.៣៩.១០.៣ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេច ដែលសមាជិកទទួលបន្ទុករដ្ឋបាលបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងមួយ( ១ )ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

៧.៣៩.១០.៤ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ា ទៅនឹងសេចក្តីសម្រេចរបស់ គខ/កប ទៅ គជប ក្នុងរយៈពេលពីរ( ២ ) ថ្ងៃយ៉ាងយូរបន្ទាប់ពីគាត់បានទទួលសេចក្តីសំរេចបដិសេធលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

៧.៣៩.១០.៥ ប្រគល់ជូនតំណាងគណបក្សនយោបាយ ដែលប្តឹងតវ៉ានូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំនួនបួន ( ៤ )ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

៧.៣៩.១១ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនិងការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ៧.៣៩.៧ ៧.៣៩.៨ និង ៧.៣៩.៩ ខាងលើ គខ/កប ពិនិត្យឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងប្រតិបត្តិការនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផល

នៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គខ/កប ត្រូវផ្អែកលើការសំរេចរបស់ខ្លួន ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ហើយត្រូវបើកសវនាការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធ ។ នៅក្នុងសវនាការនៃ គខ/កប ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវ ៖

៧.៣៩.១១.១ ចារយល់ព្រមលើពាក្យបណ្ដឹង ដែលត្រូវប្រគល់ជូនអ្នកប្ដឹងមួយ ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

៧.៣៩.១១.២ ចាត់សមាជិកដែលទទួលបន្ទុករដ្ឋបាល ឱ្យបំពេញសេចក្ដីសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ( ទម្រង់បែបបទលេខ ១២០៣ ) ចំនួនបី( ៣ )ច្បាប់ ដែលត្រូវព្យួរជាបណ្ដោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៧.៣៩.១១.៣ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្ដីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្ដឹងមួយ( ១ )ច្បាប់ ផ្ញើជូន គជប មួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ។

៧.៣៩.១១.៤ ជម្រាបអ្នកប្ដឹងថា គខ/កប នឹងលើកសំណើពាក់ព័ន្ធនឹងករណីនេះ ព្រមទាំងវេចខ្ចប់សំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធដោយឡែក និងបញ្ជូនទៅ គជប ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន( ២៤ )ម៉ោង បន្ទាប់ពី គខ/កប សំរេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីស្នើសុំ គជប ពិនិត្យសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ និងចាត់ចែងឱ្យបោះឆ្នោតសាជាថ្មី ។

៧.៣៩.១២ ការដាក់ពាក្យប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលបានកើតមានឡើង នៅក្នុងតំបន់បោះឆ្នោតពាក់ព័ន្ធ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត / ការិយាល័យរាប់សន្លឹកឆ្នោតនោះ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងនីតិវិធី ដូចចែងក្នុងជំពូកទី ៨ នៃបទបញ្ជានិងនីតិវិធីរបស់ គជប ។

៧.៣៩.១៣ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលបានកើតមានឡើង នៅក្នុងតំបន់បោះឆ្នោតពាក់ព័ន្ធ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការបោះឆ្នោត

និងរាប់សន្លឹកឆ្នោត ត្រូវបានកំណត់ជាក់ស្តែងតាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភមួយចំនួន ដូចខាងក្រោម ៖

៧.៣៩.១៣.១ ការប្រើកំលាំងដកហូតឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់ប្រភេទ ពីអ្នកបោះឆ្នោត ។

៧.៣៩.១៣.២ ការប្រើកំលាំង ឬអំពើហិង្សា ដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។

៧.៣៩.១៣.៣ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។

៧.៣៩.១៣.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនឱ្យដំណើរការបាន ។

៧.៣៩.១៣.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោត ឱ្យប្រព្រឹត្តអំពើរំលោភបំពានអំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។

៧.៣៩.១៣.៦ ការប្រើកំលាំង ឬអំពើហិង្សា ឬការបំភិតបំភ័យដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

៧.៣៩.១៣.៧ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោត ដោយសម្ភារៈ ឬប្រាក់កាស ។

៧.៣៩.១៤ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកំលាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើង ដោយពាក្យសំដី ជាលាយលក្ខណ៍អក្សរ ឬដោយកាយវិការ ដូចខាងក្រោម ៖

៧.៣៩.១៤.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ដែលពោរពេញទៅដោយការគំរាមកំហែងដល់អាយុជីវិត ការគំរាមធ្វើទុក្ខទោសដល់រាងកាយ ឬការគំរាមបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ។

៧.៣៩.១៤.២ ការរំលោភដោយពាក្យសំដីថានឹងធ្វើទុក្ខទោសដល់រាងកាយ ឬការចោលសំដីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬការសរសេរជាលាយលក្ខណ៍អក្សរក្តី ក្នុងន័យថានឹងធ្វើទារុណកម្ម ។

៧.៣៩.១៤.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ។

៧.៣៩.១៤.៤ ការបង្ហាញ ឬការប្រើប្រាស់គ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

៧.៣៩.១៤.៥ ការលើកឡើងដោយផ្ទាល់មាត់ ឬ ការសរសេរជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដែលជនណាម្នាក់ ត្រូវបានគេប្រហារជីវិត ឬត្រូវគេវាយដំ ឬត្រូវគេរំលោភ ឬទ្រព្យសម្បត្តិរបស់គាត់ត្រូវបានគេបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត ។

៧.៣៩.១៤.៦ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានយន្ត ឬនៅទីកន្លែងជុំវិញខ្លួនអ្នកទាំងនោះ ។

៧.៣៩.១៤.៧ ការយកសាកសពសត្វធាតុឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ដែលអាចធ្វើឱ្យអ្នកទាំងនោះមានការភ័យខ្លាចដល់អាយុជីវិតរបស់គេ ដល់អាយុជីវិតបងប្អូនគ្រួសាររបស់គេ ឬបង្កឱ្យគេភ័យខ្លាច ។

៧.៣៩.១៤.៨ ការបណ្តើរអ្នកគាំទ្រ ឬអ្នកបោះឆ្នោតណាម្នាក់ដោយបង្ខំផ្ទុយពីឆន្ទៈរបស់គេ ដែលធ្វើឱ្យអារម្មណ៍របស់គេមានការភ័យខ្លាច ឬធ្វើឱ្យគេខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់គេ ។

៧.៣៩.១៤.៩ ការប្រើភាសាកម្លាំងបាយ ដើម្បីបង្ហាញពីការគំរាមកំហែង ។

## កិច្ចប្រតិបត្តិការរបស់ គខ/កប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងការរៀបចំតារាងបូកសរុបលទ្ធផល កំណត់ហេតុបូកសរុបលទ្ធផល និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង

**ប្រការ** ៧.៤០ បន្ទាប់ពីបានទទួលកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត និងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំណុះខេត្ត ក្រុង ដូចបានបញ្ជាក់ក្នុងចំណុច ៧.៣៧.៤ និង ៧.៣៨.៦ ខាងលើ គខ/កប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង បញ្ចូលគ្នាឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន ។ គខ/កប ត្រូវធានាថា តារាងបូកសរុបលទ្ធផល កំណត់ហេតុបូកសរុបលទ្ធផល និងក្រដាសលទ្ធផល ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ចុះហត្ថលេខានិងបោះត្រាជាផ្លូវការ ហើយកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត និងក្រដាសលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុង ត្រូវបានបិទផ្សាយជាសាធារណៈ នាពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

៧.៤០.១ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គខ/កប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ។

៧.៤០.១.១ តំណាងនៃគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗប្រចាំការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុង ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបំរុងម្នាក់ សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គខ/កប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ។

៧.៤០.១.២ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរការនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុងខាងលើ អាចផ្លាស់ប្តូរតំណាងបំរុង ឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

៧.៤០.១.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ។

៧.៤០.២ កិច្ចប្រតិបត្តិការរបស់ គខ/កប ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតចំណុះខេត្ត ក្រុង ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។

៧.៤០.៣ គខ/កប ត្រូវត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោត ដែលក្នុងនោះរួមបញ្ចូលទាំងលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យដែលមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ដែលត្រូវបាន គខ/កប បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញផង ។

៧.៤០.៣.១ ទោះបីជា គខ/កប បានសំរេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ និងបានលើកសំណើសុំ គជប សំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះក៏ដោយ ក៏ គខ/កប ត្រូវបូកសរុបបញ្ចូលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងដែរ ។

៧.៨០.៤ គខ/កប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតចំណុះខេត្ត ក្រុង នៅលេខាធិការដ្ឋានរបស់ខ្លួនដែលតម្រូវឱ្យមានបរិវេណសន្តិសុខ មានសុវត្ថិភាពល្អ និងត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត ។ ក្នុងនេះ ប្រធាន គខ/កប ត្រូវ ៖

៧.៨០.៤.១ ត្រៀមនៅលើតុខាងមុខគាត់នូវ ៖

- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងដែលត្រូវប្រគល់ជូនតំណាងគណបក្សនយោបាយ ប្រសិនបើគាត់ស្នើសុំ ។
- សម្ភារៈឯកសារចាំបាច់ផ្សេងទៀត ។

៧.៨០.៤.២ ប្រគល់ជូនអនុប្រធាននូវទម្រង់បែបបទលេខ ១១១០ មួយ( ១ ) ច្បាប់ សំរាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ។

៧.៨០.៤.៣ ប្រគល់ជូនសមាជិកទទួលបន្ទុករដ្ឋបាល នូវទម្រង់បែបបទលេខ ១១១១ ចំនួនបី( ៣ )ច្បាប់ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ទម្រង់បែបបទលេខ ១១១៤ ចំនួនបី( ៣ )ច្បាប់ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនេះ ។

៧.៨០.៤.៤ ប្រគល់ជូនសមាជិកទទួលបន្ទុកបណ្តុះបណ្តាលនិងអប់រំសាធារណជន នូវទម្រង់បែបបទលេខ ១១១០ មួយ( ១ )ច្បាប់ សំរាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ។

៧.៨០.៤.៥ ប្រគល់ជូនសមាជិកទទួលបន្ទុកហិរញ្ញវត្ថុ នូវម៉ាស៊ីនគិតលេខមួយ(១)គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនេះ ។

៧.៨០.៥ ក្នុងករណី គ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតណាមួយ ត្រូវបានដាក់ប្តឹងនៅ គខ/កប ឬមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ដែរ ប៉ុន្តែគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតី ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះទេ គខ/កប ត្រូវចាត់ចែងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ដោយមិនចាំបាច់បើកកញ្ចប់

សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។ ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលខាងលើនេះ គខ/កប គ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសម្លេងឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធប៉ុណ្ណោះ ។

៧.៤០.៦ ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុង ចំពោះករណីដូចចែងក្នុងចំណុច ៧.៤០.៥ ខាងលើ ប្រធាន គខ/កប ត្រូវ ៖

៧.៤០.៦.១ បង្គាប់មន្ត្រីទទួលបន្ទុកឯកសារ ឱ្យនាំយកកញ្ចប់ " ខ " ពីកន្លែងរក្សាទុក មកដាក់នៅលើតុចំមុខប្រធាន ។

៧.៤០.៦.២ បើកកញ្ចប់ " ខ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ( ១១០១ ) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) និងតារាងកត់ត្រាសម្លេងឆ្នោត ( ១១០៨ ) ផ្ញើជូន គខ/កប មកដាក់នៅលើតុ ។

៧.៤០.៦.៣ ដកយកស្រោមសំបុត្រដាក់កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត ផ្ញើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ពីក្នុងកញ្ចប់ " ខ " ដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " យពិសេស " ដែលត្រៀមបំរុងជាស្រេច បន្ទាប់មករក្សាកញ្ចប់ " ខ " ដែលមានកញ្ចប់សុវត្ថិភាព " ក " និងសំភារៈឯកសារនៅសល់ខាងក្នុង នៅក្បែរខ្លួនគាត់ ។

៧.៤០.៦.៤ ត្រួតពិនិត្យផ្ទៀងផ្ទាត់និងបូកសរុបតួលេខ ដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ( ១១០១ ) និងតារាងកត់ត្រាសម្លេងឆ្នោត ( ១១០៨ ) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធ ដែលមានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

៧.៤០.៦.៥ សម្រេចកែតម្រូវតួលេខលទ្ធផល ដែលកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) ប្រសិនបើបានរកឃើញថា គកប ឬក្រុមមន្ត្រីដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោត មានកំហុសក្នុងការគណនាលេខ ។ ក្នុងករណីនេះ ត្រូវឱ្យសមាជិកទទួល

រដ្ឋបាលកត់ត្រាបញ្ហានេះ នៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ។

៧.៤០.៦.៦ ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការ ដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងសន្លឹកឆ្នោតមិនបានការ ដែលបានពិនិត្យត្រឹមត្រូវហើយ ពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) នៃការិយាល័យបោះឆ្នោតម្តងមួយៗរហូតដល់អស់ និងណែនាំអនុប្រធាន
និងសមាជិកទទួលបន្ទុកបណ្តុះបណ្តាលនិងអប់រំសាធារណជន ឱ្យកត់ត្រាតួលេខទាំងនេះ ទៅក្នុងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ។

៧.៤០.៦.៧ ណែនាំអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្តុះបណ្តាលនិងអប់រំសាធារណជន ឱ្យគណនាសរុបតួលេខលទ្ធផល នៃការបោះឆ្នោត ដែលបានស្រង់កត់ត្រា លើតារាងបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ដោយធ្វើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង ហើយបន្ទាប់មក ត្រូវផ្ទៀងផ្ទាត់លទ្ធផលគ្នា ។

៧.៤០.៦.៨ ណែនាំសមាជិកទទួលរដ្ឋបាលឱ្យស្រង់ឬ/និងបូកសរុប រួចកត់ត្រាតួលេខឬ/និងទិន្នន័យពាក់ព័ន្ធ ដែលក្នុងនោះរួមមានទាំងចំនួនសរុបនៃសន្លឹកឆ្នោតបានការ ដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការ ដែលបានគណនានិងពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ពីកំណត់ហេតុនៃការបោះឆ្នោត ( ១១០១ ) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១០ ) បញ្ចូលទៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ។

៧.៤០.៦.៩ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត ( ១១០១ ) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) និងតារាងកត់ត្រាសម្លេងឆ្នោត ( ១១០៨ ) នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ និងចងក្រងទុកជាឯកសាររបស់ គខ/កប ។

៧.៤០.៦.១០ ចាត់ចែងសមាជិក គខ/កប ឱ្យវេចខ្ចប់កញ្ចប់ " ខ " ឡើងវិញ តាមលំនាំដើម បន្ទាប់មក ឱ្យនាំយកទៅរក្សាទុក នៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់និងបញ្ជូនទៅ គជប ។

៧.៤០.៧ ក្នុងករណី គខ/កប បានសំរេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ និងបានលើកសំណើសុំ គជប ផ្ទៀងផ្ទាត់ឡើងវិញ និងពិនិត្យសំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ដូចចែងក្រោមចំណុច ៧.៣៩.១១ និង ៧.៤០.៣ ខាងលើ គខ/កប ត្រូវត្រួតពិនិត្យ និងបូកសរុបបញ្ចូលលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យនោះទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងដែរ ដោយត្រូវអនុវត្តតាមការកំណត់ និងនីតិវិធី ដូចចែងក្រោមចំណុច ៧.៤០.៦ ខាងលើ ។

៧.៤០.៨ ប្រធាន គខ/កប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ទាំងពីរ( ២ )ច្បាប់ ដែលអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្តុះបណ្តាលនិងអប់រំសាធារណជន បានបំពេញលទ្ធផលនៃការបោះឆ្នោត ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង និងបានគណនាសរុបរួចហើយជាលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ត្រូវតែបានពិនិត្យផ្ទៀងផ្ទាត់ជាមួយគ្នាឱ្យបានម៉ត់ចត់ ។ ប្រសិនបើ តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងដែលបានផ្ទៀងផ្ទាត់ខាងលើ នៅមានភាពខុសគ្នា ប្រធាន គខ/កប ត្រូវ ៖

៧.៤០.៨.១ ចាត់ចែងឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដោយការធ្វើប្រមាណវិធីដោយដៃ និងការគណនាដោយម៉ាស៊ីនគិតលេខ ។

៧.៤០.៨.២ ចាត់ចែងឱ្យបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ក្នុងទម្រង់បែបបទ ១១១០ ដែលមានចង្វូមន្តស្រាប់ និងដែលបានផ្តល់ឱ្យដោយ គជប ។

៧.៤០.៨.៣ ផ្ទៀងផ្ទាត់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង រវាងទម្រង់បែបបទ ១១១០ នៅលើក្រដាស និងទម្រង់បែបបទ ១១១០ ក្នុងកុំព្យូទ័រ ដើម្បីឱ្យប្រាកដថា តួលេខលទ្ធផលមានលក្ខណៈត្រឹមត្រូវមែន ។

៧.៤០.៨.៤ ចាត់ចែងឱ្យបោះពុម្ពតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ពីក្នុងកំព្យូទ័រ ចំនួនពីរ( ២ )ច្បាប់ ។

៧.៤០.៩ ប្រធាន គខ/កប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) បំពេញដោយដៃចំនួន( ២ )ច្បាប់ និងបោះពុម្ពពីក្នុងកុំព្យូទ័រចំនួនពីរ( ២ )ច្បាប់ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងខ្លួនគាត់ផ្ទាល់ និងមានបោះត្រាផង ។ ប្រធាន គខ/កប ត្រូវចាត់ចែងប្រើប្រាស់តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងខាងលើនេះ ដូចខាងក្រោម ៖

៧.៤០.៩.១ ផ្ញើច្បាប់បំពេញដោយដៃមួយ( ១ )ច្បាប់ និងច្បាប់កុំព្យូទ័រមួយ( ១ )ច្បាប់ ជូន គជប ។

៧.៤០.៩.២ រក្សាច្បាប់បំពេញដោយដៃមួយ( ១ )ច្បាប់ និងច្បាប់កុំព្យូទ័រមួយ( ១ )ច្បាប់ ជាឯកសារ ។

៧.៤០.៩.៣ បញ្ជូនតារាងបូកសរុបលទ្ធផល នៃការបោះឆ្នោត ក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ក្នុងកំព្យូទ័រដែលមានទិន្នន័យដូចគ្នានឹងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងដែលបានចុះហត្ថលេខាជាផ្លូវការរួចហើយ តាមអ៊ីមែលជាបន្ទាន់ទៅ គជប តាមអាសយដ្ឋានដែលបានកំណត់ ។

៧.៤០.១០ ប្រធាន គខ/កប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ចំនួនបី( ៣ )ច្បាប់ ដែលសមាជិកទទួលបន្ទុករដ្ឋបាលបានបំពេញ និងគណនាសរុបរួចហើយ ដូចចែងក្នុងចំណុច ៧.៤០.៦.៨ ខាងលើ ត្រូវតែបានផ្ទៀងផ្ទាត់ឡើងវិញជាមួយនឹងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងជាផ្លូវការ ដូចចែងក្នុងចំណុច ៧.៤០.៩ ខាងលើ និងត្រូវបានចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាល និងខ្លួនគាត់ផ្ទាល់ ព្រមទាំងមានបោះត្រាផង ។

៧.៤០.១០.១ ប្រធាន គខ/កប ត្រូវដាក់បង្ហាញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងខាងលើ ចំពោះតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ព្រមទាំងអញ្ជើញតំណាងគណបក្សនយោបាយ ឱ្យចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

៧.៤០.១០.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ លើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ ។

៧.៤០.១១ ប្រធាន គខ/កប ត្រូវចាត់ចែងនិងប្រើប្រាស់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ដូចខាងក្រោម ៖

៧.៤០.១១.១ បិទផ្សាយមួយ( ១ )ច្បាប់ នៅលេខាធិការដ្ឋាននៃ គខ/កប នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដោយត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ដែលមានបញ្ជាក់ពេលវេលានិងកាលបរិច្ឆេទនៃការបិទផ្សាយផង ។

៧.៤០.១១.២ ផ្ញើមួយ( ១ )ច្បាប់ជូន គជប ដោយភ្ជាប់ទៅជាមួយនូវកំណត់ហេតុស្តីពីការបិទផ្សាយមួយ( ១ )ច្បាប់ផង ។

៧.៤០.១១.៣ រក្សាទុកមួយ( ១ )ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយមួយ ( ១ )ច្បាប់ ជាឯកសារ ។

៧.៤០.១១.៤ ថតចម្លងនិងចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធមួយ( ១ )ច្បាប់ តាមសំណើសុំ ។

៧.៤០.១២ ប្រធាន គខ/កប ត្រូវធានាថា ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៤ ) ចំនួនបី(៣)ច្បាប់ ត្រូវបានចម្លងយ៉ាងត្រឹមត្រូវនូវតួលេខលទ្ធផល ពីកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាលនិងខ្លួនគាត់ផ្ទាល់ និងមានបោះត្រាផង ។ ប្រធាន គខ/កប ត្រូវចាត់ចែងនិងប្រើប្រាស់ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៤ ) ដូចខាងក្រោម ៖

៧.៤០.១២.១ បិទផ្សាយមួយ( ១ )ច្បាប់ នៅលេខាធិការដ្ឋាននៃ គខ/កប នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

៧.៤០.១២.២ ផ្ញើមួយ( ១ )ច្បាប់ ជូន គជប ។

៧.៤០.១២.៣ រក្សាទុកមួយ( ១ )ច្បាប់ ជាឯកសារ ។

៧.៤០.១២.៤ ថតចម្លងនិងចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ប្រចាំខេត្ត ក្រុងមួយ( ១ )ច្បាប់ តាមសំណើសុំ ។

៧.៤០.១៣ ប្រធាន គខ/កប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១០ ) ដូចចែងក្នុងចំណុច ៧.៤០.៩.១ កំណត់ហេតុបូកសរុប

លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១១ ) និងកំណត់ហេតុស្តីពីការបិទផ្សាយ ដូចចែងក្នុងចំណុច ៧.៤០.១១.២ និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១៤ ) ដូចចែងក្នុងចំណុច ៧.៤០.១២.២ ខាងលើ ត្រូវបានដាក់ក្នុងស្រោមសំបុត្រធំតែមួយ ត្រៀមសម្រាប់ផ្ញើជូន គជប ។

៧.៤០.១៤ ប្រធាន គខ/កប ត្រូវថ្ងៃប្រឱតបញ្ជូនកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១១ ) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ១១១៤ ) តាមលទ្ធភាពមធ្យោបាយដែលមានក្នុងខេត្ត ក្រុង ដូចជា ទូរសារ វិទ្យុទាក់ទង អ៊ីមែល... នៅពេលល្ងាច ឬយប់នៃថ្ងៃបិទផ្សាយឯកសារទាំងនេះ នៅលេខាធិការដ្ឋាននៃ គខ/កប ។

**ការវេចខ្ចប់កញ្ចប់សុវត្ថិភាព " យពិសេស" ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុង ខេត្ត ក្រុង និងកញ្ចប់ " យ " ដាក់សំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ត្រៀមបញ្ជូនទៅ គជប**

**ប្រការ** ៧.៤១ បន្ទាប់ពី បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធី ដូចចែងចាប់ពីប្រការ ៧.៣៩ និង ៧.៤០ ខាងលើ គខ/កប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្តក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៤ ) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ព្រមទាំងរាល់កញ្ចប់ " ខ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងរាល់សំភារៈឯកសារពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ត្រូវតែបានវេចខ្ចប់ បញ្ជូន និងប្រគល់ជូន គជប ឱ្យទាន់ពេលវេលា នៅថ្ងៃទីពីរ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

៧.៤១.១ ប្រធាន គខ/កប ត្រូវចាត់ចែងវេចខ្ចប់ដាក់ក្នុងកញ្ចប់សុវត្ថិភាព " យពិសេស " មួយ នូវរាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសំខាន់ៗ ដែលពាក់ព័ន្ធនឹងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង សម្រាប់ផ្ញើជូន គជប ។

៧.៤១.១.១ នៅក្នុងកិច្ចប្រតិបត្តិការរបស់ គខ/កប ដើម្បីត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ប្រធាន គខ/កប ត្រូវដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ១១០២ ) ផ្ញើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ពីក្នុងកញ្ចប់ " ខ " ដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " យពិសេស " ។

៧.៤១.១.២ ប្រធាន គខ/កប ត្រូវត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ ទៅតាមប្រភេទស្រោមសំបុត្រដាក់ឯកសារ ដែលត្រូវបានដាក់ក្នុង កញ្ចប់សុវត្ថិភាព " ឃពិសេស " ។

៧.៤១.២ ប្រធាន គខ/កប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ឃពិសេស " ដែលត្រូវផ្ញើជូន គជប ត្រូវមានរាល់ស្រោមសំបុត្រដាក់សំភារៈឯកសារបោះឆ្នោតដូចខាងក្រោម ៖

៧.៤១.២.១ ស្រោមសំបុត្រតែមួយ ដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) កំណត់ហេតុស្តីពីការបិទផ្សាយលទ្ធផល ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៤ ) និង តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ដូចចែងក្នុងចំណុច ៧.៤០.១៣ ខាងលើ ។

៧.៤១.២.២ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ( ទម្រង់ ១១០២ ) ផ្ញើជូន គជប ( នាយកដ្ឋានប្រតិបត្តិការ ) ដូចចែង ក្នុងចំណុច ៧.៤១.១.១ ខាងលើ ។

៧.៤១.២.៣ ស្រោមសំបុត្រដាក់កំណត់ហេតុ ស្តីពីលទ្ធផល នៃការបើកកញ្ចប់ សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ឡើងវិញ និងសេចក្តីសម្រេចរបស់ គខ/កប យល់ព្រមទទួល យកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ( ប្រសិនបើមាន ) ដូចចែងក្នុងចំណុច ៧.៣៩.៩.១ ខាងលើ ។

៧.៤១.២.៤ ស្រោមសំបុត្រតែមួយ ដាក់រាល់សេចក្តីសម្រេចរបស់ គខ/កប ដែលបានបដិសេធលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ( ទម្រង់ បែបបទលេខ ១២០៣ ) ផ្ញើជូន គជប ( នាយកដ្ឋានសេវាកម្ម ច្បាប់ និងវិវាទកម្ម ) ដូចចែងក្នុងចំណុច ៧.៣៩.១០.៣ ខាង លើ ។

៧.៤១.២.៥ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារ បោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) មួយ( ១ )ច្បាប់ ដូចចែងក្នុងចំណុច ៧.៤១.៣ ខាងក្រោម ។

៧.៤១.៣ ប្រធាន គខ/កប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនបី(៣)ច្បាប់ ដោយមានរាយមុខសំភារៈឯកសារដែលបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ខាងលើ ហើយត្រូវដាក់មួយ( ១ )ច្បាប់ក្នុងស្រោមសំបុត្រនិងដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ដាក់មួយ( ១ )ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់សុវត្ថិភាព" ឃពិសេស " និងត្រៀមទុកមួយ( ១ )ច្បាប់សំរាប់ប្រើក្នុងការប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតនៅ គជប ។

៧.៤១.៤ ប្រធាន គខ/កប ត្រូវធានាថា រាល់ស្រោមសំបុត្រដាក់សំភារៈឯកសារបោះឆ្នោតដូចចែងក្រោមចំណុច ៧.៤១.២ ខាងលើ ត្រូវបានរៀបចំដាក់ក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ឱ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ នៅមុនពេលត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលមានបំរុងស្រាប់ ។ ប្រធាន គខ/កប ត្រូវសរសេរសំគាល់ឈ្មោះខេត្ត ក្រុង និងលេខរៀងមណ្ឌលភូមិភាគពាក់ព័ន្ធ នៅលើផ្នែកខាងក្រៅនៃកញ្ចប់ " ឃពិសេស " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

៧.៤១.៥ ចំពោះខេត្ត ក្រុងដែលមានការិយាល័យបោះឆ្នោតលើសពីមួយ ហើយក្នុងករណី គខ/កប បានសម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងខេត្ត ក្រុង ប្រធាន គខ/កប ត្រូវធានាថា សេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត កំណត់ហេតុ និងសម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗ និងបញ្ជូនទៅ គជប ។ ក្នុងនេះ ប្រធាន គខ/កប ត្រូវ ៖

៧.៤១.៥.១ រៀបចំដាក់ក្នុងស្រោមសំបុត្រធំមួយ នូវឯកសារបោះឆ្នោត ដូចខាងក្រោម ៖

- កំណត់ហេតុស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ៧.៣៩.៩.១ ខាងលើ ។
- សេចក្តីសំរេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលត្រូវព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដូចចែងក្នុងចំណុច ៧.៣៩.១១.២ ខាងលើ ។

- សំណើរបស់ គខ/កប ដូចចែងក្នុងចំណុច ៧.៣៩.១១.៤ ខាងលើ ដើម្បីដាក់ជូន គជប ពិនិត្យសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ និងចាត់ចែងឱ្យបោះឆ្នោតសាជាថ្មី ។

៧.៤១.៥.២ ចាត់ចែងដាក់ទៅក្នុងកញ្ចប់ " ឃ " មួយដោយឡែក នូវ ៖

- កញ្ចប់ " ខ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រដាក់សំភារៈឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ ដែលលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យនោះ ត្រូវបានព្យួរជាបណ្ដោះអាសន្នដោយ គខ/កប ។
- ស្រោមសំបុត្រធំដាក់ឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៤១.៥.១ ខាងលើ ។
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនមួយ ( ១ )ច្បាប់ដូចចែងក្នុងចំណុច ៧.៤១.៥.៣ ខាងក្រោម ។

៧.៤១.៥.៣ ចាត់ចែងបំពេញនិងចុះហត្ថលេខាលើលិខិតបញ្ជូននិងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនបី( ៣ )ច្បាប់ ដែលត្រូវដាក់មួយ( ១ )ច្បាប់ក្នុងស្រោមសំបុត្រនិងដាក់ទៅក្នុងកញ្ចប់ " ឃ " ដាក់មួយ( ១ )ច្បាប់ក្នុងហោប៉ៅកញ្ចប់ " ឃ " និងត្រៀមមួយ( ១ )ច្បាប់សំរាប់ប្រើនៅពេលប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតនៅ គជប ។

៧.៤១.៥.៤ ចងភ្ជិតកញ្ចប់ " ឃ " រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅកញ្ចប់ " ឃ " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះនូវលេខកូដនិងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឈ្មោះខេត្ត ក្រុង និងលេខរៀងមណ្ឌលភូមិភាគពាក់ព័ន្ធ និងពាក្យ " ព្យួរលទ្ធផល " ។

៧.៤១.៥.៥ បញ្ជូនកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤១.៥.៤ ខាងលើ ដើម្បីប្រគល់ជូន គជប យ៉ាងយូរត្រឹមម្ភៃបួន( ២៤ )ម៉ោង គិតចាប់ពីពេលដែល គខ/កប បានចេញសេចក្ដីសំរេចយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ដែលត្រូវព្យួរជាបណ្ដោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៧.៤១.៦ ចំពោះការិយាល័យបោះឆ្នោតផ្សេងទៀត ក្នុងខេត្ត ក្រុង ដែលទោះបីមាន ឬគ្មាន បណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់ក៏ដោយ ក៏ប៉ុន្ដែត្រូវបាន គខ/កប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ឬទាំងនោះ ប្រធាន គខ/កប ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ " ខ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រដាក់សំភារៈឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់ " ឃ " ត្រៀមសំរាប់ការបញ្ជូននិងប្រគល់ជូន គជប ។ ក្នុងនេះ ប្រធាន គខ/កប ត្រូវ ៖

៧.៤១.៦.១ ចាត់ចែងវេចខ្ចប់រាល់កញ្ចប់ " ខ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រដាក់សំភារៈឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដែល គខ/កប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតទៅក្នុងកញ្ចប់ " ឃ " ។

៧.៤១.៦.២ ចាត់ចែងបំពេញនិងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសំភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ចំនួនបី( ៣ )ច្បាប់ ដែលត្រូវដាក់មួយ( ១ )ច្បាប់ក្នុងស្រោមសំបុត្រនិងដាក់ទៅក្នុងកញ្ចប់ " ឃ " ដាក់មួយ( ១ )ច្បាប់ក្នុងហោប៉ៅកញ្ចប់ " ឃ " និងត្រៀមមួយ( ១ )ច្បាប់ សំរាប់ប្រើនៅពេលប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតនៅ គជប ។

៧.៤១.៦.៣ ចងភ្ជិតកញ្ចប់ " ឃ " រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅកញ្ចប់ " ឃ " ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះនូវលេខកូដការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឈ្មោះខេត្ត ក្រុង និងលេខរៀងមណ្ឌលភូមិភាគពាក់ព័ន្ធ និងពាក្យ " យល់ព្រម " ។

៧.៤១.៧ ប្រធាន គខ/កប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្ស ព្រមទាំងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ បានសង្កេតពិនិត្យមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គជប និងត្រូវអនុញ្ញាតឱ្យកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់កញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤១.៥.៤ និង ៧.៤១.៦.៣ ខាងលើ ។

៧.៤១.៨ ប្រសិនបើ កញ្ចប់ " ឃ " ដូចចែងក្រោមចំណុច ៧.៤១.៥ ឬ ៧.៤១.៦ ខាងលើ មានចំនួនច្រើនលើសពីមួយ ប្រធាន គខ/កប ត្រូវចាត់ចែងឱ្យសរសេរ

សម្គាល់លេខរៀង នៅខាងក្រៅកញ្ចប់ " ឃ " ទាំងនោះផង ។ ឧទាហរណ៍ ប្រសិនបើមានកញ្ចប់ " ឃ " ចំនួនបី(៣) ត្រូវសរសេរលើកញ្ចប់ " ឃ " ទីមួយ ១/៣ លើកញ្ចប់ " ឃ " ទីពីរ ២/៣ និងលើកញ្ចប់ " ឃ " ទីបី ៣/៣ ។

៧.៤១.៩ ប្រធាន គខ/កប ត្រូវធានាថារាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបំរុងសម្រាប់ខេត្ត ក្រុងនីមួយៗ ( ប្រសិនបើមាន ) ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ចប់ដោយឡែក និងមិនត្រូវដាក់ក្នុងកញ្ចប់ " ឃ " ហើយត្រូវបញ្ជូននិងប្រគល់ជូន គជប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " ។

៧.៤១.៩.១ នៅក្នុងការវេចខ្ចប់ បញ្ជូននិងប្រគល់ទទួលសន្លឹកឆ្នោតត្រៀមបំរុង ប្រធាន គខ/កប ត្រូវធានាថា ទម្រង់បែបបទលេខ ១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមការកំណត់ក្នុងការបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ។

៧.៤១.១០ ប្រធាន គខ/កប ត្រូវធានាថា រាល់សម្ភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលបានទទួលពី គកប ចំណុះខេត្ត ក្រុង ត្រូវតែបានវេចខ្ចប់ ដោយដាក់ក្នុងកេស ឬបាវ ឬកញ្ចប់ ទៅតាមសភាពជាក់ស្តែង និងបញ្ជូនទៅ គជប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " ។

៧.៤១.១០.១ នៅក្នុងការវេចខ្ចប់ បញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ប្រធាន គខ/កប ត្រូវធានាថា ទម្រង់បែបបទលេខ ១១០៧ ត្រូវតែបានបំពេញនិងប្រើប្រាស់តាមការកំណត់ក្នុងការបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ។

៧.៤១.១១ ប្រធាន គខ/កប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ឃពិសេស " ដូចចែងក្នុងចំណុច ៧.៤១.៤ រាល់កញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤១.៥.៤ និង ៧.៤១.៦.៣ កញ្ចប់សន្លឹកឆ្នោតបំរុង ដូចចែងក្នុងចំណុច ៧.៤១.៩ និង រាល់សម្ភារៈឯកសារបោះឆ្នោតនៅសល់ ដូចចែងក្នុងចំណុច ៧.៤១.១០ ខាងលើ ត្រូវតែបានបញ្ជូនទៅ គជប នៅថ្ងៃទីពីរ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ការដាក់ពាក្យប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចរបស់ គខ/កប ដែលបានបដិសេធលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់នៅទីស្តីការ គជប**

**ប្រការ ៧.៤២** អ្នកប្តឹងតវ៉ាឬអ្នកប្តឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គខ/កប លើពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់របស់គាត់ពាក់ព័ន្ធនឹងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងខេត្ត ក្រុង ដូចចែងក្នុងចំណុច ៧.៣៩.១០ ខាងលើ មានសិទ្ធិប្តឹងតវ៉ាទៅ គជប ក្នុងរយៈពេលយ៉ាងយូរពីរ( ២ )ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹង ។

៧.៤២.១ រាល់ការប្តឹងតវ៉ា ដូចចែងក្នុងប្រការ ៧.៤២ ខាងលើ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់ពាក្យប្តឹងនៅទីស្តីការ គជប ហើយ គជប ត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ានេះក្នុងរយៈពេលយ៉ាងយូរពីរ(២)ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

៧.៤២.១.១ ប្រសិនបើ នៅក្នុងរយៈពេលកំណត់ខាងលើ គជប មិនបានទទួលពាក្យបណ្តឹងតវ៉ាណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គខ/កប លើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធ ។

៧.៤២.២ អ្នកប្តឹងតវ៉ាឬអ្នកប្តឹងជំទាស់ ឬតំណាងដែលមានបំណងប្តឹងតវ៉ា ដូចបញ្ជាក់ក្នុងប្រការ ៧.៤២ និងចំណុច ៧.៤២.១ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខាលើពាក្យបណ្តឹងតវ៉ា ដែលក្នុងនោះត្រូវផ្តល់ពត៌មានច្បាស់លាស់មួយចំនួន ដូចចែងក្នុងចំណុច ៧.៣៩.២ ខាងលើ ។

៧.៤២.៣ ចំពោះពាក្យបណ្តឹងតវ៉ាដែលត្រូវបានដាក់ប្តឹងនៅ គជប ក្រោយពេលវេលា ដូចចែងក្នុងប្រការ ៧.៤២ ខាងលើ និងពាក្យបណ្តឹងតវ៉ា ដូចចែងក្នុងចំណុច ៧.៤២.២ ខាងលើដែលគ្មានឯកសារនិងភស្តុតាងគ្រប់គ្រាន់ គជប មិនត្រូវទទួលដោះស្រាយទេ ។

៧.៤២.៣.១ មន្ត្រីទទួលពាក្យបណ្តឹងនៃ គជប ត្រូវចុះពេលវេលានិងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូនអគ្គលេខាធិការចារបញ្ជាក់ពីការហួសពេលទទួលពាក្យបណ្តឹង ចុះហត្ថលេខា និងបោះត្រាលើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាងមួយ( ១ )ច្បាប់ រក្សាទុកជាឯកសារមួយ( ១ )ច្បាប់ និងជំរាបអ្នកប្តឹង ឬតំណាងថាពាក្យបណ្តឹងរបស់គាត់ ដែលបានដាក់នៅក្រោយពេលកំណត់ មិនអាចទទួលដោះស្រាយបានទេ ។

៧.៤២.៣.២ គជប ត្រូវបដិសេធមិនទទួលដោះស្រាយពាក្យបណ្តឹងតវ៉ា ដែលគ្មានឯកសារនិងភស្តុតាងគ្រប់គ្រាន់ ដោយប្រគល់សិទ្ធិជូនអគ្គលេខាធិការចារបដិសេធលើបណ្តឹងតវ៉ា និងបញ្ជាក់មូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខានិងបោះត្រា និងប្រគល់ជូនអ្នកប្តឹង ឬតំណាងមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ ) ច្បាប់ ។

៧.៤២.៤ ចំពោះពាក្យបណ្តឹងតវ៉ាមានឯកសារ និងភស្តុតាងគ្រប់គ្រាន់ ដែលត្រូវបានដាក់ប្តឹងនៅ គជប ក្នុងរយៈពេលដូចចែងក្នុងប្រការ ៧.៤២ ខាងលើ មន្ត្រីទទួលពាក្យបណ្តឹងនៃ គជប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ហើយដោយផ្អែកតាមការណែនាំរបស់ គជប ត្រូវបំពេញពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដែល គជប នឹងត្រូវបើកសវនាការដោះស្រាយបណ្តឹងតវ៉ានោះ ។ មន្ត្រីទទួលពាក្យបណ្តឹងនៃ គជប ត្រូវចុះហត្ថលេខាទទួលលើពាក្យបណ្តឹង បន្ទាប់មកត្រូវ ៖

៧.៤២.៤.១ ប្រគល់ពាក្យបណ្តឹងនេះមួយ( ១ )ច្បាប់ ជូនអ្នកប្តឹងឬតំណាង ។

៧.៤២.៤.២ ប្រាប់អ្នកប្តឹង ឬតំណាងថា គជប នឹងបើកសវនាការសម្រេចលើពាក្យបណ្តឹងតវ៉ារបស់គាត់ តាមកាលបរិច្ឆេទកំណត់ បន្ទាប់ពីក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។

៧.៤២.៤.៣ បិទផ្សាយពាក្យបណ្តឹងនេះមួយ( ១ )ច្បាប់ ជាសាធារណៈ ។

៧.៤២.៤.៤ ត្រៀមពាក្យបណ្តឹងតវ៉ាពីរ( ២ )ច្បាប់សម្រាប់ គជប ប្រើក្នុងសវនាការ ដោះស្រាយលើពាក្យបណ្តឹងនោះ ។

៧.៤២.៥ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរាយការណ៍ជាបន្ទាន់ជូន គជប តាមរយៈអគ្គលេខាធិការ អំពីករណីនៃបណ្តឹង ដោយភ្ជាប់ពាក្យបណ្តឹងតវ៉ាដែលបានទទួល និងសេចក្តីសម្រេចរបស់ គខ/កប បដិសេធលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដូចចែងក្នុងចំណុច ៧.៤១.២.៤ ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " ឃពិសេស " និងដើម្បីសុំការណែនាំរបស់ គជប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីរាប់សន្លឹកឆ្នោតឡើងវិញ ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកប្តឹងតវ៉ា ឬតំណាង និងអ្នកសង្កេតការណ៍ ។

**ការបង្កើតក្រុមទទួលសម្ភារៈឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ និងការត្រៀមលក្ខណសម្បត្តិបំពេញការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ**

**ប្រការ ៧.៤៣** ក្នុងគោលបំណងត្រួតពិនិត្យបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គជប ត្រូវបង្កើតក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតមួយ( ១ ) ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈមួយ( ១ ) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីបំពេញការងារត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគនីមួយៗ ។

៧.៤៣.១ ក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គជប ដើម្បីធានាការទទួលកញ្ចប់សុវត្ថិភាព " ឃពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងកញ្ចប់ " ឃ " ដាក់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធដែល គខ/កប បានបញ្ជូននិងប្រគល់ជូន គជប ព្រមទាំងធានាការបែងចែកនិងរក្សាទុកសម្ភារៈឯកសារទាំងនោះ នៅបន្ទប់ស្តុកតាមភូមិភាគនីមួយៗ ។

៧.៤៣.១.១ ក្រុមទទួលសម្ភារៈឯកសារបោះឆ្នោត ត្រូវដឹកនាំដោយប្រធាន ឬអនុប្រធាននាយកដ្ឋានរដ្ឋបាល ហើយរួមមានមន្ត្រីនាយកដ្ឋានរដ្ឋបាលមួយ(១)រូប មន្ត្រីនាយកដ្ឋានប្រតិបត្តិការពីរ(២)រូប មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្មមួយ(១)រូប និងមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុមួយ(១)រូប ជាសមាជិក ។

៧.៤៣.១.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គជប តាមរយៈអគ្គលេខាធិការ ។

៧.៤៣.២ ផ្អែកតាមការចាំបាច់ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប មួយចំនួនត្រូវបានបង្កើតឡើង ដើម្បីធានាការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគទាំង ៨ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនីមួយៗ រួមមានសមាសភាព ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានាចំណុះអគ្គលេខាធិការដ្ឋាននៃ គជប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគមួយ ឬច្រើន ។

៧.៤៣.២.១ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនីមួយៗ ត្រូវមានសមាសភាពបួន ( ៤ )រូប ដែលដឹកនាំដោយប្រធានមួយ( ១ )រូប និងចាត់តាំងឱ្យមានលេខាធិការមួយ( ១ )រូបដើម្បីសំរួលក្នុងការបំពេញភារកិច្ច ។

៧.៤៣.២.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គជប តាមរយៈអគ្គលេខាធិការ ។

៧.៤៣.៣ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនីមួយៗរបស់ គជប មានភារកិច្ចត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគនីមួយៗ ដោយឡែកពីគ្នា រួចត្រូវបំពេញតួលេខលទ្ធផលនៅលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) ដែលត្រូវចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសំរេច ។ ការត្រួតពិនិត្យនិងបូកសរុបលទ្ធផលតាមមណ្ឌលភូមិភាគនេះត្រូវអនុវត្តដោយផ្អែកលើឯកសារបោះឆ្នោត ដែលស្ថិតក្នុងក្របខ័ណ្ឌនៃខេត្ត ក្រុងទាំងអស់ចំណុះភូមិភាគពាក់ព័ន្ធ ដូចខាងក្រោម ៖

៧.៤៣.៣.១ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង ( ទម្រង់បែបបទលេខ ១១១១ ) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៤ ) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ។

៧.៤៣.៣.២ រាល់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០២ ) ។

៧.៤៣.៣.៣ កំណត់ហេតុរបស់ គខ/កប ស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ( ប្រសិនបើមាន ) ។

៧.៤៣.៣.៤ សេចក្តីសម្រេចរបស់ គខ/កប យល់ព្រម ឬបដិសេធលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ( ប្រសិនបើមាន ) ។

៧.៤៣.៣.៥ កំណត់ហេតុស្តីពីលទ្ធផលនៃការបើកកញ្ចប់ " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើ គជប សម្រេចតម្រូវឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលធ្វើដូច្នេះ ។

៧.៤៣.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គជប ត្រូវបានបង្កើតឡើង ដើម្បីបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗ ចំណុះភូមិភាគពាក់ព័ន្ធ ទៅក្នុងកុំព្យូទ័ររួចធ្វើការផ្ទៀងផ្ទាត់លទ្ធផល ដែលបូកសរុបឃើញក្នុងកុំព្យូទ័រ ជាមួយនឹងតួលេខលទ្ធផលដែលមានក្នុងតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) ដែល គជប បានយល់ព្រមទទួលយកលទ្ធផលនោះរួចហើយ ។ ប្រសិនបើ ការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតគ្រប់ភូមិភាគទូទាំងប្រទេសឃើញត្រឹមត្រូវហើយ ក្រុមកំណត់បែងចែកអាសនៈត្រូវបោះ

ពុម្ពសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច និងបិទផ្សាយ ។ ក្នុងករណី គ្មានបណ្ដឹងតវ៉ា ឬរាល់បណ្ដឹងតវ៉ាត្រូវបានដោះស្រាយចប់ជាស្ថាពរ ក្រុមកំណត់បែងចែកអាសនៈត្រូវរៀបចំសេចក្ដីព្រាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងសេចក្ដីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈ រួចដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេចជាផ្លូវការ ។

៧.៤៣.៤.១ ក្រុមកំណត់បែងចែកអាសនៈត្រូវមានសមាសភាពមួយចំនួន តាមការចាំបាច់ ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃខុទ្ទកាល័យអគ្គលេខាធិការដ្ឋាននៃ គជប នាយដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ។

៧.៤៣.៤.២ ក្រុមនេះត្រូវដឹកនាំដោយប្រធានមួយ(១)រូប ដែលជាប្រធាននាយកដ្ឋានប្រតិបត្តិការ អនុប្រធានមួយ(១)រូបដែលជាប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុប្រធានមួយ( ១ )រូបដែលជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវចាត់តាំងលេខាធិការមួយ( ១ )រូបជាជំនួយការ ។

៧.៤៣.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គជប តាមរយៈអគ្គលេខាធិការ ។

៧.៤៣.៥ ក្រុមកំណត់បែងចែកអាសនៈនៃ គជប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការ និងត្រូវមានការទទួលខុសត្រូវនិងភារកិច្ច ដូចខាងក្រោម ៖

៧.៤៣.៥.១ បញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗ ចំណុះភូមិភាគពាក់ព័ន្ធទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងនិងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ឬទាំងនោះ ។ បន្ទាប់មក កែតម្រូវ ឬ/និងផ្ទៀងផ្ទាត់លទ្ធផល ដែលបានបូកសរុបឃើញក្នុងកុំព្យូទ័រ ជាមួយនឹងតួលេខលទ្ធផលដែលមានក្នុងតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) ដែល គជប យល់ព្រមទទួលយកលទ្ធផលនោះ ។

៧.៤៣.៥.២ បោះពុម្ពសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច និងបិទផ្សាយជាសាធារណៈ ។

៧.៤៣.៥.៣ កែតម្រូវតួលេខលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា យោងតាមសេចក្ដីសំរេចរបស់ គជប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្ដឹងតវ៉ា ( ប្រសិនបើមាន ) និងរៀបចំបោះពុម្ពសេចក្ដីព្រាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេចជាផ្លូវការ និងបិទផ្សាយជាសាធារណៈ ។

៧.៤៣.៥.៤ កំណត់បែងចែកអាសនៈតាមរូបមន្តដែលកំណត់ដោយច្បាប់ ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ ដូចចែងក្នុងឧបសម្ព័ន្ធនៃបទបញ្ជានិងនីតិវិធីនេះ ស្ដីពីការបែងចែកអាសនៈ និងដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ យោងតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៤៣.៥.៥ បោះពុម្ពតារាងលទ្ធផលនៃការបែងចែកអាសនៈ តាមមណ្ឌលភូមិភាគដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយ ដែលត្រូវទទួលបានអាសនៈ បំពេញទៅក្នុងសេចក្ដីព្រាងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ ។

៧.៤៣.៥.៦ រៀបចំតារាងលទ្ធផលនៃការបែងចែកអាសនៈនិងសេចក្ដីព្រាងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោត ជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ រួចដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេចជាផ្លូវការ ។

៧.៤៣.៦ អគ្គលេខាធិការនៃ គជប ត្រូវត្រៀមបន្ទប់មួយចំនួននៃអាគារទីស្ដីការ គជប សម្រាប់ធ្វើជាកន្លែងស្តុកកញ្ចប់ " ឃពិសេស" ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងកញ្ចប់ " ឃ " ដាក់សម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ។ ក្នុងនោះត្រូវ ៖

៧.៤៣.៦.១ ត្រៀមបន្ទប់មួយដោយឡែក នៅជាន់ផ្ទាល់ដី សម្រាប់រក្សាទុករាល់កញ្ចប់ " ឃ " ដាក់សំណុំឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតមួយឬច្រើនដែល គខ/កប បានសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ហើយដែលត្រូវព្យួរលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

៧.៤៣.៦.២ ត្រៀមបន្ទប់មួយចំនួននៅជាន់ផ្ទាល់ដី សម្រាប់ស្តុកកញ្ចប់ " ឃ " ដែលមានដាក់កញ្ចប់ " ខ " ហើយដែលត្រូវដាក់ដោយឡែកពីគ្នា ទៅតាមខេត្ត ក្រុង និងភូមិភាគ ។

៧.៤៣.៦.៣ ត្រៀមបន្ទប់មួយដោយឡែក នៅជាន់ទី ១ សម្រាប់ដាក់រាល់កញ្ចប់សុវត្ថិភាព " ឃពិសេស " នៃ គខ/កប ទាំងអស់ ។

៧.៤៣.៧ អគ្គលេខាធិការនៃ គជប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗច្រើន ដែលអាចឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលបំពេញការងាររបស់ខ្លួនបានល្អ ។

៧.៤៣.៧.១ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលពីរ ឬច្រើន អាចបំពេញការងាររបស់ខ្លួន នៅជុំគ្នាក្នុងបន្ទប់តែមួយឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែកតាមលទ្ធភាពជាក់ស្តែង ។

៧.៤៣.៧.២ ក្នុងករណី គជប តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ សេចក្តីជូនដំណឹងស្តីពីពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះខេត្ត ក្រុង ឈ្មោះនិងលេខកូដការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង ដែលត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ព្រមទាំងលេខរៀងក្រុម និងឈ្មោះប្រធានក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ត្រូវតែបានបិទផ្សាយជាសាធារណៈ នៅមុខទីស្តីការ គជប ដើម្បីជាដំណឹងដល់តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ អ្នកប្តឹងតវ៉ា ឬតំណាង ដែលទទួលបានការអនុញ្ញាត ឱ្យចូលរួមសង្កេតមើលក្នុងដំណើរការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនេះ ។

៧.៤៣.៨ ក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៅ គជប ល័ក្ខខ័ណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្តីការ គជប ព្រមទាំងសណ្តាប់ធ្នាប់និងរបៀបរៀបរយ ត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាល ដែលគ្រប់គ្រងនិងចាត់ចែងដោយអគ្គលេខាធិការនៃ គជប ។

៧.៤៣.៨.១ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៅទីស្តីការ គជប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងនិងការណែនាំរបស់អគ្គលេខាធិការនៃ គជប ឬ/និង

ប្រធានក្រុមដែលត្រូវបានប្រគល់សិទ្ធិស្របតាមល័ក្ខខ័ណ្ឌ ដូចចែងក្នុង បទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយ និងក្រុមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ បោះឆ្នោត ។

៧.៤៣.៨.២ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍និងអ្នកប្ដឹង ឬ តំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួត ពិនិត្យនិងបូកសរុបលទ្ធផលនៅទីស្តីការ គជប មិនត្រូវបានអនុញ្ញាត ឱ្យធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខាន អុកឡុក ឬរាំងដំណើរ ការត្រួតពិនិត្យនិងបូកសរុបលទ្ធផល ឬបំពានលើសិទ្ធិអំណាច និង ឯករាជភាពរបស់ គជប ឡើយ ។

៧.៤៣.៩ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ ដែលក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល និងក្រុម កំណត់បែងចែកអាសនៈរបស់ គជប កំពុងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការ បោះឆ្នោតតាមមណ្ឌលភូមិភាគដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី គជប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល និងក្រុមកំណត់ បែងចែកអាសនៈខាងលើនេះ នូវជនទាំងឡាយដូចខាងក្រោម ៖

៧.៤៣.៩.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល និងក្រុមកំណត់បែង ចែកអាសនៈរបស់ គជប ដែលបានទទួលការតែងតាំងពី គជប ។

៧.៤៣.៩.២ តំណាងនៃគណបក្សនយោបាយ ដែលបានឈរឈ្មោះក្នុងមណ្ឌល ភូមិភាគពាក់ព័ន្ធ អ្នកប្ដឹងពាក់ព័ន្ធ ឬតំណាង ព្រមទាំងអ្នកសង្កេត ការណ៍និងអ្នកយកពត៌មានដែលបានទទួលការអនុញ្ញាតពី គជប ក្នុង ករណីតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់ សន្លឹកឆ្នោតឡើងវិញ ។ ប្រសិនបើ បន្ទប់មានលក្ខណៈចង្អៀត ការ ចូលរួមសង្កេតមើលរបស់តំណាង ដូចចែងក្នុងចំណុចនេះ ត្រូវស្ថិត ក្រោមការគ្រប់គ្រងនិងចាត់ចែងរបស់ប្រធានក្រុមនីមួយៗ តាមសភាព ជាក់ស្តែង ។

៧.៤៣.៩.៣ សមាជិកនៃ គជប និងអគ្គលេខាធិការនៃ គជប ដែលមានបំណង ត្រួតពិនិត្យ តាមដាន និងណែនាំការអនុវត្តរបស់ក្រុមនីមួយៗ ។

**ការប្រគល់ និងការទទួលកញ្ចប់សុវត្ថិភាព " ឃពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងកញ្ចប់ " ឃ " ដាក់សំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ នៅទីស្តីការ គជប**

**ប្រការ ៧.៤៤** សមាសភាពក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គជប ដែលបានតែងតាំងក្រោមចំណុច ៧.៤៣.១ ខាងលើ ត្រូវមានវត្តមានជាប្រចាំនៅទីស្តីការ គជប ចាប់ពីពេលព្រឹកនៃថ្ងៃទីពីរបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីរង់ចាំទទួលសម្ភារៈឯកសារបោះឆ្នោតដែល គខ/កប បានបញ្ជូននិងប្រគល់ជូន គជប ។

៧.៤៤.១ ក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គជប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារៈឯកសារបោះឆ្នោត ដោយផ្អែកតាមករណី និងប្រភេទសំភារៈឯកសារបោះឆ្នោតនីមួយៗ ដែល គខ/កប ត្រូវវេចខ្ចប់និងបញ្ជូនទៅ គជប ដូចចែងក្រោមប្រការ ៧.៤១ ខាងលើ ។

៧.៤៤.២ ក្នុងករណី គខ/កប បានបញ្ជូននិងប្រគល់កញ្ចប់ " ឃ " ដែលមានចារសំគាល់ពាក្យ " ព្យួរលទ្ធផល " ដូចចែងក្នុងចំណុច ៧.៤១.៥.៤ ខាងលើជូន គជប ក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គជប ត្រូវបើកកញ្ចប់ " ឃ " និងត្រូវត្រួតពិនិត្យសំភារៈឯកសារនៅខាងក្នុង ដោយផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារបោះឆ្នោត ( ទម្រង់បែបបទលេខ ១១០៧ ) ទាំងបី( ៣ )ច្បាប់ ដែលមួយ( ១ )ច្បាប់នៅក្នុងកញ្ចប់ " ឃ " មួយ( ១ )ច្បាប់នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " និងមួយ( ១ )ច្បាប់នៅនឹងមន្ត្រីនៃ គខ/កប ដែលបញ្ជូនសម្ភារៈឯកសារមក ។ ក្រុមទទួលសំភារៈឯកសារអាចបើកស្រោមសំបុត្រធំ ដើម្បីត្រួតពិនិត្យឯកសារខាងក្នុង ប៉ុន្តែមិនត្រូវបើកកញ្ចប់ " ខ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀតទេ ។ ក្នុងនេះ ប្រធានក្រុមទទួលសម្ភារៈឯកសារត្រូវ ៖

៧.៤៤.២.១ ចាត់មន្ត្រីក្នុងក្រុម ឱ្យកត់ត្រាមុខសម្ភារៈឯកសារពិនិត្យឃើញក្នុងកញ្ចប់ " ឃ " ដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ហើយប្រសិនបើមានគ្រប់ចំនួនហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

៧.៤៤.២.២ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារ ដូចចែងក្នុងចំណុច ៧.៤៤.២ ខាងលើ រួចប្រគល់មួយ( ១ )ច្បាប់ជូនមន្ត្រី គខ/កប ទទួលបន្ទុកការបញ្ជូន ដាក់មួយ( ១ )ច្បាប់ទៅក្នុងហោប៉ៅកញ្ចប់ " ឃ " វិញ និងដកមួយ( ១ )ច្បាប់ចងក្រងទុកជាឯកសារ ។

៧.៤៤.២.៣ ដកយកស្រោមសំបុត្រធំ ពីក្នុងកញ្ចប់ " ឃ " រួចប្រគល់ជាបន្ទាន់ជូនអគ្គលេខាធិការ និងរាយការណ៍អំពីឈ្មោះនិងលេខកូដការិយាល័យបោះឆ្នោតនៃខេត្ត ក្រុងដែលត្រូវ គខ/កប សម្រេចព្យួរលទ្ធផលនៃការបោះឆ្នោត ដើម្បីអគ្គលេខាធិការបន្តរាយការណ៍ជូន គជប ។

៧.៤៤.២.៤ ចាត់មន្ត្រីក្នុងក្រុមឱ្យនាំយកកញ្ចប់ " ឃ " ផ្ទុកកញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គខ/កប សំរេចព្យួរជាបណ្តោះអាសន្ននោះ ទៅរក្សាទុកនៅក្នុងបន្ទប់ ដែលបានត្រៀមបំរុងទុកស្រាប់ ។

៧.៤៤.៣ ក្នុងករណី គខ/កប បានបញ្ជូននិងប្រគល់ជូន គជប នូវកញ្ចប់ " ឃពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងឯកសារពាក់ព័ន្ធសំខាន់ៗ ដូចចែងក្នុងចំណុច ៧.៤១.៤ ខាងលើ និងកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤១.៦.៣ ខាងលើដែលដាក់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងខេត្ត ក្រុងដែលលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យនោះ ឬទាំងនោះ ត្រូវបាន គខ/កប សម្រេចយល់ព្រម ក្រុមទទួលសម្ភារៈឯកសារនៃ គជប ត្រូវចាត់ចែងត្រួតពិនិត្យ និងទទួលកញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " ដូចខាងក្រោម ។ ក្នុងនេះ ប្រធានក្រុមទទួលសម្ភារៈឯកសារត្រូវ ៖

៧.៤៤.៣.១ ត្រួតពិនិត្យឱ្យប្រាកដថា កញ្ចប់សុវត្ថិភាព " ឃពិសេស " មិនត្រូវបានរុះរើឡើយ ហើយមិនត្រូវបើកកញ្ចប់សុវត្ថិភាព " ឃពិសេស " ដើម្បីធ្វើការត្រួតពិនិត្យទេ ។ ប្រធានក្រុមត្រូវចុះហត្ថលេខាលើលិខិតបញ្ជូននិងប្រគល់ទទួលសម្ភារៈឯកសារ ( ១១០៧ ) ចំនួនពីរ( ២ ) ច្បាប់ដែលមួយ( ១ )ច្បាប់នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃពិសេស " និងមួយ( ១ )ច្បាប់នៅនឹងមន្ត្រី គខ/កប ដែលទទួលការបញ្ជូនបន្ទាប់មក ត្រូវប្រគល់ជូនមន្ត្រី គខ/កប វិញមួយ( ១ )ច្បាប់ និង ចងក្រងទុកជាឯកសារមួយ( ១ )ច្បាប់ ។

៧.៤៤.៣.២ ចាត់មន្ត្រីក្នុងក្រុមឱ្យកត់ត្រាក្នុងបញ្ជីរបស់ខ្លួន និងយកកញ្ចប់សុវត្ថិភាព " ឃពិសេស " ទៅរក្សាទុកនៅបន្ទប់ស្តុក ដែលបានត្រៀមបំរុងស្រាប់ ។

៧.៤៤.៣.៣ ចាត់មន្ត្រីក្នុងក្រុមឱ្យបើកកញ្ចប់ " ឃ " និងត្រួតពិនិត្យសំភារៈឯកសារនៅខាងក្នុង ដោយផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូននិងប្រគល់ទទួល

សម្ភារៈឯកសារ ( ១១០៧ ) ទាំងបី( ៣ )ច្បាប់ដែលមួយ( ១ ) ច្បាប់នៅក្នុងកញ្ចប់ " ឃ " មួយ( ១ )ច្បាប់នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " និងមួយច្បាប់នៅនឹងមន្ត្រី គខ/កប ដែលបញ្ជូនសម្ភារៈឯកសារមក ។

៧.៤៤.៣.៤ ចាត់មន្ត្រីក្នុងក្រុម ឱ្យកត់ត្រាមុខសម្ភារៈឯកសារពិនិត្យឃើញក្នុងកញ្ចប់ " ឃ " ដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើមានគ្រប់ចំនួនហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

៧.៤៤.៣.៥ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈឯកសារ ដូចចែងក្នុងចំណុច ៧.៤៤.៣.៣ ខាងលើ រួចប្រគល់មួយ( ១ )ច្បាប់ជូនមន្ត្រី គខ/កប ទទួលបន្ទុកការបញ្ជូនវិញ ដាក់មួយ( ១ )ច្បាប់ទៅក្នុងហោប៉ៅកញ្ចប់ " ឃ" និងដកមួយ( ១ )ច្បាប់ចងក្រងទុកជាឯកសារ ។

៧.៤៤.៣.៦ ចាត់មន្ត្រីក្នុងក្រុមឱ្យនាំយកកញ្ចប់ " ឃ " នៃខេត្ត ក្រុង ដែលលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ ត្រូវបាន គខ/កប សម្រេចយល់ព្រមទទួលយក បើទោះបីមាន ឬគ្មានបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ក្តី ទៅរក្សាទុកនៅក្នុងបន្ទប់ស្តុកដែលបានត្រៀមបំរុងស្រាប់ ដោយត្រូវដាក់តាមខេត្ត ក្រុងនិងភូមិភាគ ។

៧.៤៤.៣.៧ រាយការណ៍ជូនអគ្គលេខាធិការជាបន្ទាន់នូវខេត្ត ក្រុង ដែលបានប្រគល់កញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " ដាក់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត ដែលលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យនោះ ឬទាំងនោះ ត្រូវបាន គខ/កប សម្រេចយល់ព្រមទទួលយក ដើម្បីអគ្គលេខាធិការបន្តរាយការណ៍ជូន គជប ។ ប្រសិនបើក្នុងខេត្ត ក្រុងពាក់ព័ន្ធ មានការិយាល័យបោះឆ្នោតមួយឬច្រើន ដែលមានបណ្តឹងត្រូវបានដាក់នៅ គខ/កប និងដែលមានកញ្ចប់សុវត្ថិភាព " ក " ត្រូវបានបើកផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធានក្រុមត្រូវបញ្ជាក់បន្ថែមអំពីឈ្មោះ និងលេខកូដការិយាល័យបោះឆ្នោតនោះ ឬទាំងនោះផង ។

៧.៤៤.៤ ក្នុងករណី គខ/កប បានបញ្ជូននិងប្រគល់សន្លឹកឆ្នោតបំរុងសំរាប់ខេត្ត ក្រុងដែលនៅសល់មិនប្រើប្រាស់ ដូចចែងក្នុងចំណុច ៧.៤១.៩ ខាងលើជូន គជប ក្រុមទទួល

សម្ភារៈឯកសារបោះឆ្នោតនៃ គជប ត្រូវណែនាំមន្ត្រី គខ/កប ទទួលបន្ទុកការបញ្ជូន ឱ្យដឹកជញ្ជូនសន្លឹកឆ្នោតបំរុង ដែលនៅសល់ទាំងនោះទៅឃ្លាំង គជប ។ អនុប្រធាននាយកដ្ឋានប្រតិបត្តិការទទួលបន្ទុកភស្តុភារត្រូវចាត់ចែងមន្ត្រីក្រោមឱវាទ ឱ្យត្រួតពិនិត្យទទួលនិងរក្សាទុកសន្លឹកឆ្នោតបំរុងនៅសល់ទាំងនោះនៅក្នុងឃ្លាំង គជប ដោយអនុវត្តតាមលក្ខការណ៍នៃការងារជំនាញ ដែលក្នុងនោះ ត្រូវយកចិត្តទុកដាក់ជាពិសេសអំពីបរិមាណ គុណភាព និងបែបបទប្រគល់ទទួល និងបញ្ចូលឃ្លាំង ។

៧.៤៤.៤.១ ការត្រួតពិនិត្យបរិមាណ និងគុណភាពនៃសន្លឹកឆ្នោតបំរុងសំរាប់ខេត្ត ក្រុង ដែលនៅសល់មិនប្រើប្រាស់ ត្រូវអនុវត្តយ៉ាងម៉ត់ចត់ ប៉ុន្តែមិនចាំបាច់តម្រូវឱ្យហែកកញ្ចប់សន្លឹកឆ្នោតទាំងនោះទេ ។

៧.៤៤.៤.២ សន្លឹកឆ្នោតបំរុង ដែលនៅសល់មិនប្រើប្រាស់ ត្រូវតែបានរក្សាទុកយ៉ាងគត់មត់ ដោយត្រូវដាក់តាមខេត្ត ក្រុង និងភូមិភាគ ។

៧.៤៤.៥ ក្នុងករណី គខ/កប បានបញ្ជូននិងប្រគល់សម្ភារៈឧបករណ៍បំរើការបោះឆ្នោតនៅសល់ដូចចែងក្នុងចំណុច ៧.៤១.១០ ខាងលើជូន គជប ក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គជប ត្រូវណែនាំមន្ត្រី គខ/កប ទទួលបន្ទុកការបញ្ជូន ឱ្យដឹកជញ្ជូនសម្ភារៈឧបករណ៍បោះឆ្នោតនៅសល់ទាំងនោះទៅឃ្លាំង គជប ។ អនុប្រធាននាយកដ្ឋានប្រតិបត្តិការទទួលបន្ទុកភស្តុភារ ត្រូវចាត់ចែងមន្ត្រីក្រោមឱវាទ ឱ្យត្រួតពិនិត្យទទួលនិងរក្សាទុកសម្ភារៈឧបករណ៍បំរើការបោះឆ្នោតនៅសល់ទាំងនោះក្នុងឃ្លាំង គជប ដោយអនុវត្តតាមលក្ខការណ៍នៃការងារជំនាញ ដែលក្នុងនោះត្រូវយកចិត្តទុកដាក់ជាពិសេសអំពីបរិមាណ គុណភាព និងបែបបទប្រគល់ ទទួលនិងបញ្ចូលឃ្លាំង ។ ដោយឡែកចំពោះគ្រឿងបរិក្ខារអេឡិកត្រូនិច អនុប្រធាននាយកដ្ឋានប្រតិបត្តិការទទួលបន្ទុកប្រតិបត្តិការត្រូវចាត់ចែងមន្ត្រីក្រោមឱវាទ ឱ្យត្រួតពិនិត្យទទួល និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយអនុវត្តតាមលក្ខការណ៍នៃការងារជំនាញ ដែលក្នុងនោះ ត្រូវយកចិត្តទុកដាក់ជាពិសេសអំពីបរិមាណ គុណភាព និងបែបបទប្រគល់ទទួល ។

## កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ក្នុងភាគត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ

**ប្រការ ៧.៤៥** ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប មានភារកិច្ចត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងមួយ ឬច្រើនចំណុះភូមិភាគ បញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ក្នុងគោលបំណងបញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការបូក

សរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងខេត្ត ក្រុង និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ខេត្ត ក្រុងក្នុងភូមិភាគ ។ ប្រសិនបើ ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលយល់ព្រមតាមកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងទាំងអស់ចំណុះភូមិភាគ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវបំពេញតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) ហើយដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ប្រសិនបើ គជប សំរេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនោះ គជប ត្រូវប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនិងសំណុំឯកសារពាក់ព័ន្ធ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់ចំនួនអាសនៈដែលត្រូវបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងរៀបចំជាសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រួចដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច និងបិទផ្សាយជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៤៥.១ នៅពេលដែល គជប បានទទួលតាមរយៈអគ្គលេខាធិការនូវរបាយការណ៍ ពីនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ដូចចែងក្នុងចំណុច ៧.៤២.៥ ខាងលើ និងពីក្រុមទទួលសម្ភារៈឯកសារ ដូចចែងក្នុងចំណុច ៧.៤៤.២.៣ និង ៧.៤៤.៣.៧ ខាងលើ គជប ត្រូវកំណត់ និងណែនាំអំពីករណីដែលនឹងត្រូវធ្វើការត្រួតពិនិត្យនិងបូកសរុបលទ្ធផលបោះឆ្នោតតាមភូមិភាគ និងត្រូវសម្រេចអំពីភាពមិនចាំបាច់ ឬភាពចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើ លក្ខខណ្ឌតម្រូវឱ្យធ្វើដូច្នេះ ។

៧.៤៥.២ ផ្អែកតាមការកំណត់ណែនាំរបស់ គជប ជាដំបូង អគ្គលេខាធិការត្រូវចាត់ចែងក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគនីមួយៗដែលក្រុមទទួលបន្ទុក ។ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវបំពេញការងារពាក់ព័ន្ធ តាមការចាំបាច់ និងតាមករណីជាក់ស្តែងនៃខេត្ត ក្រុងចំណុះភូមិភាគនីមួយៗ ដូចខាងក្រោម ៖

៧.៤៥.២.១ ខេត្ត ក្រុងចំណុះភូមិភាគ ដែលមានលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបាន គខ/កប សម្រេចព្យួរជាបណ្តោះអាសន្ន និងដែលបានបញ្ជូនមក គជប ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ។

៧.៤៥.២.២ ខេត្ត ក្រុងចំណុះភូមិភាគ ដែលគ្មានឬមានបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបានដាក់នៅ គខ/កប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតណាមួយ ត្រូវបានបើកផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ទេ ហើយ គខ/កប បានសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

៧.៤៥.២.៣ ខេត្ត ក្រុងចំណុះភូមិភាគ ដែលមានបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ត្រូវបានដាក់នៅ គខ/កប ឬ/និងនៅ គជប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក" នៃការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបានបើកផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ប៉ុន្តែ គខ/កប បានសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

៧.៤៥.២.៤ ខេត្ត ក្រុងចំណុះភូមិភាគដែលមានការិយាល័យបោះឆ្នោតមួយឬច្រើន មិនបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ឬដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គជប បដិសេធ ហើយដែល គជប បានសំរេចឱ្យបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

៧.៤៥.៣ អ្នកប្តឹងពាក់ព័ន្ធឬតំណាងដែលពាក្យបណ្តឹងតវ៉ារបស់គាត់ ត្រូវបាន គខ/កប សម្រេចយល់ព្រម ឬបដិសេធ ដែលត្រូវសំរេចទទួលយក ឬព្យួរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន និងអ្នកប្តឹងពាក់ព័ន្ធឬតំណាងដែលបានដាក់ពាក្យប្តឹងតវ៉ានៅ គជប ដូចចែងក្រោមប្រការ ៧.៤២ ខាងលើ ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើល ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគដែល គជប តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅទីស្តីការ គជប ។ ការចូលរួមសង្កេតមើលរបស់អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ដែលចែងក្នុងចំណុចនេះត្រូវស្ថិតក្រោមការគ្រប់គ្រង និងការណែនាំរបស់ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដោយផ្អែកតាមសភាពជាក់ស្តែង ។

៧.៤៥.៤ ក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ប្រសិនបើ មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតនៃ

ការិយាល័យមួយ ឬច្រើនឡើងវិញ ត្រូវតែធ្វើឱ្យចប់ចុងចប់ដើមសំរាប់ការិយាល័យនោះ ឬទាំងនោះ ដោយមិនគិតពីពេលវេលានៃម៉ោងការងារឡើយ ។

៧.៤៥.៥ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ត្រូវបើកកិច្ចប្រតិបត្តិការ ដើម្បីត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដែលក្រុមទទួលបន្ទុកម្តងមួយៗ នៅបន្ទប់ធំទូលាយណាមួយ ឬបន្ទប់តូចៗដោយឡែកពីគ្នា ដែលបានត្រៀមបំរុងជាមុន ដូចចែងក្នុងចំណុច ៧.៤៣.៧.១ ខាងលើ ។ ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនេះ ប្រធានក្រុមត្រូវធានាឱ្យមានសម្ភារៈឯកសារបោះឆ្នោត នៃខេត្ត ក្រុងចំណុះភូមិភាគពាក់ព័ន្ធ និងទម្រង់បែបបទចាំបាច់មួយចំនួន សម្រាប់យោង និងប្រើប្រាស់ ដូចខាងក្រោម ៖

៧.៤៥.៥.១ រាល់កំណត់ហេតុបូកសរុបលទ្ធផល ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត កំណត់ហេតុរបស់ គខ/កប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ( ប្រសិនបើមាន ) សេចក្តីសំរេចរបស់ គខ/កប យល់ព្រម ឬបដិសេធលើបណ្តឹងតវ៉ា ( ប្រសិនបើមាន ) និងលិខិតរបស់ គខ/កប ស្នើសុំ គជប ពិនិត្យឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតដែល គខ/កប បានសំរេចព្យួរជាបណ្តោះអាសន្ន ( ប្រសិនបើមាន ) ។

៧.៤៥.៥.២ រាល់កញ្ចប់ " ឃ " ផ្ទុកកញ្ចប់ " ខ " ដាក់កញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតដែល គជប តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ( ប្រសិនបើតម្រូវឱ្យធ្វើដូច្នេះ ) ។

៧.៤៥.៥.៣ ទម្រង់បែបបទ ១១០៧គព សម្រាប់បំពេញតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ។

៧.៤៥.៥.៤ ម៉ាស៊ីនគិតលេខមួយគ្រឿង ។

**ការត្រួតពិនិត្យឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើននៃខេត្ត ក្រុងចំណុះភូមិភាគ ដែលត្រូវបាន គខ/កប សម្រេចព្យួរជាបណ្តោះអាសន្ន**

**ប្រការ ៧.៤៦** យោងតាមការកំណត់ណែនាំរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៥.២.១ ខាងលើ បានតម្រូវឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត នៅ

ការិយាល័យបោះឆ្នោតមួយ ឬច្រើននៃខេត្ត ក្រុងចំណុះភូមិភាគ ដែលត្រូវបាន គខ/កប សម្រេចព្យួរជាបណ្ដោះអាសន្ន ។ ចំពោះករណីនេះ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ដែលទទួលបន្ទុកតាមភូមិភាគ ឱ្យអនុវត្តតាមនីតិវិធី ដូចខាងក្រោម ៖

៧.៤៦.១ អគ្គលេខាធិការត្រូវធានាថា ការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតមួយ ឬច្រើនចំណុះខេត្ត ក្រុង ដែលត្រូវបាន គខ/កប សម្រេចព្យួរជាបណ្ដោះអាសន្ន ត្រូវតែបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គជប ពិនិត្យសម្រេចក្នុងរយៈពេលយ៉ាងយូរពីរ( ២ )ថ្ងៃ បន្ទាប់ពីថ្ងៃដែល គជប បាន ទទួលកញ្ចប់ " ឃ " ដាក់សំណុំឯកសារនៃការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត នៅ ការិយាល័យបោះឆ្នោត ដែលត្រូវព្យួរលទ្ធផលនោះ ឬទាំងនោះ ដូចចែងក្នុងចំណុច ៧.៤៤.២ ខាងលើ ។

៧.៤៦.២ ក្នុងករណី គជប សម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវពិនិត្យផ្ទៀង ផ្ទាត់លទ្ធផល ដោយគ្រាន់តែផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រ ធំដែលដកយកពីកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤៤.២.៣ ប៉ុណ្ណោះ ។

៧.៤៦.៣ ក្នុងករណី គជប សម្រេចតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវពិនិត្យផ្ទៀង ផ្ទាត់លទ្ធផល ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំដែល ដកយកពីកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ៧.៤៤.២.៣ ផង និងត្រូវអនុវត្ត បន្ថែមតាមលក្ខខណ្ឌ និងនីតិវិធីទាំងឡាយ ដូចខាងក្រោម ៖

៧.៤៦.៣.១ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវចាត់សមាជិករបស់ ខ្លួនពីររូប ឱ្យទៅនាំយកកញ្ចប់ " ឃ " ផ្ទុកកញ្ចប់ " ខ " មានដាក់ កញ្ចប់សុវត្ថិភាព " ក " និងសំភារៈឯកសារពាក់ព័ន្ធ ពីបន្ទប់ស្តុក ដូចចែងក្នុងចំណុច ៧.៤៤.២.៤ ខាងលើ មកកាន់បន្ទប់ដែលត្រូវ អនុវត្តការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹក ឆ្នោតឡើងវិញ ។

៧.៤៦.៣.២ ក្នុងការបើកកញ្ចប់សុវត្ថិភាព " ក " ពិនិត្យផ្ទៀងផ្ទាត់សម្ភារៈឯកសារ បោះឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវអនុវត្ត ស្របជៀងគ្នា តាមលំនាំនីតិវិធីដែលតម្រូវឱ្យ គខ/កប អនុវត្ត ដូចចែង ចាប់ពីចំណុច ៧.៣៩.៦ ដល់ចំណុច ៧.៣៩.៩ ខាងលើ ។

៧.៤៦.៣.៣ ក្នុងការរាប់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយឡើងវិញ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវអនុវត្តស្រដៀងគ្នា តាមលំនាំនីតិវិធី ដែលតម្រូវឱ្យ គកប អនុវត្ត ដូចចែងក្រោមប្រការ ៧.៣៤ និង ៧.៣៥ ខាងលើ ។

៧.៤៦.៣.៤ ដោយផ្អែកលើលិខិតរបស់ គខ/កប ស្នើសុំ គជប ពិនិត្យឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតដែលត្រូវបានព្យួរជាបណ្ដោះអាសន្ន សេចក្ដីសំរេចរបស់ គខ/កប យល់ព្រមលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ កំណត់ហេតុស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប និងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គជប ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវធ្វើរបាយការណ៍ត្រួតពិនិត្យលទ្ធផល សរសេរដោយដៃ ដោយលើកយោបល់ជូន គជប ដើម្បីពិនិត្យសំរេចទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។ របាយការណ៍នេះចំនួនមួយ( ១ )ច្បាប់ ត្រូវតែបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ។

៧.៤៦.៣.៥ ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលត្រូវធានាថា រាល់កំណត់ហេតុទម្រង់បែបបទ និងសំភារៈឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៤៦.៣ និង ៧.៤៦.៣.១ ខាងលើ ដែលបានប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនេះ ត្រូវតែបានដាក់តាមលំដាប់លំដោយទៅក្នុងស្រោមសំបុត្រធំឬកញ្ចប់សុវត្ថិភាព " ក " កញ្ចប់ " ខ " និងកញ្ចប់ " ឃ " តាមលំនាំដូចដើម ដែលត្រូវយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈឯកសាររក្សាទុកនៅបន្ទប់ស្តុកវិញ លើកលែងតែរបាយការណ៍ កំណត់ហេតុ និងរាល់ឯកសារ ដូចចែងក្នុងចំណុច ៧.៤៦.៤ ខាងក្រោម ។

៧.៤៦.៤ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធី ដូចចែងក្នុងចំណុច ៧.៤៦.៣ ខាងលើ ប្រធានក្រុមត្រូវធានាថា របាយការណ៍ត្រួតពិនិត្យសរសេរដោយដៃ ព្រមទាំងលិខិត កំណត់ហេតុនិងឯកសារពាក់ព័ន្ធផ្សេងទៀត ដូចចែងក្នុងចំណុច ៧.៤៦.៣.៤ ខាងលើ ចំនួនមួយ( ១ )ច្បាប់ ត្រូវតែបានដាក់ជូន គជប តាម

រយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវបញ្ជាក់ច្បាស់ក្នុងរបាយការណ៍ត្រួតពិនិត្យសរសេរដោយដៃ តាមការកំណត់ ដូចខាងក្រោម ៖

៧.៤៦.៤.១ ប្រសិនបើលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបង្ហាញថា ពិតជាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធ ប្រធានក្រុមត្រូវលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ និងសំរេចឱ្យបោះឆ្នោតសាជាថ្មី ។

៧.៤៦.៤.២ ប្រសិនបើលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបង្ហាញថា គ្មានភាពមិនប្រក្រតីណាមួយ ដែលអាចនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធទេ ប្រធានក្រុមត្រូវលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ។

៧.៤៦.៥ ប្រសិនបើ គជប សម្រេចយល់ព្រមតាមសេចក្តីសម្រេចរបស់ គខ/កប ក្នុងការព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត និងដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ គជប ត្រូវ ៖

៧.៤៦.៥.១ ចារយល់ព្រមលើសេចក្តីសម្រេចរបស់ គខ/កប ដែលព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនិងចារយល់ព្រមលើរបាយការណ៍ត្រួតពិនិត្យសរសេរដោយដៃ ដែលបានលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៦.៥.២ ចាត់ចែងមន្ត្រីជំនាញ ឱ្យបំពេញសេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ( ទម្រង់បែបបទលេខ ១២០៣ ) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធផង ហើយដែលត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទ ដោយ គជប ។

៧.៤៦.៥.៣ ធានាថា សេចក្តីសម្រេចបដិសេធខាងលើ ត្រូវបានប្រគល់ជូនម្ចាស់ដើមបណ្តឹងមួយ( ១ )ច្បាប់ ផ្ញើជូន គខ/កប ពាក់ព័ន្ធមួយ( ១ ) ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ព្រមទាំងថតចម្លង និងចែកជូនគ្រប់តំណាងគណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគមួយច្បាប់ ។

៧.៤៦.៥.៤ ប្រកាសថាសេចក្ដីសម្រេចរបស់ គជប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ជាសេចក្ដីសម្រេចចុងក្រោយ ហើយ គជប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ក្នុងរយៈពេលយ៉ាងយូរប្រាំបី(៨) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីសេម្រេចបដិសេធ ។

៧.៤៦.៥.៥ ប្រគល់តាមរយៈអគ្គលេខាធិការ នូវរបាយការណ៍ត្រួតពិនិត្យសរសេរដោយដៃ និងរាល់ឯកសារភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៦.៤ ខាងលើ ទៅឱ្យក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ដើម្បីរៀបចំដាក់ក្នុងស្រោមសំបុត្រធំ រួចបន្តប្រគល់ជូនក្រុមទទួលសម្ភារៈឯកសាររក្សាទុកនៅកន្លែងដើមវិញ ។

៧.៤៦.៦ យោងសេចក្ដីសម្រេចបដិសេធរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៦.៥.២ ខាងលើ គជប ត្រូវណែនាំអគ្គលេខាធិការនៃ គជប និង គខ/កប ពាក់ព័ន្ធឱ្យចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី និងការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ការវេចខ្ចប់បញ្ជូនកំណត់ហេតុ និងសំភារៈឯកសារបោះឆ្នោតជូន គខ/កប ព្រមទាំងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៅ គខ/កប និងការវេចខ្ចប់បញ្ជូនកំណត់ហេតុ និងសំភារៈឯកសារបោះឆ្នោតជូន គជប ដោយត្រូវអនុវត្តតាមលំនាំ នីតិវិធីនិងលក្ខខណ្ឌ ដូចចែងក្រោមប្រការ ៧.៣៣ នៃបទបញ្ជានិងនីតិវិធីនេះ ។

៧.៤៦.៦.១ គជប ត្រូវធានាថា លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតដែល គជប សំរេចឱ្យបោះឆ្នោតសាជាថ្មី ដូចចែងក្នុងចំណុច ៧.៤៦.៦ ខាងលើ ត្រូវតែបានត្រួតពិនិត្យ និងបូកសរុបលទ្ធផលបញ្ចូលគ្នា ជំនួសលទ្ធផលនៃការបោះឆ្នោត ដែលត្រូវបានបដិសេធទៅក្នុងកំណត់ហេតុ ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធចំណុះភូមិភាគនៅមុនពេលពិនិត្យផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ៧.៤៩ ខាងក្រោម ។

៧.៤៦.៧ ប្រសិនបើ គជប សម្រេចមិនយល់ព្រមតាមសេចក្ដីសម្រេចរបស់ គខ/កប ក្នុងការព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត និងដែលត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ គជប ត្រូវ ៖

៧.៤៦.៧.១ ចារបដិសេធលើសេចក្តីសម្រេចរបស់ គខ/កប ដែលញ្ញើរជាបណ្តឹង អាសន្នទូវលទ្ធផលនៃការបោះឆ្នោតនិងចារយល់ព្រមលើរបាយការណ៍ ត្រួតពិនិត្យសរសេរដោយដៃ ដែលបានលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះ ឆ្នោតនោះ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៦.៧.២ ចាត់ចែងមន្ត្រីជំនាញ ឱ្យបំពេញសេចក្តីសម្រេចយល់ព្រមទទួលយក លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ( ទម្រង់ បែបបទលេខ ១២០៣ ) ដោយបញ្ជាក់ច្បាស់អំពីមូលហេតុនៃការ យល់ព្រមផង ហើយដែលត្រូវចុះហត្ថលេខានិងកាលបរិច្ឆេទ ដោយ គជប ។

៧.៤៦.៧.៣ ធានាថា សេចក្តីសម្រេចយល់ព្រមខាងលើ ត្រូវបានប្រគល់ជូនម្ចាស់ ដើមបណ្តឹងមួយ( ១ )ច្បាប់ ផ្ញើជូន គខ/កប ពាក់ព័ន្ធមួយ( ១ ) ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ព្រមទាំងថតចម្លង និងចែកជូនគ្រប់តំណាងគណបក្សនយោបាយ ដែលបានឈរឈ្មោះ បោះឆ្នោតក្នុងភូមិភាគមួយច្បាប់ ។

៧.៤៦.៧.៤ ប្រកាសថា សេចក្តីសម្រេចរបស់ គជប ដែលយល់ព្រមទទួលយក លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ជាសេចក្តី សម្រេចចុងក្រោយ ។

៧.៤៦.៧.៥ ប្រគល់តាមរយៈអគ្គលេខាធិការ នូវរបាយការណ៍ត្រួតពិនិត្យសរសេរ ដោយដៃ និងរាល់ឯកសារភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៦.៤ ខាងលើ ទៅឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលដើម្បីមុខការ ។

៧.៤៦.៨ យោងសេចក្តីសម្រេចយល់ព្រមរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៦.៧.២ ខាង លើ អគ្គលេខាធិការនៃ គជប ត្រូវធានាថាផ្នែកលើរបាយការណ៍ត្រួតពិនិត្យសរសេរ ដោយដៃ កំណត់ហេតុ និងរាល់ឯកសារផ្សេងទៀតភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៦.៧.៥ ខាងលើ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលបានផ្ទៀងផ្ទាត់ ឬ/និង កែតម្រូវតាមកំណែរបស់ គជប ( ប្រសិនបើមាន ) នូវទិន្នន័យលទ្ធផលនៃការ បោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ នៅលើកំណត់ហេតុ ក្រដាសលទ្ធផល និង តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងពាក់ព័ន្ធ ហើយត្រូវបន្តពិនិត្យ ផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនិងតាមភូមិភាគ ដែល

ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន ដូចចែងក្រោមចំណុច ៧.៤៣.២ និង ៧.៤៣.៣ ខាងលើ ព្រមទាំងប្រការ ៧.៤៧ ឬ/និង ៧.៤៨ ខាងក្រោម ។

៧.៤៦.៩ ផ្អែកតាមសេចក្តីសំរេចរបស់ គជប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ និងបន្ទាប់ពីបានបូកសរុបលទ្ធផល នៃការបោះឆ្នោតនោះ បញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធ និងលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគរួច ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវធានាថា តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ និងរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ព្រមទាំងកំណត់ហេតុក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផលពាក់ព័ន្ធ ត្រូវតែបានដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ដោយឡែកត្រូវធានាថា រាល់ឯកសារបោះឆ្នោតផ្សេងទៀត ដែលមិនត្រូវដាក់ភ្ជាប់ជូន គជប ត្រូវតែបានវេចខ្ចប់តាមលំនាំដូចដើមទៅក្នុងស្រោមសំបុត្រធំ រួចប្រគល់ជូនក្រុមទទួលសម្ភារៈឯកសារ ដែលត្រូវរក្សាទុកជាមួយគ្នានឹងកញ្ចប់សុវត្ថិភាព " យពិសេស " នៅកន្លែងស្តុក ។

៧.៤៦.១០ ផ្អែកលើតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ចំណុះភូមិភាគ ព្រមទាំងសំណុំឯកសារបោះឆ្នោតផ្សេងទៀតភ្ជាប់ជាមួយ ដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤៦.៩ ខាងលើ ប្រសិនបើ គជប ពិនិត្យឃើញថាត្រឹមត្រូវហើយ គជប ត្រូវសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោត តាមភូមិភាគនោះ ដែលក្នុងនោះ ប្រធាន គជប ត្រូវ ៖

៧.៤៦.១០.១ ចារយល់ព្រម លើរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៦.១០.២ ចារយល់ព្រមលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៦.១០.៣ ប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធដែលត្រូវបាន គជប ចារយល់ព្រម

និងសំណុំឯកសារភ្ជាប់មកជាមួយ ដូចចែងក្នុងចំណុច ៧.៤៦.១០ ខាងលើ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ និងប្រការ ៧.៥០ ខាងក្រោម ។

**ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ដែលគ្មាន ឬមានបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបានដាក់នៅ គខ/កប ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ**

**ប្រការ៧.៤៧** យោងតាមការកំណត់ណែនាំរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៥.២.២ ខាងលើ បានតម្រូវឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងចំណុះភូមិភាគ ដែលគ្មាន ឬមានបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបានដាក់នៅ គខ/កប ហើយដែលគ្មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញទេ ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលដែលទទួលបន្ទុកតាមភូមិភាគ ឱ្យអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៧.៤៧.១ ក្នុងករណីខាងលើនេះ ជាដំបូង ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ចំណុះភូមិភាគ ដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នាម្ដងមួយខេត្ត ក្រុង ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងរាល់ឯកសារបោះឆ្នោតពាក់ព័ន្ធ ដែលមាននៅក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ប៉ុណ្ណោះ ដោយមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។ ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងណាមួយចំណុះភូមិភាគ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ត្រូវ ៖

៧.៤៧.១.១ ចាត់សមាជិកក្រុមពីររូបឱ្យទៅនាំយកកញ្ចប់ " ឃពិសេស " នៃខេត្ត ក្រុងចំណុះភូមិភាគដែលក្រុមទទួលបន្ទុក ម្ដងមួយខេត្ត ក្រុងពីកន្លែងរក្សាស្តុក មកកាន់បន្ទប់ដែលត្រូវអនុវត្តការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ។

៧.៤៧.១.២ បើកកញ្ចប់ " ឃពិសេស " រួចដកយករាល់ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង ( ទម្រង់

បែបបទលេខ ១១១១ ) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១៩ ) និងតារាងបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ដូចចែងក្រោមចំណុច ៧.៤១.២.១ ខាងលើ មកដាក់នៅលើតុ ។

៧.៤៧.១.៣ រក្សាទុកកញ្ចប់ " ឃពិសេស " ដែលមានរាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត កំណត់ហេតុស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងរាល់សេចក្តីសម្រេចរបស់ គឧ/កប បដិសេធលើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងឯកសារផ្សេងទៀត នៅក្បែរខ្លួនគាត់ ។

៧.៤៧.១.៤ ចាត់ចែងសមាជិកក្នុងក្រុម ឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ដោយផ្អែកលើកំណត់ហេតុ ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.២ ខាងលើ ហើយប្រសិនបើ មានភាពមិនច្បាស់លាស់ ត្រូវឱ្យពិនិត្យបន្ថែម នូវកំណត់ហេតុនិងឯកសារផ្សេងទៀត ដូចចែងក្នុងចំណុច ៧.៤៧.១.៣ ខាងលើ ។

៧.៤៧.១.៥ ធានាថា របាយការណ៍ត្រួតពិនិត្យលទ្ធផលសរសេរដោយដៃចំនួនមួយ (១)ច្បាប់ ត្រូវបានធ្វើនិងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើ បានរកឃើញថា ៖

- តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់ មានភាពត្រឹមត្រូវ ។
- គឧ/កប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ។

៧.៤៧.១.៦ ធានាថា លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគពាក់ព័ន្ធដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញត្រឹមត្រូវហើយ ឬបានកែតម្រូវត្រឹមត្រូវហើយ ត្រូវតែបានបូកសរុបលទ្ធផលរួមបញ្ចូលគ្នា ទៅក្នុងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ

( ទម្រង់បែបបទលេខ ១១១៧តព ) ចំនួនមួយ( ១ )ច្បាប់ និង ត្រូវចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ និងបូក សរុបលទ្ធផល ។

៧.៤៧.២ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដែលតម្រូវឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ដូចករណីចែងក្នុងប្រការ ៧.៤៧ ខាងលើ ត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់ម្តងមួយខេត្ត ក្រុង រហូតដល់អស់ខេត្ត ក្រុងចំណុះភូមិភាគ និងត្រូវអនុវត្តតាមនីតិវិធី ដូចចែងចាប់ពីចំណុច ៧.៤៧.១.១ ដល់ ៧.៤៧.១.៦ ខាងលើ ។

៧.៤៧.៣ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវធានាថា តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.៦ និងរបាយការណ៍ត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.៥ ខាងលើ ព្រមទាំងកំណត់ហេតុ ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.២ ខាងលើ ត្រូវតែបានដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ដោយឡែកត្រូវធានាថា រាល់ឯកសារបោះឆ្នោតផ្សេងទៀតដែលមិនត្រូវដាក់ភ្ជាប់ជូន គជប ត្រូវតែបានវេចខ្ចប់តាមលំនាំដូចដើម និងដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " រួចប្រគល់ជូនក្រុមទទួលសំភារៈឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

៧.៤៧.៤ ផ្អែកលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល របាយការណ៍ត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយដែលបានដាក់ជូន ដូចបានចែងក្នុងចំណុច ៧.៤៧.៣ ខាងលើ ប្រសិនបើ គជប ពិនិត្យឃើញថាត្រឹមត្រូវហើយ គជប ត្រូវសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនោះ ដែលក្នុងនោះ ប្រធាន គជប ត្រូវ ៖

៧.៤៧.៤.១ ចារយល់ព្រម លើរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៧.៤.២ ចារយល់ព្រមលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧តព ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៧.៤.៣ ប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធដែលត្រូវបាន គជប ចារយល់ព្រម និងសំណុំឯកសារភ្ជាប់មកជាមួយ ដូចចែងក្នុងចំណុច ៧.៤៧.៤ ខាងលើ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ និងប្រការ ៧.៥០ ខាងក្រោម ។

**ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ដែលមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបានដាក់នៅ គខ/កប ឬ/និង គជប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយឬច្រើនត្រូវបានបើកផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ប៉ុន្តែ គខ/កប បានសំរេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ**

**ប្រការ៧.៤៨** យោងតាមការកំណត់ណែនាំរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៥.២.៣ ខាងលើ បានតម្រូវឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងចំណុះភូមិភាគ ដែលមានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបានដាក់នៅ គខ/កប ឬ/និងនៅ គជប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើកផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដែលទទួលបន្ទុកតាមភូមិភាគ ឱ្យអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៧.៤៨.១ ប្រសិនបើ ផ្អែកតាមសំណុំឯកសារដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤២.៥ និង ៧.៤៤.៣.៧ ខាងលើ គជប យល់ឃើញថា កំរិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្តឹង មិនមានលក្ខណៈធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ហើយដែល គជប បានសម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញទេនោះ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ត្រូវពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ឬទាំងនោះចំណុះភូមិភាគ ដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នាម្តងមួយខេត្ត ក្រុង ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងរាល់ឯកសារបោះឆ្នោតពាក់ព័ន្ធដែលមាននៅក្នុងកញ្ចប់សុវត្ថិភាព " យពិសេស " ប៉ុណ្ណោះ ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវណែនាំ

ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលដែលទទួលបន្ទុកតាមភូមិភាគ ឱ្យអនុវត្តតាមលំនាំនីតិវិធី ដូចចែងចាប់ពីចំណុច ៧.៤៧.១ ដល់ ៧.៤៧.៣ ខាងលើ ។

៧.៤៨.២ បន្ទាប់ពីបានអនុវត្តចំណុច ៧.៤៨.១ ខាងលើរួច ផ្អែកលើតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផល របាយការណ៍ត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយដែលបានដាក់ជូន ដូចបានចែងក្នុងចំណុច ៧.៤៧.៣ ខាងលើ ប្រសិនបើ គជប ពិនិត្យឃើញថាត្រឹមត្រូវហើយ គជប ត្រូវសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនោះ ដែលក្នុងនោះ ប្រធាន គជប ត្រូវ ៖

៧.៤៨.២.១ ចារយល់ព្រម លើរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៨.២.២ ចារយល់ព្រមលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១០៧គព ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៨.២.៣ ប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធដែលត្រូវបាន គជប ចារយល់ព្រម និងសំណុំឯកសារភ្ជាប់មកជាមួយ ដូចចែងក្នុងចំណុច ៧.៤៨.២ ខាងលើ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ និងប្រការ ៧.៥០ ខាងក្រោម ។

៧.៤៨.៣ ប្រសិនបើ ផ្អែកតាមសំណុំឯកសារ ដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤២.៥ និង ៧.៤៩.៣.៧ ខាងលើ គជប យល់ឃើញថា អាចនឹងមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលនាំឱ្យមានការផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងណាមួយចំណុះភូមិភាគពាក់ព័ន្ធ ហើយដែល គជប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃ គជប ត្រូវ ៖

៧.៤៨.៣.១ ចាត់ចែងឱ្យនាំយកកញ្ចប់សុវត្ថិភាព " យពិសេស " ផ្ទុកកំណត់ហេតុ និងឯកសារបោះឆ្នោតសំខាន់ៗ ដូចចែងក្នុងចំណុច ៧.៤៩.៣.២

និងកញ្ចប់ " ឃ " ពាក់ព័ន្ធដែលផ្ទុកកញ្ចប់ " ខ " មានដាក់កញ្ចប់សុវត្ថិភាព " ក " និងសំភារៈឯកសារពាក់ព័ន្ធ ដូចចែងក្នុងចំណុច ៧.៤៨.៣.៦ ខាងលើ ពីបន្ទប់ស្តុកមកកាន់បន្ទប់ដែលត្រូវអនុវត្តការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ។

៧.៤៨.៣.២ ចាត់ចែងការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សំភារៈឯកសារបោះឆ្នោតឡើងវិញតាមការណែនាំរបស់ គជប ដែលត្រូវអនុវត្តស្រដៀងគ្នាតាមលំនាំនីតិវិធីដែលតម្រូវឱ្យ គខ/កប អនុវត្តដូចចែងចាប់ពីចំណុច ៧.៣៩.៦ ដល់ ៧.៣៩.៩ ខាងលើ ។

៧.៤៨.៣.៣ ចាត់ចែងការរាប់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតនោះឡើងវិញដោយត្រូវអនុវត្តស្រដៀងគ្នា តាមលំនាំនីតិវិធី ដែលតម្រូវឱ្យ គកប អនុវត្ត ដូចចែងក្រោមប្រការ ៧.៣៤ និង ៧.៣៥ ខាងលើ ។

៧.៤៨.៣.៤ ចាត់ចែងការត្រួតពិនិត្យផ្ទៀងផ្ទាត់ នូវទិន្នន័យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ ដោយផ្អែកលើកំណត់ហេតុតារាងបូកសរុបលទ្ធផល របាយការណ៍ និងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ដែលបានដកយកពីក្នុងកញ្ចប់សុវត្ថិភាព " ក " ឬ/និងពីក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ប្រសិនបើចាំបាច់ ។

៧.៤៨.៣.៥ ផ្អែកលើសេចក្តីសម្រេចរបស់ គខ/កប លើបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ ដែលបានដាក់នៅ គខ/កប ព្រមទាំងរបាយការណ៍របស់ គខ/កប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងយោងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធឡើងវិញនៅ គជប ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ត្រូវធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធឡើងវិញដោយលើកស្នើយោបល់ តាមរយៈអគ្គលេខាធិការជូន គជប ដើម្បីពិនិត្យសំរេចយល់ព្រម ឬបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។ របាយការណ៍ នេះចំនួនមួយ ( ១ )ច្បាប់ ត្រូវតែបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ។

៧.៤៨.៣.៦ ធានាថា រាល់កំណត់ហេតុ តារាងបូកសរុបលទ្ធផល របាយការណ៍ និងសំភារៈឯកសារបោះឆ្នោតពាក់ព័ន្ធ ដែលបានប្រើប្រាស់ក្នុងការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញខាងលើ ត្រូវតែបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ឬកញ្ចប់សុវត្ថិភាព " ក " កញ្ចប់ " ខ " និងកញ្ចប់ " ឃ " តាមលំនាំដូចដើម ដែលនឹងត្រូវនាំយក ទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈឯកសារ ដើម្បីរក្សាទុកនៅបន្ទប់ស្តុកវិញ លើកលែងតែរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ កំណត់ហេតុ និងសំណុំឯកសារបោះឆ្នោតពាក់ព័ន្ធ ដូចចែងក្នុងចំណុច ៧.៤៨.៤ ខាងក្រោម ។

៧.៤៨.៤ បន្ទាប់ពីបានបញ្ចប់ការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ តាមនីតិវិធីដូចចែងក្នុងចំណុច ៧.៤៨.៣ ខាងលើ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវធានាថា របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ ព្រមទាំងកំណត់ហេតុនិងឯកសារពាក់ព័ន្ធផ្សេងទៀត ចំនួនមួយ( ១ )ច្បាប់ ត្រូវតែបានដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលត្រូវបញ្ជាក់ច្បាស់ក្នុងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ តាមការកំណត់ ដូចខាងក្រោម ៖

៧.៤៨.៤.១ ប្រសិនបើ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ បង្ហាញថា ពិតជាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធ ប្រធានក្រុមត្រូវលើកស្នើយោបល់ជូន គជប ដើម្បីពិនិត្យសំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ និងសំរេចឱ្យបោះឆ្នោតសាជាថ្មី ។

៧.៤៨.៤.២ ប្រសិនបើ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ បង្ហាញថា គ្មានភាពមិនប្រក្រតីណាមួយដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធទេ ប្រធានក្រុមត្រូវលើកស្នើយោបល់ជូន គជប ដើម្បីពិនិត្យសំរេចទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ ។

៧.៤៨.៥ ផ្អែកលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤៨.៤ ខាងលើ ប្រសិនបើ គជប សម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ គជប ត្រូវ ៖

៧.៤៨.៥.១ ចារបដិសេធលើសេចក្តីសម្រេចរបស់ គខ/កប ដែលបានបដិសេធបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ និងចារយល់ព្រមតាមរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ដែលបានលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ រួចចុះហត្ថលេខានិងកាលបរិច្ឆេទ ។

៧.៤៨.៥.២ ចាត់ចែងមន្ត្រីជំនាញ ឱ្យបំពេញសេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ ( ទម្រង់បែបបទលេខ ១២០៣ ) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធផង ហើយដែលត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទ ដោយ គជប ។

៧.៤៨.៥.៣ ធានាថា សេចក្តីសម្រេចបដិសេធខាងលើត្រូវបានប្រគល់ជូនម្ចាស់ដើមបណ្តឹងមួយ( ១ )ច្បាប់ ផ្ញើជូន គខ/កប ពាក់ព័ន្ធមួយ( ១ )ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ព្រមទាំងថតចម្លងនិងចែកជូនគ្រប់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធមួយច្បាប់ ។

៧.៤៨.៥.៤ ប្រកាសថាសេចក្តីសម្រេចរបស់ គជប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ជាសេចក្តីសម្រេចចុងក្រោយ ហើយ គជប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ ក្នុងរយៈពេលយ៉ាងយូរប្រាំបី(៨)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសេម្រេចបដិសេធ ។

៧.៤៨.៥.៥ ប្រគល់សេចក្តីសំរេចបដិសេធរបស់ គជប របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ និងរាល់សំណុំឯកសារភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៨.៥ ខាងលើ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដើម្បីបន្តប្រគល់ជូនក្រុមទទួលសម្ភារៈឯកសារដាក់ក្នុងកញ្ចប់សុវត្ថិភាព " យពិសេស " នៃខេត្ត ក្រុងពាក់ព័ន្ធ និងរក្សាទុកនៅកន្លែងដើមវិញ ។

៧.៤៨.៦ យោងសេចក្ដីសម្រេចបដិសេធរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៨.៥.២ ខាងលើ គជប ត្រូវណែនាំអគ្គលេខាធិការដ្ឋាននៃ គជប និង គខ/កប ពាក់ព័ន្ធឱ្យចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីនិងល័ក្ខខ័ណ្ឌ ដូចចែងក្រោមប្រការ ៧.៣៣ នៃបទបញ្ជានិងនីតិវិធីនេះ ។

៧.៤៨.៧ ផ្អែកលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤៨.៤ ខាងលើ ប្រសិនបើ គជប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ គជប ត្រូវ ៖

៧.៤៨.៧.១ ចារយល់ព្រមលើសេចក្ដីសម្រេចរបស់ គខ/កប ដែលបានបដិសេធបណ្ដឹងតវ៉ាឬ/និងបណ្ដឹងជំទាស់ និងចារយល់ព្រមលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញដែលបានលើកស្នើយោបល់ជូន គជប ពិនិត្យសំរេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ រួចចុះហត្ថលេខានិងកាលបរិច្ឆេទ ។

៧.៤៨.៧.២ ចាត់ចែងមន្ត្រីជំនាញ ឱ្យបំពេញសេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ( ទម្រង់បែបបទលេខ ១២០៣ ) ដោយបញ្ជាក់ច្បាស់អំពីមូលហេតុនៃការយល់ព្រមនេះ ហើយដែលត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទដោយ គជប ។

៧.៤៨.៧.៣ ធានាថា សេចក្ដីសម្រេចយល់ព្រមខាងលើ ត្រូវបានប្រគល់ជូនម្ចាស់ដើមបណ្ដឹងមួយ( ១ )ច្បាប់ ផ្ញើជូន គខ/កប ពាក់ព័ន្ធមួយ( ១ ) ច្បាប់ និងរក្សាទុកជាឯកសារមួយ( ១ )ច្បាប់ ព្រមទាំងថតចម្លង និងចែកជូនគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគពាក់ព័ន្ធមួយ( ១ )ច្បាប់ ។

៧.៤៨.៧.៤ ប្រកាសថា សេចក្ដីសម្រេចរបស់ គជប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ជាសេចក្ដីសម្រេចចុងក្រោយ ។

៧.៤៨.៧.៥ ប្រគល់សេចក្ដីសំរេចយល់ព្រមរបស់ គជប របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ និងរាល់សំណុំឯកសារភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៨.៧ ខាងលើ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលដើម្បីចាត់ចែងតាមមុខការ ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ចំណុះភូមិភាគពាក់ព័ន្ធ ។

៧.៤៨.៨ បន្ទាប់ពីបានអនុវត្តចប់នីតិវិធីដូចចែងចាប់ពីចំណុច ៧.៤៨.៣ ដល់ ៧.៤៨.៧ ខាងលើ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវបន្តត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគដែលក្រុមទទួលបន្ទុក ដោយឡែកពីគ្នាម្ដងមួយខេត្ត ក្រុង ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងពាក់ព័ន្ធ និងរាល់ឯកសារបោះឆ្នោតដែលមានក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ដែលត្រូវអនុវត្តរាល់នីតិវិធី ដូចចែងចាប់ពីចំណុច ៧.៤៧.១.២ ដល់ ៧.៤៧.១.៦ ខាងលើ និងត្រូវផ្ទៀងផ្ទាត់បន្ថែមដោយផ្អែកលើសេចក្ដីសំរេចរបស់ គជប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញ និងរាល់សំណុំឯកសារផ្សេងទៀតភ្ជាប់ជាមួយ ដូចចែងក្នុងចំណុច ៧.៤៨.៧.៥ ខាងលើ ។

៧.៤៨.៩ ក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ដែលតម្រូវឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ដូចករណីចែងក្នុងប្រការ ៧.៤៨ ខាងលើ ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ម្ដងមួយខេត្ត ក្រុង រហូតដល់អស់ខេត្ត ក្រុងចំណុះភូមិភាគ និងត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្នុងចំណុច ៧.៤៧.៨ ខាងលើ ។

៧.៤៨.១០ ប្រធានក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលត្រូវធានាថា តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដូចចែងក្នុងចំណុច ៧.៤៧.១.៦ និងរបាយការណ៍ត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.៥ ខាងលើ ព្រមទាំងកំណត់ហេតុ ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផល ដូចចែងក្នុងចំណុច ៧.៤៧.១.២ ខាងលើ ត្រូវតែបានដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ដោយឡែក ត្រូវធានាថារាល់ឯកសារបោះឆ្នោតផ្សេងទៀតដែល

មិនត្រូវដាក់ភ្ជាប់ជូន គជប ត្រូវតែបានវេចខ្ចប់តាមលំនាំដូចដើម និងដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ឬ កញ្ចប់ " ឃ " នៃខេត្ត ក្រុងពាក់ព័ន្ធ រួចប្រគល់ជូនក្រុមទទួលសំភារៈឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

៧.៤៨.១១ ផ្អែកលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល របាយការណ៍ត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារផ្សេងទៀតភ្ជាប់ជាមួយដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤៨.១០ ខាងលើ ប្រសិនបើ គជប ពិនិត្យឃើញថាត្រឹមត្រូវហើយ គជប ត្រូវសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនោះ ដែលក្នុងនោះ ប្រធាន គជប ត្រូវ ៖

៧.៤៨.១១.១ ចារយល់ព្រម លើរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៨.១១.២ ចារយល់ព្រមលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៨.១១.៣ ប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធដែលត្រូវបាន គជប ចារយល់ព្រម និងសំណុំឯកសារភ្ជាប់មកជាមួយ ដូចចែងក្នុងចំណុច ៧.៤៨.១០ ខាងលើ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ និងប្រការ ៧.៥០ ខាងក្រោម ។

**ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះមណ្ឌលភូមិភាគ ដែលមានការិយាល័យបោះឆ្នោតមួយឬច្រើន ត្រូវបាន គជប សំរេចឱ្យបោះឆ្នោតសាជាថ្មី**

**ប្រការ៧.៤៩** យោងតាមការកំណត់ណែនាំរបស់ គជប ដូចចែងក្នុងចំណុច ៧.៤៥.២.៤ ខាងលើ បានតម្រូវឱ្យក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ដែលមានការិយាល័យបោះឆ្នោតមួយ ឬច្រើន មិនបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោតដោយសារករណីប្រធានស័ក្តិ ឬអសន្តិសុខ ឬគ្រោះមានអាសន្ន ឬ/និងដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យមួយ ឬច្រើន ត្រូវបាន គជប បដិសេធ ហើយដែលបានសំរេច

ឱ្យបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដោយអនុវត្តតាមល័ក្ខខ័ណ្ឌនិង នីតិវិធី ដូចចែងក្រោមប្រការ ៧.៣៣ ខាងលើ ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវណែនាំ នាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្ម ក្រុមទទួលសំភារៈឯកសារ និងក្រុមត្រួតពិនិត្យនិងបូកសរុប លទ្ធផល ឱ្យអនុវត្តតាមនីតិវិធី ដូចខាងក្រោម ៖

៧.៤៩.១ ប្រសិនបើ មានការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុង ខេត្ត ក្រុងចំណុះភូមិភាគណាមួយ ហើយដែល គខ/កប បានបញ្ជូនកញ្ចប់ " ឃ " ផ្ទុកកំណត់ហេតុ និងសំភារៈឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ឬទាំង នោះជូន គជប ក្រុមទទួលសំភារៈឯកសារត្រូវចាត់ចែងទទួល និងរក្សាទុកនៅកន្លែង ដែលបានកំណត់សំរាប់ខេត្ត ក្រុងនិងភូមិភាគ ហើយត្រូវរាយការណ៍ជាបន្ទាន់ តាម រយៈអគ្គលេខាធិការជូន គជប ។

៧.៤៩.២ ប្រសិនបើ មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យដែលបាន បោះឆ្នោតសាជាថ្មី ត្រូវបានដាក់និងបើកសវនាការដោះស្រាយនៅ គខ/កប ឬ/និងត្រូវ បានដាក់នៅ គជប នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវប្រមូលរាល់សេចក្តី សំរេចរបស់ គខ/កប លើពាក្យបណ្តឹង និងរាល់ពាក្យបណ្តឹងតវ៉ាដែលបានទទួល នៅទីស្តីការ គជប រួចរាយការណ៍ជាបន្ទាន់ តាមរយៈអគ្គលេខាធិការជូន គជប ។

៧.៤៩.៣ ប្រសិនបើ លទ្ធផលនៃការបោះឆ្នោតសាជាថ្មីនៅការិយាល័យមួយ ឬច្រើន ត្រូវបាន គខ/កប សំរេចព្យួរជាបណ្តោះអាសន្ន គជប ត្រូវកំណត់និងណែនាំក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់នូវលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនោះ ឬទាំងនោះ និងបន្តបូកសរុបបញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនិង តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយត្រូវអនុវត្ត តាមលំនាំនីតិវិធី ដូចចែងក្រោមប្រការ ៧.៤៦ ខាងលើ ។

៧.៤៩.៤ ប្រសិនបើ មានបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹក ឆ្នោត និងលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនៅការិយាល័យមួយ ឬច្រើន ត្រូវបាន ដាក់នៅ គខ/កប ហើយដែលគ្មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញទេ ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃ ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះ គជប ត្រូវកំណត់និង ណែនាំក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការ

បោះឆ្នោតសាជាថ្មីនោះ ឬទាំងនោះ និងបន្តបូកសរុបបញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងក្នុងតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធី ដូចចែងក្រោមប្រការ ៧.៤៧ ខាងលើ ។

៧.៤៩.៥ ប្រសិនបើ មានបណ្តឹងតវ៉ាឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនៅការិយាល័យមួយឬច្រើន ត្រូវបានដាក់នៅ គខ/កប ឬ/និងនៅ គជប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយឬច្រើនត្រូវបានបើកផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គខ/កប ប៉ុន្តែ គខ/កប បានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ គជប ត្រូវកំណត់និងណែនាំក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់នូវលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនោះ ឬទាំងនោះ និងបន្តបូកសរុបបញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង និងក្នុងតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីដូចចែងក្រោមប្រការ ៧.៤៨ ខាងលើ ។

៧.៤៩.៦ ក្នុងករណី គជប សំរេចបដិសេធលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនៅការិយាល័យមួយ ឬច្រើន គជប ត្រូវណែនាំអគ្គលេខាធិការដ្ឋាននៃ គជប និង គខ/កប ឱ្យចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មីមួយលើកទៀត នៅការិយាល័យនោះ ឬទាំងនោះ ដោយត្រូវអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ៧.៣៣ ខាងលើ ។ ក្នុងការរៀបចំការបោះឆ្នោតសាជាថ្មីមួយលើកទៀតនេះ ត្រូវតែគ្រប់គ្រង និងចាត់ចែងដោយសមាសភាព គកប ថ្មី ។

៧.៤៩.៧ ក្នុងករណី គជប សំរេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតសាជាថ្មី នៅការិយាល័យមួយ ឬច្រើន គជប ត្រូវធានាថា អគ្គលេខាធិការនៃ គជប បានណែនាំក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផល ឱ្យបន្តបូកសរុបលទ្ធផលនៃការបោះឆ្នោតសាជាថ្មីនោះឬទាំងនោះ បញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធ និងតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយត្រូវអនុវត្តតាមនីតិវិធីដែល គជប បានកំណត់ ។

៧.៤៩.៨ ផ្អែកតាមសេចក្តីសំរេចរបស់ គជប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតសាជាថ្មី នៅការិយាល័យមួយ ឬច្រើន និងបន្ទាប់ពីបានបូកសរុបលទ្ធផល

នៃការបោះឆ្នោតសាជាថ្មីនោះ ឬទាំងនោះ បញ្ចូលទៅក្នុងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងពាក់ព័ន្ធ និងលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគរួចហើយ ប្រធានក្រុមត្រួតពិនិត្យនិងបូកសរុបលទ្ធផលត្រូវធានាថា តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ និងរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ព្រមទាំងកំណត់ហេតុ ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផលពាក់ព័ន្ធ ត្រូវតែបានដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ ដោយឡែក ត្រូវធានាថា រាល់ឯកសារបោះឆ្នោតផ្សេងទៀតដែលមិនត្រូវដាក់ភ្ជាប់ជូន គជប ត្រូវតែបានវេចខ្ចប់តាមលំនាំដើម និងដាក់ទៅក្នុងកញ្ចប់ " ឃ " ឬកញ្ចប់សុវត្ថិភាព " ឃពិសេស " នៃខេត្ត ក្រុងពាក់ព័ន្ធ រួចប្រគល់ជូនក្រុមទទួលសំភារៈឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

៧.៤៩.៩ ផ្អែកលើតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ចំណុះភូមិភាគ ព្រមទាំងសំណុំឯកសារបោះឆ្នោតផ្សេងទៀតភ្ជាប់ជាមួយ ដែលបានដាក់ជូន គជប ដូចចែងក្នុងចំណុច ៧.៤៩.៨ ខាងលើ ប្រសិនបើ គជប ពិនិត្យឃើញថាត្រឹមត្រូវហើយ គជប ត្រូវសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោត តាមភូមិភាគនោះ ដែលក្នុងនោះ ប្រធាន គជប ត្រូវ ៖

៧.៤៩.៩.១ ចារយល់ព្រម លើរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៩.៩.២ ចារយល់ព្រមលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផល នៃការបោះឆ្នោតតាមភូមិភាគ ( ទម្រង់បែបបទលេខ ១១១៧គព ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៧.៤៩.៩.៣ ប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងខេត្ត ក្រុងនីមួយៗចំណុះភូមិភាគពាក់ព័ន្ធដែលត្រូវបាន គជប ចារយល់ព្រម និងសំណុំឯកសារភ្ជាប់មកជាមួយ ដូចចែងក្នុងចំណុច ៧.៤៩.៩ ខាងលើ តាមរយៈអគ្គលេខាធិការទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួនដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ និងប្រការ ៧.៥០ ខាងក្រោម ។

**ការបញ្ចូលនិងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគក្នុងកុំព្យូទ័រ និងការកំណត់បែងចែកអាសនៈតាមមណ្ឌលភូមិភាគ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវបានទទួល**

**ប្រការ ៧.៥០** នៅពេលបានទទួលតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងចំណុះភូមិភាគ ព្រមទាំងសំណុំឯកសារបោះឆ្នោតផ្សេងទៀតភ្ជាប់ជាមួយ ដែលត្រូវបាន គជប ចារយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគរួចហើយដូចចែងក្នុងចំណុច ៧.៤៦.១០.៣ ៧.៤៧.៤.៣ ៧.៤៨.២.៣ ៧.៤៨.១១.៣ និង ៧.៤៩.៩.៣ ខាងលើ ក្រុមកំណត់បែងចែកអាសនៈនៃ គជប ត្រូវចាត់ចែងអនុវត្តភារកិច្ចរបស់ខ្លួនដែលបានកំណត់ ដូចចែងក្រោមចំណុច ៧.៤៣.៤ និង ៧.៤៣.៥ ខាងលើ ដើម្បីរៀបចំសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សេចក្តីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគត្រូវបានទទួល និងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ដែលត្រូវដាក់ជូន គជប ដើម្បីពិនិត្យសំរេច ។

៧.៥០.១ ក្រុមកំណត់បែងចែកអាសនៈ ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការ ដែលមានកុំព្យូទ័រនិងបណ្តាញបរិក្ខារអេឡិកត្រូនិកគ្រប់គ្រាន់ ហើយដែលត្រូវបានបំពាក់កម្មវិធីប្រតិបត្តិការបញ្ចូល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ កម្មវិធីប្រតិបត្តិការបែងចែកអាសនៈដែលផ្អែកតាមរូបមន្ត និង នីតិវិធីដូចចែងក្នុងឧបសម្ព័ន្ធនៃបទបញ្ជានិងនីតិវិធីនេះស្តីពីការបែងចែកអាសនៈ និងមានរក្សាទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៧.៥០.២ ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដែលជាអនុប្រធានក្រុមកំណត់បែងចែកអាសនៈ ត្រូវធានាឱ្យមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ( បញ្ជីផ្លូវការ ) មួយ( ១ )ច្បាប់ សម្រាប់ប្រើក្នុងការផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលត្រូវជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលទី ២ ។

៧.៥០.៣ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែងសមាជិករបស់ខ្លួនឱ្យបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគទាំងអស់ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗ ( ទម្រង់បែបបទលេខ ១១១៧គព ) និងរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត

ក្រុង ដែលត្រូវបាន គជប ចារយល់ព្រមរួចហើយ ព្រមទាំងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១១ ) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង ( ទម្រង់បែបបទលេខ ១១១០ ) ដែល គខ/កប បានផ្ញើជូនជាឯកសារផ្លូវការ ឬ/និងតាមអ៊ីមែល ។ បន្ទាប់ពីបានបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតពីគ្រប់ខេត្ត ក្រុងចំណុះភូមិភាគទាំងអស់រួចរាល់ហើយ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវតែបានផ្ទៀងផ្ទាត់ឡើងវិញ ដោយប្រៀបធៀបទៅនឹងតួលេខលទ្ធផល ដែលមានក្នុងតារាងបូកសរុបលទ្ធផលនិងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងទាំង ២៤ ចំណុះភូមិភាគទាំង ៨ ដើម្បីឱ្យដឹងប្រាកដថា មានលក្ខណៈត្រឹមត្រូវហើយ ។

៧.៥០.៣.១ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានបោះពុម្ព រួចចារបញ្ជាក់ថាត្រឹមត្រូវនិងចុះហត្ថលេខាដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម ដែលត្រូវដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច ។

៧.៥០.៣.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើចំនួនប្រាំ( ៥ )ច្បាប់ ដែលត្រូវចុះហត្ថលេខាកាត់ ដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈ និងដាក់ភ្ជាប់ជាមួយសេចក្តីព្រាងលទ្ធផល ដូចបានចែងក្នុងចំណុច ៧.៥០.៣.១ ខាងលើ ជូនប្រធាន គជប ចុះហត្ថលេខា និងបោះត្រាជាផ្លូវការ ។

៧.៥០.៤ នៅពេលក្រុមកំណត់បែងចែកអាសនៈ បានបញ្ចប់ការងាររបស់ខ្លួន ប្រធានក្រុមត្រូវធានាថា រាល់តារាងត្រួតពិនិត្យ របាយការណ៍ កំណត់ហេតុ តារាងលទ្ធផល និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតនិងក្នុងការគណនាបែងចែកអាសនៈ ដូចចែងក្រោមប្រការ ៧.៥០ នៃបទបញ្ជានិងនីតិវិធីនេះ ត្រូវតែបានច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " យពិសេស " នៃខេត្ត ក្រុងពាក់ព័ន្ធតាមលំនាំដូចដើម រួចប្រគល់ឱ្យក្រុមទទួលសំភារៈឯកសារ រក្សាទុកក្នុងបន្ទប់ស្តុកវិញ ។

៧.៥០.៥ ផ្អែកលើសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចចែងក្រោមចំណុច ៧.៥០.៣ ខាងលើ ប្រសិនបើ គជប បានពិនិត្យឃើញថាលទ្ធផលទាំងនោះមានលក្ខណៈត្រឹមត្រូវហើយ ប្រធាន គជប ត្រូវចារឯកភាព និងចុះហត្ថលេខាលើសេចក្ដីព្រាងលទ្ធផលដូចចែងក្នុងចំណុច ៧.៥០.៣.១ ខាងលើ ហើយត្រូវចុះហត្ថលេខា និងបោះត្រាផ្ដល់សុពលភាពលើតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចចែងក្នុងចំណុច ៧.៥០.៣.២ ខាងលើ ជាផ្លូវការ ។

៧.៥០.៦ គជប ត្រូវចាត់ចែងឱ្យបិទផ្សាយតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចចែងក្នុងចំណុច ៧.៥០.៣.២ ខាងលើមួយ( ១ )ច្បាប់ នៅទីស្ដីការ គជប និងឱ្យផ្សព្វផ្សាយតារាងលទ្ធផលនេះ ជាសាធារណៈ តាមគ្រប់រូបភាព ។ ទន្ទឹមនឹងនេះ គជប ត្រូវចាត់ចែងនិងប្រើប្រាស់តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចខាងក្រោម ៖

៧.៥០.៦.១ ទូលថ្វាយព្រះមហាក្សត្រ ច្បាប់ដើមមួយ( ១ )ច្បាប់ ។

៧.៥០.៦.២ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ដើមមួយ( ១ )ច្បាប់ ។

៧.៥០.៦.៣ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា ច្បាប់ចម្លងមួយ( ១ )ច្បាប់ ។

៧.៥០.៦.៤ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ច្បាប់ចម្លងមួយ( ១ )ច្បាប់ ។

៧.៥០.៦.៥ ផ្ញើជូនរាជរដ្ឋាភិបាល ច្បាប់ចម្លងមួយ( ១ )ច្បាប់ ។

៧.៥០.៦.៦ ថតចម្លង និងផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មួយ( ១ )ច្បាប់ ។

៧.៥០.៦.៧ រក្សាទុកជាឯកសារនិងប្រើប្រាស់នៅ គជប ច្បាប់ដើមពីរ(២)ច្បាប់ ។

៧.៥០.៧ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬមួយផ្នែកនៃលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដោយត្រូវដាក់ពាក្យប្ដឹងជាលាយល័ក្ខណ៍អក្សរនៅ គជប ឬ ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរចិតសិបពីរ( ៧២ )ម៉ោង គិតចាប់ពីពេលបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៧.៥០.៦ ខាងលើ ។

៧.៥០.៧.១ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គជប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញមិនបានទទួលពាក្យបណ្ដឹងតវ៉ាណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថា គ្មានការប្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទេ ។

៧.៥០.៨ ចំពោះពាក្យបណ្តឹងតវ៉ា ដែលបានដាក់ក្រោយពេលវេលាកំណត់ ដូចចែងក្នុងចំណុច ៧.៥០.៧ ខាងលើ និងពាក្យបណ្តឹងតវ៉ា ដែលបានដាក់ក្នុងរយៈពេលស្របតាមការកំណត់នៅ គជប ប៉ុន្តែគ្មានឯកសារ និងភស្តុតាងគ្រប់គ្រាន់ មិនត្រូវបាន គជប ទទួលដោះស្រាយទេ ។

៧.៥០.៨.១ មន្ត្រីទទួលពាក្យបណ្តឹងនៃ គជប ត្រូវចុះពេលវេលានិងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូនអគ្គលេខាធិការចារបញ្ជាក់ពីការហួសពេលទទួលពាក្យបណ្តឹង ចុះហត្ថលេខា និងបោះត្រាលើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹងឬតំណាងមួយ( ១ )ច្បាប់ រក្សាទុកជាឯកសារមួយ( ១ )ច្បាប់ និងជំរាបអ្នកប្តឹងឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ មិនអាចទទួលដោះស្រាយបានទេ ។

៧.៥០.៨.២ គជប ត្រូវបដិសេធមិនទទួលដោះស្រាយចំពោះពាក្យបណ្តឹងដែលគ្មានឯកសារនិងភស្តុតាងគ្រប់គ្រាន់ ដោយប្រគល់សិទ្ធិជូនអគ្គលេខាធិការចារបដិសេធលើបណ្តឹងតវ៉ា និងបញ្ជាក់មូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ ចុះហត្ថលេខា និងបោះត្រា រួចប្រគល់ជូនអ្នកប្តឹងឬតំណាងមួយ(១)ច្បាប់ និងរក្សាទុកជាឯកសារមួយ(១)ច្បាប់ ។

៧.៥០.៨.៣ អ្នកប្តឹងតវ៉ា ឬតំណាង ដូចចែងក្នុងចំណុច ៧.៥០.៨.១ និង ៧.៥០.៨.២ ខាងលើ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរចិតសិបពីរ( ៧២ )ម៉ោង បន្ទាប់ពីបានទទួលការជូនដំណឹងបដិសេធ ។

៧.៥០.៩ ចំពោះបណ្តឹងតវ៉ាមានឯកសារ និងភស្តុតាងគ្រប់គ្រាន់ ដែលបានដាក់ប្តឹងនៅ គជប ស្របតាមរយៈពេលកំណត់ដូចចែងក្នុងចំណុច ៧.៥០.៧ ខាងលើ គជប ត្រូវបើកសវនាការដោះស្រាយលើពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំបី( ៤៨ )ម៉ោង គិតចាប់ពីពេលបានទទួលពាក្យបណ្តឹងតវ៉ា ។ នីតិវិធីសំរាប់ការបើកសវនាការដោះស្រាយបណ្តឹងតវ៉ា ដែលបានដាក់នៅ គជប ត្រូវបានកំណត់ដោយយោងតាមសិទ្ធិអំណាចរបស់ គជប និងការកំណត់ក្នុងបទបញ្ជានិងនីតិវិធីនេះ ។

៧.៥០.៩.១ ប្រសិនបើ គជប សម្រេចយល់ព្រមតាមបណ្តឹងតវ៉ាដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន និងត្រូវចាត់ចែងរៀបចំឱ្យមានការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ។

៧.៥០.៩.២ ប្រសិនបើ គជប សម្រេចបដិសេធបណ្តឹងតវ៉ា ដែលត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ អ្នកប្តឹងតវ៉ា ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជំទាស់នឹងសេចក្តីសម្រេចរបស់ គជប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរចិតសិបពីរ( ៧២ )ម៉ោង បន្ទាប់ពីពេលដែលបានទទួលសេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹង ។

៧.៥០.១០ ចំពោះបណ្តឹងតវ៉ាមានឯកសារនិងភស្តុតាងគ្រប់គ្រាន់ ដែលបានដាក់ប្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមរយៈពេលកំណត់ដូចចែងក្នុងចំណុច ៧.៥០.៧ ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការដោះស្រាយពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេលយ៉ាងយូរពីដប់( ១០ )ថ្ងៃទៅម្ភៃ( ២០ )ថ្ងៃ គិតចាប់ពីពេលបានទទួលពាក្យបណ្តឹងតវ៉ា ។ នីតិវិធីសំរាប់ការទទួលពាក្យបណ្តឹងតវ៉ា និងការដោះស្រាយបណ្តឹងតវ៉ា នៅក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដោយយោងតាមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

៧.៥០.១១ បន្ទាប់ពីរាល់ពាក្យបណ្តឹងតវ៉ាដែលបានដាក់នៅ គជប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ គជប ត្រូវណែនាំក្រុមកំណត់បែងចែកអាសនៈឱ្យកែតម្រូវតួលេខលទ្ធផល ឬ/និងណែនាំអគ្គលេខាធិការឱ្យចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី ប្រសិនបើមាន ដោយផ្អែកតាមសេចក្តីសំរេចរបស់ គជប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ ។ បន្ទាប់ពី បានកែតម្រូវតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិងពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ គជប ត្រូវផ្តល់សុពលភាពតារាងលទ្ធផលបណ្តោះអាសន្ន ទៅជាតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៥០.១១.១ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវធានាថា សេចក្តីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានបោះពុម្ពនិងចុះហត្ថលេខាដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច ។

៧.៥០.១១.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើ ចំនួនប្រាំ( ៥ )ច្បាប់ ដែលត្រូវចុះហត្ថលេខាកាត់ ដោយសមាសភាពទាំងអស់នៃក្រុមកំណត់

បែងចែកអាសនៈ និងដាក់ភ្ជាប់ជាមួយសេចក្តីព្រាងតារាងលទ្ធផល ដូចបានចែងក្នុងចំណុច ៧.៥០.១១.១ ខាងលើ ជូនប្រធាន គជប ចុះហត្ថលេខានិងបោះត្រាជាផ្លូវការ ។

៧.៥០.១២ ផ្អែកតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចចែងក្នុងចំណុច ៧.៥០.១១ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គជប ត្រូវធានាថា គាត់បានចាត់ចែងសមាជិកក្រុម ឱ្យបញ្ចូលតួលេខលទ្ធផលសម្លេងឆ្នោតគាំទ្រគណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ឬ/និងឱ្យគណនាតាមការធ្វើប្រមាណវិធីដោយដៃ ដោយផ្អែកតាមរូបមន្តក្នុងការកំណត់បែងចែកអាសនៈ ដែលកំណត់ដោយច្បាប់ និងដូចចែងក្នុងឧបសម្ព័ន្ធនៃបទបញ្ជា និងនីតិវិធីនេះ ស្តីពីការបែងចែកអាសនៈ ។ ប្រធានក្រុមត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបែងចែកអាសនៈខាងលើ រវាងការគណនាដោយដៃ និងការគណនាដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលនៃការគណនាទាំងពីររបៀបមានលក្ខណៈដូចគ្នានិងត្រឹមត្រូវ ។

៧.៥០.១២.១ ប្រធានក្រុមត្រូវធានាថាតារាងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមមណ្ឌលភូមិភាគបានទទួល និងដែលបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានបោះពុម្ពនិងចុះហត្ថលេខា ដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម និងដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច ។

៧.៥០.១២.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្តីព្រាងតារាងលទ្ធផល នៃការបែងចែកអាសនៈខាងលើចំនួនប្រាំ( ៥ )ច្បាប់ ដែលត្រូវចុះហត្ថលេខាកាត់ដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈ និងដាក់ភ្ជាប់ជាមួយតារាងលទ្ធផលនៃការបែងចែកអាសនៈ ដូចបានចែងក្នុងចំណុច ៧.៥០.១២.១ ខាងលើជូន ប្រធាន គជប ចុះហត្ថលេខានិងបោះត្រាជាផ្លូវការ ។

៧.៥០.១៣ ផ្អែកតាមតារាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងតារាងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគត្រូវបានទទួល ប្រធានក្រុមកំណត់បែងចែកអាសនៈរួមជា

មួយអនុប្រធានក្រុម ត្រូវផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា និងត្រូវរៀបចំសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលទី ២ ចំនួនប្រាំ( ៥ )ច្បាប់ ដែលត្រូវចុះហត្ថលេខាកាត់ ដោយសមាសភាពទាំងអស់ នៃក្រុមកំណត់បែងចែកអាសនៈ រួចដាក់ជូន គជប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសំរេច ព្រមទាំងចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាជាផ្លូវការ ។

៧.៥០.១៤ គជប ត្រូវចាត់ចែងឱ្យបិទផ្សាយ នូវតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តារាងលទ្ធផលនៃការបែងចែកអាសនៈ និងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ មួយ( ១ )ច្បាប់ នៅទីស្តីការ គជប និងឱ្យផ្សព្វផ្សាយជាសាធារណៈតាមគ្រប់រូបភាព ។ ទន្ទឹមនឹងនេះ គជប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តារាងលទ្ធផលនៃការបែងចែកអាសនៈ និងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ ដូចខាងក្រោម ៖

៧.៥០.១៤.១ ទូលថ្វាយព្រះមហាក្សត្រ ច្បាប់ដើមមួយ( ១ )ច្បាប់ ។

៧.៥០.១៤.២ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា ច្បាប់ចម្លងមួយ(១)ច្បាប់ ។

៧.៥០.១៤.៣ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ច្បាប់ចម្លងមួយ(១)ច្បាប់ ។

៧.៥០.១៤.៤ ផ្ញើជូនរាជរដ្ឋាភិបាល ច្បាប់ចម្លងមួយ( ១ )ច្បាប់ ។

៧.៥០.១៤.៥ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ដើមមួយ( ១ )ច្បាប់ ។

៧.៥០.១៤.៦ ថតចម្លង និងផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មួយ( ១ )ច្បាប់ ។

៧.៥០.១៤.៧ ផ្ញើជូនមជ្ឈមណ្ឌលដំកល់ឯកសារជាតិ ច្បាប់ចម្លងមួយ(១)ច្បាប់ ។

៧.៥០.១៤.៨ រក្សាទុកជាឯកសារនិងប្រើប្រាស់នៅ គជប ច្បាប់ដើមពីរ(២)ច្បាប់ ។

# ជំពូកទី ៨
# សមត្ថកិច្ច នីតិវិធីសវនាការដោះស្រាយវិវាទ និងនីតិវិធីដាក់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិ ដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្ដីពីការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា

## សមត្ថកិច្ចដោះស្រាយវិវាទ

**ប្រការ** ៨.១ អនុលោមតាមជំពូកទី ៨ មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតជាអ្នកសម្រេចដំបូងបង្អស់លើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្នុងករណីមានបណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ច ពិនិត្យ និងសម្រេច ។

ក្នុងករណីមានបណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

៨.១.១ សមត្ថកិច្ចដូចមានកំណត់ក្នុងប្រការ ៨.១ ខាងលើត្រូវយកមកអនុវត្តក្នុងដំណាក់ការបិទផ្សាយបញ្ជីបោះឆ្នោត ចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត និងដំណាក់ការបិទផ្សាយលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន ។

៨.១.២ ចំពោះសមត្ថកិច្ចដោះស្រាយបណ្ដឹងក្នុងដំណាក់ការឃោសនាបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចដោះស្រាយបណ្ដឹងដោយអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងជំពូកទី ៨ ក្រោមចំណុច ៨.៣.៣ និងចំណុច ៨.៣.៤ នៃបទបញ្ជា និង នីតិវិធី គជប ។

៨.១.៣ ចំពោះសមត្ថកិច្ចដោះស្រាយបណ្ដឹងក្នុងដំណាក់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធនឹងករណីរំលោភលើជំពូកទី ៧ ប្រការ ៧.៣៩ នៃបទបញ្ជា និង នីតិវិធី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចដោះស្រាយបណ្ដឹងដោយអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងជំពូកទី ៨ ក្រោមចំនុច ៨.៣.៣ និង ៨.៣.៤ នៃបទបញ្ជា និង នីតិវិធី គជប ។

៨.១.៤ ចំពោះសមត្ថកិច្ចដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិ ដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចដោះស្រាយបណ្តឹងដោយអនុវត្តតាមបញ្ញត្តិ ដូចមានចែងក្នុងជំពូកទី ៨ ក្រោមប្រការ ៨.៣.៣ និងប្រការ ៨.៣.៤ នៃ បទបញ្ជា និង នីតិវិធី គជប ។

## នីតិវិធីសវនាការដោះស្រាយវិវាទ

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

**ប្រការ** ៨.២ នីតិវិធីសវនាការដោះស្រាយបណ្តឹងដូចមានចែងក្រោមប្រការ ៨.២ នេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់ការទាំងអស់នៃដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភារួមមាន ដំណាក់ការបិទផ្សាយបញ្ជីបោះឆ្នោត ចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ឃោសនាបោះឆ្នោត បោះឆ្នោត រាប់សន្លឹកឆ្នោត និងដំណាក់ការបិទផ្សាយលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន និងបណ្តឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៨.២.១ សមាជិក គជប ឬសមាជិក គខ,កប ដែលត្រូវបានតែងតាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្តឹងហៅថា **ក្រុមប្រឹក្សាជំនុំជំរះ** ។

៨.២.១.១ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គជប ត្រូវមានដូចខាងក្រោម ៖

- ប្រធាន គជប ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
- សមាជិកទាំងអស់របស់ គជប ជាសមាជិក
- ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឬតំណាងដែលមានការតែងតាំងជាលេខាធិការ ។

៨.២.១.១.១ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គជប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ១៧ថ្មី នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងរបស់ គជប គឺដូចគ្នានឹងកូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ គជប ។

៨.២.១.១.២ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះ មិនត្រូវមានសំលេងអនុប្បវាទឡើយ ។

៨.២.១.១.៣ ក្រុមប្រឹក្សាជំនុំជំរះថ្នាក់ គជប មានសិទ្ធិអំណាចកោះហៅភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

៨.២.១.២ ក្រុមប្រឹក្សាជំនុំជំរះនៅ គជប និង គខ,កប ត្រូវមានលេខាធិការម្នាក់ជាជំនួយការដែលជ្រើសតាំងពីចំណោមមន្ត្រីផ្នែកសេវាកម្មច្បាប់ និងវិវាទកម្មនៅថ្នាក់របស់ខ្លួន ។

៨.២.១.៣ សមាសភាពក្រុមប្រឹក្សាជំនុំជំរះតាមថ្នាក់ អាចធ្វើការផ្លាស់ប្តូរតាមការចាំបាច់ដែលសម្រេចដោយ គជប ឬ គខ,កប ។ ប្រធាន ឬតំណាងដែលត្រូវបានប្រគល់ សិទ្ធិដោយ គជប ឬ គខ,កប ជាប្រធានក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់របស់ខ្លួន ។

៨.២.១.៤ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គខ,កប ត្រូវមានដូចខាងក្រោម ៖

- ប្រធាន គខ,កប ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
- អនុប្រធាន គខ,កប ជាសមាជិក
- សមាជិក គខ,កប ម្នាក់ ជាសមាជិក
- សមាជិក ឬមន្ត្រី គខ,កប ម្នាក់ ជាលេខាធិការ ។

៨.២.១.៤.១ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គខ,កប ត្រូវអនុវត្តតាមសំលេងភាគច្រើន ។

៨.២.១.៤.២ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះថ្នាក់ គខ,កប មិនត្រូវមានសំលេងអនុប្បវាទឡើយ។

៨.២.១.៤.៣ ក្រុមប្រឹក្សាជំនុំជំរះថ្នាក់ គខ,កប មានសិទ្ធិអំណាចកោះហៅភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

៨.២.១.៥ ក្រុមប្រឹក្សាជំនុំជំរះត្រូវប្រកាសសេចក្តីសម្រេចរបស់ខ្លួនតាមទម្រង់បែបបទ ១២០៣ ចំនួនប្រាំ ( ៥ )ច្បាប់ ដែលត្រូវចាត់ចែងដោយ គជប ឬ គខ,កប នៅពេលបញ្ចប់សវនាការ ។

៨.២.១.៦ ក្នុងពេលសវនាការក្រុមប្រឹក្សាជំនុំជំរះមានអំណាចស្នើឱ្យចេញពីបន្ទប់សវនាការ ចំពោះជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងសវនាការដូចមានចែងក្នុង ឧបសម្ព័ន្ធស្តីពីបទបញ្ជាផ្ទៃក្នុងសវនាការដោះស្រាយបណ្តឹង ។

**ប្រភេទសវនាការ**

៨.២.២ តាមនីតិវិធី នៃច្បាប់រដ្ឋប្បវេណី ក្រុមប្រឹក្សាជំនុំជំរះអាចធ្វើសវនាការសង្ខេប ( Summary Judgment ) ឬសវនាការប្រតិបក្ស ( Adversary System ) ឬសវនាការសួរដេញដោល ( Inquisitorial System ) ។ សេចក្តីអត្ថាធិប្បាយសង្ខេបស្តីពីប្រភេទសវនាការនីមួយៗ មានដូចខាងក្រោមនេះ ៖

៨.២.២.១ **សវនាការសង្ខេប** ៖ ជាសវនាការដែលគ្មានទម្រង់ការច្រើន ។ ក្រុមប្រឹក្សាជំនុំជំរះ គ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតបនៅពេលយល់ឃើញថា មានតែចំណោទខាងច្បាប់ប៉ុណ្ណោះហើយគ្មានចំណោទខាងអង្គហេតុ ។

៨.២.២.២ **សវនាការប្រតិបក្ស** ៖ ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងវិវាទ ។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ ។

៨.២.២.៣ **សវនាការដេញដោល** ៖ ជាសវនាការដែលក្រុមប្រឹក្សាជំនុំជំរះមានតួនាទីយ៉ាងសំខាន់ក្នុងការដេញដោលសួររកហេតុផលក្នុងរឿងក្តី ។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជំរះទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលអង្គហេតុផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជំរះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំនួរដល់សាក្សី ឯចំណែកគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ ។

៨.២.២.៤ ប្រភេទសវនាការទាំងបី ( ៣ )យ៉ាងនេះ ត្រូវយកមកអនុវត្តដូចនីតិវិធីច្បាប់រដ្ឋប្បវេណីនៃ ព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្ន ។

**ពេលវេលាដោះស្រាយបណ្តឹង និងការចាត់ចែងបើកសវនាការ**

៨.២.៣ គជប ឬ គខ,កប អាចបើកសវនាការជារៀងរាល់ថ្ងៃ ចាប់តាំងពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់ ។ ក្នុងករណីចាំបាច់សវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ ។

៨.២.៣.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដោយមានការពិគ្រោះយោបល់ជាមួយនឹងអគ្គលេខាធិការនៃ គជប ត្រូវកំណត់ប្រតិទិនមួយសម្រាប់ដោះស្រាយបណ្តឹង ឬ,និងបើកសវនាការនៅថ្នាក់ គជប ទៅតាមករណីនៃបណ្តឹងក្នុងដំណាក់ការនីមួយៗនៃដំណើរការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុងច្បាប់បោះឆ្នោត និង បទបញ្ជា និង នីតិវិធី របស់ គជប និងត្រូវធានាជំរុញឱ្យសេចក្តីជូនដំណឹងអំពីការបើកសវនាការត្រូវបានប្រគល់ជូនដល់ដើមបណ្តឹង ឬ,និងចុងចម្លើយបានទាន់ពេលវេលាយ៉ាងតិចម្ភៃបួន(២៤)ម៉ោងមុនពេលបើកសវនាការ ។

៨.២.៣.២ គខ,កប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនមួយសម្រាប់ដោះស្រាយបណ្តឹង ឬ,និងបើកសវនាការនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃបណ្តឹងក្នុងដំណាក់ការនីមួយៗនៃដំណើរការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុងច្បាប់បោះឆ្នោត និង បទបញ្ជានិងនីតិវិធីរបស់ គជប និងត្រូវធានាជំរុញឱ្យសេចក្តីជូនដំណឹង អំពីការបើកសវនាការត្រូវបានប្រគល់ជូនដល់ដើមបណ្តឹង ឬ,និងចុងចម្លើយបានទាន់ពេលវេលាយ៉ាងតិចម្ភៃបួន (២៤)ម៉ោង មុនពេលបើកសវនាការ ។

៨.២.៣.៣ ក្នុងកម្មវិធីនៃការបើកសវនាការសម្រេចលើពាក្យបណ្តឹងមួយពេលអាចកំណត់ធ្វើការជំនុំជំរះច្រើនករណីបាន ។

៨.២.៣.៤ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងមន្ត្រីទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម មានភារកិច្ចស៊ើបអង្កេតរៀបចំសំណុំរឿងទាំងឡាយ សម្រាប់សវនាការនៅតាមថ្នាក់របស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយទាំងអង្គហេតុ អង្គច្បាប់ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ជូនក្រុមប្រឹក្សាជំនុំជំរះនៅតាមថ្នាក់របស់ខ្លួន ។

## សិទ្ធិ និងភារកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ តំណាង ឬមេធាវី

៨.២.៤ ដើមបណ្តឹង ឬចុងចម្លើយមានសិទ្ធិអញ្ជើញតំណាង ឬមេធាវី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងការប្តឹងឱ្យចូលរួមដើម្បីបំភ្លឺក្នុងសវនាការប៉ុន្តែត្រូវសុំការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាជំនុំជំរះ មុនពេលបើកសវនាការ ។

៨.២.៤.១ ដើម្បីប្រគល់សិទ្ធិជូនមេធាវី ឬតំណាងរបស់ខ្លួន អ្នកប្តឹងត្រូវធ្វើលិខិតប្រគល់សិទ្ធិដល់មេធាវី ឬអ្នកតំណាងដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា ឬផ្តិតមេដៃពីមេធាវី ឬអ្នកតំណាងនោះផង ។ មេធាវី ឬអ្នកតំណាងត្រូវតែជានីតិជន ។

៨.២.៤.២ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហា ដែលកើតមានឡើង ។ ចុងចម្លើយនៃបណ្តឹងក៏អាចធ្វើរបាយការណ៍អំពីបញ្ហានានាដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈតំណាង ឬមេធាវីដែលទទួលសិទ្ធិផងដែរ ។

៨.២.៤.៣ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារ ភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន ។

៨.២.៤.៤ ចុងចម្លើយត្រូវបង្ហាញពីសំណុំរឿងរបស់ខ្លួន ហើយអាចបង្ហាញនូវឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន ។

៨.២.៤.៥ នៅក្នុងនីតិវិធីសវនាការប្រតិបក្ស ចុងចម្លើយអាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងអំពីភស្តុតាងដែលគេមាន ដើមបណ្តឹងក៏អាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយអំពីភស្តុតាងដែលមានដែរ ។

៨.២.៤.៦ ចុងចម្លើយអាចបង្ហាញភស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈតំណាង ឬមេធាវីដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង ។

៨.២.៤.៧ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជំរះក្តីក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងដំណើរការសវនាការនេះ ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាមច្បាប់នៃសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធី គជប ។

៨.២.៤.៨ ដើមបណ្តឹង និងចុងចម្លើយមិនត្រូវបានបង្ខំឱ្យធ្វើសម្បថជាមុននោះទេ ។

៨.២.៤.៩ សាមីដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ដើមបណ្តឹង ឬចុងចម្លើយ អាចស្នើសុំឱ្យ គជប ឬ គខ,កប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួន ដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ ។ ការថតចម្លងត្រូវធ្វើដោយផ្ទាល់ ដោយមន្ត្រី គជប ឬមន្ត្រី គខ,កប ដែលបានតែងតាំង ។

៨.២.៤.១០ ភាគីទាំងអស់មានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះ តាមការកំណត់ក្នុងច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធី គជប ។

៨.២.៤.១១ មុនពេលក្រុមប្រឹក្សាជំនុំជំរះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ក្រុមប្រឹក្សាជំនុំជំរះ ។

**សិទ្ធិ និងភារកិច្ចរបស់សាក្សី**

៨.២.៥ សាក្សីត្រូវធ្វើសម្បថ និងឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជំរះនៅចំពោះមុខក្រុមប្រឹក្សាជំនុំជំរះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (ខ្លឹមសារសម្បថ មានក្នុងឧបសម្ព័ន្ធស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ) ។

៨.២.៥.១ សាក្សីដើមបណ្តឹង និងចុងចម្លើយមានសិទ្ធិឆ្លើយបំភ្លឺតាមការយល់ឃើញរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ ។

៨.២.៥.២ សាក្សីដើមបណ្តឹង និងចុងចម្លើយ ត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នារង់ចាំការអញ្ជើញ ឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាជំនុំជំរះ ។

៨.២.៥.៣ សាក្សីដើមបណ្តឹង និងចុងចម្លើយ មិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នាទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមសវនាការ ។

៨.២.៥.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ជំនុំជំរះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

## នីតិវិធីដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភលើបញ្ញត្តិដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**ប្រការ** ៨.៣ នីតិវិធីដូចមានចែងក្រោមប្រការ ៨.៣ នេះ មានគោលដៅកំណត់ពីនីតិវិធីនៃការដាក់ពាក្យបណ្ដឹង និងការដោះស្រាយបណ្ដឹងអំពីភាពមិនប្រក្រតីណាមួយដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ហើយដែលអាចកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់ការទាំងអស់នៃដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៨.៣.១ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយត្រូវបានកំណត់ដូចខាងក្រោម ៖

៨.៣.១.១ ការប្រើកម្លាំងដកហូតឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់ប្រភេទ ពីអ្នកបោះឆ្នោត ។

៨.៣.១.២ ការប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។

៨.៣.១.៣ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ។

៨.៣.១.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនឱ្យដំណើរការបាន ។

៨.៣.១.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោត ឱ្យប្រព្រឹត្តអំពើរំលោភបំពានអំពើគំរាមកំហែង ឬអំពើហឹង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។

៨.៣.១.៦ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

៨.៣.១.៧ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោត ដោយសម្ភារៈ ឬប្រាក់កាស ។

៨.៣.២ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្ដែងឡើង ដោយពាក្យសំដី ជាលាយល័ក្ខណ៍អក្សរ ឬដោយកាយវិការ ដូចខាងក្រោម ៖

៨.៣.២.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយល័ក្ខណ៍អក្សរ ដែលពោរពេញទៅដោយការគំរាមកំហែងដល់អាយុជីវិត ការគំរាមធ្វើទុក្ខទោសដល់រាងកាយ ឬការគំរាមបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ។

៨.៣.២.២ ការរំលោភដោយពាក្យសំដីថានឹងធ្វើទុក្ខទោសដល់រាងកាយ ឬការចោលសំដីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬការសរសេរជាលាយលក្ខណ៍អក្សរក្តី ក្នុងន័យថានឹងធ្វើទារុណកម្ម ។

៨.៣.២.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ។

៨.៣.២.៤ ការបង្ហាញ ឬប្រើប្រាស់គ្រឿងសព្វាវុធ ដើម្បីធ្វើការបំភិតបំភ័យ ។

៨.៣.២.៥ ការលើកឡើងដោយផ្ទាល់មាត់ ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលយោលទៅលើព្រឹត្តិការណ៍ពីអតីតកាលដែលជនណាម្នាក់ត្រូវបានគេប្រហារជីវិត ឬត្រូវគេវាយដំ ឬត្រូវគេរំលោភ ឬទ្រព្យសម្បត្តិរបស់គាត់ត្រូវបានគេបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត។

៨.៣.២.៦ ការបាញ់ដោយកាំភ្លើងបង្អើរលើក្បាលអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានយន្ត ឬនៅទីកន្លែងជុំវិញខ្លួនអ្នកទាំងនោះ ។

៨.៣.២.៧ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ ដែលអាចធ្វើឱ្យអ្នកទាំងនោះមានការភ័យខ្លាចដល់អាយុជីវិតរបស់គេ ដល់អាយុជីវិតបងប្អូនគ្រួសាររបស់គេ ឬបង្កឱ្យគេភ័យខ្លាច ។

៨.៣.២.៨ ការបណ្តើរអ្នកគាំទ្រ ឬអ្នកបោះឆ្នោតណាម្នាក់ដោយបង្ខំផ្ទុយពីឆន្ទៈរបស់គេ ដែលធ្វើឱ្យអារម្មណ៍របស់គេមានការភ័យខ្លាច ឬធ្វើឱ្យគេខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់គេ ។

៨.៣.២.៩ ការប្រើភាសាកម្លាំងបាយ ដើម្បីបង្ហាញពីការគំរាមកំហែង ។

## ៨.៣.៣ បណ្តឹងពាក់ព័ន្ធនឹងបុគ្គលដែលមិនមែនជាមន្ត្រីបោះឆ្នោត

**នីតិវិធីដាក់ពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅ គខ/កប**

៨.៣.៣.១ ជនគ្រប់រូប ឬតំណាង ឬត្រូវប្តឹងទៅ គខ/កប ក្នុងរយៈពេលបី (៣)ថ្ងៃយ៉ាងយូរបន្ទាប់ពីពេល កើតហេតុលើកលែងតែមានកាលបរិច្ឆេទកំណត់ផ្សេងពីនេះក្នុងច្បាប់បោះឆ្នោត និង បទបញ្ជានិងនីតិវិធីរបស់ គជប ។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវពត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង

- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស
- ប្រភេទនៃអំពើល្មើស
- កម្មវត្ថុនៃបណ្តឹង
- បើអាចធ្វើបានបញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលត្រូវបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងអំពើល្មើស
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សីបើមាន
- ភស្តុតាងផ្សេងៗទៀតបើមាន ។

៨.៣.៣.២ អ្នកប្តឹងត្រូវបំពេញទម្រង់បែបបទប្តឹងលេខ ១២០២ ចំនួនបួន ( ៤ )ច្បាប់ និងត្រូវផ្តិតមេដៃ និងចុះកាលបរិច្ឆេទលើពាក្យបណ្តឹងរបស់ខ្លួន ។ ក្នុងករណីអ្នកប្តឹងមកប្តឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពីទម្រង់បែបបទលេខ ១២០២ មន្ត្រីទទួលពាក្យបណ្តឹងដែលបានតែងតាំង ត្រូវណែនាំអ្នកប្តឹងឱ្យបំពេញទម្រង់បែបបទ គជប លេខ ១២០២ ។

៨.៣.៣.៣ តួនាទី និងចំណាត់ការរបស់ គខ/កប នៅពេលបានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងបទល្មើសដូចមានកំណត់ក្នុងជំពូកទី ១១ នៃច្បាប់បោះឆ្នោត និងបទបញ្ជា និង នីតិវិធីរបស់ គជប គឺត្រូវពិនិត្យជាបន្ទាន់លើភាពអាចទទួលយកបាននៃបណ្តឹង ជាអាទិ៍ អត្តសញ្ញាណនៃអ្នកប្តឹង មូលដ្ឋានច្បាប់នៃបណ្តឹង និងការគោរពអំឡុងពេលដូចមានកំណត់ក្នុងចំណុច ៨.៣.៣.១ ខាងលើ នៃនីតិវិធីនេះ ។ ចំពោះពាក្យបណ្តឹងដែលគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវឬពុំមានពត៌មានចាំបាច់គ្រប់គ្រាន់ ឬពុំបានធ្វើឡើងក្នុងអំឡុងពេលដូចបានកំណត់ក្នុងចំណុច ៨.៣.៣.១ ខាងលើ ប្រធាន គខ/កប ត្រូវចារបដិសេធនៅលើជ្រុងខាងស្តាំផ្នែកខាងលើ ដោយបញ្ជាក់អំពីមូលហេតុដែលថា មិនអាចទទួលយកបាន ។

៨.៣.៣.៤ ដែនកំណត់សមត្ថកិច្ចរបស់ គខ/កប ក្នុងការដោះស្រាយបណ្តឹងគ្រប់បទល្មើសទាំងឡាយដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់បោះឆ្នោតអាចធ្វើតាមពីរដំណាក់ការ គឺដំណាក់ការសម្រុះសម្រួលជាបឋម និងដំណាក់ការបើកសវនាការ ។

៨.៣.៣.៥ ក្នុងករណី គខ/កប ពិនិត្យឃើញថាបណ្ដឹងមានលក្ខណៈត្រឹមត្រូវតាមការកំណត់ខាងលើ គខ/កប ត្រូវចាត់វិធានការសមស្របជាបន្ទាន់តាមច្បាប់ និងបទបញ្ជា និង នីតិវិធី របស់ គជប ។

៨.៣.៣.៥.១ វិធានការសមស្រប ជាបន្ទាន់ នោះ ជាបឋម គខ/កប ត្រូវកោះអញ្ជើញភាគីពាក់ព័ន្ធនឹងបណ្ដឹង ដើម្បីធ្វើការសម្រុះសម្រួលគ្នាសិនមុននឹងឈានទៅដល់ការរៀបចំនីតិវិធីបើកសវនាការ ។

៨.៣.៣.៥.២ ប្រសិនបើការសម្រុះសម្រួល ផ្សះផ្សាគ្នារវាងភាគីមានជំលោះមិនបានសម្រេច គខ/កប ត្រូវរៀបចំបើកសវនាការ ទៅតាមនីតិវិធីដូចបានកំណត់នៅក្រោមចំណុច ៨.២.២ នៃបទបញ្ជា និង នីតិវិធីនេះ ។ ដើមបណ្ដឹង ឬចុងចម្លើយ អាចប្ដឹងតវ៉ា ឬប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ គខ/កប ទៅ គជប ក្នុងរយៈពេលបី ( ៣ )ថ្ងៃយ៉ាងយូរបន្ទាប់ពី គខ/កប សម្រេចបដិសេធបណ្ដឹង ។ សេចក្ដីសម្រេចរបស់ គខ/កប តាមទម្រង់បែបបទលេខ ១២០៣ ត្រូវធ្វើជាប្រាំ ( ៥ )ច្បាប់ ៖ មួយ ( ១ )ច្បាប់សម្រាប់ដើមបណ្ដឹង មួយ ( ១ )ច្បាប់សម្រាប់ចុងចម្លើយ មួយ ( ១ )ច្បាប់សម្រាប់ទុកជាឯកសារ មួយ ( ១ )ច្បាប់បញ្ជូនមក គជប និង មួយ ( ១ )ច្បាប់ទៀតសម្រាប់បិទផ្សាយជាសាធារណៈ ។

៨.៣.៣.៥.៣ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គខ,កប ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្រោមប្រការ ៨.២.១.៤ នៃបទបញ្ជា និង នីតិវិធីនេះ ។

៨.៣.៣.៥.៤ គខ,កប ត្រូវរាយការណ៍ជាបន្ទាន់អំពីសេចក្ដីសម្រេចរបស់ខ្លួនទៅ គជប បន្ទាប់ពីសវនាការចប់ ។

៨.៣.៣.៥.៥ ប្រសិនបើការសម្រុះសម្រួល ផ្សះផ្សាគ្នារវាងភាគីមានជំលោះបានសម្រេច ដោយការព្រមព្រៀងគ្នានោះ គខ,កប ត្រូវចុះក្នុងកំណត់ហេតុស្ដីពីការសម្រុះសម្រួល ហើយធ្វើរបាយការណ៍សង្ខេបបញ្ជូនមក គជប ជាបន្ទាន់ ។ កំណត់ហេតុសម្រុះសម្រួល ដែលទទួលការព្រមព្រៀងពីភាគីរួចហើយ ត្រូវឱ្យភាគីទាំងអស់ផ្ដិតមេដៃលើកំណត់ហេតុនោះហើយត្រូវមានសាក្សីដឹងឮ ផ្ដិតមេដៃនៅលើកំណត់ហេតុនោះផង។ កំណត់ហេតុនេះ ត្រូវចម្លងជូនភាគីពាក់ព័ន្ធមួយ( ១ )ច្បាប់ ។

៨.៣.៣.៦ បើ គខ/កប ពិនិត្យឃើញថា ពាក្យបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងបទល្មើស មានចែងក្នុងជំពូកទី ១១ នៃច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គខ/កប ត្រូវណែនាំអ្នកប្ដឹងឱ្យដាក់ពាក្យបណ្ដឹងទៅតុលាការវិញ ។

៨.៣.៣.៧ គខ/កប មិនចាំបាច់បើកការស៊ើបអង្កេតទេ ប្រសិនបើជនល្មើសបានប្រព្រឹត្តបទល្មើសជាក់ស្ដែងដូចបានកំណត់ក្នុងជំពូកទី ១១ នៃច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ ក្នុងករណីនេះ គខ/កប ត្រូវចាត់វិធានការទៅតាមនីតិវិធីដូចបានកំណត់ក្រោមចំណុច ៨.៣.៣.៥ នៃបទបញ្ជា និង នីតិវិធីរបស់ គជប ។

៨.៣.៣.៨ បន្ទាប់ពីទទួលបានពាក្យបណ្ដឹង និងក្រោយពីបានស្រាវជ្រាវស៊ើបអង្កេតបានចប់សព្វគ្រប់ គខ/កប មានអំណាចឆន្ទានុសិទ្ធិដោយមិនយកបណ្ដឹងនោះ មកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថា ពាក្យបណ្ដឹងមិនមានអំណះអំណាងណាមួយដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងស្រពិចស្រពិលមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គខ/កប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្ដឹង ។ ការបដិសេធមិនទទួលដោះស្រាយរបស់ គខ/កប ត្រូវធ្វើតាមរយៈលិខិតរដ្ឋបាលក្នុងរយៈពេលសមស្របមួយទៅសាមីដើមបណ្ដឹង ដើម្បីជូនជ្រាបថាបណ្ដឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយទេ ។

**នីតិវិធីដាក់ពាក្យបណ្ដឹង និងដោះស្រាយបណ្ដឹងនៅ គជប**

៨.៣.៣.៩ ជនគ្រប់រូប ឬតំណាងត្រូវប្ដឹងទៅ គជប ក្នុងរយៈពេលបី ( ៣ ) ថ្ងៃយ៉ាងយូរបន្ទាប់ពី គខ/កប ធ្វើការបដិសេធបណ្ដឹងលើកលែងតែចំណុច ៨.៣.៣.១ ។ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុងចំណុច ៨.៣.៣.១ ខាងលើ ។

៨.៣.៣.១០ ចំណាត់ការរបស់ គជប គឺត្រូវបើកសវនាការដោះស្រាយលើបណ្ដឹងតាមកាលវេលាសមគួរបន្ទាប់ពីបានទទួលពាក្យបណ្ដឹង ។ គជប ត្រូវរៀបចំ និងជូនដំណឹងទៅភាគីពាក់ព័ន្ធដើម្បីកំណត់កាលបរិច្ឆេទ និងទីកន្លែងសវនាការ ។ សវនាការត្រូវគោរពតាមនីតិវិធីដូចមានកំណត់ក្នុងចំណុច ៨.២.១ ៨.២.២ ៨.២.៣ ៨.២.៤ និងចំណុច ៨.២.៥ នៃបទបញ្ជា និង នីតិវិធីរបស់ គជប ។

៨.៣.៣.១១ មន្ត្រីសេវាកម្មច្បាប់ដែលត្រូវបានចាត់តាំង ត្រូវពិនិត្យជាបន្ទាន់លើភាពអាចទទួលយកបាននៃបណ្ដឹង ជាអាទិ៍ អត្តសញ្ញាណនៃអ្នកប្ដឹង មូលដ្ឋានច្បាប់នៃបណ្ដឹង និងការគោរពអំឡុងពេលដូចមានកំណត់ក្នុងចំណុច ៨.៣.៣.១ នៃនីតិវិធីនេះ ។

ចំពោះពាក្យបណ្ដឹងដែលគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ ឬពុំមានពត៌មានចាំបាច់គ្រប់គ្រាន់ ឬពុំបានធ្វើឡើងក្នុងអំឡុងពេលដូចបានកំណត់ក្នុងចំណុច ៨.៣.៣.១ នៃនីតិវិធីនេះ ឬករណីបណ្ដឹងនេះត្រូវបានភាគីជំលោះយល់ព្រមស្រុះស្រួលគ្នានៅ គខ/កប រួចហើយនោះ គជប ត្រូវចារបដិសេធនៅលើជ្រុងខាងស្ដាំផ្នែកខាងលើ ដោយបញ្ជាក់អំពីមូលហេតុដែលថាមិនអាចទទួលយកបាន ។

៨.៣.៣.១១.១ ក្នុងករណី គជប ពិនិត្យឃើញថាបណ្ដឹងមានលក្ខណៈត្រឹមត្រូវតាមការកំណត់ខាងលើ គជប ត្រូវចាត់វិធានការសមស្របជាបន្ទាន់ដើម្បីរៀបចំបើកសវនាការទៅតាមនីតិវិធីរបស់ខ្លួន ។

៨.៣.៣.១១.២ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គជប ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៨.២.៣ នៃបទបញ្ជា និង នីតិវិធីនេះ ។

៨.៣.៣.១២ ក្រុមប្រឹក្សាជំនុំជំរះ ត្រូវប្រកាសសេចក្តីសម្រេចរបស់ខ្លួនតាមទម្រង់បែបបទ ១២០៣ ចំនួនប្រាំ ( ៥ )ច្បាប់ដែលត្រូវចាត់ចែងដោយ គជប នៅពេលបញ្ចប់សវនាការ ។

៨.៣.៣.១៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់ គជប ជាសេចក្តីសម្រេចមានអានុភាពអនុវត្តភ្លាម និងបិទផ្លូវតវ៉ា ។

៨.៣.៣.១៤ បន្ទាប់ពីទទួលបានពាក្យបណ្តឹង និងក្រោយពីបានស្រាវជ្រាវស៊ើបអង្កេតបានចប់សព្វគ្រប់ គជប មានអំណាចឆន្ទានុសិទ្ធិ ដោយមិនយកបណ្តឹងនោះ មកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងមិនមានអំណះអំណាងណាមួយដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងស្រពិចស្រពិលមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គជប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង ។

ការបដិសេធ មិនទទួលដោះស្រាយរបស់ គជប ត្រូវធ្វើតាមរយៈលិខិតរដ្ឋបាលក្នុងរយៈពេលសមស្របមួយ ទៅសាមីដើមបណ្តឹង ដើម្បីជូនជ្រាបថា បណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយទេ ។

### ៨.៣.៤ បណ្តឹងពាក់ព័ន្ធ នឹងមន្ត្រី ឬសមាជិករបស់អាជ្ញាធររៀបចំការបោះឆ្នោត

៨.៣.៤.១ គ្រប់បណ្តឹងពាក់ព័ន្ធនឹងអំពើល្មើស ដូចមានកំណត់ក្រោមចំណុច **៨.៣.១ និង ៨.៣.២ នៃបទបញ្ជា និង នីតិវិធី គជប** ដែលធ្វើឡើង ចំពោះមន្ត្រី ឬសមាជិករបស់អាជ្ញាធររៀបចំការបោះឆ្នោតត្រូវចាត់ចែង និងដោះស្រាយតាមច្បាប់បោះឆ្នោត និងបទបញ្ជា និង នីតិវិធីរបស់ គជប ។ ជនគ្រប់រូប ឬតំណាងមានសិទ្ធិធ្វើបណ្តឹងដូចបានរៀបរាប់ខាងលើ នៅចំពោះមុខអាជ្ញាធររៀបចំការបោះឆ្នោត ថ្នាក់លើមួយថ្នាក់ក្នុងរយៈពេលបី ( ៣ )ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ លើកលែងតែមានកាលបរិច្ឆេទកំណត់ផ្សេងពីនេះក្នុងច្បាប់បោះឆ្នោត ។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុងចំណុច ៨.៣.៣.១ នៃបទបញ្ជា និង នីតិវិធីនេះ ។

៨.៣.៤.២ ចំពោះបណ្តឹងពាក់ព័ន្ធនឹងសមាជិកការិយាល័យបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតត្រូវប្តឹងទៅ គខ/កប តាមនីតិវិធីកំណត់ក្នុងចំណុច ៨.៣.៤.១ ទៅតាមទម្រង់បែបបទលេខ ១២០២ ចំនួនបួន ( ៤)

ច្បាប់ ដែលពីរ ( ២ )ច្បាប់សម្រាប់ គខ/កប ប្រើក្នុងសវនាការ មួយ ( ១ )ច្បាប់បិទផ្សាយជាសាធារណៈ និងមួយ ( ១ )ច្បាប់ប្រគល់ជូនដើមបណ្តឹង ។

៨.៣.៤.៣ ចំពោះបណ្តឹងពាក់ព័ន្ធនឹងមន្ត្រី ឬសមាជិក គខ/កប ត្រូវប្តឹងទៅ គជប តាមនីតិវិធីកំណត់ក្នុងចំណុច ៨.៣.៤.១ តាមទម្រង់បែបបទលេខ ១២០២ ចំនួនបួន ( ៤ )ច្បាប់ ដែលពីរ ( ២ )ច្បាប់សម្រាប់ប្រើក្នុងសវនាការ មួយ ( ១ )ច្បាប់បិទផ្សាយជាសាធារណៈ និងមួយ ( ១ )ច្បាប់ប្រគល់ជូនដើមបណ្តឹង ។

៨.៣.៤.៤ ចំពោះបណ្តឹងពាក់ព័ន្ធនឹងមន្ត្រីរបស់ គជប ត្រូវប្តឹងទៅប្រធាន គជប តាមនីតិវិធីកំណត់ក្នុងចំណុច ៨.៣.៤.១ តាមទម្រង់បែបបទលេខ ១២០២ ចំនួនបួន ( ៤ )ច្បាប់ ដែលពីរ ( ២ )ច្បាប់សម្រាប់ប្រើក្នុងសវនាការ មួយ ( ១ )ច្បាប់បិទផ្សាយជាសាធារណៈ និងមួយ ( ១ )ច្បាប់ប្រគល់ជូនដើមបណ្តឹង ។

៨.៣.៤.៥ ចំពោះបណ្តឹងពាក់ព័ន្ធនឹងសមាជិក គជប ត្រូវប្តឹងទៅរដ្ឋសភាដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៥ នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

# ជំពូកទី ៩

# ការជ្រើសតាំងជំនួសសមាជិកព្រឹទ្ធសភា

**ប្រការ** ៩.១ សមាជិកព្រឹទ្ធសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម ៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកព្រឹទ្ធសភា
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

៩.១.១ ក្នុងករណីសមាជិកព្រឹទ្ធសភាណាម្នាក់ បាត់បង់សមាជិកភាព តាមមូលហេតុដូចមានចែងក្នុងប្រការ ៩.១ ខាងលើ ដែលកើតឡើង ៦ (ប្រាំមួយ)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើសុំជ្រើសតាំងសមាជិកថ្មីជំនួសបាន ។

៩.១.២ សាមីគណបក្សនយោបាយ អាចស្នើជ្រើសតាំងសមាជិកថ្មី ក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលភូមិភាគរបស់សមាជិកព្រឹទ្ធសភា មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

# ជំពូកទី ១០
# ថវិកា និងហិរញ្ញវត្ថុ

**ប្រការ ១០.១** ថវិកា នៃគណនីពិសេសនៅរតនាគារ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលប្រើប្រាស់ដោយ គជប ត្រូវបើកនៅរតនាគារជាតិ ។

១០.១.១ តាមច្បាប់ស្តីពីគណនីពិសេសនៃ គជប រាជរដ្ឋាភិបាលត្រូវដាក់ថវិការួមចំណែករបស់ខ្លួនក្នុងគណនីពិសេសនេះ ។

១០.១.២ ថវិកានៃគណនីពិសេសនឹងបានមកពីមូលនិធិទាយជ្ជទានដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការមិនមែនរដ្ឋាភិបាលនិងចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ១០.២** គជប ត្រូវបើកគណនីនៅធនាគារមួយ ឬច្រើនតាមតំរូវការជាក់ស្តែង ឬរតនាគារខេត្ត ក្រុង និងផ្ទេរប្រាក់ចូលក្នុងគណនីនេះតាមចំនួនថវិកា ដែលត្រូវការចាំបាច់សម្រាប់ចំណាយលើការងារបោះឆ្នោត ។

**ប្រការ ១០.៣** គជប ត្រូវកំណត់បរិបថក្នុងការចំណាយថវិកាដូចបានបញ្ជាក់ក្នុងប្រការ ១០.១ មានដូចខាងក្រោម ៖

១០.៣.១ ការប្រើប្រាស់មូលប្បទានប័ត្រសម្រាប់ការចំណាយរបស់ខ្លួន ៖

១០.៣.១.១ នៅលើមូលប្បទានប័ត្រត្រូវមានហត្ថលេខាចំនួនពីរដែលក្នុងនោះត្រូវតែមានហត្ថលេខាមួយរបស់ប្រធាន គជប ។

១០.៣.១.២ ក្នុងករណីប្រធាន គជប អវត្តមាន អនុប្រធានអាចចុះហត្ថលេខាជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន គជប ។

១០.៣.១.៣ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការចុះហត្ថលេខាលើមូលប្បទានប័ត្ររបស់ គជប ។

១០.៣.១.៤ ក្នុងករណី ដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុមិនអាចបំពេញការងារបានអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុអាចចុះហត្ថលេខាជំនួសប្រសិនបើគាត់ត្រូវបានប្រគល់សិទ្ធិអំណាចឱ្យដោយ គជប ។

១០.៣.២ រាល់ការចំណាយ ត្រូវតែមានការយល់ព្រមពី នាយកដ្ឋានហិរញ្ញវត្ថុមុនពេលដំណើរការទូទាត់ ។

១០.៣.២.១ រាល់សក្ខីប័ត្រចំណាយទាំងអស់ត្រូវតែបានផ្ទៀងផ្ទាត់ ដោយត្រឹមត្រូវ ។

១០.៣.២.២ សក្ខីប័ត្រត្រឹមត្រូវរួមមាន ៖ គំរោងសំណើសុំ ឯកសារបញ្ជាទិញ ឯកសារស្ទាបស្ទង់តម្លៃ លិខិតប្រគល់ ទទួល និងវិក័យប័ត្រ ។

១០.៣.២.៣ លិខិតបញ្ជាបេសកកម្មត្រូវមានចុះទិដ្ឋាការច្បាស់លាស់ ហើយមានវិក័យប័ត្រលើមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ។

១០.៣.២.៤ ការទូទាត់ប្រាក់កំរៃដែល គជប ជាអ្នកកំណត់ ត្រូវមានពាក្យសុំចូលបំរើការងារ កិច្ចសន្យា សេចក្តីសម្រេចកំណត់ប្រាក់កំរៃ តារាងប្រាក់កំរៃ តារាងប្រៀបធៀប ប្រាក់កំរៃដែលមានចុះហត្ថលេខាដោយ គជប និងមានចុះហត្ថលេខានៃអ្នកដែលត្រូវបានទទួលប្រាក់កំរៃ ។

១០.៣.៣ រាល់ការចំណាយដោយផ្ទាល់ ត្រូវមាន ៖

- សំណើសុំទូទាត់
- កំណត់ហេតុប្រគល់/ទទួល
- កំណត់ហេតុដេញថ្លៃ ឬពិគ្រោះថ្លៃ
- ប័ណ្ណបញ្ចេញ និងប័ណ្ណបញ្ចូលទំនិញ/សម្ភារៈ
- កិច្ចសន្យា
- ប័ណ្ណប៉ាតង់
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិបើកប្រាក់
- សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ
- អាណត្តិបើកប្រាក់ ។

១០.៣.៤ រាល់ការចំណាយដែលផ្ទុយពីចំណុច ១០.៣.១ ១០.៣.២ ១០.៣.៣ ត្រូវតែមានឯកសារដទៃទៀត ដូចជាលិខិតអនុញ្ញាតឱ្យចំណាយពី គជប សំណៅមូលប្បទានប័ត្រ ឯកសារមួយចំនួន ដែលតំរូវឱ្យធ្វើការទូទាត់តាមការកំណត់ដោយនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ១០.៤** គជប ត្រូវកំណត់យកប្រព័ន្ធគណនេយ្យមួយសមស្របសម្រាប់ធ្វើការណែនាំដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ឱ្យអនុវត្តការងារចុះបញ្ជីការគណនេយ្យមានការឯកភាពគ្នា និងងាយស្រួលក្នុងការទូទាត់ ។ គំរូលិខិតស្នាម ឯកសារ បទដ្ឋាននានា ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានការឯកភាពគ្នាតាមការកំណត់ពី គជប និងការណែនាំពីនាយកដ្ឋានហិរញ្ញវត្ថុ អនុលោមតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ១០.៥** គជប ត្រូវកំណត់បរិបថការងារក្នុងការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារៈ ទំនិញ និងសេវាកម្មផ្សេងៗ ។ ការត្រួតពិនិត្យក្នុងការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារៈ ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវធ្វើឡើងដោយសេវាកម្មពីរ (២) ដាច់ពីគ្នា ។

១០.៥.១ សម្រាប់គោលបំណងនៃចំណុច ១០.៥.១ គណៈកម្មការត្រួតពិនិត្យក្នុងការទិញសម្ភារៈ បរិក្ខាររួមមាន ៖

១. នាយកដ្ឋាន ហិរញ្ញវត្ថុ

២. នាយកដ្ឋាន រដ្ឋបាល

៣. នាយកដ្ឋាន ពាក់ព័ន្ធ

នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការរៀបចំដាក់ឱ្យដេញថ្លៃ ឬពិគ្រោះថ្លៃ សមស្របតាមនីតិវិធីហិរញ្ញវត្ថុ ឯនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធទទួលខុសត្រូវក្នុងការត្រួតពិនិត្យ អំពីបរិមាណ និងគុណភាពទំនិញសម្ភារៈបរិក្ខារ និងសេវាកម្មផ្សេងៗ រួចហើយធ្វើការកត់ត្រាបញ្ចូលឃ្លាំង និងធ្វើការបែងចែក ។

១០.៥.២ ទំនិញ សម្ភារៈ បរិក្ខារមួយចំនួន ជាចលនវត្ថុ និងអចលនវត្ថុ ទាំងនៅក្នុង ឬក្រៅសន្និធិត្រូវកត់ត្រាឱ្យបានច្បាស់លាស់ បញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌ ដែលជាការទទួលខុសត្រូវរបស់នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋាន ពាក់ព័ន្ធ ។

**ប្រការ ១០.៦** នាយកដ្ឋានហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន ត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុប្រចាំខែត្រូវបានបំពេញមិនឱ្យយឺតជាងសប្តាហ៍ទីបី (៣) នៃខែបន្ទាប់ ។

**ប្រការ ១០.៧** ឆ្នាំសារពើពន្ធនៃ គជប ត្រូវគិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ។

**ប្រការ** ១០.៨ នៅដំណាច់ឆ្នាំសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន ត្រូវធានារៀបចំ និងត្រួតពិនិត្យ ឱ្យបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានអនុវត្តមិនយឺតជាងបី (៣)ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ។

១០.៨.១ គជប ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមួយច្បាប់ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១០.៨.២ គជប ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្ត កម្មវិធីចំណូល និងកម្មវិធីចំណាយ មួយច្បាប់ជូនរដ្ឋសភា មួយច្បាប់ជូនព្រឹទ្ធសភា និងមួយច្បាប់ទៀតជូនទៅរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនឱ្យហួសពីបី (៣)ខែ បន្ទាប់ពីប្រតិបត្តិការបោះឆ្នោតបញ្ចប់ជាស្ថាពរ ។

# ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**ប្រការ** ១១.១ អនុលោមតាមជំពូកទី ១១ មាត្រា ៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មាត្រា ១២៤ថ្មី ១២៥ថ្មី ១២៦ថ្មី ១២៧ថ្មី ១២៨ថ្មី ១២៩ថ្មី ១៣០ថ្មី ១៣១ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

១១.១.១ ទណ្ឌកម្មត្រូវអនុវត្តតាមប្រភេទនៃបទល្មើសដូចមានបញ្ញត្តិ ក្នុងប្រការនីមួយៗខាងក្រោម ៖

១១.១.១.១ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ,និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១១.១.១.១.១ ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យអ្នកមានសិទ្ធិបោះឆ្នោត ទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះអ្នក ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

១១.១.១.១.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពានអំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

១១.១.១.១.៣ ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។

១១.១.១.១.៤ ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងអ្នកដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

១១.១.១.១.៥ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយ មិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។

១១.១.១.១.៦ ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើ ឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

១១.១.១.១.៧ បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។

១១.១.១.១.៨ បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។

១១.១.១.១.៩ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

១១.១.១.១.១០ ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស។

១១.១.១.២ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ,និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំចំពោះសមាជិកគណៈកម្មាធិការជាតិសមាជិកគណៈកម្មការខេត្ត ក្រុង និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

១១.១.១.៣ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀលដល់ហាសិបលាន (៥០.០០០.០០០)រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈ-កម្មការរៀបចំការបោះឆ្នោតណា ដែលពុំមានជំហរអព្យាក្រឹត ឬ,និង លំអៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

១១.១.១.៤ ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៥ថ្មី ឬមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និង

ដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី (៤៨) ម៉ោងដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង យោងទៅតាមកម្រិតនៃបទល្មើស ។
- លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបំរើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេលដប់ (១០) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃចំណុច ១១.១.១.៤ នេះ ។

១១.១.១.៥ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ )ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ឱ្យដាក់វិន័យរដ្ឋបាលចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀតដែលមិនផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១១.១.១.៦ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀលដល់ដប់លាន (១០.០០០.០០០)រៀល ឬ,និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលបង្គាប់បញ្ជា ឬលួងលោម បោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។ ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបំរើការងារក្នុងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។ ប្រសិនបើជនប្រព្រឹត្តល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃចំនុច ១១.១.១.៦ នេះ ។

១១.១.១.៧ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ,និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោតដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្ដើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។ ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មា-ធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបំរើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។ ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃចំណុច ១១.១.១.៧ នេះ ។

១១.១.១.៨ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ,និងត្រូវដកហូតបណ្ណបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬគណបក្សនយោបាយណាដែល ៖

១១.១.១.៨.១ ពុំគោរពតាមវិធានបទប្បញ្ញត្តិ គោលការណ៍ក្រមសីលធម៌ និងបទបញ្ជា និង នីតិវិធី ស្តីពីការឃោសនាបោះឆ្នោត របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

១១.១.១.៨.២ ពុំគោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១១.១.១.៨.៣ ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយ និងបេក្ខជនបានប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ សាបព្រួសឱ្យមានការភ័យខ្លាច ការភ័ន្តច្រឡំ ធ្វើឱ្យប្រឬកប្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

១១.១.១.៩ ជនណាដែលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត លើសរយៈពេលដូចមានកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងលើសរយៈពេលដូចមានកំណត់ក្នុងបទបញ្ជា និងនីតិវិធី គជប ជននោះនឹងត្រូវទទួលការព្រមាន ។ ក្នុងករណីដែលនៅតែពុំអនុវត្តតាម ត្រូវដកហូតសិទ្ធិបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ )ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ,និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ។

១១.១.២ ជនទាំងឡាយណាដែលត្រូវបាន គជប ឬ គឃ,កប ផ្តន្ទាទោសពិន័យជាប្រាក់ ត្រូវបង់ប្រាក់ពិន័យរបស់ខ្លួនតាមពេលវេលាដែល គជប បានកំណត់ ។ ករណីយឺតយ៉ាវក្នុងការបង់ប្រាក់ពិន័យ គជប នឹងចាត់វិធានការតាមផ្លូវច្បាប់ដើម្បី

ឱ្យមានការគោរពច្បាប់បោះឆ្នោត បទបញ្ជា និង នីតិវិធី គជប ។ ច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រម រដ្ឋប្បវេណី និងសេចក្តីបង្គាប់លេខ ១១៧ សរ.រវ.៩៧ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការនឹងត្រូវយកមកអនុវត្ត ។

១១.១.៣ ជនល្មើសត្រូវចូលខ្លួនមកបង់ប្រាក់ពិន័យនៅទីស្តីការ គជប តាមរយៈនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម គជប ។

១១.១.៤ ប្រាក់ដែលបានមកពីការពិន័យ ត្រូវដាក់បញ្ចូលក្នុងថវិកាជាតិ ។

# ឧបសម្ព័ន្ធ
# ស្តីពី
# ការបែងចែកអាសនៈ

១. យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រដោយយកភូមិភាគ ដែលរួមមានខេត្ត ក្រុងមួយ ឬច្រើនជាមណ្ឌលបោះឆ្នោត ហើយការបែងចែកអាសនៈតាមមណ្ឌលភូមិភាគនីមួយៗ ត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ។

២. អាសនៈក្នុងព្រឹទ្ធសភាត្រូវបានបែងចែក ដោយផ្អែកលើចំនួនអាសនៈតាមភូមិភាគ និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ។ គជប ត្រូវធ្វើការបែងចែកអាសនៈ និងកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយជាប់ឆ្នោត តាមភូមិភាគនីមួយៗ ។

៣. បេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាត្រូវបានប្រកាស ដោយផ្អែកតាមលំដាប់លេខរៀងនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតនៅក្នុង មណ្ឌលភូមិភាគនីមួយៗ ។

**ការកំណត់កូតា និងការបែងចែកអាសនៈ**

៤. ដើម្បីបែងចែកអាសនៈតាមមណ្ឌលភូមិភាគនីមួយៗ គជប ត្រូវអនុវត្តតាមករណីដូចតទៅ ៖

៤.១ អាសនៈនៅក្នុងមណ្ឌលភូមិភាគ ត្រូវបានបែងចែកដោយផ្អែកលើចំនួនអាសនៈនិងលទ្ធផលនៃការបោះឆ្នោតក្នុងភូមិភាគតាមជំហានទាំងឡាយដូចខាងក្រោម ៖

**<u>ជំហានទី១:</u> ការកំណត់កូតា ( Quota )**

៤.១.១ កូតា គឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលភូមិភាគនីមួយៗ ដែលកំណត់ឡើងសំរាប់ឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅក្នុងមណ្ឌលភូមិភាគនោះទទួលបានមួយ (១)អាសនៈ ។

៤.១.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបក្នុងមណ្ឌលបោះឆ្នោតភូមិភាគពាក់ព័ន្ធ ចែកនឹងចំនួនអាសនៈសរុប ដែលបានកំណត់សំរាប់មណ្ឌលបោះឆ្នោតភូមិភាគនោះ ។

$$គ_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

- $ក_{ត}$ តាងឱ្យកូតា ជាផលចែកដែលមិនគិតសំណល់ចែក ។
- $ស_{ស}$តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ។
- $អ_{ស}$ តាងឱ្យចំនួនអាសនៈសរុប ។

**<u>ឧទាហរណ៍</u>: ការកំណត់កូតា**

នៅមណ្ឌលភូមិភាគ A មាន ៖

- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ១.៧៦៥ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៨ អាសនៈ

$$ក_{ត} = \frac{ស_{ស}}{អ_{ស}} = \frac{១.៧៦៥}{៨} = ២២០$$

កូតាស្មើនឹង ២២០ ($ក_{ត}$ = ២២០)

## <u>ជំហានទី២</u>: ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១

៨.១.៣ ដើម្បីកំណត់ចំនួនអាសនៈបឋមសំរាប់គណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនីមួយៗទទួលបាន មកចែកនឹងកូតា ដោយមិនគិតសំណល់ចែក តាមរូបមន្តដូចខាងក្រោម ៖

$$អ_{ទ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

- $អ_{ទ}$ តាងឱ្យចំនួនអាសនៈ ជាផលចែកមិនគិតសំណល់ចែក ដែលគណបក្សនយោបាយនីមួយៗ ទទួលបាន ក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់គណបក្សនយោបាយ នីមួយៗ ។
- $ក_{ត}$ តាងឱ្យកូតា ។

**<u>ឧទាហរណ៍:</u> ការបែងចែកអាសនៈលើកទី១**

នៅមណ្ឌលភូមិភាគ A ដដែល មានគណបក្សនយោបាយឈរឈ្មោះចំនួន ៧ ៖

គណបក្ស ក មានសន្លឹកឆ្នោតបានការ ស្បក = ១៨៣ សន្លឹក

គណបក្ស ខ មានសន្លឹកឆ្នោតបានការ ស្បខ = ៣៣១ សន្លឹក

គណបក្ស គ មានសន្លឹកឆ្នោតបានការ ស្បគ = ៩៨ សន្លឹក

គណបក្ស ឃ មានសន្លឹកឆ្នោតបានការ ស្ប = ៥១២ សន្លឹក

គណបក្ស ង មានសន្លឹកឆ្នោតបានការ ស្បង = ២៨៥ សន្លឹក

គណបក្ស ច មានសន្លឹកឆ្នោតបានការ ស្បច = ១០៤ សន្លឹក

គណបក្ស ឆ មានសន្លឹកឆ្នោតបានការ ស្បឆ = ២៥២ សន្លឹក

អនុវត្តតាមរូបមន្ត ដូចចែងក្នុងចំណុច ៤.១.៣ យើងបាន ៖

គណបក្ស ក អ្ទក = ១៨៣/២២០ = ០,៨៣ ត្រូវជា ០ អាសនៈ

គណបក្ស ខ អ្ទខ = ៣៣១/២២០ = ១,៥០ ត្រូវជា ១ អាសនៈ

គណបក្ស គ អ្ទគ = ៩៨/២២០ = ០,៤៤ ត្រូវជា ០ អាសនៈ

គណបក្ស ឃ អ្ទឃ = ៥១២/២២០ = ២,៣២ ត្រូវជា ២ អាសនៈ

គណបក្ស ង អ្ទង = ២៨៥/២២០ = ១,២៩ ត្រូវជា ១ អាសនៈ

គណបក្ស ច អ្ទច = ១០៤/២២០ = ០,៤៧ ត្រូវជា ០ អាសនៈ

គណបក្ស ឆ អ្ទឆ = ២៥២/២២០ = ១,១៤ ត្រូវជា ១ អាសនៈ

៤.១.៤ បន្ទាប់ពីការគណនាបែងចែកអាសនៈ គ្រប់គណបក្សនយោបាយទាំងអស់ក្នុងជំហានទី២ រួច ប្រសិនបើគ្មានអាសនៈនៅសល់ នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង ។

**<u>ជំហានទី៣:</u> ការកំណត់មធ្យមភាគខ្ពស់បំផុត**

៤.១.៥ ក្នុងករណីមានអាសនៈនៅសល់ គជប ត្រូវបន្តបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមការគណនាដូចខាងក្រោម ៖

៤.១.៥.១ ត្រូវកំណត់ជាដំបូងនូវមធ្យមភាគ របស់គណបក្សនយោបាយនីមួយៗ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយ

ចែកនឹងចំនួនអាសនៈបឋម ដែលគណបក្សនយោបាយនីមួយៗបាន ទទួល បន្ទាប់ពីការគណនាក្នុងជំហានទី ២ បូកនឹងលេខនិមិត្តចំនួនមួយ តាមរូបមន្តដូចខាងក្រោម ៖

$$\text{ម}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ}_{\text{ទ}}+1}$$

(លេខ ១ ជាលេខនិមិត្ត)

ក្នុងនោះ ៖

- $\text{ម}_{\text{ធ}}$ តាងឱ្យមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ។
- $\text{ស}_{\text{ប}}$ តាងឱ្យសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។
- $\text{អ}_{\text{ទ}}$ តាងឱ្យចំនួនអាសនៈបឋម ដែលគណបក្សនយោបាយនីមួយៗ ទទួលបាន បន្ទាប់ពីការបែងចែកលើកទី១ ។

៨.១.៥.២ ក្នុងការគណនារកមធ្យមភាគ របស់គណបក្សនយោបាយ នីមួយៗ ប្រសិនបើលេខចែកមិនដាច់ ត្រូវបន្តចែកដល់ចំនួន ទសភាគពីរ(២) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់រកគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

៨.១.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗរួច ហើយ ត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុតត្រូវទទួលបានអាសនៈមួយ(១) ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈលើកទី២**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល

តាមការបែងចែកអាសនៈលើកទី១ យើងបាន ៖

គណបក្ស ក បានទទួលអាសនៈ 0

គណបក្ស ខ បានទទួលអាសនៈ ១

គណបក្ស គ បានទទួលអាសនៈ 0

គណបក្ស ឃ បានទទួលអាសនៈ ២

គណបក្ស ង បានទទួលអាសនៈ ១

គណបក្ស ច បានទទួលអាសនៈ 0

គណបក្ស ឆ បានទទួលអាសនៈ ១

- អាសនៈដែលបានបែងចែកលើកទី១ មាន ៥ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលភូមិភាគ A មាន ៨ អាសនៈ
- អាសនៈនៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | ក | $ម_{ធ}ក$ | = | $\frac{១៨៣}{០+១}$ | = | **១៨៣,០០** |
| គណបក្ស | ខ | $ម_{ធ}ខ$ | = | $\frac{៣៣១}{១+១}$ | = | ១៦៥,៥០ |
| គណបក្ស | គ | $ម_{ធ}គ$ | = | $\frac{៩៨}{០+១}$ | = | ៩៨,០០ |
| គណបក្ស | ឃ | $ម_{ធ}ឃ$ | = | $\frac{៥១២}{២+១}$ | = | ១៧០,៦៦ |
| គណបក្ស | ង | $ម_{ធ}ង$ | = | $\frac{២៨៥}{១+១}$ | = | ១៤២,៥០ |
| គណបក្ស | ច | $ម_{ធ}ច$ | = | $\frac{១០៤}{០+១}$ | = | ១០៤,០០ |
| គណបក្ស | ឆ | $ម_{ធ}ឆ$ | = | $\frac{២៥២}{១+១}$ | = | ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើ គណបក្ស ក មានមធ្យមភាគខ្ពស់ជាងគេគឺ **១៨៣,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះគណបក្ស ក ត្រូវទទួលបានអាសនៈ មួយ (១) ។

៨.១.៦ បន្ទាប់ពីអនុវត្តតាមរូបមន្តជំហានទី៣ អាសនៈចំនួនមួយ (១) ត្រូវបានបែងចែកជាលើកទី២ ទៅឱ្យគណបក្សនយោបាយណា ដែលមានមធ្យមភាគខ្ពស់បំផុត ។

៨.១.៧ ក្នុងករណីមាននៅសល់អាសនៈ គជប ត្រូវបន្តបែងចែកទៀតតាមរូបមន្តជំហានទី៣ ដដែល ។

**ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី៣**

នៅក្នុងមណ្ឌលភូមិភាគ A ដដែល

តាមការបែងចែកអាសនៈលើកទី២ យើងបាន ៖

គណបក្ស ក បានទទួលអាសនៈ ១ (ទើបបានទទួលក្នុងការបែងចែក)

គណបក្ស ខ បានទទួលអាសនៈ ១ ដដែល

គណបក្ស គ បានទទួលអាសនៈ ០ ដដែល

គណបក្ស ឃ បានទទួលអាសនៈ ២ ដដែល

គណបក្ស ង បានទទួលអាសនៈ ១ ដដែល

គណបក្ស ច បានទទួលអាសនៈ ០ ដដែល

គណបក្ស ឆ បានទទួលអាសនៈ ១ ដដែល

- សរុបអាសនៈដែលបានបែងចែកលើកទី១ និងលើកទី២មាន ៦ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលភូមិភាគ **A** មាន ៨ អាសនៈ

ដូចនេះនៅសល់អាសនៈពីរ (២) ទៀត ដែលត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | ក | $ម_{ធ}ក$ | = | $\frac{១៨៣}{១+១}$ | = | ៩១,៥០ |
| គណបក្ស | ខ | $ម_{ធ}ខ$ | = | $\frac{៣៣១}{១+១}$ | = | ១៦៥,៥០ |
| គណបក្ស | គ | $ម_{ធ}គ$ | = | $\frac{៩៨}{០+១}$ | = | ៩៨,០០ |
| គណបក្ស | ឃ | $ម_{ធ}ឃ$ | = | $\frac{៥១២}{២+១}$ | = | **១៧០,៦៦** |
| គណបក្ស | ង | $ម_{ធ}ង$ | = | $\frac{២៨៥}{១+១}$ | = | ១៤២,៥០ |
| គណបក្ស | ច | $ម_{ធ}ច$ | = | $\frac{១០៤}{០+១}$ | = | ១០៤,០០ |
| គណបក្ស | ឆ | $ម_{ធ}ឆ$ | = | $\frac{២៥២}{១+១}$ | = | ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើ គណបក្ស ឃ មានមធ្យមភាគធំជាងគេ **១៧០,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្សនយោបាយ ឃ ត្រូវបានទទួលអាសនៈមួយ(១) នាំឱ្យ ៖

| | | | |
|---|---|---|---|
| គណបក្ស ក | បានទទួលអាសនៈ | ១ | ដដែល |
| គណបក្ស ខ | បានទទួលអាសនៈ | ១ | ដដែល |
| គណបក្ស គ | បានទទួលអាសនៈ | ០ | ដដែល |
| គណបក្ស ឃ | បានទទួលអាសនៈ | ៣ | (ទើបទទួលបន្ថែម ១ អាសនៈ) |
| គណបក្ស ង | បានទទួលអាសនៈ | ១ | ដដែល |
| គណបក្ស ច | បានទទួលអាសនៈ | ០ | ដដែល |
| គណបក្ស ឆ | បានទទួលអាសនៈ | ១ | ដដែល |
| | សរុប = ប្រាំពីរ (៧) អាសនៈ | | |

៤.១.៨ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ ហើយបន្តបែងចែកតាមរបៀបនេះម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈដែលនៅសល់ ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈបន្ត**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល

បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួនមួយ (១)ទៀត ដែលត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន ៖

| | | | |
|---|---|---|---|
| គណបក្ស ក | $ម_{ធ}ក$ | $= \frac{១៨៣}{១+១}$ | = ៩១,៥០ |
| គណបក្ស ខ | $ម_{ធ}ខ$ | $= \frac{៣៣១}{១+១}$ | = **១៦៥,៥០** |
| គណបក្ស គ | $ម_{ធ}គ$ | $= \frac{៩៨}{០+១}$ | = ៩៨,០០ |
| គណបក្ស ឃ | $ម_{ធ}ឃ$ | $= \frac{៥១២}{៣+១}$ | = ១២៨,០០ |
| គណបក្ស ង | $ម_{ធ}ង$ | $= \frac{២៨៥}{១+១}$ | = ១៤២,៥០ |
| គណបក្ស ច | $ម_{ធ}ច$ | $= \frac{១០៩}{០+១}$ | = ១០៩,០០ |
| គណបក្ស ឆ | $ម_{ធ}ឆ$ | $= \frac{២៥២}{១+១}$ | = ១២៦,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើឃើញថា គណបក្ស **ខ** មានមធ្យមភាគធំជាងគេ **១៦៥,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ គណបក្ស **ខ** ត្រូវបានទទួលអាសនៈមួយ (១) ដែលនៅសល់ចុងក្រោយនេះ ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលភូមិភាគ **A** យើងបាន ៖

គណបក្ស ក បានទទួលអាសនៈ ១

គណបក្ស ខ បានទទួលអាសនៈ ២

គណបក្ស ឃ បានទទួលអាសនៈ ៣

គណបក្ស ង បានទទួលអាសនៈ ១

គណបក្ស ឆ បានទទួលអាសនៈ ១

គណបក្ស គ និង ច ពុំបានទទួលអាសនៈ

សរុប = ប្រាំបី (៨) អាសនៈ

៩.២ ក្នុងករណី ការបែងចែកអាសនៈតាមជំហានទី២ ពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គជប ត្រូវបន្តបែងចែក ដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈ ។

**<u>ឧទាហរណ៍</u>**

**នៅក្នុងមណ្ឌលបោះឆ្នោតភូមិភាគ B មាន ៖**

- គណបក្សនយោបាយមានចំនួន = ៥
- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ៨៤៦ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៣ អាសនៈ
- កូតា $ក_{ត}$ = ២៨២

| គណបក្ស | $ស_{ស}$ | $អ_{ទ}$ ១ លើកទី១ | $ម_{ធ}$ ១ | $អ_{ទ}$ ២ លើកទី២ | $ម_{ធ}$ ២ | $អ_{ទ}$ ៣ លើកទី៣ | $ម_{ធ}$ ៣ | $អ_{ទ}$ ៤ លើកទី៤ |
|---|---|---|---|---|---|---|---|---|
| **ក** | ១៤៧ | ០ | ១៤៧ / ០+១ | ០ | ១៤៧ / ០+១ | ០ | ១៤៧ / ០+១ | ០ |
| **ខ** | ២០៣ | ០ | ២០៣ / ០+១ | ១ | ២០៣ / ១+១ | ០ | ២០៣ / ១+១ | ០ |
| **គ** | ១៨៤ | ០ | ១៨៤ / ០+១ | ០ | ១៨៤ / ០+១ | ០ | ១៨៤ / ០+១ | ១ |
| **ឃ** | ១៩៥ | ០ | ១៩៥ / ០+១ | ០ | ១៩៥ / ០+១ | ១ | ១៩៥ / ១+១ | ០ |
| **ង** | ១១៧ | ០ | ១១៧ / ០+១ | ០ | ១១៧ / ០+១ | ០ | ១១៧ / ០+១ | ០ |

ករណីនេះអាចកើតមានក្នុងមណ្ឌលភូមិភាគណា ដែលគណបក្សនយោបាយឈរឈ្មោះមានចំនួនសន្លឹកឆ្នោតបានការប្រហាក់ប្រហែលគ្នា ។

តាមតារាងឧទាហរណ៍ខាងលើ ៖

- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ
- អ$_{ទ}$១ តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ដែលក្នុងនោះពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ។
- ម$_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស ខ មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$២ តាងឱ្យអាសនៈ ដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី២ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅគណបក្ស ខ ។
- ម$_{ធ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស ឃ មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$៣ តាងឱ្យអាសនៈ ដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅគណបក្ស ឃ ។
- ម$_{ធ}$៣ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៣ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស គ មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$៤ តាងឱ្យអាសនៈ ដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៤ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅគណបក្ស គ ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលភូមិភាគ **B** យើងបាន ៖

- គណបក្ស ខ ទទួលបានមួយ (១) អាសនៈ
- គណបក្ស ឃ ទទួលបានមួយ (១) អាសនៈ
- គណបក្ស គ ទទួលបានមួយ (១) អាសនៈ

សរុប = បី (៣) អាសនៈ

**ករណីគណបក្សនយោបាយជាប់ឆ្នោតណាមួយបោះបង់ចោលអាសនៈ ឬអាសនៈនៅទំនេរ**

៥. ក្នុងករណី ដែលគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើនក្នុងព្រឹទ្ធសភា ប៉ុន្តែបានប្រកាសបោះបង់ចោលអាសនៈដែលខ្លួនបានទទួល ឬត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ គជប ត្រូវបែងចែកអាសនៈដែលបោះបង់ចោល ឬនៅទំនេរនោះទៅឱ្យគណបក្សនយោបាយផ្សេងទៀត ដែលមានអាសនៈនៅក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធ ក្នុងអំឡុងពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានលិខិតបោះបង់អាសនៈចោល ឬលិខិតលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយជាផ្លូវការ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

**<u>ជំហានទី១:</u> ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ**

៥.១ ដើម្បីកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ សំរាប់ឱ្យគណបក្សនយោបាយឈ្នះឆ្នោតក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធទទួលបានមួយ (១) អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយ ដែលបានទទួលអាសនៈក្នុងមណ្ឌលភូមិភាគនោះ ដកចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈដែលទំនេរ ឬបោះបង់ចោល តាមរូបមន្ត ៖

$$\text{កំ}_{\text{ត}} = \frac{\text{សំ}_{\text{ប}}}{\text{អំ}_{\text{ប}}}$$

ក្នុងនោះ ៖

- $\text{កំ}_{\text{ត}}$ តាងឱ្យកូតានៃអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលជាផលចែកមិនគិតសំណល់ចែក ។
- $\text{សំ}_{\text{ប}}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប របស់គណបក្សនយោបាយទាំងអស់ដែលបានទទួលអាសនៈក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធ ដកចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយណា ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជី ។
- $\text{អំ}_{\text{ប}}$ តាងឱ្យចំនួនអាសនៈ ដែលបោះបង់ចោល ឬនៅទំនេរ ។

**<u>ឧទាហរណ៍</u> : ការកំណត់កូតា នៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ**

នៅក្នុងមណ្ឌលភូមិភាគ A ដំដែល ៖

គណបក្ស ក បានទទួលអាសនៈ ១

គណបក្ស ខ បានទទួលអាសនៈ ២

គណបក្ស ឃ បានទទួលអាសនៈ ៣

គណបក្ស ង បានទទួលអាសនៈ ១

គណបក្ស ឆ បានទទួលអាសនៈ ១

គណបក្ស គ និង ច ពុំបានទទួលអាសនៈ

- គណបក្សនយោបាយ ខ បានបោះបង់ចោលអាសនៈទាំងពីរ (២) ។
- គណបក្សនយោបាយដែលបានទទួលអាសនៈក្នុងមណ្ឌលភូមិភាគ A មាន ៥ គឺ គណបក្សនយោបាយ ក ខ ឃ ង និង ឆ ។

នៅពេលដែលគណបក្សនយោបាយ ខ បានបោះបង់ចោលអាសនៈរបស់ខ្លួន អាសនៈដែលបោះបង់ចោលនោះត្រូវយកមកបែងចែកឱ្យគណបក្សនយោបាយ ក ឃ ង និង ឆ ដែលមានអាសនៈក្នុងមណ្ឌលភូមិភាគ A រីឯ គណបក្ស គ និង ច ដែលពុំបានទទួលអាសនៈក្នុងមណ្ឌលភូមិភាគនោះ មិនត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈដែលគណបក្ស ខ បានបោះបង់ចោលឡើយ ។

អនុវត្តតាមរូបមន្តក្នុងចំណុច ៥.១ យើងបាន ៖

$$សប_{ប} = (១៨៣+៣៣១+៥១២+២៨៥+២៥២)-៣៣១ = ១.២៣២ \text{ សន្លឹក}$$

$$អប_{ប} = ២ \text{ អាសនៈ}$$

$$កត_{ត} = \frac{សប_{ប}}{អប_{ប}} = \frac{១.២៣២}{២} = ៦១៦$$

កូតាស្មើនឹង ៦១៦ ($កត_{ត}$ = ៦១៦) ។

## ជំហានទី២: ការកំណត់ចំនួនអាសនៈ ដែលបោះបង់ចោល ឬនៅទំនេរលើកទី១

៥.២ ដើម្បីកំណត់ចំនួនដំបូងនៃអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរ ឱ្យទៅគណបក្ស ក ឃ ង និង ឆ ត្រូវយកចំនួនសន្លឹកឆ្នោតបានការ ដែលគណបក្សនីមួយៗបានទទួលមកចែកនឹងកូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ តាមរូបមន្តដូចខាងក្រោម ៖

$$អប_{ទ} = \frac{សប_{ប}}{កត_{ត}}$$

ក្នុងនោះ ៖

- អ$_{ទ}$ តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលគណបក្សនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ។
- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ
- ក$_{ត}$ តាងឱ្យកូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ ដែលបានកំណត់ក្នុងជំហានទី១ ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី១**

នៅក្នុងមណ្ឌលភូមិភាគ A ដដែល

បន្ទាប់ពីអនុវត្តន៍ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោល តាមរូបមន្តក្នុងជំហានទី២ យើងបាន ៖

គណបក្ស ក អ$_{ទ}$ក $= \frac{១៨៣}{៦១៦} =$ ០,២៩

គណបក្ស ឃ អ$_{ទ}$ឃ $= \frac{៥១២}{៦១៦} =$ ០,៨៣

គណបក្ស ង អ$_{ទ}$ង $= \frac{២៨៥}{៦១៦} =$ ០,៤៦

គណបក្ស ឆ អ$_{ទ}$ឆ $= \frac{២៥២}{៦១៦} =$ ០,៤០

តាមការគណនាខាងលើ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោល ឬនៅទំនេរនេះទេ ។

៥.៣ ក្នុងករណីគ្មានអាសនៈនៅសល់សម្រាប់បែងចែកបន្ត បន្ទាប់ពីការបែងចែកលើទី១ តាមរូបមន្តក្នុងជំហានទី២ ចំនួនអាសនៈដែលគណបក្សនយោបាយបានទទួលក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធត្រូវកំណត់យកតែម្តង ។

## <u>ជំហានទី៣:</u> ការកំណត់មធ្យមភាគខ្ពស់បំផុត

៥.៤ ក្នុងករណី បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈដែលមាន ឬនៅសល់នោះត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ខាងក្រោម ។

៥.៨.១ ដើម្បីគណនាករមធ្យមភាគ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនីមួយៗ ចែកនឹងចំនួនអាសនៈ ដែលគណបក្សទាំងនោះបានទទួល បន្ទាប់ពីការបែងចែកលើកទី១ ក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួនមួយ តាមរូបមន្តខាងក្រោម ៖

$$ម៉_{ធ} = \frac{ស_{ប}}{អ៉_{ទ}+១}$$

ក្នុងនោះ ៖

- $ម៉_{ធ}$ តាងឱ្យមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។
- $អ៉_{ទ}+១$ តាងឱ្យចំនួនអាសនៈ ដែលបោះបង់ចោល ឬនៅទំនេរដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី ១ បូកនិងលេខនិមិត្តចំនួនមួយ ។

៥.៨.២ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់គណបក្សនយោបាយនីមួយៗ ហើយត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានធម្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត នឹងត្រូវទទួលបានអាសនៈមួយ (១) ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី២**

បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តក្នុងជំហានទី២ ពុំមានគណបក្សណាមួយទទួលអាសនៈដែលត្រូវបានបោះបង់ចោលទេ ។

បន្ទាប់ពីអនុវត្តតាមរូបមនមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

$$\text{គណបក្ស ក} \quad ម៉_{ធ}ក = \frac{១៨៣}{០+១} = ១៨៣,០០$$

$$\text{គណបក្ស ឃ} \quad ម៉_{ធ}ឃ = \frac{៥១២}{០+១} = ៥១២,០០$$

$$\text{គណបក្ស ង} \quad ម៉_{ធ}ង = \frac{២៨៥}{០+១} = ២៨៥,០០$$

$$\text{គណបក្ស ឆ} \quad ម៉_{ធ}ឆ = \frac{២៥២}{០+១} = ២៥២,០០$$

តាមការប្រៀបធៀបមធ្យមភាគ របស់គណបក្សនយោបាយទាំងបួនខាងលើ គណបក្ស ឃ មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្ស ឃ ត្រូវទទួលបានអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរចំនួនមួយ(១) ។

៥.៤.៣ ប្រសិនបើនៅមានសល់អាសនៈ បន្ទាប់ពីការបែងចែកលើកទី២ អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែក ម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ តាមរូបមន្តក្នុងជំហានទី៣ដដែល ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី៣**
បន្ទាប់ពីការបែងចែកលើកទី២ នូវអាសនៈដែលត្រូវបានបោះបង់ចោល នៅមានសល់អាសនៈមួយ(១)ទៀត ត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

គណបក្ស ក $ម៉_{ធ}ក = \frac{១៨៣}{០+១} = ១៨៣,០០$

គណបក្ស ឃ $ម៉_{ធ}ឃ = \frac{៥១២}{១+១} = ២៥៦,០០$

គណបក្ស ង $ម៉_{ធ}ង = \frac{២៨៥}{០+១} = ២៨៥,០០$

គណបក្ស ឆ $ម៉_{ធ}ឆ = \frac{២៥២}{០+១} = ២៥២,០០$

តាមការប្រៀបធៀបមធ្យមភាគ របស់គណបក្សនយោបាយទាំងបួនខាងលើ គណបក្ស ង មានមធ្យមភាគធំជាងគេគឺ **២៨៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្ស ង ត្រូវទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោលចំនួនមួយ(១) ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលភូមិភាគ **A** ៖

គណបក្ស ក បានទទួលអាសនៈ ១

គណបក្ស ឃ បានទទួលអាសនៈ ៤

គណបក្ស ង បានទទួលអាសនៈ ២

គណបក្ស ឆ បានទទួលអាសនៈ ១

សរុប = ប្រាំបី (៨) អាសនៈ

**ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន**

៦. ក្នុងករណីដែលការគណនាតាមរូបមន្តបែងចែកអាសនៈដូចមានចែងក្រោមចំណុច ៥.១.៥ និង ៥.៣ នៃឧបសម្ព័ន្ធនេះមានលទ្ធផលមធ្យមភាគស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម ៖

៦.១ ក្នុងករណីអាសនៈមាននៅសល់តែមួយគត់ ហើយគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុត (ចែកដល់ចំនួនទសភាគ) ស្មើគ្នា អាសនៈដែលនៅសល់នោះ ត្រូវផ្តល់ជូនទៅគណបក្សនយោបាយណា ដែលមានចំនួនសន្លឹកឆ្នោតបានការច្រើនជាងគេ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលភូមិភាគ C មាន ៖

- គណបក្សនយោបាយចំនួន = ៦
- សន្លឹកឆ្នោតបានការសរុប $ស_ស$ = ៩៦៤ សន្លឹក
- អាសនៈសរុប $អ_ស$ = ៦ អាសនៈ
- កូតា $ក_ត$ = ១៦០

| គណបក្ស | $ស_ប$ | $អ_ទ១$ លើកទី១ | $ម_ធ១$ | $អ_ទ២$ លើកទី២ | $ម_ធ២$ | $អ_ទ៣$ លើកទី៣ |
|---|---|---|---|---|---|---|
| ក | ១៧២ | ១ | ១៧២ / (១+១) = ៨៦,០០ | ០ | ១៧២ / (១+១) = ៨៦,០០ | ០ |
| ខ | ៨៤ | ០ | ៨៤ / (០+១) = ៨៤,០០ | ០ | ៨៤ / (០+១) = ៨៤,០០ | ០ |
| គ | ៣៧៤ | ២ | ៣៧៤ / (២+១) = ១២៤,៦៦ | ១ | ៣៧៤ / (៣+១) = ៩៣,៥០ | ១ |
| ឃ | ៧១ | ០ | ៧១ / (០+១) = ៧១,០០ | ០ | ៧១ / (០+១) = ៧១,០០ | ០ |
| ង | ១៨៧ | ១ | ១៨៧ / (១+១) = ៩៣,៥០ | ០ | ១៨៧ / (១+១) = ៩៣,៥០ | ០ |
| ច | ៧៦ | ០ | ៧៦ / (០+១) = ៧៦,០០ | ០ | ៧៦ / (០+១) = ៧៦,០០ | ០ |

- សប  តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។
- អ១  តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី១ ។
- ម១  តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១របស់គណបក្ស នីមួយៗ ដែលក្នុងនោះគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **១២៩,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ២  តាងឱ្យចំនួនអាសនៈដែលគណបក្សនីមួយៗទទួលបាន បន្ទាប់ពីការបែងចែកលើកទី២ ដែលក្នុងនោះគណបក្ស **គ** ត្រូវបានទទួលអាសនៈមួយ(១) បន្ថែមទៀត ។
- ម២  តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស គ និង ង មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **៩៣,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ប៉ុន្តែ ដោយគណបក្ស គ មានសន្លឹកឆ្នោតបានការចំនួន ៣៧៤ សន្លឹក ច្រើនជាងគណបក្ស ង ដែលមានតែ ១៨៧ សន្លឹក ដូចនេះអាសនៈដែលនៅសល់មួយ (១) ចុងក្រោយត្រូវផ្តល់ជូនទៅគណបក្ស គ ។

លទ្ធផលសំរេចគឺ ៖

- គណបក្សនយោបាយ ក ទទួលបានមួយ (១) អាសនៈ
- គណបក្សនយោបាយ គ ទទួលបានបួន (៤) អាសនៈ
- គណបក្សនយោបាយ ង ទទួលបានមួយ (១) អាសនៈ
- គណបក្សនយោបាយ ខ ឃ និង ច ពុំបានទទួលអាសនៈ ។

សរុប = ប្រាំមួយ (៦) អាសនៈ ។

៦.២ ក្នុងករណីចំនួនអាសនៈនៅសល់ត្រូវបែងចែកបន្តមានចំនួនស្មើគ្នា ឬលើស បើប្រៀបធៀបទៅនឹងចំនួនគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នានោះ គជប ត្រូវបែងចែកអាសនៈដែលនៅសល់ឱ្យទៅគណបក្សនយោបាយទាំងនោះម្នាក់មួយអាសនៈ (១) ។ ហើយបើមាននៅសល់អាសនៈទៀត ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល ។

**<u>ឧទាហរណ៍</u>**

នៅក្នុងមណ្ឌលភូមិភាគ D មាន ៖

- គណបក្សនយោបាយចំនួន ៧
- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ២.៣១៩ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៩ អាសនៈ
- កូតា $ក_{ត}$ = ២៥៧

| គណបក្ស | $ស_{ប}$ | $អ_{ទ}$១ លើកទី១ | $ម_{ធ}$១ | $អ_{ទ}$២ លើកទី២ | $ម_{ធ}$២ | $អ_{ទ}$៣ លើកទី៣ |
|---|---|---|---|---|---|---|
| **ក** | ៥០១ | ១ | ៥០១ / (១+១) = ២៥០,៥០ | ១ | ៥០១ / (២+១) = ១៦៧,០០ | ០ |
| **ខ** | ២៦១ | ១ | ២៦១ / (១+១) = ១៣០,៥០ | ០ | ២៦១ / (១+១) = ១៣០,៥០ | ០ |
| **គ** | ២០២ | ០ | ២០២ / (០+១) = ២០២,០០ | ០ | ២០២ / (០+១) = ២០២,០០ | ១ |
| **ឃ** | ២៥៩ | ១ | ២៥៩ / (១+១) = ១២៩,៥០ | ០ | ២៥៩ / (១+១) = ១២៩,៥០ | ០ |
| **ង** | ៥១ | ០ | ៥១ / (០+១) = ៥១,០០ | ០ | ៥១ / (០+១) = ៥១,០០ | ០ |
| **ច** | ១០០២ | ៣ | ១០០២ / (៣+១) = ២៥០,៥០ | ១ | ១០០២ / (៤+១) = ២០០,៤០ | ០ |
| **ឆ** | ៤៣ | ០ | ៤៣ / (០+១) = ៤៣,០០ | ០ | ៤៣ / (០+១) = ៤៣,០០ | ០ |

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។
- $អ_{ទ}$១ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។
- $ម_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស ក និង ច មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **២៥០,៥០**

ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះអនុវត្តតាមចំណុច ៦.២ គជប ត្រូវបែងចែកអាសនៈឱ្យទៅគណបក្ស ក មួយ (១) អាសនៈ និងគណបក្ស ច មួយ (១) អាសនៈ ។

- អ$_{ទ}$២ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះគណបក្សនយោបាយ ក និង ច ត្រូវទទួលបានអាសនៈម្នាក់មួយ(១) អាសនៈ ។
- ម$_{ធ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស គ មានមធ្យមភាគធំជាងគេគឺ **២០២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ$_{ទ}$៣ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈដែលនៅសល់មួយចុងក្រោយ ត្រូវផ្តល់ជូនទៅគណបក្ស គ ។

លទ្ធផលសំរេចក្នុងមណ្ឌលភូមិភាគ **D** គឺ ៖

- គណបក្សនយោបាយ ក ទទួលបានពីរ(២)អាសនៈ
- គណបក្សនយោបាយ ខ ទទួលបានមួយ(១)អាសនៈ
- គណបក្សនយោបាយ គ ទទួលបានមួយ(១)អាសនៈ
- គណបក្សនយោបាយ ឃ ទទួលបានមួយ(១)អាសនៈ
- គណបក្សនយោបាយ ច ទទួលបានបួន(៤)អាសនៈ
- គណបក្សនយោបាយ ង និង ច ពុំបានទទួលអាសនៈ

សរុប = ប្រាំបួន (៩) អាសនៈ ។

**ករណីគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងចំនួនសន្លឹកឆ្នោតបានការស្មើគ្នា ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ**

៧. ក្នុងករណីលទ្ធផលនៃការគណនារកមធ្យមភាគខ្ពស់បំផុតស្មើគ្នា ហើយចំនួនសន្លឹកឆ្នោតបានការក៏ស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែកនេះ គជប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់យកគណបក្សនយោបាយណាដែលត្រូវបានទទួលអាសនៈ ដែលនៅសល់តែមួយគត់ចុងក្រោយ ។

៧.១ ករណីនេះ គជប ត្រូវប្រគល់ភារកិច្ចឱ្យនាយកដ្ឋានប្រតិបត្តិការចាត់ចែងរៀបចំពិធីចាប់ឆ្នោតជាសាធារណៈ ។

៧.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើ នៅក្រោយពេលបញ្ចប់ការគណនាបែងចែកអាសនៈតាមមណ្ឌលភូមិភាគទូទាំងប្រទេសនៅ គជប ។ គជប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីចាប់ឆ្នោតជាសាធារណៈ ហើយត្រូវអញ្ជើញ ៖

- តំណាងផ្លូវការនៃគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត
- អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ ។

៧.៣ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- នាយកដ្ឋានប្រតិបត្តិការត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នា នូវឈ្មោះនៃគណបក្សនយោបាយទាំងឡាយដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ ។ តួអក្សរឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទទំហំ និងពណ៌ដូចគ្នា ។ ក្រដាសដែលសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយរួចហើយ ត្រូវបត់ជាផ្នត់ដូចគ្នាដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិត ។
- មន្ត្រីទទួលខុសត្រូវការចាប់ឆ្នោត ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈមុននឹងដាក់សំបុត្រសន្លឹកឆ្នោតទៅក្នុងហិបនោះ និងបិទគំរប ។
- មន្ត្រីទទួលខុសត្រូវការចាប់ឆ្នោតត្រូវក្រឡុកហិបឆ្នោត រួចហើយលើកហិបឆ្នោតនោះទៅដាក់លើតុមួយខ្ពស់ ។
- ត្រូវនិមន្តព្រះសង្ឃ ឬមន្ត្រីចូលនិវត្តន៍ ឬព្រឹទ្ធាចារ្យ ចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបឆ្នោតរួចប្រគល់ជូនទៅប្រធាន ឬតំណាង គជប ។
- ប្រធាន ឬតំណាង គជប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រសន្លឹកឆ្នោតនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលឈ្នះឆ្នោត និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលបានចូលរួមក្នុងពិធីចាប់ឆ្នោត បានឃើញច្បាស់ថា ឈ្មោះគណបក្សនយោបាយដែលបានប្រកាសដូចគ្នានឹងឈ្មោះគណបក្សនយោបាយដែលបានសរសេរ ឬបោះពុម្ពលើសន្លឹកឆ្នោតនោះប្រាកដមែន ។

៧.៤ នាយកដ្ឋានប្រតិបត្តិការត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពី កាលបរិច្ឆេទ ទីកន្លែង តំណាងចូលរួម (គជប តំណាងគណបក្សនយោបាយដែលបានចូលរួមបោះឆ្នោតក្នុងមណ្ឌល អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ...) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

៧.៤.១ កំណត់ហេតុត្រូវចុះហត្ថលេខាដោយ ៖
- អ្នកធ្វើកំណត់ហេតុ
- ប្រធាន ឬតំណាង គជប
- តំណាងគណបក្សនយោបាយដែលមានលទ្ធផល គណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា ។

៧.៤.២ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់តាមតម្រូវការដូចខាងក្រោមដើម្បី ៖
- ផ្ញើជូនគ្រប់គណបក្សនយោបាយ ដែលបានចូលរួមបោះឆ្នោត
- រក្សាទុកជាឯកសារ ។

**<u>ឧទាហរណ៍</u> : ការចាប់ឆ្នោតកំណត់យកគណបក្សណាមួយដែលត្រូវទទួលបានអាសនៈ** នៅក្នុងមណ្ឌលភូមិភាគ E ៖
- គណបក្សនយោបាយ មាន ៥
- គណបក្ស ក មានសន្លឹកឆ្នោតបានការ ស$_{ប}$ក = ៩១ សន្លឹក
- គណបក្ស ខ មានសន្លឹកឆ្នោតបានការ ស$_{ប}$ខ = ២៧៩ សន្លឹក
- គណបក្ស គ មានសន្លឹកឆ្នោតបានការ ស$_{ប}$គ = ១៨៤ សន្លឹក
- គណបក្ស ឃ មានសន្លឹកឆ្នោតបានការ ស$_{ប}$ឃ = ២៥៣ សន្លឹក
- គណបក្ស ង មានសន្លឹកឆ្នោតបានការ ស$_{ប}$ង = ២៧៩ សន្លឹក
- សន្លឹកឆ្នោតបានការសរុប ស$_{ស}$ = ១.០៥០ សន្លឹក
- អាសនៈសរុប អ$_{ស}$ = ៥ អាសនៈ
- កូតា ក$_{ត}$ = ២១០

| គណបក្ស | ស$_{ប}$ | អ$_{ទ}$១ លើកទី១ | ម$_{ធ}$១ | អ$_{ទ}$២ លើកទី២ | ម$_{ធ}$២ | អ$_{ទ}$៣ លើកទី៣ |
|---|---|---|---|---|---|---|
| **ក** | ៩១ | 0 | ៩១ / (0+១) = ៩១,00 | 0 | ៩១ / (0+១) = ៩១,00 | 0 |
| **ខ** | ២៧៩ | ១ | ២៧៩ / (១+១) = ១៣៩,៥0 | 0 | ២៧៩ / (១+១) = ១៣៩,៥0 | ១ ? |
| **គ** | ១៨៤ | 0 | ១៨៤ / (0+១) = ១៨៤,00 | ១ | ១៨៤ / (១+១) = ៧៤,00 | 0 |
| **ឃ** | ២៥៣ | ១ | ២៥៣ / (១+១) = ១២៦,៥0 | 0 | ២៥៣ / (១+១) = ១២៦,៥0 | 0 |
| **ង** | ២៧៩ | ១ | ២៧៩ / (១+១) = ១៣៩,៥0 | 0 | ២៧៩ / (១+១) = ១៣៩,៥0 | ១ ? |

- សប តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។
- អទ១ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ ។
- មធ១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស គ មានមធ្យមភាគធំជាងគេគឺ **១៩៨,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អទ២ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះគណបក្ស គ ត្រូវទទួលបានអាសនៈមួយ(១) ។
- មធ២ គណបក្សនយោបាយ ខ និង ង មានមធ្យមភាគធំជាងគេស្មើ គ្នាគឺ **១៣៩,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត និងមានចំនួនសន្លឹកបានការសរុបស្មើគ្នា ដែលតម្រូវឱ្យធ្វើការចាប់ឆ្នោត ។

**ការស្រង់បញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា**

៨. បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗបានទទួលរួចហើយ គជប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលភូមិភាគនីមួយៗតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

៨.១ ឈ្មោះបេក្ខជនជាប់ឆ្នោតទាំងអស់ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្ស ដែលជាប់ឆ្នោតទៅតាមចំនួនអាសនៈដែលគណបក្សជាប់ឆ្នោតនីមួយៗ បានទទួល ។

៨.២ ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀងពីខ្ពស់មកទាប តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

៨.៣ ក្នុងករណីនៅមណ្ឌលបោះឆ្នោតភូមិភាគមួយ មានគណបក្សនយោបាយតែមួយគត់ ដែលត្រូវបានអនុម័តយល់ព្រមឱ្យចុះបញ្ជី ឬមានគណបក្សនយោបាយតែមួយគត់ ដែលជាប់ឆ្នោតនោះ ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយតែមួយនោះ តាមលំដាប់លេខរៀងពីខ្ពស់មកទាបរហូតដល់គ្រប់អាសនៈដែលមានក្នុងមណ្ឌលបោះឆ្នោតភូមិភាគនោះ ។

៨.៤ ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃគណបក្សនយោបាយមានអ្នកជាប់ឆ្នោតណាមួយទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកព្រឹទ្ធសភា បេក្ខជន

ដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយនោះត្រូវបានប្រកាសថា ជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភារបស់សាមីគណបក្សនយោបាយ ។

៨.៥ ក្នុងករណីដែលគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ ដោយមូលហេតុដូចមានចែងក្នុងចំណុច ៨.៤ គជប ត្រូវលើកសំណើជាលាយលក្ខអក្សរ ទៅគណបក្សនយោបាយពាក់ព័ន្ធ ។ សាមីគណបក្សនយោបាយនោះ ត្រូវផ្ញើឈ្មោះបេក្ខជនបន្ថែមក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសំណើ ។

៨.៥.១ បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៣៣ថ្មី (ប៉ុន្តែបេក្ខជនត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ) ៣៤ថ្មី ៣៥ថ្មី ៣៦ថ្មី ៣៨ថ្មី ៤១ថ្មី ៤២ថ្មី និង ៤៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៨.៥.២ ក្នុងករណី គណបក្សនយោបាយណាមួយមិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលំអរការខ្វះខាតដែលស្នើឡើងដោយ គជប ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈទំនេរបាននោះ គជប ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

៨.៥.២.១ ក្នុងករណីនេះ គជប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃបោះបង់ចោលជាផ្លូវការ ដោយអនុវត្តតាមវិធីគណនាដូចមានចែងក្រោមចំណុច **៥** ។

៨.៦ ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងប្រការ ៤ ៥ និង ៦ គជប អាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតភូមិភាគនីមួយៗ ជាបន្តបន្ទាប់ ។

៨.៧ មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គជប ត្រូវធ្វើរបាយការណ៍ជូនគ្រប់គណបក្សនយោបាយដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ពចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ៕

# ឧបសម្ព័ន្ធ
# ស្តីពី
# ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ

## សេចក្តីផ្តើម

ប្រទេសដែលមាននិន្នាការប្រកាន់លទ្ធិប្រជាធិបតេយ្យបច្ចុប្បន្នតែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតទាំងឡាយប្រព្រឹត្តទៅដោយ សេរី ត្រឹមត្រូវ យុត្តិធម៌ និងស្របទៅតាមលទ្ធិប្រជាធិតេយ្យពិតប្រាកដ ។

ដើម្បីសម្រេចនូវគោលដៅដ៏ធំធេងនេះបាន យើងទាំងអស់គ្នា ជាប្រជាពលរដ្ឋ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ ត្រូវតែរួបរួមគ្នាគោរពឱ្យបានខ្ជាប់ខ្ជួន ច្បាប់បោះឆ្នោត បទបញ្ជា នីតិវិធីបោះឆ្នោត លិខិតបទដ្ឋានពាក់ព័ន្ធនានា និងក្រមសីលធម៌ ។

ឆ្លងតាមបទពិសោធន៍ជាច្រើនកន្លងមក ក្រមសីលធម៌ជាវិធានមួយដ៏មានសារៈសំខាន់ និងមានប្រសិទ្ធភាពបំផុតសម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយអនុវត្តក្នុងអំឡុងពេលបោះឆ្នោតទាំងមូល ហើយតាមរយៈការអនុវត្តនេះ ធ្វើឱ្យដំណើរការបោះឆ្នោតទទួលបានលទ្ធផលល្អប្រសើរ ។

ក្រមសីលធម៌នេះ រៀបចំតាក់តែងឡើងស្របទៅនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធីរបស់ គជប និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ។ ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលស្ថាពរមានដំណើរប្រព្រឹត្តទៅដោយរលូន និងប្រសិទ្ធភាព ។ ការប្រតិបត្តិក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ_អន្តរជាតិ និងគណបក្សនយោបាយជាដៃគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នា និងគ្នា ក្នុងការសហការបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន ។ ការគោរពក្រមសីលធម៌បោះឆ្នោតបានល្អ ជាកត្តាកាត់បន្ថយបាននូវហិង្សាជម្លោះ ការរើសអើង ការបែងចែក ចំពោះអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម ។ ការគោរពក្រមសីលធម៌បានល្អ ជាកត្តាលើកស្ទួយកិត្យានុភាពជាតិយើង លើឆាកអន្តរជាតិលើវិស័យបោះឆ្នោត ក្នុងការបង្ហាញឱ្យគេមើលឃើញពីការគោរពច្បាប់ ការឯកភាពជាតិ ការទុកចិត្តគ្នាទៅវិញទៅមករវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងស្ថាប័នទាំងអស់ក្នុងសង្គម ។

ប្រសិនបើយើងសម្រេចបាននូវគោលដៅដ៏ល្អប្រសើរខាងលើនេះ នោះលទ្ធផលនៃការបោះឆ្នោតពិតជានឹងអាចទទួលស្គាល់ពីសំណាក់អ្នកបោះឆ្នោត ប្រជាពលរដ្ឋ បេក្ខជន គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ_អន្តរជាតិ អង្គការសង្គមស៊ីវិល ប្រទេសផ្តល់ជំនួយ និងមជ្ឈដ្ឋាននានា នៅលើពិភពលោកទាំងមូល ។

# ផ្នែកទី ១

# សិទ្ធិរបស់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ

**ប្រការ ១** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយមានសិទ្ធិពេញលេញ និងស្មើភាពចូលរួមក្នុងការបោះឆ្នោត ដូចជា ៖

១.១ សិទ្ធិចុះបញ្ជីគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោត ។

១.២ សិទ្ធិឃោសនាបោះឆ្នោត ។

១.៣ សិទ្ធិសង្កេតមើលដំណើរការបោះឆ្នោត ។

១.៤ សិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ។

១.៥ សិទ្ធិទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

**ប្រការ ២** តំណាងគណបក្សនយោបាយមានសិទ្ធិមានវត្តមាននៅតាមទីកន្លែងចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយអាជ្ញាធរបោះឆ្នោត ។

**ប្រការ ៣** តំណាងគណបក្សនយោបាយ មានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់ ។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គជប ។

**ប្រការ ៤** តំណាងគណបក្សនយោបាយ មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គជប ។

**ប្រការ ៥** តំណាងគណបក្សនយោបាយ មានសិទ្ធិសុំផ្លាស់ប្តូរតំណាងពេញសិទ្ធិ និងបម្រុងរបស់ខ្លួន ទៅតាមមូលហេតុសមស្រប និងទៅតាមកាលកំណត់ចុងក្រោយរបស់ គជប ។

**ប្រការ ៦** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរបោះឆ្នោតទាំងមូល ។

**ប្រការ** ៧ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយទាំងអស់ មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរីក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស ។

**ប្រការ** ៨ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មានឱកាសស្មើភាពគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន របស់រដ្ឋតាមការរៀបចំរបស់ គជប ក្នុងពេលយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។

**ប្រការ** ៩ គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់អាចធ្វើការផ្សព្វផ្សាយព័ត៌មាន ឬគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតាមការជួលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ដែលត្រូវបើកចំហរដោយស្មើភាពចំពោះមុខគណបក្សនយោបាយ ។

**ប្រការ** ១០ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅតាមបទបញ្ជា និងនីតិវិធី គជប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាងបញ្ជាក់ថា អំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធី របស់ គជប ក្នុងដំណើររៀបចំការបោះឆ្នោត ។

**ប្រការ** ១១ គណបក្សនយោបាយ បេក្ខជន មានសិទ្ធិសុំជួលមណ្ឌលកីឡា ឧទ្យាន សាធារណៈ សាលសាធារណៈទៅអ្នកគ្រប់គ្រង ដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ ។

**ប្រការ** ១២ គណបក្សនយោបាយ បេក្ខជនមានសិទ្ធិធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅអាជ្ញាធររៀបចំការបោះឆ្នោតពាក់ព័ន្ធ ។

**ប្រការ** ១៣ គណបក្សនយោបាយ មានសិទ្ធិប្តឹងតវ៉ាពីការសម្រេចបដិសេធរបស់ គជប មិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយបេក្ខជនឈរឈ្មោះបោះឆ្នោត ។

# ផ្នែកទី ២
# គោលការណ៍ប្រតិបត្តិ

**ប្រការ** ១៤ ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។

**ប្រការ** ១៥ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ_អន្តរជាតិ និងផ្តល់ព័ត៌មានគ្នាទៅវិញទៅមក ។

**ប្រការ** ១៦ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវប្រើកម្លាំង អំពើហិង្សា ឬបំភិតបំភ័យដល់អ្នកបោះឆ្នោត ។

**ប្រការ** ១៧ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវញុះញង់ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃឡើយ ។

**ប្រការ** ១៨ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយមួយដែលខ្លួនចូលចិត្ត ។

**ប្រការ** ១៩ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវប្រើកម្លាំង ឬអំពើហិង្សាណាមួយដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

**ប្រការ** ២០ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវរារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គជប ។

**ប្រការ** ២១ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវប្រើកម្លាំង អំពើហិង្សា បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**ប្រការ** ២២ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវបង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោត មិនអាចប្រព្រឹត្តទៅបាន ។

**ប្រការ** ២៣ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវបង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត ។

**ប្រការ** ២៤ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

**ប្រការ** ២៥ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ឬដោយមធ្យោបាយណាមួយឡើយ ។

**ប្រការ** ២៦ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវបង្ខាប់បញ្ជា ឬល្បួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយ តាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

**ប្រការ** ២៧ មិនត្រូវធ្វើឱ្យរបើកហិបឆ្នោតដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

**ប្រការ** ២៨ គណបក្សនយោបាយ និងបេក្ខជន ត្រូវគោរពគោលការណ៍ឃោសនាបោះឆ្នោត ដែលមានរយៈពេលម្ភៃមួយ (២១)ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ម្ភៃបួន(២៤) ម៉ោងមុនថ្ងៃបោះឆ្នោត ។

**ប្រការ** ២៩ គ្រប់សកម្មភាពឃោសនាដោយបំពងសម្លេងរបស់គណបក្សនយោបាយ បេក្ខជន ត្រូវឈប់សម្រាកចាប់ពីម៉ោង ១២ ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល និងចាប់ពីម៉ោង ១០យប់រហូតដល់ម៉ោង ៦ព្រឹក ។

**ប្រការ** ៣០ ក្នុងពេលឃោសនាបោះឆ្នោតគ្រប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ សមាជិក និងអ្នកគាំទ្រទាំងអស់ ត្រូវគោរពបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង

ច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធី គជប ក្រមសីលធម៌ គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣១** ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គ្រប់គណបក្សនយោបាយ បេក្ខជន មិនត្រូវប្រើអំពើហិង្សាអំពើរំលោភ ប្រើពាក្យសម្ដីប្រមាថមើលងាយ មិនត្រូវសាបព្រួសធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**ប្រការ ៣២** គណបក្សនយោបាយ និងបេក្ខជន មិនត្រូវទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើតំណាងគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយនោះទេ ។

**ប្រការ ៣៣** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតឡើយ ។

**ប្រការ ៣៤** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត បោះឆ្នោត រាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោតឡើយ ។

**ប្រការ ៣៥** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយទាំងអស់ ហាមរិះគន់ ឬរើសអើងប្រកាន់បក្សពួក ជាតិសាសន៍ ភេទ ឋានៈក្នុងសង្គមសាសនា និងគ្រប់រូបភាពទាំងអស់ ។

**ប្រការ ៣៦** ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។

**ប្រការ ៣៧** ក្នុងការឃោសនា ការរិះគន់គណបក្សនយោបាយដទៃ ត្រូវឆ្លុះបញ្ចាំងតែទៅលើគោលនយោបាយ កម្មវិធីនយោបាយ និងបទពិសោធន៍ការងារ ។ ត្រូវចៀសវាងដាច់ខាតចំពោះការរិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ ។

**ប្រការ** ៣៨ រាល់សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តប័ណ្ណ រូបភាពបិទផ្សាយទាំងឡាយ និងសម្ភារៈឃោសនាផ្សេងទៀត ត្រូវចៀសវាងដាច់ខាតការប្រើភាសា ឬរូបភាពរំលោភបំពានខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សា ។ ល ។

**ប្រការ** ៣៩ គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន ។

**ប្រការ** ៤០ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អ នូវរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរ ។

**ប្រការ** ៤១ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយមិនត្រូវ ៖

- រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាជនមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀតឡើយ ។

- ប្រើប្រាស់នូវភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំបំភិតបំភ័យណាមួយឡើយ ។

- យល់ព្រមឱ្យដាក់តាំង ឬបង្ហាញ ឬចែកចាយការពិពណ៌នាអំពីការវាយប្រហារ ឬអាវុធនោះឡើយ ។

**ប្រការ** ៤២ គណបក្សនយោបាយ បេក្ខជន មិនត្រូវចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗ លុបលើសំឡេងរបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀតឡើយ ។

**ប្រការ** ៤៣ គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ និងអ្នកគាំទ្រ មិនត្រូវប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ឬព្រះនាមព្រះមហាក្សត្រ ឬព្រះនាមព្រះមហាវីរក្សត្រ ឬផ្លាកសញ្ញា គជបដើម្បីឃោសនារកសម្លេងឆ្នោតឡើយ ។

**ប្រការ ៤៤** គណបក្សនយោបាយ បេក្ខជន មិនត្រូវចម្លងយកសញ្ញាសម្គាល់ របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់បំរើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន ។

**ប្រការ ៤៥** គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទប័ណ្ណ ខិត្តប័ណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗ របស់អ្នកដទៃ ឬគណបក្សនយោបាយដទៃឡើយ ។

**ប្រការ ៤៦** គណបក្សនយោបាយ បេក្ខជន តំណាង និងអ្នកគាំទ្រទាំងអស់ មិនត្រូវបក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយខិត្តប័ណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗ របស់គណបក្សនយោបាយដទៃ ស្ថាប័ននានា ឬអាជ្ញាធរដែនដីឡើយ ។

**ប្រការ ៤៧** គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទបណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាដទៃទៀត ក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយមិនតិចជាង ១០០ម៉ែត្រ និងមិនត្រូវចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈឡើយ ។

**ប្រការ ៤៨** គណបក្សនយោបាយ បេក្ខជន មិនត្រូវទិញសន្លឹកឆ្នោត ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ដើម្បីទទួលបានសំលេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។

**ប្រការ ៤៩** គណបក្សនយោបាយ បេក្ខជន តំណាង និងអ្នកគាំទ្រទាំងអស់ មិនត្រូវប្រើប្រាស់តួនាទីសិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទំលាប់ ដើម្បីបង្ខំ ឬគំរាមគំហែងក្នុងគោលបំណងទទួលបានការគាំទ្រ ។

**ប្រការ ៥០** គណបក្សនយោបាយ បេក្ខជន តំណាង និងអ្នកគាំទ្រទាំងអស់ មិនត្រូវក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោតឡើយ ។

# ឧបសម្ព័ន្ធ
# ស្តីពី
# ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

## I. សេចក្តីផ្តើម

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺជាដំណើរការមួយដែលតម្រូវឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង និងតំណាងរាស្ត្រក្នុងតំណែងប្រើសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព និងគ្រប់មជ្ឈដ្ឋានទាំងអស់ទទួលស្គាល់ អ្នកសង្កេតការណ៍ត្រូវមានជំហរអព្យាក្រឹត មិនលំអៀង និងមិនប្រកាន់បក្សពួក និងមិនជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុម័តក្រមសីលធម៌នេះសម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាក្នុងព្រះរាជាណាចក្រកម្ពុជា ។

## II. ការបកស្រាយ

១. ពាក្យ " **ការបោះឆ្នោត** " និង " **ដំណើរការបោះឆ្នោត** " មានន័យរួមបញ្ចូលទាំងការចុះឈ្មោះបោះឆ្នោត កុំព្យូទ័រកម្មបញ្ជីបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលបណ្តោះអាសន្ន និងបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងករណីខាងលើ ។ ប៉ុន្តែពាក្យនេះ ក៏មានន័យ រួមបញ្ចូលផងដែរនូវសកម្មភាពនានា មុន និងក្រោយថ្ងៃបោះឆ្នោតរបស់ គជប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងរបស់តំណាងគណបក្សនយោបាយ ។

២. ពាក្យ " **អ្នកសង្កេតការណ៍** " ក្នុងន័យនេះ គឺសំដៅតែលើអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិប៉ុណ្ណោះ មិនបានគិតបញ្ចូលអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ឬតំណាងគណបក្សនយោបាយទេ ។

## III. គោលដៅ នៃក្រមសីលធម៌

គោលដៅនៃក្រមសីលធម៌នេះ គឺដើម្បីធានា ៖

១. កិច្ចសង្កេតការណ៍ការបោះឆ្នោត ត្រូវធ្វើឡើងដោយសុច្ចរិត និង តម្លាភាព ។

២. មន្ត្រីបោះឆ្នោត ត្រូវអនុញ្ញាតឱ្យអ្នកសង្កេតការណ៍បំពេញការងារ ដោយពុំមានការជ្រៀតជ្រែកឡើយ ។

## IV. តួនាទី នៃអ្នកសង្កេតការណ៍

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត ។

រាជរដ្ឋាភិបាលកម្ពុជា ត្រូវអញ្ជើញបណ្តាប្រទេស និងអង្គការអន្តរជាតិនានាឱ្យបញ្ជូនតំណាងរបស់ខ្លួនមកសង្កេតការណ៍ការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់ពីបានទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍ដោយឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើសពីនេះទៀតអ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិសង្កេតមើលដំណើរការនៃការបោះឆ្នោតដោយឯករាជ្យ ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធររៀបចំការបោះឆ្នោតកម្ពុជាទៀតផង ។

អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិសង្កេតមើលគ្រប់សកម្មភាព ដែលទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជន ការឃោសនាបោះឆ្នោត ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ ប៉ុន្តែអ្នកសង្កេតការណ៍មិនត្រូវជ្រៀតជ្រែក ឬប៉ុនប៉ងប្រើឥទ្ធិពលរបស់ខ្លួនទៅលើដំណើរការនៃការបោះឆ្នោតឡើយ ។

## V. សិទ្ធិ និង ភារកិច្ចរបស់អ្នកសង្កេតការណ៍

នៅពេលបានទទួលស្គាល់ជាផ្លូវការ និងបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយនឹងមានឯករាជ្យភាព ព្រមទាំងមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

១. អ្នកសង្កេតការណ៍អន្តរជាតិ អាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ ។ អ្នកសង្កេតការណ៍ជាតិ អាចធ្វើដំណើរសង្កេតការណ៍ក្នុងរង្វង់ខេត្ត ក្រុងដែលខ្លួនបានស្នើសុំ ។

២. ក្នុងករណីអ្នកសង្កេតការណ៍មានជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយត្រូវជូនដំណឹងទៅអាជ្ញាធរបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយទាន់ពេលវេលា ។

៣. អមដំណើរគណៈប្រតិភូមន្ត្រីបោះឆ្នោតនៅរាល់ពេលដឹកជញ្ជូនហិបឆ្នោត និងសម្ភារៈបោះឆ្នោតទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៤. សង្កេតការណ៍នូវរាល់ការប្រជុំនៃគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលពាក់ព័ន្ធទៅនឹងបណ្តឹងតវ៉ា បណ្តឹងជំទាស់ និងបណ្តឹងផ្សេងៗទៀត ។

៥. មិនអនុញ្ញាតឱ្យជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ជាមួយនឹងអ្នកបោះឆ្នោត ឬបេក្ខជនណាម្នាក់ឡើយ ។

៦. សង្កេតការណ៍លើលទ្ធផលបោះឆ្នោត នៃការិយាល័យបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៧. ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលផ្លូវការជាមួយនឹងលទ្ធផលបណ្តោះអាសន្នដែលបានកត់ត្រាក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោតនៅថ្ងៃរាប់សន្លឹកឆ្នោត ។

៨. ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។

៩. គោរពការសម្ងាត់នៃការបោះឆ្នោត ។

១០. មានសេរីភាពធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន ។ សេរីភាពនេះ មិនគិតរួមបញ្ចូលនូវការចេញសេចក្តីថ្លែងការណ៍ឯករាជ្យដោយឯកឯងជូនបណ្តាញសារព័ត៌មានពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត និងលទ្ធផលបោះឆ្នោតព្រមទាំងមិនគិតបញ្ចូលនូវអ្វីៗដែលធ្វើទៅតាមឆន្ទៈរបស់ខ្លួននោះទេ ។

១១. មានសេរីភាពក្នុងការជួប ឬនិយាយជាមួយគ្រប់គណបក្សនយោបាយ បេក្ខជន និងមន្ត្រីបោះឆ្នោត ប្រសិនបើកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំង និងគណបក្សនយោបាយណាមួយ ។

១២. ត្រូវគោរពច្បាប់ដែលមានជាធរមាននៅកម្ពុជា និងមិនត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា និងត្រូវទទួលស្គាល់អធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ។

១៣. ត្រូវតែយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី នៃការបោះឆ្នោត ក្នុងករណីមានការរំលោភត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន ។

១៤. ចូលរួមសង្កេតមើលដំណើរការនៃការបោះឆ្នោតទាំងមូល ដែលរួមមានដំណើរការត្រៀមរៀបចំការចុះឈ្មោះអ្នកបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានា នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត ។ អ្នកសង្កេតការណ៍គ្មានសិទ្ធិជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយឡើយ ។

១៥. មានសិទ្ធិចេញចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប៉ុន្តែមិនត្រូវជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោតឡើយ ។ លើសពីនេះទៀតនៅគ្រប់ពេលវេលាចំនួនអ្នកសង្កេតការណ៍ដែលចូលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងពេលតែមួយ ត្រូវបានកំណត់ត្រឹម ៤នាក់យ៉ាងច្រើន ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤នាក់ អ្នកសង្កេតការណ៍ទាំងនោះត្រូវធ្វើការផ្លាស់ប្តូរតាមការកំណត់របស់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១៦. ត្រូវស្ថិតនៅជាអព្យាក្រឹត និងមិនត្រូវប្រកាន់បក្សពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១៧. ពុំមានសិទ្ធិចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោតឡើយ ។ ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្តឹងនេះបាន ។

១៨. ត្រូវបង្ហាញភ័ស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច ដែលបានសាកសួរដល់ខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយអាជ្ញាធររៀបចំការបោះឆ្នោត ដែលមានសមត្ថកិច្ច ។

១៩. មិនត្រូវយកតាមខ្លួននូវគ្រឿងអាវុធ ឬជាតិផ្ទុះក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួនក្នុងការបោះឆ្នោតនៅកម្ពុជាឡើយ ។

២០. ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការបោះឆ្នោតនៅថ្នាក់ក្រោមហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់នីតិវិធីនៃការបោះឆ្នោតឡើយ ។

២១. មានសិទ្ធិសាកសួរ និងលើកសំណួរចំពោះមន្ត្រីរៀបចំការបោះឆ្នោត ប៉ុន្តែមិនត្រូវផ្តល់ដំបូន្មានកែតម្រូវកំហុស ដែលខ្លួនបានរកឃើញ និងបង្អាក់ដំណើរការបោះឆ្នោតឡើយ ។ ប៉ុន្តែអាចធ្វើរបាយការណ៍អំពីបញ្ហាកំហុសធ្ងន់ធ្ងរជាបន្ទាន់ជូនអាជ្ញាធររៀបចំការបោះឆ្នោតដែលមានវត្តមាន និងត្រូវជូនរបាយការណ៍នេះមួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផង ។

២២. ត្រូវទទួលខុសត្រូវទូទាត់ផ្ទាល់ដោយខ្លួនឯង ឬ/និងដោយអង្គការរបស់ខ្លួនលើរាល់តម្លៃ និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន ។

២៣. ការប្រើម៉ាស៊ីនថតរូបនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវហាមឃាត់ ។

២៤. ប្រសិនបើពុំមានការអនុញ្ញាតពីអាជ្ញាធររៀបចំការបោះឆ្នោត មិនត្រូវប៉ះពាល់សម្ភារៈបរិក្ខារបោះឆ្នោតក្នុងនោះរួមទាំងសន្លឹកឆ្នោតផង ។

## VI. ទោសប្បញ្ញត្តិ

ដោយផ្អែកតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបដិសេធលែងទទួលស្គាល់ និងប្រគល់សិទ្ធិជូន គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមឱ្យបណ្តេញចេញពីទីស្នាក់ការ ឬការិយាល័យបោះឆ្នោតនានានូវអង្គការសង្កេតការណ៍ ឬអ្នកសង្កេតការណ៍ណាម្នាក់ដោយមិនទាន់គិតពីទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់បោះឆ្នោតនៅពេលដែលគណៈកម្មការនោះ យល់ឃើញថា អង្គការ ឬបុគ្គលអ្នកសង្កេតការណ៍នោះ ៖

ក. មិនគោរពតាមសេចក្តីណែនាំ និងសេចក្តីបង្គាប់បញ្ជានៃអាជ្ញាធរបោះឆ្នោតមានសមត្ថកិច្ចថ្នាក់ណាមួយ ។

ខ. បង្ហាញជាសាធារណៈថា បានលំអៀងទៅលើបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

គ. បង្អាក់ ឬធ្វើឱ្យរាំងស្ទះក្នុងការបំពេញការងារនៃមន្ត្រីបោះឆ្នោត ។

ឃ. រំលោភបំពានលើក្រមសីលធម៌នេះ ។

ដើម្បីអនុវត្តសិទ្ធិអំណាចខាងលើ គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមត្រូវរាយការណ៍ពីព្រឹត្តិការណ៍នេះ តាមឋានានុក្រមមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## VII. នីតិវិធីទទួលស្គាល់អ្នកសង្កេតការណ៍

### ក. អ្នកសង្កេតការណ៍ជាតិ

១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យពាក្យសុំ និងសម្រេចទទួលស្គាល់អ្នកសង្កេតការណ៍ជាតិ ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រគល់សិទ្ធិអំណាចឱ្យមន្ត្រីនៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធចេញបណ្ណសម្គាល់ខ្លួនអ្នកសង្កេតការណ៍ជាតិទាំងអស់ ដែលទទួលស្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ បណ្ណសម្គាល់ខ្លួននេះនឹងអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ជាតិមានសិទ្ធិ និងបំពេញភារកិច្ចរបស់ខ្លួននៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅខេត្ត ក្រុង ។ បណ្ណសម្គាល់ខ្លួននេះ ត្រូវតែជាបណ្ណដែលផលិតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣. បណ្ណសម្គាល់ខ្លួននេះ ក៏អាចប្រើប្រាស់បាននៅក្នុងការបោះឆ្នោតសាជាថ្មី ។

### ខ. អ្នកសង្កេតការណ៍អន្តរជាតិ

១. អ្នកសង្កេតការណ៍អន្តរជាតិ ឬអង្គការអន្តរជាតិណាមួយដែលចង់ចូលរួមសង្កេតមើលការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា អាចទាក់ទងជាមួយស្ថានឯកអគ្គរាជទូតកម្ពុជាដែលប្រចាំនៅសាមីប្រទេស ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងចេញឱ្យអ្នកសង្កេតការណ៍អន្តរជាតិនូវបណ្ណសម្គាល់ខ្លួន ដែលអនុញ្ញាតឱ្យសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## VIII. សំណូមពរ

បន្ទាប់ពីដំណើរបោះឆ្នោតបានចប់សព្វគ្រប់ហើយ អ្នកសង្កេតការណ៍ទាំងឡាយគប្បីផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការនៃការបោះឆ្នោតជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ឧបសម្ព័ន្ធ
# ស្តីពី
# គោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន

## I. គោលបំណង

- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។
- ដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយ ។
- ដើម្បីអនុវត្តនូវជំពូកទី៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- ដើម្បី ឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន មានភាពអព្យាក្រឹតក្នុងការផ្សព្វផ្សាយពត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។

  គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កំណាត់នូវគោលការណ៍មួយចំនួនសំរាប់ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន ដូចខាងក្រោម ។

## II. គោលការណ៍ទូទៅ

ដើម្បី ឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចទទួលយកបាននូវលទ្ធផលនៃការបោះឆ្នោត អ្នកយកពត៌មានជាតិ (រដ្ឋនិងឯកជន) និងអន្តរជាតិមានតួនាទីសំខាន់ក្នុងការប្រមូលពត៌មាន និងរាយការណ៍អំពីដំណើរការបោះឆ្នោតទូទាំងប្រទេស។

ដើម្បី ឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាមានលក្ខណៈប្រជាធិបតេយ្យ និងតម្លាភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញគោលការណ៍សំរាប់គ្រប់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ដែលមានបំណងចូលរួមយកពត៌មានក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោតដូចខាងក្រោម ៖

១. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវផ្តល់ពត៌មានឱ្យបានត្រឹមត្រូវ មិនលំអៀង និងដោយមានការថ្លឹងថ្លែងអោយមានតុល្យភាព ។

២. ប្រព័ន្ធផ្សព្វផ្សាយពត៌មានដែលផ្តល់ពត៌មានអំពីការបោះឆ្នោតត្រូវតែផ្ទៀងផ្ទាត់អំពីប្រភពពត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍ ។

៣. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវតែផ្តល់ពត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សំរាប់អ្នកបោះឆ្នោត ។

៤. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវជៀសវាងការប្រើប្រាស់ភាសា ញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហឹង្សា និងត្រូវថ្លឹងថ្លែងជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

៥. ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកគ្រប់គ្រងត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាពចូលរួមធ្វើឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ តាមរយៈការផ្តល់ពត៌មានអំពីការបោះឆ្នោត និងចាត់ទុកពត៌មានអំពីការបោះឆ្នោតជាពត៌មានអាទិភាព ។

៦. អ្នកសារពត៌មានមិនត្រូវបោះបង់គោលជំហរឬក្រមសីលធម៌របស់ខ្លួនដោយសារតែអំណោយផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ ។

៧. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវមានភារកិច្ច និងការទទួលខុសត្រូវក្នុងការស៊ើបអង្កេត និងរាយការណ៍នូវបញ្ហាដែលទាក់ទងដល់ការបោះឆ្នោតឱ្យបានត្រឹមត្រូវ ដើម្បីរក្សាស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។

៨. ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ត្រូវស្វែងរក និងត្រូវផ្សព្វផ្សាយពត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗ គ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត ។

៩. ប្រព័ន្ធផ្សព្វផ្សាយពត៌មាន ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអសត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គជប នៅក្នុងដំណើរការបោះឆ្នោត ។

១០. គជប លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយពត៌មានក្នុងលក្ខណៈជាដៃគូជាមួយ គជប និងសង្គមស៊ីវិល ដើម្បីធ្វើការផ្តល់ពត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត ។

១១. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវតែជៀសវាងការផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការរើសអើង ដល់ស្ត្រីភេទ និងជនពិការ ។

១២. ប្រព័ន្ធផ្សព្វផ្សាយពត៌មានត្រូវផ្សព្វផ្សាយពត៌មាន អំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី និងជនពិការក្នុងជីវភាពសង្គម និងនយោបាយ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈ ។

១៣. ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋត្រូវតែធ្វើការបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយពត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ ឬបេក្ខជន ។

១៤. អ្នកយកពត៌មានរបស់រដ្ឋ អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសំដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថតាមរយៈការលើកដាក់សំលេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត ។

១៥. ការផ្សព្វផ្សាយដែលមានលក្ខណៈបរិហារកេរ្តិ៍លើបេក្ខជន ឬគណបក្សនយោបាយណាមួយ បេក្ខជន ឬគណបក្សនយោបាយនោះ មានសិទ្ធិប្តឹងពីបទបរិហារកេរ្តិ៍ ឬការប្រមាថមើលងាយ ឬ/និងសុំឱ្យអ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហាកេរ្តិ៍នោះធ្វើការកែសំរួល ឬបញ្ឈប់ការផ្សព្វផ្សាយនូវពត៌មានទាំងនោះ ។ ក្នុងករណីនេះ អ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍ ត្រូវធ្វើការឆ្លើយតបទៅនឹងបេក្ខជន ឬគណបក្សនយោបាយនោះ ឬក៏ធ្វើការកែតំរូវលើការផ្សព្វផ្សាយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ។
ការផ្សព្វផ្សាយឡើងវិញអំពីខ្លឹមសារកែតំរូវ ត្រូវផ្សព្វផ្សាយក្នុងរយៈពេលប្រហែលគ្នានឹងរយៈពេលដែលបានផ្សព្វផ្សាយបរិហារកេរ្តិ៍ ។

១៦. ប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋត្រូវបង្ហាញនូវកំរិតគុណភាពខ្ពស់នៃវិជ្ជាជីវៈសារពត៌មាន និងត្រូវផ្តល់ពត៌មាន និងហេតុការថ្មីៗឱ្យបានសមរម្យ ពិតប្រាកដ និងឥតលំអៀងដើម្បីធានានូវយុត្តិធម៌ និងតុល្យភាព តាមគោលការណ៍សមធម៌ ដល់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតទាំងអស់ ។

# ឧបសម្ព័ន្ធ

# ស្តីពី

# ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត

## I. គោលបំណង និងការប្រតិបត្តិតាមក្រមសីលធម៌

### ក. គោលបំណង

គោលបំណងនៃក្រមសីលធម៌សំរាប់មន្ត្រីបោះឆ្នោត (ក្រមសីលធម៌) គឺដើម្បីផ្តល់លទ្ធភាពឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) និងមន្ត្រីបោះឆ្នោតទាំងអស់សំរេចបាននូវ ៖

- ការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ចាញ់ផ្ចាល់ ។

### ខ. ការប្រតិបត្តិ

មន្ត្រីបុគ្គលិកគ្រប់រូបនៃ គជប និងមន្ត្រីដែលត្រូវបានប្រតិភូកម្មអំណាចឱ្យដោយ គជប គឺជាមន្ត្រីបោះឆ្នោត ។ មន្ត្រីបុគ្គលិកបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន ។

### គ. ការអនុវត្តរបស់មន្ត្រីបោះឆ្នោត

#### ១. ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គជប

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម និងគាំទ្រច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គជប ។

#### ២. លក្ខខណ្ឌការងារ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខ័ណ្ឌការងាររបស់ខ្លួន ។ លក្ខខ័ណ្ឌការងារនេះរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ ។

### ៣. ការអនុវត្តក្រមសីលធម៌

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌ ។

### ៤. ការគាំទ្រ និងការផ្សព្វផ្សាយ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តក្នុងការផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គជប និងក្រមសីលធម៌នេះ ។

## II. ភាពប្រព្រឹត្តជាទូទៅ

### ១. ការផ្តន្ទាទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្ត គ្រប់ពេលវេលាទាំងអស់ ដើម្បីអនុវត្តទៅតាមសិទ្ធិអំណាចរបស់ខ្លួនក្នុងការផ្តន្ទាទោស និងរារាំងចំពោះ អំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទិនដល់ដំណើរការបោះឆ្នោត ។

### ២. ភាពមិនលំអៀងរវាងគណបក្សនយោបាយ

២.១ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវលំអៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសំដែងឥរិយាបថ ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលំអៀង ឬការចូលចិត្តទៅលើគណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយណាមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។

២.២ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវធ្វើអ្វីមួយជះឥទ្ធិពលទៅលើអ្នកបោះឆ្នោតដែលធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

២.៣ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានការពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ ។

### ៣. បរិយាកាសការងារ

៣.១ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលំអៀងភាពបោះឆ្នោតសម្ងាត់ និងសេចក្តីថ្លៃថ្នូរ ។

៣.២ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្រប ទៅតាមព្រឹត្តិការណ៍ពិសេស ឬថែដន្យដែលកើតមានឡើងក្នុងដំណើរការរៀបចំការបោះឆ្នោត ។ មន្ត្រីបោះឆ្នោតត្រូវ ៖

- អនុវត្តភារកិច្ចរបស់ខ្លួនក្នុងកាលៈទេសៈលំបាក ។
- អនុវត្តកិច្ចការថ្មី ឬកិច្ចការបន្ថែមទៀតដែលសមស្របសមត្ថភាពរបស់ខ្លួន ប៉ុន្តែកិច្ចការនោះស្ថិតនៅក្រៅពីទីកន្លែងដែលខ្លួនកំពុងបំពេញការងារ ។

៣.៣ ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ ៖

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន ។
- រក្សាសុវត្ថិភាពចំពោះសំភារៈបរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ ។ សំភារៈបោះឆ្នោតរាប់បញ្ចូលទាំងទម្រង់បែបបទផ្សេងៗ លិខិតបញ្ជាក់ សន្លឹកឆ្នោត សេចក្តីជូនដំណឹង សោរឃ្លុំ និងស្រោមសំបុត្រ ឬប្រដាប់ដាក់សំភារៈបោះឆ្នោត ។
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្តីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន ។

## ៤. ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល ៖

- ពិការ ។
- មិនដឹង មិនយល់ពីចំណុចណាមួយ ឬច្រើន ដែលខ្លួនត្រូវធ្វើ ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងមិនដឹងពីរបៀបដាក់ពាក្យប្តឹងតវ៉ា ឬប្តឹងជំទាស់ ។
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវឱ្យ ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះ ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ ។

## ៥. ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

៥.១ មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង ៖

- ការគំរាមកំហែង ។
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់ ។

- ការធ្វើឱ្យខូចខាតដល់បរិវេណការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ។
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ ឬលាក់ទុកសំភារៈបរិក្ខារ ឬទ្រព្យសម្បត្តិបោះឆ្នោតណាមួយ ។
- ការបង្អាក់ ឬរារាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៥.២ មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវមានវិធានការទប់ស្កាត់ និងដោះស្រាយឱ្យបានសមស្របតាមសមត្ថកិច្ចរបស់ខ្លួនទៅនឹងការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះដូចខាងលើ ។

## ៦. ការជក់បារី និងការបង្ការភ្លើង

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវ ៖

- ជក់បារីនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។
- គូសឈើគូស ដែកកេះ ឬឧបករណ៍ដែលអាចឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានភារកិច្ចបញ្ជាក់ឱ្យធ្វើ ។

## ៧. ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវបរិភោគនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការបញ្ជាក់អនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ ខ្លួន ។

## ៨. គ្រឿងស្រវឹង និងគ្រឿងញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះឡើយ ។

## ៩. ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែង និងក្នុងពេលម៉ោងធ្វើការឡើយ ។

## III. លក្ខខណ្ឌចាំបាច់សំរាប់ការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

### ក. លក្ខខណ្ឌចាំបាច់សំរាប់ការិយាល័យចុះឈ្មោះបោះឆ្នោត

#### ១. ភារកិច្ចទូទៅ

មន្ត្រីបោះឆ្នោតគ្រប់រូប ដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួនដើម្បីធានាបានថា អ្នកបោះឆ្នោតគ្រប់រូបអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការចុះឈ្មោះជាអ្នកបោះឆ្នោត ។

#### ២. អ្នកចុះឈ្មោះបោះឆ្នោតដែលមានពិការភាព

២.១ អ្នកចុះឈ្មោះបោះឆ្នោតដែលមិនមាំមួន មានពិការភាពណាមួយ មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកំរិតណាមួយដែលខ្លួនត្រូវការជាជំនួយ ក្នុងការចុះឈ្មោះបោះឆ្នោត ។

២.២ មន្ត្រីចុះឈ្មោះបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកចុះឈ្មោះដែលមិនមាំមួន មានពិការភាព នោះត្រូវធ្វើទៅតាមកំរិតដែលបានស្នើសុំដោយអ្នកពិការរូបនោះតែប៉ុណ្ណោះ ។

### ខ. លក្ខខណ្ឌចាំបាច់ទូទៅសំរាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

#### ១. ការិយាល័យបោះឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូប ដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសំភារៈបរិក្ខារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាពត្រឹមត្រូវ និងគ្រប់ចំនួន ។

#### ២. ការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូប ដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការិយាល័យរាប់សន្លឹកឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាពត្រឹមត្រូវ និងគ្រប់ចំនួន ។

## ៣. ការប៉ះពាល់ទៅលើសំភារៈបោះឆ្នោត

៣.១ មន្ត្រីបោះឆ្នោតដែលកំពុងបំរើការងារនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសំងាត់ ត្រាការិយាល័យ ឯកសារ ឬសំភារៈបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ ។

៣.២ ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមិនត្រូវ ៖

- ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសំភារៈបោះឆ្នោត ។
- យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសំភារៈបោះឆ្នោតនៅខាងក្នុង ។
- យកសំភារៈបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ ។
- គូសសំគាល់ ឬសរសេរលើសំភារៈបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយ ចេញពីសំភារៈបោះឆ្នោតណាមួយ ។

## ៤. សន្លឹកឆ្នោត និង ហិបឆ្នោត

ប្រសិនបើមន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយមិនមានការបញ្ជាក់អនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតរូបនោះមិនត្រូវ ៖

- ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់ ។
- បោះត្រាសំងាត់ផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ ។
- ផ្លាស់ប្តូរ ឬបំផ្លាញត្រាសំងាត់ផ្លូវការនៅលើសន្លឹកឆ្នោត ។
- ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត ។
- គូសនៅលើសន្លឹកឆ្នោត ។
- ចាប់យក ឬប៉ះពាល់ហិបឆ្នោត ។
- ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត ។
- យកសន្លឹកឆ្នោតចេញពីហិបឆ្នោត ។

## គ. លក្ខខណ្ឌចាំបាច់ពិសេសសំរាប់ការិយាល័យបោះឆ្នោត

### ១. ការិយាល័យបោះឆ្នោត

១.១ មន្ត្រីបោះឆ្នោតដែលកំពុងបំរើការងារនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវព្យាយាម ៖

- ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត ។
- ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត ។
- គូសសញ្ញាសំគាល់ណាមួយ នៅលើសន្លឹកឆ្នោតដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណ នៃអ្នកបោះឆ្នោត ។
- ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថាអ្នកនោះមិនមានសិទ្ធិបោះឆ្នោត ។
- ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ ដោយគ្មានភារកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត រហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ។
- ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានភារកិច្ច ។

១.២ មន្ត្រីបោះឆ្នោតត្រូវរាយការណ៏ជាបន្ទាន់ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច នូវសកម្មភាពរបស់បុគ្គលណាម្នាក់ ទាក់ទិនដល់ការសុំឱ្យបង្ហាញ ឬការចង់ដឹងអំពីរបៀបដែលអ្នកបោះឆ្នោតណាម្នាក់បានបោះឆ្នោត ។

### ២. អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត

២.១ អ្នកបោះឆ្នោតដែលពិការ មិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ កវិតណាមួយដែលខ្លួនត្រូវការជាជំនួយក្នុងការបោះឆ្នោត ។

២.២ មន្ត្រីបោះឆ្នោតត្រូវធ្វើទៅតាមកវិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គជប ។ កិច្ចការនេះតម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកពិការត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ ។

### ឃ. លក្ខខណ្ឌចាំបាច់ពិសេសសំរាប់ការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានភារកិច្ចអនុញ្ញាតិឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាង ៖

- សន្លឹកឆ្នោតណាមួយ ដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ ។
- លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត ។
- ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ ។
- ចំនួនសម្លេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ ។

## IV. ទំនាក់ទំនងជាមួយគណបក្សនយោបាយ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

### ១. ទំនាក់ទំនង

១.១ មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវរាក់ទាក់ មិនលំអៀង និងត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយបេក្ខជន តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ នៅគ្រប់ពេលវេលាទាំងអស់ ។

១.២ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់ របស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែល ៖

- មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅខាងក្នុងបរិវេណនៃការិយាល័យទាំងនេះ ដើម្បីសង្កេតការណ៍មើលដំណើរការបោះឆ្នោត ។
- ធ្វើការតវ៉ា ឬជំទាស់ ឬដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សំរាប់តំណាងគណបក្សនយោបាយតែប៉ុណ្ណោះ) ។

១.៣ មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវអនុវត្តតាមបទបញ្ជា និងនីតិវិធីរបស់ គជប ។

### ២. ភាពគ្មានសិទ្ធិអំណាច

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា ៖

- គណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍មិនមានសិទ្ធិធ្វើសេចក្តីណែនាំណាមួយដល់មន្ត្រីបោះឆ្នោតណាម្នាក់ឡើយ ។

- មិនត្រូវប្រតិបត្តិតាមសេចក្ដីណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ ។

### ៣. ការជូនរង្វាន់ និងការសន្យា

៣.១ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្ដីនូវចំនួនទឹកប្រាក់រង្វាន់ ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ ។

៣.២ រង្វាន់មានរាប់បញ្ចូលទាំងស្បៀងអាហារ ឬភេសជ្ជៈ ឬសេវាកម្មផ្ទាល់ខ្លួនផ្សេងទៀតដែលផ្ដត់ផ្គង់ដល់មន្ត្រីបោះឆ្នោតណាម្នាក់ ដោយគណបក្សនយោបាយណាមួយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានការយល់ព្រមដោយចំហពីតំណាងគណបក្សនយោបាយទាំងអស់ដែលមានវត្តមាននៅក្នុងការិយាល័យនោះ ។

### ៤. សកម្មភាពដែលត្រូវហាមឃាត់

មន្ត្រីបោះឆ្នោតម្នាក់ៗ នៅក្នុងអំឡុងពេលបោះឆ្នោត មិនត្រូវ ៖

- មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។
- ធ្វើការងារឱ្យ ឬទទួលថ្លៃឈ្នួលពីគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ។
- ជាអ្នកកាន់មុខតំណែងណាមួយ នៅក្នុងការិយាល័យគណបក្សនយោបាយ ។

## V. ការបណ្ដុះបណ្ដាល

មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្ដុះបណ្ដាល ឬសិក្ខាសាលាទាំងអស់ដែលខ្លួនត្រូវទទួល ។

## VI. ទោសប្បញ្ញត្តិ

មន្ត្រីបោះឆ្នោតគ្រប់រូបដែលអនុវត្តផ្ទុយពីច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា នីតិវិធី និងក្រមសីលធម៌នេះនឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

# ឧបសម្ព័ន្ធ
# ស្តីពី
# ក្រមសីលធម៌សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ

## ផ្នែកទី ១

### I. សេចក្តីផ្តើម

ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅថ្ងៃអាទិត្យទី ២២ ខែមករា ឆ្នាំ២០០៦ ប្រព្រឹត្តទៅដោយសុវត្ថិភាព ប្រកបដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងដើម្បីពង្រឹងបរិយាកាសសង្គមឱ្យបានល្អសម្រាប់ការរៀបចំការបោះឆ្នោត ដែលមានការយោគយល់គ្នា មានការគោរពច្បាប់ មិនមានការបំពុលបរិយាកាសសង្គមនាំឱ្យមានការភ័យខ្លាច ការច្របូកច្របល់ និងការគំរាម កំហែង អំពើហិង្សា និងអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុម័តក្រមសីលធម៌សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ដែលមានខ្លឹមសារលំអិតដូចខាងក្រោមនេះ ។

### II. គោលបំណងនៃក្រមសីលធម៌

គោលបំណងនៃក្រមសីលធម៌គឺដើម្បី ៖

១. ឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅបានជោគជ័យ គ្មានការគំរាមកំហែង គ្មានអំពើហិង្សា ។

២. ការពារសុវត្ថិភាពជូនអ្នកបោះឆ្នោត បេក្ខជននៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងសង្គមជាតិទាំងមូល ។

៣. ឱ្យសមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងនគរបាលជាតិ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ប្រើប្រាស់តាមគ្រប់វិធានការជំនាញ និងគ្រប់មធ្យោបាយ លើកកំពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីធានាដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

### III. សិទ្ធិទទួលការការពារសន្តិសុខ

ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានាថ្ងៃអាទិត្យទី២២ ខែមករា ឆ្នាំ២០០៦ ខាងមុខនេះ សមាជិកនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលំអៀង និងមិនត្រូវបង្ហាញ

ការគាំទ្រ ឬប្រឆាំងដល់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឡើយ ។ សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ត្រូវចងចាំថា ៖

- អ្នកបោះឆ្នោតមានសិទ្ធិទទួលការការពារសន្តិសុខ និងសុវត្ថិភាព ដើម្បីឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
- បេក្ខជនឈរឈ្មោះគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់ មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលបោះឆ្នោត ។

## IV. ភារកិច្ច និងការទទួលខុសត្រូវរបស់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ

### ក_ សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ៖

១. ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ។

២. ត្រូវរក្សាបរិយាកាសសុវត្ថិភាពក្នុងពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ។

៣. ត្រូវធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៤. ត្រូវចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ ។

៥. នៅថ្ងៃបោះឆ្នោត កងកម្លាំងនគរបាលជាតិ ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ដើម្បីការពារបរិវេណសន្តិសុខនេះ ដោយស្លៀកពាក់ជាឯកសណ្ឋាននគរបាលជាតិ និងមានពាក់ផ្លាកសញ្ញា ឬបណ្ណសម្គាល់ភ្នាក់ងារសន្តិសុខបោះឆ្នោតរបស់ គជប ។

៦. ត្រូវយាម និងត្រួតពិនិត្យការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត យ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៧. ត្រូវបានស្នើឱ្យជួយការពារការដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅកាន់ គឃ/កប និងទៅកាន់ទីស្នាក់ការ គជប ។

៨. ត្រូវស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ចក្នុងករណីមានសំណូមពរ ពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ។

៩. មេបញ្ជាការ ឬមន្ត្រីនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ត្រូវចូលរួមប្រជុំជាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ។

១០. មេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ត្រូវចេញសេចក្ដីណែនាំទៅមន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលការប្រព្រឹត្តរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋ ព្រមទាំងការការពារសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចមានចែងក្នុងមាត្រា ៣១ និង ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ខ_ សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិត្រូវអនុវត្តបំរាមដូចតទៅ ៖**

១. មិនត្រូវចូលរួមជាសកម្ម ក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាមួយឡើយ ។ ការចូលរួម ជាសកម្ម ត្រូវបានកំណត់ ដូចតទៅ ៖

១.១. ជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬក្រុមអ្នកឃោសនាបោះឆ្នោតនៃគណបក្សនយោបាយ ។

១.២. ការចូលរួមក្នុងក្បួនដង្ហែ ការជួបជុំ និងក្បួនព្យុហយាត្រា ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៣. ការដាក់តាំងរូបភាពផ្សាយ ឬឯកសារបោះឆ្នោតផ្សេងៗទៀត ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់នៅតាមយានជំនិះផ្ទាល់របស់ខ្លួន ឬរបស់អង្គភាព ។

១.៤. ការស្ទង់មតិសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៥. ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៦. ការធ្វើសកម្មភាពចែកចាយសម្ភារៈដល់អ្នកបោះឆ្នោត ក្នុងគោលដៅគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៧. ការចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈក្នុងការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៨. ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងការច្រៀងចម្រៀង ឬ/និងការផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

២. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋាន ។

៣. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាណាមួយក្នុងពេលបំពេញភារកិច្ច ។

៤. មិនត្រូវដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៥. មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការប្រតិបត្តិការបោះឆ្នោតឡើយ ។

៦. មិនត្រូវស្លៀកពាក់ជាឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ឬ/និងយកអាវុធជាតិផ្ទុះតាមខ្លួនចូលក្នុងបរិវេណខាងក្រៅ និងខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៧. មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលនេះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៧.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរដែលមានន័យ គំរាមកំហែងដល់អាយុជីវិតរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

៧.២ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថា នឹងធ្វើទារុណកម្ម ។

៧.៣ ការវាយតប់បង្កិចបង្ខូច ឬធ្វន់ធ្ងរលើបុគ្គលណាម្នាក់ ។

៧.៤ ការរំលោភដោយពាក្យសម្ដីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

៧.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

៧.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៧.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៧.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ខ្លួន ។

៧.៩ ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៧.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៧.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លីផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

៨. មិនត្រូវអនុញ្ញាតអោយជនណាម្នាក់ដែលប្រដាប់អាវុធ ឬមានលាក់អាវុធនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានទេ លើកលែងតែជាសមាជិកនៃកងយោធពលខេមរភូមិន្ទ ឬកងនគរបាលជាតិដែលមានភារកិច្ចត្រូវបានស្នើសុំជាផ្លូវការដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយដើម្បីដោះស្រាយបាតុភាពដែលអាចនឹងកើតមាន ។

៩. មិនត្រូវអនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខ និងសុវត្ថិភាពក្នុងពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែមានការស្នើសុំពីប្រធាន គជប ប្រធាន គខ/កប និងពីប្រធានគណៈកម្មការ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## V. ការរៀបចំយន្តការ និងសហប្រតិបត្តិការផ្នែកសន្តិសុខ

ដើម្បីការពារសន្តិសុខ ស្ថេរភាព សុវត្ថិភាព សម្រាប់ការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួងមហាផ្ទៃ ត្រូវរៀបចំនូវយន្តការ រចនាសម្ព័ន្ធចាត់តាំង និងកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ដូចតទៅ ៖

### ១_ អំពីយន្តការ និងកិច្ចសហការផ្នែកសន្តិសុខ

#### ក- រចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខរបស់ គជប

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខាធិការដ្ឋាន ឬគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត
- គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

#### ខ- រចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខរបស់ ក្រសួងមហាផ្ទៃ

- ក្រសួងមហាផ្ទៃ
- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់

## ២_ កិច្ចសហប្រតិបត្តិការសន្តិសុខរវាង គជប និង ក្រសួងមហាផ្ទៃ



# ផ្នែកទី ២

# មុខសញ្ញា និងគោលដៅការពារ

## I. មុខសញ្ញា និងគោលដៅដែលត្រូវការពារ

កិច្ចការពារមុខសញ្ញា និងគោលដៅដែលត្រូវការពារ ត្រូវរៀបចំជាផែនការដោយតំរូវឱ្យមានការការពារ ជាលក្ខណៈប្រយោល ។

មុខសញ្ញា និងគោលដៅជាអាទិភាព ដែលត្រូវការពារ រួមមាន ៖

**ក_ មុខសញ្ញាការពារ**

- បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- ឃោសនិក វាគ្មិន ឬក្រុមឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ
- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងតំណាងគណបក្សនយោបាយ
- មន្ត្រីប្រតិបត្តិការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ របស់ គជប
- អ្នកបោះឆ្នោត ( សមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ) ។

**ខ_ គោលដៅការពារ**

- ទីកន្លែងស្នាក់នៅរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឃោសនិក អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងតំណាងគណបក្សនយោបាយ
- ទីស្នាក់ការរបស់គណបក្សនយោបាយ
- ទីស្នាក់ការរបស់ គខ/កប
- ទីកន្លែងបិទផ្សាយបញ្ជីបោះឆ្នោតដំបូង
- ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ការដឹកជញ្ជូនសម្ភារៈបោះឆ្នោត និងសន្លឹកឆ្នោតរបស់ គជប ទៅកាន់ គខ/កប និង ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ការដឹកជញ្ជូនកំណត់ហេតុរាប់សន្លឹកឆ្នោត សម្ភារៈបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនីមួយៗ ទៅកាន់ គខ/កប
- ការដឹកជញ្ជូនសម្ភារៈបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុង ខេត្ត ក្រុងនីមួយៗទៅកាន់ គជប ។

## II. ខ្លាត និងប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

- គ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានបរិវេណខាងក្នុងជារង្វង់មណ្ឌលមួយ ដែលមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ ។
- គ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានបរិវេណខាងក្រៅដែលជាតំបន់នៅជុំវិញការិយាល័យទាំងនោះមានកាំប្រវែង ១០០ម៉ែត្រ ឬមានទម្រង់ផ្សេងៗ ឬមានកាំតូចជាងស្របទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។







**គំនូសខ្លាត នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**គំនូសប្រព័ន្ធការពារសន្តិសុខ នៃការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត**

**កំណត់ចំណាំ**

(ពណ៌ផ្ទៃមេឃ) - ពណ៌ផ្ទៃមេឃមានរង្វង់មណ្ឌលកាំ ១៥ម៉ែត្រ គឺជាបរិវេណខាងក្នុង នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

(ពណ៌ទ្រលោត) - ពណ៌ទ្រលោតមានរង្វង់មណ្ឌលកាំ ១០០ម៉ែត្រ គឺជាបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

X - ភ្នាក់ងារសន្តិសុខបោះឆ្នោត ស្លៀកពាក់ឯកសណ្ឋានគរបាលជាតិ និងមានពាក់ផ្លាកសញ្ញា ឬប័ណ្ណសម្គាល់ របស់ គជប ។

**ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

❖ ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ៣នាក់ ស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ និងមានពាក់ផ្លាកសញ្ញា ឬប័ណ្ណសម្គាល់ភ្នាក់ងារសន្តិសុខបោះឆ្នោតរបស់ គជប ការពារនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗក្នុង ២៤ ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ១នាក់ ត្រូវចល័តការពារជុំវិញបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ( ចម្ងាយពី ១៥_៤០ ម៉ែត្រ )គ្មានសិទ្ធិប្រើអាវុធឡើយ ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ២នាក់ទៀត ត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ចម្ងាយពី ១០០_១៥០ ម៉ែត្រ) មានសិទ្ធិប្រើប្រាស់អាវុធវែង ១ដើម បង់ ១ មានគ្រាប់យ៉ាងច្រើន ចំនួន ៣០គ្រាប់ ។

❖ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំងយាមការពារការដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត ពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅកាន់ គខ/កប និងទៅកាន់ គជប ។

## III. ការចងចាំ អំពីគោលការណ៍ និងយន្តការការពារសន្តិសុខបោះឆ្នោត

សមាជិកនៃកងកម្លាំងនគរបាលជាតិ ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវគោរព និងអនុវត្តតាមគោលការណ៍សំខាន់ៗ ដូចតទៅ ៖

- **គោលការណ៍ទូទៅ**

១. រក្សាបរិយាកាសនយោបាយអព្យាក្រឹត និងគោរពវិន័យយ៉ាងម៉ឺងម៉ាត់ ដើម្បីឱ្យការបោះឆ្នោតដំណើរការទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សា ។

២. ត្រូវផ្អែកលើច្បាប់ និងបទបញ្ជា និងនីតិវិធី គជប ធ្វើជាមូលដ្ឋាន ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។

៣. ពង្រឹងការពារសន្តិសុខ សម្រាប់សង្គមជាតិទាំងមូល ។

៤. ត្រូវមានអព្យាក្រឹតភាពក្នុងមុខនាទី និងសកម្មភាពការងារ ក្នុងនាមជាកងកម្លាំងរបស់ជាតិ ។

- **យន្តការការពារសន្តិសុខ សម្រាប់ការបោះឆ្នោត**

១. ចាត់តាំងកម្លាំងការពារគ្រប់ទីតាំងបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូង ។

២. ចាត់តាំងកម្លាំងការពារសកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត ។

៣. ការពារពេលបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងការពារការដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតតាមការិយាល័យបោះឆ្នោតដោយត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយ គជប គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៤. បន្តរក្សាសន្តិសុខ ស្ថេរភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រហូតដល់ការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ ។

<u>**បញ្ជាក់**</u>

- ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣នាក់ ស្លៀកពាក់ឯកសណ្ឋាននគរបាលជាតិ និងមានពាក់ផ្លាកសញ្ញា ឬប័ណ្ណសម្គាល់ភ្នាក់ងារសន្តិសុខបោះឆ្នោតរបស់ គជប ប្រចាំការនៅតាមបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចាប់តាំង ពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៦ រហូតដល់ចប់ភារកិច្ច ។
- នៅថ្ងៃអាទិត្យ ទី ២២ ខែមករា ឆ្នាំ ២០០៦ ប្រធានការិយាល័យបោះឆ្នោតប្រកាសបើកការបោះឆ្នោត នៅម៉ោង ៧:០០ និងប្រកាសបិទការបោះឆ្នោត នៅម៉ោង ១៥:០០ រសៀល នៅថ្ងៃដដែល ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយចាត់វិធានការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឱ្យបានតឹងរ៉ឹង ។
- ក្នុងករណីមានសំណូមពរ ពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងគោលបំណងស្នើសុំឱ្យជួយថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយ ភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលត្រូវបានបំពាក់អាវុធសមស្រប ឬភ្នាក់ងារសង្គ្រោះ អាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធនោះ ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចូលរួមការពារការដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅកាន់ គខ/កប និង គជប ។

# ផ្នែកទី ៣
# សម្រង់មាត្រាច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ត្រូវយល់ និងចងចាំនូវមាត្រាមួយចំនួននៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៣ ។

**មាត្រា ១៦ ថ្មី** (សម្រង់ចំណុចទី ៥)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិអំណាច និងភារកិច្ច " លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត " ។

**មាត្រា ២៩ ថ្មី**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមសំណើរបស់គណកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៥៥ ថ្មី**

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហាមឃាត់មិនឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ព្រមទាំងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងសាលាឃុំ សង្កាត់ ឬទីកន្លែងកំណត់សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត លើកលែងតែមានជនណាបង្កការអុកឡុករំខាន ទើបមេឃុំ ចៅសង្កាត់អាចស្នើសុំឱ្យមានអន្តរាគមន៍ ពីអាជ្ញាធរមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឱ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យនានា ។

**មាត្រា ១០០**

ហាមដាច់ខាតមិនឱ្យយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខ នៃការិយាល័យបោះឆ្នោត និងហាមមិនឱ្យស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ ២.០០០ ម៉ែត្រការ៉េ ហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចម្ងាយប្រមាណ ២០០ ម៉ែត្រជុំវិញការិយាល័យបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**អំពីទោសប្បញ្ញត្តិ**

***មាត្រា ១២៤_ថ្មី***

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកទុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ។

***មាត្រា ១២៧_ថ្មី***

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៥ថ្មី ឬមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និងដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី (៤៨)ម៉ោង ដោយភ្ជាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មាន បៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងយោលទៅតាមកម្រិតនៃបទល្មើស ។
- លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

***មាត្រា ១២៨_ថ្មី***

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ថ្មី នៃច្បាប់នេះ ។

***មាត្រា ១២៩_ថ្មី***

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលបង្កាប់បញ្ជា ឬលួងលោមបោក បញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

***មាត្រា ១៣០_ថ្មី***

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោតដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួន ចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

***<u>មាត្រា ១៣១</u>***

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវដកហូតប័ណ្ណបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ឬលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ ឬមាត្រា ៧៦ នៃច្បាប់នេះ ។

# ឧបសម្ព័ន្ធ

# ស្តីពី

# បទបញ្ជាផ្ទៃក្នុងសវនាការដោះស្រាយបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខ ក្នុងបន្ទប់សវនាការ ជនគ្រប់រូប ដែលមានវត្តមានក្នុងបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តបទបញ្ជា ដូចតទៅ ៖

១. ហាមជក់បារីក្នុងបន្ទប់សវនាការ ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់សវនាការ ដូចជា ៖

- ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត ។
- ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ ។

៣. ហាមយកក្មេងអាយុក្រោម ១៨ឆ្នាំ ចូលក្នុងបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាត ជាមុនពីក្រុមប្រឹក្សាជំនុំជំរះ ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបន្ទប់សវនាការ ។

៥. ហាមថតរូប និងអាត់សំឡេងក្នុងបន្ទប់សវនាការលើកលែងតែមានការអនុញ្ញាតពីប្រធានក្រុម ប្រឹក្សាជំនុំជំរះ ។

ជនណាមិនគោរពតាមបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

# ឧបសម្ព័ន្ធ

# ស្តីពី

# នីតិវិធី និងខ្លឹមសារនៃសម្បថ

សាក្សីត្រូវធ្វើសម្បថ និងឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជំរះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត ។ នីតិវិធីនៃការធ្វើសម្បថ និងខ្លឹមសារនៃសម្បថមានដូចខាងក្រោម ៖

## I. នីតិវិធីនៃការធ្វើសម្បថ

**តាមនីតិវិធី សម្បថត្រូវធ្វើឡើង ដូចខាងក្រោម ៖**

- សាក្សីត្រូវធ្វើសម្បថលើកលែងក្នុងករណីដែលមានកំណត់ពិសេស ។
- សម្បថរបស់សាក្សីត្រូវធ្វើមុនពេលសាកសួរ ឬការឆ្លើយបំភ្លឺ ។
- នៅពេលធ្វើសម្បថ សាក្សីត្រូវក្រោកឈរឡើងហើយត្រូវធ្វើការស្មិងស្មាធិ៍ ។
- លេខាធិការសវនាការត្រូវឱ្យសាក្សី អានលិខិតសម្បថ ហើយត្រូវឱ្យចុះហត្ថលេខាលើលិខិតនោះផង ។ នៅពេលសាក្សីមិនអាចអានលិខិតសម្បថបានទេ លេខាធិការសវនាការត្រូវអានលិខិតសម្បថនោះ រួចឱ្យសាក្សីថាតាម ។ បន្ទាប់មកឱ្យសាក្សីផ្តិតមេដៃលើលិខិតសម្បថនេះ ។
- មុនពេលធ្វើសម្បថ លេខាធិការសវនាការត្រូវពន្យល់អំពីគោលបំណងនៃសម្បថ និងប្រាប់ឱ្យដឹងជាមុនអំពីទុក្ខទោសនៃការក្លែងបន្លំពាក្យសម្បថ ។

## II. ខ្លឹមសារនៃពាក្យសម្បថ

**ពាក្យសម្បថ ត្រូវមានខ្លឹមសារ ដូចខាងក្រោម ៖**

### សម្បថ

យើងទាំងអស់គ្នា សូមស្បថចំពោះមុខព្រះអង្គដងកើ លោកយាយទេពដងកើ ទេព្តាថែរក្សាព្រះស្វេតច្ឆត្រ លោកមេទ័ពសេះស រក្សាក្នុងវាំង ព្រះអង្គវិហារសួគ៌ ព្រះអង្គគោកធ្លក ព្រះនាងចេក ព្រះនាងចម ។

សូមលោកអញ្ជើញលោកតាព្រះចៅ លោកតាដំបងក្រញូង លោកតាក្រហមក លោកតាក្បាលប្រាំបីរក្សាក្បាលជ្រោយ បើយើងខ្ញុំសច្ចានេះមិនស្មោះត្រង់ មានចិត្តវៀចវេរ សូមឱ្យព្រះអង្គដាក់ទោសតាមពាក្យសម្បថ ដូចខាងក្រោមនេះ ៖

- បើយើងខ្ញុំនៅផ្ទះឱ្យភ្លើងឆេះប្រាំបីរយជាតិ បើយើងខ្ញុំជិះទូកកប៉ាល់សូមឱ្យលិចលង់ប្រាំបីរយជាតិ បើយើងខ្ញុំស្លាប់ទៅជាខ្មោចសូមឱ្យស៊ីខ្ទុះឈាម ឬហែលនៅក្នុងខ្ទះភ្លើងប្រាំបីរយជាតិ បើកើតមកជាមនុស្ស សូមឱ្យជួបតែក្រខ្វះខាតគ្រប់ប្រាំបីរយជាតិ និងសូមឱ្យបារមីគ្រប់ព្រះអង្គបរាមុខ និងវាយបំបាក់កគ្រប់ប្រាំបីរយជាតិ ។
- បើយើងខ្ញុំមានការទៀងត្រង់សូមវត្ថុសក្តិសិទ្ធិគ្រប់ទិសទី និងទេព្តារក្សាទិសទាំងប្រាំបីជួយឱ្យយើងខ្ញុំទាំងអស់ ជួបតែសេចក្តីសុខគ្រប់ប្រការ បើខ្ញុំស្លាប់ពីជាតិនេះ អន្លោលទៅកើតក្នុងភពធំ ឬភពតូចណាក្តី សូមបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានបញ្ញាស្មារតីឆ្លាតវៃ កុំឱ្យស្គាល់សេចក្តីក្រលំបាក ជម្ងឺដង្កាត់ជារៀងរាល់ជាតិរហូតដល់បានសម្រេចព្រះនិព្វានជាឋានបរមសុខនោះហោង ។

យើងខ្ញុំសូមស្បថថា នឹងបរិយាយការពិតដោយយោលទៅតាមមនសិការ មិនលាក់រឿងអ្វីទាំងអស់ និងមិនបន្ថែមបន្ថយរឿងអ្វីឡើយ ។

# ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី២ ឆ្នាំ ២០០៦

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត | ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៥ |
| ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ | ថ្ងៃទី ២៤ ខែតុលា ដល់ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ |
| ការប្ដឹងតវ៉ា និងការដោះស្រាយបណ្ដឹងនៅ ក្រុមប្រឹក្សាធម្មនុញ្ញ | ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០៥ *(កាលបរិច្ឆេទចុងក្រោយ)* |
| ការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ | ថ្ងៃទី ២៦ ខែវិច្ឆិកា ដល់ ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០៥ *(តាមករណីគ្មាន ឬមានបណ្ដឹង)* |
| ការស្រង់ឈ្មោះអ្នកបោះឆ្នោត | ថ្ងៃទី ២៤ ខែតុលា ដល់ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០០៥ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង | ថ្ងៃទី ២ ខែធ្នូ ឆ្នាំ២០០៥ |
| ការប្ដឹងតវ៉ា ឬជំទាស់ និងការដោះស្រាយបណ្ដឹងលើបញ្ជីបោះឆ្នោតដំបូង | ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ២០០៥ ដល់ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០០៦ |
| ការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតដោយ គជប | ថ្ងៃទី ៧ ខែមករា ឆ្នាំ២០០៦ |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៥ ដល់ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៦ |
| ថ្ងៃបោះឆ្នោត | ថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៦ |
| ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត | ថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៦ *(ក្រោយពេលបោះឆ្នោត)* |
| ការប្ដឹងជំទាស់ ឬតវ៉ា ទៅ គខ/កប | ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៦ *(រយៈពេលយ៉ាងយូរត្រឹមម៉ោង ១១:៣០ នាទីព្រឹក)* |
| ការដោះស្រាយបណ្ដឹង ការបូកសរុបលទ្ធផល និងការបិទផ្សាយលទ្ធផលនៅខេត្ត ក្រុង | ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៦ *(ពេលល្ងាច)* |
| ការប្ដឹងតវ៉ាទៅ គជប លើការសម្រេចរបស់ គខ/កប | ថ្ងៃទី ២៤-២៥ ខែមករា ឆ្នាំ២០០៦ |
| ការដោះស្រាយបណ្ដឹងដោយ គជប | ថ្ងៃទី ២៦-២៧ ខែមករា ឆ្នាំ២០០៦ |
| ការប្រកាសផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ដោយ គជប | ថ្ងៃទី ២៤-២៨ ខែមករា ឆ្នាំ២០០៦ *(តាមករណីគ្មាន ឬមានបណ្ដឹង)* |
| ការប្ដឹងតវ៉ាទៅ គជប ក្នុងរយៈពេល ៧២ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្ន | ថ្ងៃទី ២៥-៣១ ខែមករា ឆ្នាំ២០០៦ |
| ការដោះស្រាយបណ្ដឹងដោយ គជប ក្នុងរយៈពេល ៤៨ម៉ោង បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | ថ្ងៃទី ២៦ ខែមករា ដល់ ថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ២០០៦ |
| ការប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ម៉ោង បន្ទាប់ពីការបដិសេធរបស់ គជប | ថ្ងៃទី ២៧ ខែមករា ដល់ ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០០៦ |
| ការដោះស្រាយបណ្ដឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល១០-២០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | ថ្ងៃទី ២៨ ខែមករា ដល់ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៦ |
| ការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងប្រកាសផ្សាយបញ្ជីបេក្ខជនជាប់ឆ្នោត | ថ្ងៃទី ២៨ ខែមករា ដល់ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៦ *(តាមករណីគ្មាន ឬមានបណ្ដឹង)* |